# ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨

## មេធាវីរៀបចំសំណើផ្លូវច្បាប់ ដើម្បីអោយស្ត្រី ៣២នាក់ ជាប់ឃុំរឿងពពោះជំនួសបាននៅក្រៅឃុំ

https://www.rfa.org/khmer/news/ ដោយ សុ ជីវី 2018-10-30

ស្ត្រីចំនួន៣២នាក់ ដែលកំពុងជាប់ឃុំខ្លួន ពីបទជួញដូរមនុស្ស តាមរយៈការពពោះជំនួសអាចនឹងត្រូវពិចារណាឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ប្រសិនបើតុលាការរកឃើញថា ពួកគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការចញ្ចឹមថែទាំកូន និងបោះបង់ចោលគំនិតបង្កើតកូន ដើម្បីដោះដូរប្រាក់កាសតទៅទៀត។ បើទោះជាយ៉ាងណាអាជ្ញាធរជំនាញ ដែលកំពុងរៀបចំសំណើឲ្យមានការសុំនៅក្រៅឃុំនេះបញ្ជាក់ថា មានស្ត្រីជាង ១០នាក់ហើយ បានសម្រាលកូន ហើយពួកគេកំពុងស្នាក់នៅមន្ទីរពេទ្យ ដោយមានកិច្ចការពារ និងថែទាំពីសមត្ថកិច្ច និងអង្គការដៃគូ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការប្រឆាំងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ប្រាប់អាស៊ីសេរីតាមទូរស័ព្ទ នៅថ្ងៃទី២៩ ខែតុលាថា មេធាវីការពារឲ្យស្ត្រី ទាំង ៣២នាក់ កំពុងរៀបចំឯកសារដាក់ទៅតុលាការ ដើម្បីពិចារណាឲ្យដោះលែងពួកគេបាននៅក្រៅឃុំបណ្ដោះអាសន្ន។ អ្នកស្រីថា ក្រុមស្ត្រីបានលើកឡើងពីការធានាថា នឹងចិញ្ចឹមកូនៗ ដែលពួកគេស៊ីឈ្នួលបង្កើតឲ្យអ្នកផ្សេងនោះ ដោយមិនបញ្ជូនកូនទៅឲ្យអ្នកដែលជួលពួកគេឡើយ៖ «នៅពេលដែលពួកគាត់មានទារកអ៊ីចឹង ជាចេតនារបស់យើងមិនចង់ដាក់ទោសទណ្ឌទេ តែដោយសារវាជាកំហុស។ ប៉ុន្តែរឿងសំខាន់ យើងគិតថា បើសិនជាគាត់ផ្លាស់ប្ដូរការគិតរបស់គាត់ថា គាត់នឹងមិនបន្តចង់ដោះដូរកូនតទៅទៀតទេ មានន័យថា គាត់ដូចជាឪពុកម្ដាយទូទៅអ៊ីចឹង គឺគាត់មានផ្ទៃពោះ ហើយគាត់ក៏ចិញ្ចឹមកូនទៅ។ ប៉ុន្តែបើគាត់មានផ្ទៃពោះហើយ នៅមានចេតនាមួយមិនចញ្ចឹមកូនហ្នឹងទេ ពីព្រោះគាត់នៅតែត្រូវការលុយ ហើយយកកូនទៅលក់ទៅដូរអីហ្នឹង គឺគាត់ទទួលទោសទៅ»។

ការិយាល័យប្រឆាំងការជួញដូរមនុស្ស រាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០១៨ បានឃាត់ខ្លួនមនុស្សចំនួន ៣៥នាក់ ក្នុងនោះមាន ៣២នាក់ជាស្ត្រីមានផ្ទៃពោះ ដែលជាអ្នកពពោះជំនួស និងមេខ្យល់ ៥នាក់ ក្នុងនោះមានម្នាក់ជាជនជាតិចិន នៅខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។ ក្រុមស្ត្រីមានផ្ទៃពោះត្រូវចោទប្រកាន់ពីបទ «ការជួញដូរមនុស្សដោយឆ្លងដែន» ក្រោមមាត្រា ១៦ នៃច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម។ ចំណែកមេខ្យល់ត្រូវចោទពីបទ «ការជួញដូរមនុស្សដោយឆ្លងដែន និងបទអន្តរការីជាមួយស្ត្រីពពោះ»។

អ្នកស្រី ជូ ប៊ុនអេងឲ្យដឹងថា ភ្លាមៗ ក្រោយការចាប់ខ្លួន ស្ត្រីទាំង ៣២នាក់ ត្រូវបាននាំទៅស្នាក់នៅអង្គការក្រៅរដ្ឋាភិបាលជាដៃគូឈ្មោះអង្គការមេត្រីអន្តរជាតិ (AIM) ប៉ុន្តែដោយសារពួកគេសុទ្ធតែជាស្ត្រីមានផ្ទៃពោះទើបអាជ្ញាធរពាក់ព័ន្ធសម្រេចឲ្យពួកគេស្នាក់នៅមន្ទីរពេទ្យមួយកន្លែងក្នុងរាជធានីភ្នំពេញ ដើម្បីងាយស្រួលទទួលបានការថែទាំសុខភាព ប៉ុន្តែនៅក្រោមកិច្ចការពារពីក្រុមនគរបាល។ អ្នកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ពេលនេះមានស្ត្រីជាង ១០នាក់ហើយ បានសម្រាលកូន ក្នុងនោះស្ត្រីខ្លះមានកូនភ្លោះ។ អ្នកស្រីថា អង្គការដៃគូបានផ្ដល់ជំនួយចាំបាច់ប្រចាំថ្ងៃ។

នាយកប្រតិបត្តិអង្គការមេត្រីអន្តរជាតិ ហៅកាត់ថា AIM ប្រចាំនៅកម្ពុជា លោក ដុន ប្រ៊ូស្ទ័រ (Don Brewster) បានប្រាប់សារព័ត៌មានក្នុងស្រុកថា អង្គការនេះកំពុងធ្វើការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីបណ្ដុះបណ្ដាលដល់ស្ត្រីទាំង ៣២នាក់ ឲ្យយល់ពីបញ្ហាការជួញដូរមនុស្ស និងការពពោះជំនួស។ លោករំពឹងថា ស្ត្រីទាំង ៣២នាក់ នឹងបាននៅក្រៅឃុំបណ្ដោះអាសន្ន។

អ្នកស្រី ជូ ប៊ុនអេង បញ្ជាក់ថា អាជ្ញាធរជាតិមានតួនាទីទប់ស្កាត់ និងបង្ក្រាបបទល្មើសនៃអំពើជួញដូរមនុស្ស។ ហេតុនេះត្រូវតែប្រាកដថា ការដោះលែងស្ត្រីទាំង ៣២នាក់នេះឲ្យនៅក្រៅឃុំបណ្ដោះអាសន្ននោះមិននាំទៅរកការជួញដូរមនុស្ស គឺការលក់កូនៗ របស់ពួកគេ ដែលជាទង្វើខុសច្បាប់៖ «ហើយបើយកហេតុផលថា ស្ត្រីដែលកំពុងពពោះ គឺសុទ្ធតែជាអ្នកក្រីក្រ ដើម្បីដោះស្រាយជីវភាព ដោះបំណុលដោយគ្រាន់តែយកទារកក្នុងផ្ទៃហ្នឹងធ្វើជា

ការដោះដូរជីវភាព គឺយើងចាត់ទុកថា ជាបទល្មើស ពីព្រោះអ្នកក្រីក្រមានន័យថា ធ្វើអ្វីក៏បានទេ គឺយើងត្រូវតែប្រុងប្រយ័ត្នក្នុងករណីហ្នឹង។ បើសិនជាគិតថា រឿងទាំងអស់នេះ ជាសិទ្ធិរបស់ស្ត្រីដែលគាត់មានចេតនា ដើម្បីនឹងយកកូនដោះដូរជីវភាព គឺកាន់តែខុសទៀតហើយ។ មានន័យថា គាត់អត់បានគិត ដល់សិទ្ធិរបស់ទារកដែលមានសិទ្ធិដែរនោះទេ»។

ក្រុមគ្រួសារស្ត្រីពរពោះជំនួសមួយចំនួនដែលសារព័ត៌មានក្នុងស្រុកបានសម្ភាសទទួចអោយអាជ្ញាធរពាក់ព័ន្ធដោះលែងសមាជិកគ្រួសារបានទៅជួបជុំគ្រួសារ ដោយប្ដេជ្ញាថានឹងចិញ្ចឹមទារក ដែលពួកគេពពោះជំនួសនោះវិញ ដោយមិនបញ្ជូនទារកទាំងនោះទៅក្រៅប្រទេស។

កាលពីឆ្នាំ២០១៧ អាជ្ញាធរក្រុងភ្នំពេញក៏បានបង្ក្រាបករណីជួញដូរតាមរយៈការពពោះជំនួសនេះម្ដងដែរ ដោយបានឃាត់ខ្លួនស្ត្រីជនជាតិអូស្ត្រាលីម្នាក់ឈ្មោះ Tammy-Alayne Chales និងជនជាតិខ្មែរ ២នាក់។

មន្ត្រីជំនាញការិយាល័យប្រឆាំងការជួញដូរធ្លាប់ឲ្យដឹងថា ស្ត្រីខ្មែរត្រូវបានជួលឲ្យពពោះជំនួសក្នុងតម្លៃ ១ម៉ឺនដូល្លារម្នាក់ ដោយពួកគេទទួលបានប្រាក់កក់ដំបូងពេលមានផ្ទៃពោះចំនួន ៥០០ដុល្លារ ហើយពេលកូនកើតមកពួកគេទទួលបាន ៣០០ដូល្លារក្នុងខែរហូតគ្រប់ចំនួន៕

## មន្ត្រី ៖ តុលាការជាអ្នកសម្រេច រឿងស្ត្រីស៊ីឈ្នួលពពោះ ៣២ នាក់

https://www.postkhmer.com/ ម៉ិច ដារ៉ា and គង់ មេគ្គា date 01 November 2018 08:40 ICT

**ភ្នំពេញៈ** ស្ត្រីស៊ីឈ្នួលពពោះចំនួន ៣២ នាក់ដែលកំពុងជាប់ឃុំពីបទជួញដូរមនុស្សកំពុងស្ថិតនៅក្នុងការពិចារណារបស់សាលាដំបូងរាជធានីភ្នំពេញអំពីការដោះលែងឲ្យនៅក្រៅឃុំ ឬត្រូវបន្តឃុំខ្លួន បន្ទាប់ពីពួកគេត្រូវបានចាប់ឃុំខ្លួនកាលពីខែកក្កដាកន្លងមក។ នេះបើយោងតាមការអះអាងរបស់លោកស្រី ជូ ប៊ុនអេង ថ្លែងទៅកាន់អ្នកសារព័ត៌មានបន្ទាប់ពីកិច្ចប្រជុំនៅក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៨។

លោកស្រី ជូ ប៊ុនអេង បានឲ្យដឹងថាការពិចារណានេះធ្វើឡើងបន្ទាប់ពីមេធាវីការពារឲ្យស្ត្រីពពោះទាំង ៣២ នាក់បានរៀបចំឯកសារដាក់ទៅតុលាការដើម្បីស្នើសុំឲ្យតុលាការធ្វើការពិចារណាដោះលែងពួកគេឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដើម្បីឲ្យពួកគេបានចិញ្ចឹមកូនៗដែលពួកគេស៊ីឈ្នួលបង្កើតឲ្យអ្នកផ្សេងនោះ ដោយពួកគេមិនបញ្ជូនកូនទាំងនោះទៅឲ្យអ្នកដែលជួលពួកគេឡើយ។ លោកស្រីបានថ្លែងថា៖ «វាអាស្រ័យលើទឡ្ហីករណ៍មួយចំនួនដែលតុលាការអាចជឿជាក់ថា ពេលដែលគាត់នៅក្រៅឃុំ តើគាត់នឹងប្រព្រឹត្តបទល្មើសបន្តទៀតទេដោយសារតែកូននៅក្នុងដៃគាត់។ បើគាត់ចង់ដោះដូរកូនគាត់នៅពេលណាគឺជារឿងមួយដែលគាត់នឹងអាចធ្វើ បើគាត់នៅតែមានចេតនាហើយយើងក៏ត្រូវការវិធានការមួយចំនួនដូច្នេះយើងចាំមើលថា តើតុលាការលោកនឹងសម្រេចយ៉ាងណា?វាអាស្រ័យលើចេតនារបស់គាត់ និងចម្លើយរបស់គាត់»។ លោកស្រីបានបន្ថែមថា៖ «យើងខ្ញុំគ្មានចេតនាចង់ធ្វើឲ្យមានភាពអយុត្តិធម៌ទេទៅលើស្ត្រីទាំងអស់ហ្នឹង។ វាអាស្រ័យលើទង្វើរបស់គាត់ថា បើគាត់នៅតែមានចេតនាប្រព្រឹត្តបទល្មើសគឺជាការទទួលខុសត្រូវរបស់គាត់ខ្លួនឯង»។ លោកស្រីបានបន្តថាក្នុងចំណោមស្ត្រី ៣២ នាក់គឺមានស្ត្រី ៣ នាក់បានរលូតកូន ស្ត្រីម្នាក់ដែលបានសម្រាលកូនតែកូនរបស់គាត់បានស្លាប់មុនពេលការបង្ក្រាបមានស្ត្រី ៩ នាក់បានបង្កើតកូនក្រោយការបង្ក្រាបផងដែរ។ លោកស្រីបានអះអាងថា ស្ត្រីទាំងនោះគឺមានចេតនាក្នុងការពពោះដើម្បីយកទារកទៅដោះដូរយកផលប្រយោជន៍ដោយពួកគេបានអះអាងថាគឺជាការលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្រ ឬដោះដូរបំណុល។លោកស្រីបានបញ្ជាក់បន្ថែមថា៖ «ករណីពពោះជំនួសនេះគឺជារឿងរំលោភសិទ្ធិទារកយ៉ាងធ្ងន់ធ្ងរ ហើយមិនមែនជារឿងលើកកម្ពស់សិទ្ធិស្ត្រីទេពីព្រោះស្ត្រីមិនមានសិទ្ធិក្នុងការលក់កូនខ្លួនឯងអ៊ីចឹងទេ»។

លោក សួស វិទ្យាវ៉ាន់ឌី អនុប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានីភ្នំពេញបានថ្លែងថា ករណីស្ត្រីពពោះជំនួសនេះគឺស្ថិតនៅក្នុងនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ ស្ត្រីចំនួន ៣២ នាក់កាលពីដំបូងត្រូវបានសមត្ថកិច្ចចាប់បញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាលក្នុងនាមជាជនរងគ្រោះ ប៉ុន្តែនៅទីបំផុតពួកគេត្រូវបានចោទប្រកាន់

និងឃុំខ្លួនមុនការជំនុំជម្រះដោយចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញកាលពីខែកក្កដាក្រោមការចោទប្រកាន់ពីបទប៉ុនប៉ងលក់ ទិញ ឬដោះដូរមនុស្សសម្រាប់ការផ្ទេរឆ្លងព្រំដែន និង ប្រព្រឹត្តជាអន្តរការីរវាងឪពុក ម្តាយសុំកូន និងស្ត្រីដែលមានផ្ទៃពោះតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌដែលអន្តរការីរវាងឪពុកម្តាយសុំកូន និងស្ត្រីមានផ្ទៃពោះអាចប្រឈមមុខនឹងការជាប់ពន្ធនាគារពី ១ ទៅ ៦ ខែ ប៉ុន្តែឥឡូវនេះស្ត្រីទាំង ៣២ នាក់ត្រូវបានបញ្ជូនទៅឃុំខ្លួនឯមន្ទីរពេទ្យ ១៦ ឧសភា ជាមន្ទីរពេទ្យនគរបាលដែលអាចប្រឈមនឹងទោសជាប់ពន្ធនាគារ ២០ ឆ្នាំ។

មន្ត្រីជំនាញការិយាល័យប្រឆាំងការជួញដូរធ្លាប់ឲ្យដឹងថា ស្ត្រីខ្មែរត្រូវបានជួលឲ្យពពោះជំនួសក្នុងតម្លៃ ១ ម៉ឺនដុល្លារក្នុងម្នាក់ដោយពួកគេទទួលបានប្រាក់កក់ដំបូងពេលមានផ្ទៃពោះចំនួន ៥០០ ដុល្លារ ហើយពេលកូនកើតមកពួកគេទទួលបាន ៣០០ ដុល្លារក្នុង ១ ខែរហូតគ្រប់ចំនួន៕

## កុមារី ប្រឈមមុខខ្ពស់នឹងការចាប់រំលោភ ពេលឪពុកម្តាយធ្វើការឆ្ងាយ

https://www.postkhmer.com/ គុង សុប្រាជ្ញ | Publication date 30 October 2018 | 09:54 ICT

នៅពេលបដិវត្តន៍ឧស្សាហកម្មជំនាន់ទី ៤ មកដល់ហើយកំពុងរីកចម្រើន និងដំណើរការលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនោះ ការប្រើប្រាស់មនុស្សយន្ត និង Cyber-Physical Systems ( CPS) ជាដើមបាននិងកំពុងចាប់ផ្តើមពី Version4.0 ទៅហើយ។ ការប្រើប្រាស់បច្ចេកវិទ្យានេះក៏កំពុងពេញនិយមផងដែរក្នុងចំណោមយុវវ័យជាច្រើនតាមបណ្តាប្រទេសនានាដែលអាចដំណើរការបានតាមរយៈអ៊ីនធឺណិត។ រីឯនៅកម្ពុជាហាក់ដូចជាងាយទទួលយកមកប្រើប្រាស់ដោយសារមានតម្លៃថោកតាមរយៈការភ្ជាប់ប្រព័ន្ធទូរស័ព្ទទិញ ១ ដុល្លារដូរបានតម្លៃ ១០០ ដុល្លារដែលនៅទីណាក៏អាចបើកមើលបានដែរឲ្យតែមានសេវាទូរស័ព្ទទៅដល់។

តាមរយៈប្រព័ន្ធឌីជីថលនៅលើទូរស័ព្ទនេះគឺទទួលបាននូវព័ត៌មានដ៏សម្បូរបែប ទាំងល្អ ទាំងអាក្រក់តាមកម្មវិធី អ៊ីនធឺណិត យូធូប YouTube និងបណ្តាញសង្គមហ្វេសប៊ុក Facebook ជាដើម។ ផលវិជ្ជមានចំពោះការប្រើនោះគឺសម្រួលរាល់ដំណើរការកិច្ចការងារ ការស្រាវជ្រាវ និងព័ត៌មានទាន់សភាពការណ៍ ប៉ុន្តែក៏មានបញ្ហាអវិជ្ជមានធ្វើឲ្យប៉ះពាល់ដល់សង្គមផងដែរ ជាពិសេសយុវជនដូចជា សកម្មភាព ប្រើអំពើហិង្សាដ៏ឃោរឃៅ ឃាតកម្ម អត្តឃាត និងរូបភាព និងវីដេអូអាសអាភាស ជាដើម។

ផ្ទុយទៅវិញការធ្វើអន្តរាគមន៍ និងការទប់ស្កាត់អំពើការចាប់រំលោភសេពសន្ថវៈ និងអំពើហិង្សាលើស្ត្រី និងកុមារីនាពេលសព្វថ្ងៃនេះ គឺដើរមិនទាន់សម័យឌីជីថលទេ ដោយសារការទប់ស្កាត់ ការអប់រំ និងយុទ្ធនាការ ១៦ ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារពីថ្ងៃទី ២៥ វិច្ឆិកាដល់ ១០ ធ្នូជារៀងរាល់ឆ្នាំដែលរៀបចំដោយក្រសួងកិច្ចការនារី និងអង្គការធ្វើការពាក់ព័ន្ធនឹងយេនឌ័រគឺធ្វើដុំៗគ្នាតែនៅរាជធានីភ្នំពេញ និងនៅទីរួមខេត្តតែប៉ុណ្ណោះ ដូចជាការបំពាក់បូពណ៌ស និងការរាំម៉ាឌីហ្សុនដដែលៗនោះ។

ចំណែកឯសមត្ថកិច្ចវិញទាល់តែមានករណីហិង្សា និងករណីរំលោភសេពសន្ថវៈ ឬរំលោភហើយសម្លាប់កើតឡើងទើបបានខ្នះខ្នែងស្វែងរកចាប់ខ្លួនអ្នកប្រព្រឹត្ត ហើយពេលចាប់បានក៏ឱ្យជនសង្ស័យឲ្យធ្វើត្រាប់តាមអ្វីដែលគេបានធ្វើនោះរួចទើបបញ្ជូនទៅតុលាការឱ្យកាត់ទោសតាមច្បាប់។ ដូចជាករណីយុវជនម្នាក់បានរំលោភសេពសន្ថវៈរួចសម្លាប់កុមារី ២ នាក់បងប្អូនក្នុងផ្ទះនៅស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំងកាលពីសប្តាហ៍មុនគឺកំពុងក្លាយជាបញ្ហាក្តៅគគុកទូទាំងប្រទេសនៅឡើយដែលជនសង្ស័យត្រូវបានសមត្ថកិច្ចឲ្យត្រាប់ពីរបៀបរំលោភ និងសម្លាប់ដែលខ្លួនបានប្រព្រឹត្តលើកុមារីទាំង ២ នាក់បងប្អូន។

ម្យ៉ាងវិញទៀតឪពុកម្តាយសម័យថ្មីនេះគឺខំប្រឹងធ្វើការងារបាត់ៗពីផ្ទះ ដូចជា ទៅធ្វើជាកម្មករ-កម្មការិនី តាមរោងចក្រដោយខ្លះក៏ធ្វើបន្ថែមម៉ោង និងធ្វើចំណាកស្រុកទៅក្រៅប្រទេសដើម្បីបំពេញតម្រូវការជីវភាពប្រចាំថ្ងៃដោយទុកឲ្យកូនៗនៅផ្ទះ និងទៅសាលារៀន ហើយខ្លះបើទោះបីជាការបែកបាក់គ្រួសាររស់ក៏ដោយ ក៏ឪពុកម្តាយយកកូន

តូចៗទៅផ្ញើនឹងយាយតា ឬក៏ពូមីងឬក៏អ៊ំជាដើម។ បើធ្វើការនៅជិតក៏ឪពុកម្តាយត្រូវចាកចេញពីផ្ទះពីព្រលឹមរហូតដល់ព្រលប់ដែរទើបបានមកផ្ទះវិញជួបមុខកូនៗដែលសកម្មភាពនេះធ្វើឲ្យកូនៗខ្វះភាពកក់ក្តៅហើយខ្លះក៏បានទៅរៀន តែខ្លះក៏មិនបានទៅរៀនដែរ។

បញ្ហាភាពក្រីក្ររបស់ឪពុកម្តាយមួយចំនួនធំគឺមកពីខ្វះចំណេះដឹង និងការទទួលកេរមរតកពីឪពុកម្តាយពួកគេបានតិចតួច ឬក៏អត់មានតែម្តងដូចជា ដីស្រែ ដីផ្ទះ និងការរកស៊ីបន្តពីឪពុកម្តាយជាដើម។ អ៊ីចឹងហើយដំណោះស្រាយគឺមានតែលក់កម្លាំងពលកម្មដើម្បីទ្រទ្រង់ជីវភាពគឺការមកធ្វើការរោងចក្រនៅទីក្រុង ឬទីប្រជុំជន និងធ្វើចំណាកស្រុក បើទោះបីជាជួបការលំបាកប្រៀបដូចទាសករក៏ដោយក៏សុខចិត្តដែរ ពោលគឺមកពីអស់ជម្រើស។ លក្ខខណ្ឌចន្លោះប្រហោងទាំង ២ នេះពោលគឺភាពងាយស្រួលដល់យុវជនមួយចំនួនក្នុងការទទួលបាននូវរូបអាសអាភាសតាមរយៈឌីជីថល និងការធ្វើចំណាកស្រុករបស់ឪពុកម្តាយដែលខំប្រឹងធ្វើការដោយទុកកូនតូចៗផ្ញើនឹងសាច់ញាតិនេះហើយ ដែលធ្វើឲ្យកុមារីប្រឈមមុខនឹងគ្រោះថ្នាក់ដែលជនល្មើសអាចឆ្លៀតឱកាសចាប់រំលោភសេពសន្ថវៈបានងាយស្រួល។ ដូចករណីរំលោភ និងសម្លាប់កុមារី ២ នាក់បងប្អូននៅខេត្តកំពង់ឆ្នាំងជាដើមគឺម្តាយបានមកធ្វើការរោងចក្រនៅភ្នំពេញ រីឯឪពុកធ្វើចំណាកស្រុកទៅប្រទេសថៃ ហើយផ្ញើកូនជាមួយពូបង្កើតដែលការគ្រប់គ្រងបែបនេះមិនបានពេញលេញដូចឪពុកម្តាយបង្កើតទេ។

រីឯការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពក៏មិនទាន់ដំណើរការបានល្អដែរពោលគឺនៅខ្វះចំណុចមួយចំនួនក្នុងការគ្រប់គ្រងស្ថានការណ៍ និងទំនាក់ទំនងល្អរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ។ ជាងនេះទៀតការផ្សព្វផ្សាយពីអំពើហិង្សាលើស្ត្រី និងកុមារដោយក្រុមគណៈកម្មការទទួលបន្ទុកផ្នែកស្ត្រី និងកុមារថ្នាក់ឃុំ និងស្រុកក៏មិនទាន់ជ្រួតជ្រាបដល់សហគមន៍ទូលំទូលាយដែរពោលគឺឲ្យតែអញ្ជើញចូលរួមគឺភាគច្រើនអ្នកភូមិមកតែស្ត្រីទេ រីឯបុរស និងយុវជនតែងតែគេចវេះមិនចង់ចូលរួមឡើយ។

ហេតុដូច្នេះទាំងក្រសួងកិច្ចការនារី និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ស្រុក និងឃុំ និងអង្គការដៃគូដែលធ្វើការជាមួយសិទ្ធិស្ត្រី និងកុមារគួរតែប្តូរយុទ្ធសាស្ត្រថ្មីៗឱ្យសមស្របនឹងសម័យឌីជីថលក្នុងការទប់ស្កាត់ការចាប់រំលោភសេពសន្ថវៈស្ត្រី និងកុមារីបើទោះបីជាប្រព័ន្ធឌីជីថលនេះមិនត្រូវបានផ្តល់ជាអាទិភាពក្នុងការធ្វើអន្តរាគមន៍ក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រីឆ្នាំ ២០១៤ ដល់ ២០១៨ នេះក៏ដោយ។

រីឯថវិកាយេនឌ័រ (Gender Budget) ក៏ត្រូវបន្ថែមមកគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារនៅថ្នាក់ស្រុក និងឃុំផងដែរដោយសារនៅជិតពលរដ្ឋដើម្បីងាយស្រួលផ្សព្វផ្សាយទាំងតាមមូលដ្ឋាន ទាំងប្រព័ន្ធឌីជីថល ដូចជាការដាក់បញ្ចូលសារអប់រំតាមហ្វេសប៊ុក (Boost) និងការបង់លុយបញ្ជ្រាបបញ្ចូលសារ និងរូបភាពអប់រំតាមឌីជីថលក្នុងយូធូប ឬក៏ក្នុងអត្ថបទសារព័ត៌មានជាដើម។ ជាងនេះទៅទៀតគឺការបង្កើនទំនាក់ទំនងគ្នាឲ្យល្អរវាងពលរដ្ឋ និងអាជ្ញាធរ ប្រសិនបើមានពលរដ្ឋចំណាកស្រុកក៏គួរតែផ្តល់ព័ត៌មានជូនអាជ្ញាធរមូលដ្ឋានឲ្យបានដឹងហើយសហគមន៍គួរតែចងក្រងជាក្រុមឲ្យកាន់តែរឹងមាំបន្ថែមទៀតក្នុងការផ្ញើសារអប់រំទៅបុរស និងយុវជនចំពោះការប្រើអំពើហិង្សា និងការចាប់រំលោភសេពសន្ថវៈនេះ ព្រោះករណីនេះឃាតករភាគច្រើនគឺជាបុរស ឬយុវជនដែលរស់នៅក្នុងភូមិជាមួយជនរងគ្រោះតែម្តង៕

## អាណាព្យាបាលទាំងឡាយ ចូរអ្នកប្រយ័ត្ន មានមេរៀនច្រើនហើយនៅប្រទេសចិន មិនត្រូវប្រហែសទេ ពុំនោះសោកស្តាយខាតបង់ដួងចិត្តអស់១ជីវិត

http://www.cen.com.kh/archives October 30, 2018

ពពួកជួញដូរមនុស្ស ពិសេសក្មេងតូចៗ កាន់តែមានវិធីចម្លែកៗ តែយ៉ាងណា គឺផ្តើមពីការធ្វេសប្រហែសរបស់អ្នកជាឪពុកម្តាយ ។ ប្រព័ន្ធផ្សព្វផ្សាយរបស់ចិនបានបង្ហាញពីវិធី ៤ ដែលពួកវានិយមប្រើគឺ ៖

**១.ដើរតាមក្រោយ ហើយរង់ចាំឱកាស ៖**

មិនត្រូវឲ្យកូនដើរពីក្រោយខ្នងជាច់ខាត ព្រោះវានឹងឆ្លៀតពេលដែលអ្នកប្រហែសតែបន្តិចនឹងចាប់ឱបកូនយកទៅបាត់ ។ កាមេរ៉ាសុវត្ថិភាពនៅចិនបានកត់ត្រារូបភាពមួយគឺ ៖ កូនស្រីរត់ពីក្រោយខ្នងម្ដាយពេលដាច់គ្នាឆ្ងាយបន្តិចស្ត្រី ២នាក់ បានចាប់ឱបក្មេងរួចរត់បែរក្រោយយ៉ាងលឿន ។

**២.ឆ្លៀតពេលដែលក្មេងគ្មានមនុស្សចាស់នៅក្បែរ**

តាមប្រព័ន្ធផ្សព្វផ្សាយរបស់ចិននោះ ស្ត្រីជាម្ដាយម្នាក់បានរំលឹកយ៉ាងជូរចត់ថា ៖ គាត់កំពុងហាលខោអាវនៅជាន់លើផ្ទះ ទុកឲ្យកូននៅលេងម្នាក់ឯងក្បែរមាត់ទ្វារ ស្រាប់តែក្រឡេកឃើញមានមនុស្សស្រីម្នាក់មកលួងលេងជាមួយវា ។ នាងក៏ប្រញាប់រត់ចុះក្រោម តែកូនសំណព្វចិត្តបាត់ស្រមោលទៅហើយ ។ ក្រោយការស្វែងរក ១១ឆ្នាំនាងបានប្រទះឃើញកូនរបស់ខ្លួន តែវាបាន "កំបុតជើងសងខាង ថែមទាំងត្រូវកាត់អណ្ដាត" កំពុងឈរសុំទានតាមផ្លូវនៅទីក្រុងមួយទៀត ។

**៣.បង្កចលាចលពេលមនុស្សកុះករ**

ម្ដាយនិងកូនកំពុងដើរតាមផ្លូវមានមនុស្សច្រើនក៏ឮសម្រែក "ចោរៗ" ម្ដាយលែងដៃកូន ស្រវ៉ាមើលរបស់របរខណៈពេលកូនចេះតែចលនាទៅមុខ ។ ពេលងាករកកូនក៏បាត់ស្រមោល ។ សំណាងល្អនាងស្រែង ហើយចោលភ្នែកឃើញកូន បានទៅដល់ម្ខាងផ្លូវក៏ប្រញាប់ដេញតាមពួកចាប់ជំរិត ក៏គេចខ្លួនបាត់ ។

**៤.បន្លំធ្វើជាបុគ្គលិកក្រុមហ៊ុនដើរបញ្ឆោត ៖**

ឪពុកម្ដាយរវល់ចេញក្រៅមួយភ្លែត ទុកឲ្យកូនៗនៅតែឯង ឬជាមួយមនុស្សចាស់ជរា ។ វាបន្លំធ្វើជាបុគ្គលិក Internet ឬរដ្ឋករទឹក មកសុំពិនិត្យមើល ។ ពេលបើកទ្វារ នោះវាស្រវ៉ាចាប់ឡើងឡាន ឬម៉ូតូភ្លាម ។ រឿងបែបគ្នានេះដែរបានកើតឡើងច្រើននៅចិនមុននេះ ហើយបច្ចុប្បន្នកំពុងរាលដាលដល់វៀតណាម ។

ខាងក្រោមជាវីដេអូដែលទូរទស្សន៍វៀតណាម បានផ្សាយឃ្លីបមួយពីរឿងក្មេងស្រីវៀតណាម ត្រូវបានចាប់យកទៅចិន ហើយក្លាយជាស្រីកម្សាន្ត ។ ពួកនាងនៅរង់ចាំគ្រាកុមាររត់ទៅជាមួយក្រុមគ្រួសារនាប្រទេសវៀតណាម ។ ក្រុមសារព័ត៌វៀតណាមក៏បានសាកល្បងទាក់ទងជាមួយក្រុមជួញដូរក្មេង ទាំងជនជាតិចិន និងជនជាតិវៀតណាម នាប្រទេសចិន ៕

## ម្ចាស់ហាងមួយកន្លែងនៅបាងកក សម្លាប់មនុស្សកាត់សាកសពកិនធ្វើម្ហូបឲ្យភ្ញៀវបរិភោគ

http://www.dailyinsider.me/ 2018-10-31

ថៃ៖ មនុស្សមួយក្រុមបានទៅរាយការណ៍ប្រាប់អាជ្ញាធរប្រទេសថៃ បន្ទាប់ពីពួកគេបានចូលទៅហូបអាហារពេលល្ងាចនៅក្នុងហាងមួយដែលមានទីតាំងក្នុងតំបន់ ឡាតក្រាបាង (Lat Krabang) ដែលស្ថិតនៅក្នុងទីក្រុងបាងកក ប្រទេសថៃ។ នេះបើយោងតាមសារព័ត៌មាន AsiaOne របស់សិង្ហបុរី និង OrientalDaily របស់ប្រទេសម៉ាឡេស៊ីបានចុះផ្សាយកាលពីរសៀលថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៨។ ពួកគេបានសន្និដ្ឋានថាសាច់ចិញ្ច្រាំដែលនៅក្នុងមីស៊ុបដែលគាត់បានហូបនោះគឺជាសាច់មនុស្ស ហើយពួកគេក៏បានចាកចេញពីហាងនោះភ្លាមដើម្បីទៅរាយការណ៍ប្រាប់អាជ្ញាធរថៃពីហេតុការណ៍ខាងលើ។

លុះពេលអាជ្ញាធរថៃចុះទៅដល់ទីតាំងកើតហេតុភ្លាម ពួកគេបានដើរសំដៅទៅត្រួតពិនិត្យនៅត្រង់ផ្ទះបាយធ្វើម្ហូបក្នុងហាងនោះ។ ស្រាប់តែឃើញសុទ្ធតែស្នាមឈាមជាបពេញជញ្ជាំង និងមានបំណែកសាកសពមនុស្សនៅពាសពេញឥដ្ឋដែលគ្រោងនឹងដាក់វាកិនធ្វើជាសាច់ចិញ្ច្រាំ។ គួរបន្តថា ជនរងគ្រោះនៅក្នុងហេតុការណ៍នេះត្រូវបានគេស្គាល់ថា ជាបុរសចំណាស់ម្នាក់មានឈ្មោះថា Prisit Inpathom ដែលតែងតែ៤ស្សាហ៍ទៅបរិភោគម្ហូបអាហារក្នុងហាងនោះជាប្រចាំ។

បើតាមសម្ដីរបស់អាជ្ញាធរក្នុងតំបន់បានសន្និដ្ឋានពីការស្លាប់នេះថា "ប្រហែលជាមានការឈ្លោះគ្នារវាងម្ចាស់ហាងនិងជនរងគ្រោះទើបបណ្ដាលឲ្យមានការកាប់សម្លាប់គ្នាយ៉ាងដូច្នេះ"។ នៅពេលអាជ្ញាធរចុះទៅធ្វើកោសល្យវិច្ច័យលើសាកសព ពួកគាត់បានឃើញស្នាមកាំបិតជាច្រើនមាននៅលើដងខ្លួនជនរងគ្រោះ (៥កាំបិតនៅត្រង់ស្មា និង ១កាំបិតនៅចំភ្លៅខាងស្ដាំ)។ ហើយសាកសពជនរងគ្រោះត្រូវបានម្ចាស់ហាងចិត្តឃោរឃៅនោះយកទៅកប់ក្នុងលូខាងក្រោយផ្ទះយ៉ាងអាណោចអាធ័ម។ ម្ចាស់ហាងនោះបានកាត់សាច់សាកសពនោះជាបំណែកៗដើម្បីយកទៅកិនធ្វើជាសាច់ចិញ្ច្រាំដាក់ចូលមីស៊ុបឲ្យភ្ញៀវបរិភោគ។ មកដល់ពេលនេះ អាជ្ញាធរបានចាត់វិធានការតាមចាប់ម្ចាស់ហាងដែលកំពុងរត់គេចខ្លួនពីសំណាញ់ច្បាប់នេះហើយ។ ពួកបាននិយាយបន្តថា " មិនដឹងជាមនុស្សប៉ុន្មាននាក់ទេដែលបានបរិភោគម្ហូបដែលធ្វើពីសាច់មនុស្សនេះ" ៕

# ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨

## កូនស្រីពីរនាក់ត្រូវរំលោភសម្លាប់ពេលឪពុកម្ដាយធ្វើចំណាកស្រុក

https://khmer.voanews.com/ 02 វិច្ឆិកា 2018 ស៊ុន ណារិន

ឃុំផ្សារ ខេត្តកំពង់ឆ្នាំង៖ អ្នកស្រី អុល ធីតា ទើបតែបាត់បង់កូនស្រីពីរនាក់។ ពួកគេត្រូវបានរំលោភសម្លាប់កាលពីថ្ងៃទី១៧ ខែតុលា ក្រោយឪពុកម្ដាយបានចាកចេញពីផ្ទះទៅធ្វើការនៅភ្នំពេញ និងនៅប្រទេសថៃ។ អ្នកស្រីធីតា អាយុ៣៤ឆ្នាំ មានប្រសាសន៍ថា អ្នកស្រីទៅភ្នំពេញបានរយៈពេល៤ថ្ងៃ ហើយប្ដីទៅធ្វើការនៅប្រទេសថៃបានរយៈពេល៥ថ្ងៃ មុននឹងមានហេតុការណ៍នេះកើតឡើង។ អង្គុយនៅក្បែរផ្ទះ ដែលជាកន្លែងកូនរបស់អ្នកស្រីត្រូវបានរំលោភសម្លាប់ដាក់ក្នុងហិបឈើមួយ អ្នកស្រី ធីតា បានរៀបរាប់ប្រាប់ VOA ថា អ្នកស្រីត្រូវសងបំណុលគេជិត១លានរៀលនៅចុងឆ្នាំនេះ ទើបអ្នកស្រីសម្រេចចាកចេញពីភូមិកំណើត ស្ថិតក្នុងភូមិថ្មី ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ អ្នកស្រីមានប្រសាសន៍ថា អ្នកស្រីបានជំពាក់បំណុលគេជិត៧ឆ្នាំមកហើយ និងមិនបានបង់ការប្រាក់សងគេ ជិតកន្លះឆ្នាំចុងក្រោយនេះ ដែលនេះនាំឲ្យអ្នកស្រីសម្រេចចិត្តចាកចេញពីកូនទៅស្វែងរកការងារនៅភ្នំពេញ។ អ្នកស្រីបានថ្លែងប្រាប់ VOA នៅផ្ទះរបស់អ្នកស្រីថា៖ «មនុស្សស្រីម្ដាយនីមួយៗ គ្មាននរណាចង់បែកពីកូនដែលកំពុងពេញស្រឡាញ់ហ្នឹងទេ។ ចង់តែនៅជិតកូន ប៉ុន្តែដោយលក្ខណៈ វាជីវភាពវាក្រមែនទែន ដល់ថ្នាក់ដល់យើងមិនដឹងរកអីនៅនេះ ដែលអាចសងគេបាន»។ អ្នកស្រី ធីតា មិនមានដីស្រែ ឬដីភូមិនោះទេ។ ដីកំពុងនៅបច្ចុប្បន្ន គឺជាដីរបស់បងប្អូន ដោយអ្នកស្រីបានសង់ខ្ទមប្រក់ស្លឹកត្នោតមួយសម្រាប់រស់នៅជាមួយកូនស្រីពីរនាក់។ អ្នកស្រីមានមុខរបរមិនប្រាកដនោះទេ គឺប្រមូលស្លឹកធ្វើកន្ត្រក កញ្ជើ និងដើររកសត្វអង្រងក្នុងព្រៃ យកទៅលក់នៅទីផ្សារ។

ចំណាកស្រុករកការងារធ្វើជាបញ្ហាទូទៅរបស់ប្រជាជនកម្ពុជា ដែលរស់នៅតាមជនបទ ដោយសារពួកគេពិបាកក្នុងការរកចំណូលពីក្នុងតំបន់ដែលពួកគេកំពុងរស់នៅ។ ពួកគេបានផ្ញើកូនទុកឲ្យយាយតា បងប្អូន ឬសាច់ញាតិ មើលថែទាំ។ ករណីនេះ បានធ្វើឲ្យក្មេងស្រីស្ថិតក្នុងហានិភ័យខ្ពស់ពីការបៀតបៀនផ្លូវភេទ ការរំលោភសម្លាប់ជាដើម។ កុមារនៅតាមជនបទ ងាយរងគ្រោះដោយសារពួកគេត្រូវឃ្វាលគោទៅស៊ីស្មៅ និងពេលខ្លះត្រូវទៅប្រមូលអនុផលធម្មជាតិពីតំបន់ឆ្ងាយៗផងដែរ។

លោកស្រី ធន សុគន្ធា មន្ត្រីសម្របសម្រួលផ្នែកសិទ្ធិស្ត្រី និងកុមាររបស់សមាគមសិទ្ធិមនុស្សអាដហុក មានប្រសាសន៍ថា កុមារដែលស្ថិតក្នុងគ្រួសារក្រីក្រ និងឪពុកម្ដាយធ្វើចំណាកស្រុក គឺជាក្រុមគ្រោះថ្នាក់ជាងគេនឹងការរំលោភបំពានផ្លូវភេទ។ លោកស្រីបញ្ជាក់ថា ក្នុងឆ្នាំ២០១៨ នេះ ករណីរំលោភផ្លូវភេទលើកុមារ គឺជាករណីរំលោភសាហាវ។ លោកស្រីមើលឃើញថា បញ្ហាគ្រឿងញៀន ការសេពគ្រឿងស្រវឹង និងការមើលវីដេអូអាសអាភាស ជាកត្តាដែលធ្វើឲ្យមានការរំលោភផ្លូវភេទលើកុមារ។ លោកស្រីបានបញ្ជាក់ថា៖ «ខ្ញុំទទួលស្គាល់ ចំពោះអ្នកទីក្រុង និងអ្នកជនបទ គាត់អាចAccess (ចូលមើល) មើលបានដូចគ្នា ប៉ុន្តែចំពោះអ្នកនៅទីក្រុង គាត់អាចមានសេវា(ផ្លូវ

ភេទ)។ ប្រសិនបើគាត់មានចំណង់អីចឹង គាត់អាចទៅរកសេវាផ្សេងៗ។ ប៉ុន្តែនៅជនបទ នៅតំបន់ជនបទដាច់ស្រយាល នៅពេលដែលគាត់មានចំណង់អញ្ចឹង គាត់ទៅណា?» នៅក្នុងករណីរំលោភសម្លាប់ក្មេងស្រី២នាក់ក្នុងខេត្តកំពង់ឆ្នាំង កាលពី២សប្តាហ៍មុន កុមារជាជនរងគ្រោះ ម្នាក់ អាយុ១៤ឆ្នាំ រៀនថ្នាក់ទី៧ និងម្នាក់ទៀតអាយុ៧ឆ្នាំ រៀនថ្នាក់ទី២។ ពួកគេជាបងប្អូនម្តាយតែមួយ ឪពុកផ្សេងគ្នា។

បើតាមសមត្ថកិច្ច ជនដៃដល់បានរំលោភកូនច្បងនៅខ្ទមតូចមួយក្នុងភូមិដែលពួកគេស្នាក់នៅ។ បន្ទាប់មកដោយសារប្អូនស្រីដឹង ខ្លាចបែកការណ៍ ជនដៃដល់ក៏បានសម្លាប់ពួកគេតែម្តង។

ម្តាយជនរងគ្រោះមានប្រសាសន៍ថាឃាតក និងក្មេងស្រីទាំងពីរនាក់ ត្រូវជាសាច់ញាតិនឹងគ្នា ដូចពូនិងក្មួយ។ ឃាតកត្រូវបានចាប់ខ្លួននាពេលក្រោយមក។ អ្នកស្រីបានថ្លែងប្រាប់ VOA ថា៖ «បងប្អូនញាតិជិតខាង គេមកមើលអញ្ចឹង គេថាអាឆ្កែ អាឆ្នាអា ស៊ីបាយបោកឆ្នាំង។ គេនិយាយគេជៀលអញ្ចឹង។ កុំបូលិសនៅជុំវិញ កុំអីងាប់បាត់ហើយ ព្រោះប្រជាជនខឹងមែនទែន វាមិនសមណាស៊ីបាយបោកឆ្នាំង។ អត់បាយហូបមីង អត់លុយចាយមីង អត់បារីជក់មីង»។

ការសេពគ្រឿងស្រវឹង គ្រឿងញៀន ការមើលវីដេអូអាសអាភាស កង្វះការអប់រំ និងការធ្លាក់ចុះនៃសីលធម៌សង្គម ត្រូវបានមើលឃើញថាជាបញ្ហាដែលនាំឲ្យមានការរំលោភបំពានផ្លូវភេទលើកុមារ។

មេឃុំផ្សារ លោក ប៊ិន សុផាន មានប្រសាសន៍ថា ជនដៃដល់បានប្រើប្រាស់គ្រឿងស្រវឹង មុននឹងរំលោភ និងសម្លាប់កុមារ។ ចំណែកសមត្ថកិច្ចបានអះអាងថា ជនដៃដល់ក៏បានប្រើប្រាស់គ្រឿងញៀនផងដែរ។ លោកមេឃុំបានថ្លែងថា៖ «មនុស្សជិតមួយម៉ឺននាក់ មានមនុស្សតែម្នាក់ហ្នឹង សកម្មភាពបែបហ្នឹង ខ្ញុំអត់ទម្លាក់ទៅលើសង្គមទេ ទម្លាក់ទៅលើអារម្មណ៍ខ្លួនឯងដែលវាព្រៃផ្សៃ អារម្មណ៍ព្រៃផ្សៃរបស់បុគ្គល»។ បើតាមលោកមេឃុំ ក្នុងចំណោមប្រជាជនសរុបជាង៧ពាន់នាក់ក្នុងឃុំផ្សារ ប្រជាជនពេញកម្លាំងដែលធ្វើចំណាកស្រុក មានទៅដល់ជាង៥០០នាក់ ដែលពួកគេទៅធ្វើការនៅក្រៅប្រទេស និងចំណាកស្រុកទៅភ្នំពេញ និងខេត្តផ្សេងៗ។ មេឃុំរូបនោះបានឲ្យដឹងថា អាជ្ញាធរនឹងបន្តអប់រំប្រជាពលរដ្ឋឲ្យមានការប្រុងប្រយ័ត្ន និងអប់រំយុវជនឲ្យមានការយល់ដឹងអំពីបញ្ហាទាំងនេះ។

អង្គភាពការពារកុមារ(Child Protection Unit) ដែលជាគំនិតផ្តួចផ្តើមរវាងអង្គការមូលនិធិកុមារកម្ពុជា និងក្រសួងមហាផ្ទៃ ដើម្បីជួយកុមារដែលរងការរំលោភបំពាន បានរាយការណ៍ថា ក្នុងឆ្នាំ២០១៦ ករណីរំលោភលើកុមារមានចំនួន២០៥ករណី ហើយបានធ្លាក់ចុះមក១៤៧ករណី ក្នុងឆ្នាំ២០១៧។ ប៉ុន្តែចំនួនជនរងគ្រោះដោយសារការសម្លាប់ បានកើនឡើងពី២១ទៅ២៤នាក់។

លោក មាស ប៊ុនលី មន្ត្រីផ្នែកទំនាក់ទំនងរបស់អង្គការយូនីសេហ្វ(UNICEF) មានប្រសាសន៍ថា ការរំលោភ និងការបំពានផ្លូវភេទនៅតែការគំរាមទៅដល់កុមារ។ លោកបានប្រាប់ VOA តាមសារអេឡិចត្រូនិក ឬអ៊ីម៉ែលថា៖ «ឧបសគ្គក្នុងការការពារកុមារ គឺថានៅពេលគ្រួសារ ឬសហគមន៍ មិននិយាយចេញមក បើទោះនៅពេលពួកគេបានដឹងអ្វីកំពុងកើតឡើងក្នុងសហគមន៍របស់ពួកគេ ពីព្រោះពួកគេគិតថា នេះមិនមែនជាការងាររបស់ពួកគេក្នុងការសួរសំណួរ។ ការមិននិយាយនេះនាំឲ្យជនបំពាន កេងប្រវ័ញ្ច និងរំលោភក្មេង»។ លោកបញ្ជាក់បន្ថែមថា៖ «វាមានសារៈសំខាន់ដែលឪពុកម្តាយ និងអ្នកមើលថែ ធានាថាក្មេងៗនឹងមិនត្រូវទុកនៅផ្ទះតែឯង ដែលជាការមិនយកចិត្តទុកដាក់ និងនាំឲ្យមានគ្រោះថ្នាក់។ ក្មេងៗគួរតែត្រូវមើលថែគ្រប់ពេលវេលា»។ ករណីរំលោភសម្លាប់ក្មេងស្រីនេះធ្វើឲ្យមានការពិភាក្សានៅលើបណ្តាញសង្គមហ្វេសប៊ុក។ ពួកគេចាត់ទុកថា នេះជាករណីសាហាវព្រៃផ្សៃមួយ ហើយអ្នកខ្លះទាមទារឲ្យមានការដាក់ទោសទណ្ឌលើសពីការជាប់ពន្ធនាគារមួយជីវិត។ ប៉ុន្តែកម្ពុជាមិនមានច្បាប់ប្រហារជីវិតនោះទេ។

លោកស្រី ញ៉េប សុភាព អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលជាស្ថាប័នរបស់រដ្ឋាភិបាល មានប្រសាសន៍ថា លោកស្រីមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការរំលោភកុមារនៅតាមជនបទ ដែលនេះ

ដោយសារពួកគេរស់នៅក្នុងភាពក្រីក្រ ឪពុកម្តាយចំណាកស្រុក ទុកកូននៅកន្លែងមិនមានសុវត្ថិភាព។ លោកស្រីបន្ថែមថា រដ្ឋាភិបាលកំពុងរៀបចំឲ្យមានច្បាប់កិច្ចការពារកុមារ ដែលនឹងផ្តោតគ្រប់ជ្រុងជ្រោយទៅលើកិច្ចការពារកុមារ បន្ថែមលើច្បាប់ និងបទដ្ឋាននានាពាក់ព័ន្ធនឹងការការពារសុវត្ថិភាពកុមារ។ លោកស្រីបន្តថា ប្រជាពលរដ្ឋត្រូវតែមានការគោរពច្បាប់ដែលមាន ហើយមិនត្រូវធ្វើអ្វីតាមកំហឹងដែលមាននោះទេ។ លោកស្រីបានបញ្ជាក់ថា៖ « ប្រទេសយើង យើងមានច្បាប់ ហើយយើងគោរពតាមសិទ្ធិមនុស្ស។ មិនមែនថាយើងមិនខឹងគាត់ឈឺចាប់ទេ យើងអាចដាក់ទោសទណ្ឌគាត់មួយជីវិត មិនអាចធ្វើអីទៅតាមកំហឹងខ្លួនឯងបានទេ»។ ក្រោយហេតុការណ៍រំលោភសម្លាប់កើតឡើង អ្នកភូមិនិយាយថា ពួកគេមានការប្រយ័ត្នប្រយែងខ្លាំងជាងមុនទៅលើសុវត្ថិភាពរបស់ក្មេងៗ។ អ្នកស្រី ធីតា ម្តាយជនរងគ្រោះ បានចាត់ទុកថា នេះជាការធ្វេសប្រហែសរបស់អ្នកស្រីដែលបានផ្ញើកូនឲ្យបងប្អូនមើលថែ ហើយអ្នកស្រីអំពាវនាវឲ្យប្រជាពលរដ្ឋមានការប្រុងប្រយ័ត្ននឹងសុវត្ថិភាពរបស់ក្មេងផងដែរ។ អ្នកស្រីមានប្រសាសន៍ថា៖ «ខ្ញុំចូលក្នុងផ្សារកំពង់ធ្នាំង គេនិយាយដូចបង្ហោះហ្វេសប៊ុកដែរ។ បងអីម្នាក់ហ្នឹង គេស្គាល់ខ្ញុំ ព្រោះខ្ញុំធ្លាប់លក់អង្រ្គងនៅហ្នឹង។ គេថាអ្ហែង កូនប៉ុណ្ណាណីអស់ហើយ មិនសមណាអ្ហែងដើរចេញចោលកូនឲ្យនៅតែឯង។ ផ្ញើម្តាយគេ ទុកឲ្យកូនស្រីពីរនាក់នៅតែឯង។ ខ្ញុំដើរចេញមក ខ្ញុំអត់តបជាមួយគេទេ ព្រោះខ្ញុំនឹកឃើញថា ខ្លួនខ្ញុំវាខុសដែរ ប៉ុន្តែលក្ខណៈដែលខ្ញុំខុសហ្នឹង គឺខ្ញុំស្វែងរកដំណោះស្រាយក្នុងគ្រួសាររបស់ខ្ញុំ»៕

## ខ្សែភាពយន្តឯកសារ "ម្តាយខ្ញុំបានលក់ខ្ញុំ"៖ ប៉ូលិសហៅស្ត្រីពីរនាក់ម្តាយកូនទៅសាកសួរ

http://bayontv.com.kh/ 02/11/2018

ភ្នំពេញ៖ ស្ត្រីពីរនាក់ម្តាយ និងកូន ដែលថតខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា "ម្តាយរបស់ខ្ញុំបានលក់ខ្ញុំ" ត្រូវបានប៉ូលិសហៅមកសាកសួរ នៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជននៃស្នងការនគរបាលរាជធានីភ្នំពេញ។

ការសាកសួរនេះ គឺបន្ទាប់ពីខ្សែភាពយន្តឯកសារមួយនេះ ត្រូវបានបង្ហោះផ្សព្វផ្សាយនៅលើបណ្តាញសង្គមហ្វេសប៊ុក ដែលធ្វើឲ្យមានការភ្ញាក់ផ្អើល និងភ័ន្តច្រឡំ ជាពិសេសធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់ស្ត្រីខ្មែរ។ ការសាកសួរស្ត្រីពីរនាក់ម្តាយ និងកូនគឺបានធ្វើឡើងតាំងពីថ្ងៃទី៣១ ខែតុលារហូតមកដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៨ នេះ នៅមិនទាន់បញ្ចប់នៅឡើយទេ។ ស្ត្រីទាំងពីរនាក់មានឈ្មោះ គៀង ស្រីម៉ិច ត្រូវជាកូន និងឈ្មោះ កៅ ម៉ាល័យ ត្រូវជាម្តាយ។ ទាំងម្តាយ និងកូនស្រីបានសារភាពថា ពួកគាត់ទទួលបានលុយ ២០០ដុល្លារ សម្រាប់ការសម្តែងនៅក្នុងខ្សែភាពយន្តនេះ។ ប៉ុន្តែអ្វីដែលថតគឺមិនមែនជាខ្សែជីវិតពិតរបស់គាត់ទាំងពីរនាក់ទេ៕

## ក្រសួងមហាផ្ទៃរកកិច្ចអន្តរាគមន៍ជួយស្ត្រីស៊ីឈ្នួលពពោះឱ្យនៅក្រៅឃុំ ថ្ងៃព្រហស្បតិ៍ ទី១ ខែកញ្ញា ឆ្នាំ២០១៨

http://wmc.org.kh ថ្ងៃព្រហស្បតិ៍ ទី១ ខែកញ្ញា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឱ្យដឹងថា ក្រសួងកំពុងស្វះស្វែងរកកិច្ចអន្តរាគមន៍តាមផ្លូវច្បាប់ដើម្បីជួយស្ត្រីស៊ីឈ្នួលពពោះជំនួសចំនួន៣២នាក់ឱ្យបាននៅក្រៅឃុំ ក្រោយពីពួកគេត្រូវបានចាប់ឃុំខ្លួនក្នុងការបង្ក្រាបពាក់ព័ន្ធករណីជួញដូរមនុស្សនៅរាជធានីភ្នំពេញ អំឡុងខែ កក្កដា ឆ្នាំ ២០១៨។

កាលពីថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ លោក កោ វណ្ណី អនុប្រធានសាលាដំបូងរាជធានីភ្នំពេញសម្រេចឃុំខ្លួនស្ត្រីស៊ីឈ្នួលពពោះជំនួសទាំង ៣២ នាក់ ជាបណ្តោះអាសន្ននៅក្នុងមន្ទីរពេទ្យរបស់ក្រសួងមហាផ្ទៃ និងជនសង្ស័យចំនួន ៥ នាក់ ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ។ ពួកគេទាំងអស់ ត្រូវបានចោទប្រកាន់ពីបទ«ជួញដូរមនុស្សដោយឆ្លងដែន» និង«អន្តរការីរវាងអ្នកសុំកូនជាមួយស្ត្រីពពោះ»។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានប្រាប់អ្នកសារព័ត៌ក្នុងកិច្ចប្រជុំមួយកាលពីថ្ងៃទី ៣១ ខែ តុលា ម្សិលមិញថា គណៈកម្មាធិការ

ជាតិបានសម្រេចឱ្យមេធាវីរៀបចំឯកសារតាមផ្លូវច្បាប់ដាក់ស្នើទៅតុលាការ ឱ្យស្ត្រីស៊ីឈ្នួលពពោះជំនួសអាចរស់នៅក្រៅឃុំបណ្ដោះអាសន្ន ដើម្បីចិញ្ចឹមកូនពេលកើតមក ។ប៉ុន្តែលោកស្រី អះអាងថា បញ្ហាវាអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការក្នុងការធ្វើសេចក្ដីសម្រេចឱ្យនៅក្រៅឃុំ ឬបន្តឃុំខ្លួនបន្តទៀត។ លោកស្រី ជូ ប៊ុនអេង៖ «យើងគិតថាស្ត្រីទាំងនោះ ជាពិសេសស្ត្រីម្នាក់កើតកូនហើយ កូនគាត់ស្លាប់ ស្ត្រីបីនាក់ទៀតរលូតតាំងពីពេលយើងមិនទាន់បានបង្ក្រាប ហើយគាត់ទៅទំនាក់ទំនងកន្លែងនិងទៀត អញ្ចឹងដឹកគាត់រលូតហើយមានន័យថាគាត់អត់មានកូនសម្រាប់លក់ទេ។ស្ត្រីដែលកូនស្លាប់ ហើយស្ត្រីកូនរលូតមានន័យគាត់គួរតែត្រូវបាននៅក្រៅឃុំ ហើយបន្ទាប់ពីនឹងទៀតគឺស្ត្រីមានកូនដែលគាត់កើតហើយក៏យើងចង់ឱ្យគាត់នៅថែទាំកូននៅក្រៅដែរ ប៉ុន្តែវាអាស្រ័យទឡ្ហីករណ៍មួយចំនួនដែលតុលាការអាចជឿជាក់ថា គាត់នៅក្រៅឃុំតើគាត់នឹងប្រព្រឹត្តិបទល្មើសនឹងបន្តទៀតទេ។»

លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ក្នុងចំណោមស្ត្រីពពោះជំនួសទាំង ៣២ នាក់ ។ ក្នុងនោះស្ត្រីពពោះជំនួសបីនាក់ត្រូវបានរលូតកូន។ ស្ត្រីកើតកូនហើយកូនស្លាប់មុនពេលការបង្ក្រាបចំនួនម្នាក់ និងស្ត្រីកើតកូនចំនួន ៩ នាក់ និងកូនមាន ១១ នាក់ ព្រោះកូនភ្លោះមានពីរគូ។ លោកស្រីបន្ថែមថា ក្រសួងគ្មានចេនាចង់ធ្វើឱ្យមានភាពអយុត្តិធម៌ចំពោះស្ត្រីទាំងនោះទេ វាអាស្រ័យទៅនឹងទង្វើរបស់ពួកគាត់ទេ បើសិនជាគាត់មានចេនាប្រព្រឹត្តិបទល្មើសគាត់នឹងត្រូវទទួលខុសត្រូវដោយខ្លួនឯកផ្ទាល់។ ទោះបីយ៉ាងណាគណៈកម្មាធិការរបស់លោកស្រីចង់ជួយជនរងគ្រោះជាទារក។ លោកស្រី ជូ ប៊ុនអេង៖ «តាមពិតគណះកម្មាធិការជាតិជួយគ្រប់តែគ្នា ប៉ុន្តែរឿងដែលសំខាន់ត្រង់ថាយើងចង់ជួយជនរងគ្រោះ ហើយជនរងគ្រោះមិនមែនជាស្ត្រីទាំងនោះទេ ជនរងគ្រោះជាទារក ដែលនៅក្នុងផ្ទៃគាត់ ហើយប្រសិនបើទារកកើតចេញមកហើយយើងតាមជួយទារកនឹងទៀត ហើយទារកនៅជាមួយនរណាដែលល្អប្រសើរជាងនៅជាមួយម្ដាយ»។

ករណីនេះដែរ ជនសង្ស័យជនជាតិចិនម្នាក់ និងគូកនជនជាតិខ្មែរ ៤ នាក់ ត្រូវបានតុលាការសម្រេចខ្លួនបណ្ដោះអាសន្នក្នុងពន្ធាគារដោយចោទប្រកាន់ តាមមាត្រា ១៦ នៃច្បាប់ស្ដីពីការបង្ក្រាបការជួញដូរមនុស្ស និងការពារអនីតិជន និងមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌ៕

## រដ្ឋាភិបាលពិនិត្យចងក្រងច្បាប់ ពីការពពោះមនុស្សធម៌ និងការពពោះជាបទល្មើស

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្ដិ៍ ចេញផ្សាយ ថ្ងៃទី 1 November, 2018

ភ្នំពេញ ៖ ករណីនៃការជួញដូរមនុស្សមានការថយចុះ ប៉ុន្តែបែរជាលេចរូបភាពពីការជួញដូរមនុស្សថ្មីមួយទៀត តាមរយៈការស៊ីឈ្នួលពពោះជំនួស។ ករណីពពោះជំនួសនេះ គឺជាការរំលោភសិទ្ធិទារកយ៉ាងធ្ងន់ធ្ងរ ដែលមិនមែនជារឿងការលើកកម្ពស់ស្ត្រីទេ ពីព្រោះស្ត្រីគ្មានសិទ្ធិលក់កូនខ្លួនឯងឡើយ។នេះបើតាម ការបញ្ជាក់របស់លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ កាលពីថ្ងៃ ទ៣១ ខែតុលា កន្លងទៅ។

លោក ស្រី ជូ ប៊ុនអេង បញ្ជាក់ថា ទាក់ទិននឹងករណីពពោះជំនួសនេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងសិក្សាពីទិដ្ឋភាពសកលដើម្បីធ្វើច្បាប់សម្រាប់ឲ្យការងារពពោះជំនួសនេះស្ថិតនៅក្នុងលក្ខខណ្ឌមួយថា តើការពពោះបែបណា ដែលហៅថាមនុស្សធម៌ ? ហើយការពពោះបែបណា ជាបទល្មើស ដើម្បីធានាដល់សិទ្ធិរស់រានមានជីវិតរបស់ទារក ។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះ មានស្ត្រីខ្មែរចំនួន៣២នាក់ហើយ ដែលត្រូវបានឃុំខ្លួនពីបទល្មើសស៊ី ឈ្នួលពពោះសម្រាលកូនជំនួស៕

## សមាគមACRAនិងអង្គការILOរៀបចំក្រមសីលធម៌ថ្មីស្តីពីការបញ្ជូនពលករទៅក្រៅប្រទេស

http://www.rasmeinews.com/ November 2, 2018, 11:28 AM

ដោយៈដេប៉ូ/ភ្នំពេញៈសមាគមភ្នាក់ងារជ្រើសរើសពលករកម្ពុជាឬហៅកាត់ថាអាក្រា (ACRA) រួមជាមួយអង្គការ ILO និងដៃគូបានរួមគ្នាបង្កើតក្រមសីលធម៌ថ្មីមួយសម្រាប់សហគមនិងក៏ដូចជាទីភ្នាក់ងារជ្រើសរើសពលករនានាប្រចាំកម្ពុជាឱ្យសម្រេចបាននាថ្ងៃខាងមុខ។

លោកស្រីឧកញ៉ា អ៊ឹង ស៊ាងរិទ្ធី ប្រធានសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជាឬហៅអាក្រាបានបញ្ជាក់ឱ្យដឹងក្នុងពិធីបើកសិក្ខាសាលាពីគ្រោះយោបល់លើកទី២ ស្តីពីការរៀបចំក្រមសីលធម៌សម្រាប់សហគមនិងទីភ្នាក់ងារជ្រើសរើសពលករនៅកម្ពុជាកាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨ នាភោជនីយដ្ឋានទន្លេបាសាក់២ក្នុងរាជធានីភ្នំពេញថាសមាគមអាក្រាមានក្រមសីលធម៌របស់ខ្លួនរួចមកហើយដែលបង្កើតឡើងតាំងពី ឆ្នាំ២០០៩។ ក្រមសីលធម៌នេះគឺជាគ្រោងឆ្អឹងដ៏សំខាន់មួយសម្រាប់ឲ្យសមាគមអាក្រាធ្វើការតាមដាននិងវាយតម្លៃលើការអនុវត្តរបស់សមាជិករបស់ខ្លួនឱ្យស្របទៅតាមច្បាប់និងលិខិតគតិយុត្តផ្សេងៗដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។ ដោយសារក្រមសីលធម៌នេះមានរយៈពេលយូរមកហើយដូច្នេះនេះ គឺជាពេលវេលាដ៏សាកសមមួយដែលសមាជិកយើងទាំងអស់គ្នាចូលរួម និងផ្តល់យោបល់ដើម្បីធ្វើបច្ចុប្បន្នភាពក្រមសីលធម៌របស់អាក្រាឱ្យអនុលោមទៅតាមបទបញ្ញត្តិថ្មីៗទាំងថ្នាក់ជាតិនិងអន្តរជាតិ។ លោកស្រីឧកញ៉ាបានបន្ថែមថា"ក្រុមហ៊ុនជ្រើសរើសពលករក្នុងប្រទេសកម្ពុជានឹងមានសមត្ថភាពអនុវត្តស្របតាមច្បាប់ជាតិ និងឈានទៅដល់ការទទួលស្គាល់ស្តង់ដារអន្តរជាតិបើសិនក្រមសីលធម៌ថ្មីនេះត្រូវបានអនុម័ត្រឱ្យប្រើប្រាស់។ ជាមួយគ្នាវាអាចជួយធ្វើឲ្យប្រសើរឡើងការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារពលករស្ត្រីជាពិសេសអ្នកបំរើការងារតាមផ្ទះ។ជាមួយគ្នាវាក៏ជានានិរន្តរភាពនៃការអភិវឌ្ឍនិងប្រត្តិបត្តិការនិងបង្កើតឲ្យមានការទទួលស្គាល់ កិត្តិនាមដោយវិជ្ជមាន ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ"។

បញ្ជាក់ក្នុងពិធីនេះដែរលោក វនវិត អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃអង្គការILOបានឱ្យដឹងថា ក្រុមសីលធម៌ថ្មីនេះមានបញ្ចូលទាំងអនុក្រិតប្រកាសនិងច្បាប់នានាស្តីពីកិច្ចការពារដល់ពលករសម្រាប់ធ្វើការងារនៅក្រៅប្រទេស។

ដោយឡែកលោក ពិនវីរៈនាយកប្រតិបត្តិសមាគមអាក្រាបានឱ្យដឹងដែរថា នៅពេលក្រមសីលធម៌ថ្មីនេះចេញហើយសមាគមរបស់លោកនៅតែបន្តតាមដានថាតើបណ្តាក្រុមហ៊ុនជ្រើសរើសពលករជាដៃគូនានាអនុវត្តបានដែរឬក៏អត់។បើករណីមិនអនុវត្តបានទេខាងសមាគមក៏នឹងមានវិធានការចំពោះពួកគេផងដែរ។S/

# ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨

## ពលរដ្ឋខ្មែរចំណាកស្រុក កើនឡើងជាង១,៨លាននាក់ ក្នុងឆមាសទី១

https://thmeythmey.com/ 04, Nov 2018 , 10:03 am

ដោយ: គួង វ៉ាន់ថា ភ្នំពេញ៖ ពលករខ្មែរចំណាកស្រុកមានការកើនឡើងក្នុងឆមាសទី១ ឆ្នាំ២០១៨ សរុបមានចំនួន ១,៨៣៦ ៦៦៦នាក់។ ពលករចំណាកស្រុកស្របច្បាប់មានចំនួន ១,០៣៩ ៧៩៧ នាក់។ ចំពោះអ្នកដែលចេញទៅធ្វើការមិនស្របច្បាប់មានចំនួន ៧៩៦,៨៦៩នាក់។ នេះបើយោងតាមរបាយការណ៍ប្រឆាំងការជួញដូរមនុស្ស។ ក្នុងរបាយការណ៍បង្ហាញទៀតថា កម្ពុជាបញ្ជូនពលករស្របច្បាប់ទៅធ្វើការក្រៅប្រទេស តាមរយៈក្រុមហ៊ុនឯកជនដែលមានអាជ្ញាប័ណ្ណ និងតាមប្រព័ន្ធអនុគ្រោះមុខរបរ មានចំនួន ២៨, ៩៩២ នាក់ ក្នុងឆ្នាំ២០១៨។ ប្រទេសទាំងនោះរួមមាន ប្រទេសថៃ, ជប៉ុន, សិង្ហបុរី, ហុងកុង, អារ៉ាប៊ីសាអូឌិត, និងប្រទេសកូរ៉េ។

ប្រទេសជប៉ុន ៩៦៤នាក់ ក្នុងនោះស្ត្រី ៤២៤នាក់។ សិង្ហបុរី ចំនួន ១៣៨នាក់ ស្ត្រីទាំងអស់។ ហុងកុង ស្ត្រី ៤១ នាក់។ អារ៉ាប៊ីសាអូឌិត ស្ត្រី ៣ នាក់។ កូរ៉េ ចំនួន ៣,៣២៨ នាក់ ក្នុងនោះស្ត្រី ៧០២ នាក់។ ពលករដែលបានទៅធ្វើការក្នុងប្រទេសថៃ មានចំនួនច្រើនជាងគេ មានចំនួន ២៥,៥១៨ នាក់ ក្នុងនោះស្ត្រី ១០,៧៧០ នាក់។ បច្ចុប្បន្នពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃមានចំនួន ជាង ១,៥លាននាក់។ កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបានមានគម្រោងបញ្ជូនពលករខ្មែរចំនួន៥ពាន់នាក់ទៅ បម្រើការងារនៅប្រទេសគុយវ៉ែត នៅឆ្នាំ២០១៩ ផងដែរ៕

## ប៉ូលិសនឹងកោះហៅមនុស្សមួយចំនួនទៀតមកសួររឿងថតខ្សែភាពយន្តឯកសារ"ម្ដាយខ្ញុំលក់ខ្ញុំ

http://www.rasmeinews.com/ November 4, 2018, 3:38 PM

ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ លោកឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញបានថ្លែងប្រាប់រស្មីកម្ពុជាថាសមត្ថកិច្ចនឹងធ្វើការកោះហៅអ្នកដែលពាក់ព័ន្ធមួយចំនួនទៀតមកសាកសួរការថតខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា "ម្ដាយរបស់ខ្ញុំបានលក់ខ្ញុំ"។ប៉ុន្តែលោកស្នងការមិនបានបញ្ជាក់អត្តសញ្ញាណមនុស្សដែលត្រូវហៅមកសាកសួរនោះទេ។

ការគ្រោងកោះហៅមនុស្សមួយចំនួនមកសាកសួរនេះ គឺបន្ទាប់ពីស្ត្រីពីរនាក់ម្ដាយ និងកូន ដែលថតខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា "ម្ដាយរបស់ខ្ញុំបានលក់ខ្ញុំ" ត្រូវបានប៉ូលិសហៅមកសាកសួរនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃស្នងការនគររាជធានីភ្នំពេញ។ ការសាកសួរនេះ គឺបន្ទាប់ពីខ្សែភាពយន្តឯកសារមួយនេះ ត្រូវបានបង្ហោះផ្សព្វផ្សាយនៅលើបណ្ដាញសង្គមហ្វេសប៊ុក ដែលធ្វើឲ្យមានការភ្ញាក់ផ្អើល និងភ័ន្តច្រឡំ ជាពិសេសធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់ស្ត្រីខ្មែរ។ ការសាកសួរស្ត្រីពីរនាក់ម្ដាយ និងកូន គឺបានធ្វើឡើងតាំងពីថ្ងៃទី៣១ ខែតុលា រហូតមកដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅមិនទាន់បញ្ចប់នៅឡើយទេ។ ស្ត្រីទាំងពីរនាក់មានឈ្មោះ គៀង ស្រីម៉ិច ត្រូវជាកូន និងឈ្មោះ កៅ ម៉ាល័យ ត្រូវជាម្ដាយ។ទាំងម្ដាយនិងកូនស្រីបានសារភាពថា ពួកគាត់ទទួលបានលុយ២០០ដុល្លារ សម្រាប់ការសម្ដែងនៅក្នុងខ្សែភាពយន្តនេះ។ ប៉ុន្តែអ្វីដែលថត គឺមិនមែនជាខ្សែជីវិតពិតរបស់គាត់ទាំងពីរនាក់ទេ។

លោកឧត្តមសេនីយ៍ឯកសថេតបានមានប្រសាសន៍ថាសមត្ថកិច្ចបានសាកសួរស្ត្រីពីរនាក់ម្ដាយនិងកូនថា តើអ្នកណាមកថតខ្សែភាពយន្តេកសារនេះថតដើម្បីអ្វី?ហើយករណីនេះកំពុងតែស្ថិតនៅក្នុងការស្រាវជ្រាវនៅឡើយ។ លោកមិនអាចបញ្ជាក់លម្អិតបានទេ ទុកឲ្យសមត្ថកកិច្ចធ្វើការស្រាវជ្រាវសិន។ លោកស្នងការបានបញ្ជាក់ថា"សមត្ថកិច្ចកំពុងតែធ្វើការងារនេះយើងនឹងមានហៅអ្នកដែលពាក់ព័ន្ធមកសាកសួរទៀត"។ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការប្រឆាំងការជួញដូរមនុស្ស បានបញ្ជាក់ថាចំពោះរឿងនេះ សមត្ថកិច្ចកំពុងតែធ្វើការសាកសួរស្ត្រីម្ដាយ និងកូន តាំងពីថ្ងៃទី៣១ ខែតុលា មកដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨ មិនទាន់ចប់ទេ ។ បើទោះបីជាគាត់ឆ្លើយថា គាត់គ្រាន់តែដើរតួស៊ីឈ្នួល ក៏ដោយក៏មិនទាន់ទៅរួចដែរ សមត្ថកិច្ចកំពុងតែស្រាវជ្រាវជាបន្តទៀតថា តើស្ត្រីពីរនាក់ម្ដាយកូនដើរតួឲ្យអ្នកណា? ហើយថតនេះក្នុងគោលបំណងអ្វី ទាំងស្ត្រីពីរនាក់ម្ដាយកូន និងអ្នកដែលឲ្យគាត់ដើរតួ។ បើគាត់ថតធ្វើខ្សែភាពយន្តសួរថា តើមានសុំច្បាប់ឬអត់? ពីព្រោះនេះ វាពាក់ព័ន្ធនិងកិត្តិយសនិងសេចក្ដីថ្លៃថ្នូររបស់ស្ត្រីខ្មែរ គឺមិនមែនតែគាត់តែម្នាក់ឯងទេ។ លោកស្រីបញ្ជាក់ថា ការផ្សព្វផ្សាយវីដេអូនេះ មិនមែនផ្សព្វផ្សាយតែនៅក្នុងប្រទេសកម្ពុជាទេ គឺជាក់ប្រព័ន្ធបង្ហោះ ទូទាំងពិភពលោកបានឃើញ ដែលនេះគឺជាចេតនាអាក្រក់ណាស់។ ក្មេងស្រីកម្ពុជាវាមិនដល់ថ្នាក់នឹងទេ។បើសិនជាទោះបីជា

គាត់(ក្មេងស្រី)ធ្លាប់មានប្រវត្តិពីមុនមកយ៉ាងម៉េចក៏ដោយតែជារឿងបុគ្គលរបស់គាត់ហេតុអ្វីបានជាគាត់យកមកប ណ្ដុះបង្អាប់នារី។វាពាក់ព័ន្ធទៅនិងចេតនាមួយ ប៉ុន្តែសមត្ថកិច្ចកំពុងតែស្រាវជ្រាវ។

សូមជម្រាបថាខ្សែភាពយន្តឯកសារនេះមានរយៈពេល២៧នាទី បានរៀបរាប់លម្អិតអំពីគ្រួសារក្រីក្រ នៅកម្ពុជាដែលលក់ព្រហ្មចារីស្រីរបស់ពួកគេក្នុងតម្លៃប្រហែល ៤០០ដុល្លារក្នុងម្នាក់ៗ។ ខ្សែភាពយន្តនេះបាន និយាយថានៅក្នុងក្លិបរាត្រីនិងខារ៉ាអូខេក្មេងស្រីជំទង់បានញ៉ាំកេសជ្ជៈ និងផ្តល់ការសេវាផ្លូវភេទដល់អតិថិជនបួនឬ ប្រាំនាក់ក្នុងមួយថ្ងៃ។ នៅក្នុងខ្សែភាពយន្តនេះក្មេងស្រីឈ្មោះគៀងស្រីម៉ិចបាននិយាយថាម្ដាយរបស់អ្នកស្រីបានបង្ខំ ឱ្យនាងចូលពេស្យាចារ។នៅក្នុងក្លឹបខារ៉ាអូខេគៀវបានហៅឱ្យអង្គុយជាមួយពួកគេ។ពួកគេបានឱ្យនាងផឹកស្រាបៀរ។ ប្រសិនបើទៅគេងជាមួយពួកគេនិងទទួលបានច្រើនជាងនេះ។បើមិនដូច្នោះទេទទួលបាន ១០ ឬ ២០ ដុល្លារ សម្រាប់ការផឹកជាមួយពួកគេ។

## ពលករជិត២ម៉ឺននាក់ត្រូវបានអាជ្ញាធរបរទេសបញ្ជូនមកកម្ពុជាវិញ ក្នុងឆមាសទី១

https://thmeythmey.com/ 04, Nov 2018 , 9:59 pm

ភ្នំពេញ៖ អាជ្ញាធរបរទេសបានបញ្ជូនពលករខ្មែរត្រឡប់មកកម្ពុជាវិញ ជិត២ម៉ឺននាក់ ក្នុងឆមាសទី ១ ខណៈស្ថានទូតខ្មែរបានជួយសង្គ្រោះពលករ ២៤៧នាក់ផងដែរ។ នេះបើយោងតាមរបាយការណ៍ ៦ខែរបស់គ ណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

របាយការណ៍ក្រសួងមហាផ្ទៃ បានបញ្ជាក់ថា ពលករខ្មែរដែលអជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុ ជាវិញមានចំនួន ១៩, ៨៨៦៩ នាក់ ក្នុងនោះស្ត្រី ៦, ៨៩៥ នាក់, កុមារ ១, ៧៨៨ នាក់។ ពលករទាំងនេះ ត្រូវ បានអាជ្ញាធរប្រទេសចំនួន១៨ បានបញ្ជូនមកវិញរួមមាន៖ ថៃ ១៩,៣៧៩ នាក់ (ស្ត្រី ៦, ៧០៧ និងកុមារ ១, ៧៨១ នាក់), វៀតណាម ៦៩ នាក់ (ស្ត្រី៣៦ នាក់), កូរ៉េខាងត្បូង ១១០នាក់, ម៉ាឡេស៊ី ៨៥ នាក់, ជប៉ុន ៣៤ នាក់, អាមេរិក ៧៦ នាក់, ចិន ៥៦ នាក់, និងសឹង្ហបូរី ៦០នាក់។ ក្រៅពីនេះក៏មានសាកសពពលករខ្មែរចំនួន ១៨៥ នាក់ ត្រូវបានបញ្ជូនមកកម្ពុជាវិញផងដែរ។

ដោយឡែកពលករខ្មែររងគ្រោះ ២៤៧ នាក់ មានស្ត្រី ១៦០ នាក់ ត្រូវបានស្ថានទូត និងអង្គការដៃ គូរធ្វើអន្តរាគមន៍ពីប្រទេសចំនួន៧ មានដូចជា ប្រទេសម៉ាឡេស៊ី ចំនួន ១៣២ នាក់ (ស្ត្រី ៧៤នាក់), ចិន ៤៥ នាក់ (ស្ត្រី៤៣នាក់), វៀតណាម ២៩នាក់ (ស្ត្រី ២០នាក់), ឡាវ ០៣នាក់ (ស្ត្រី១នាក់), ថៃ ២៨នាក់( ស្ត្រី ១៣ នាក់), សឹង្ហបូរី ស្ត្រី ៨នាក់, អារ៉ាប៊ីសាអូឌីត ២នាក់ (ស្ត្រី ១នាក់)។ បើតាមរបាយការណ៍ក្រសួងមហាផ្ទៃដដែល ពលករ-ពលការិនីខ្មែរខាងលើ បានរងគ្រោះតាមរយៈ មេខ្យល់ ក្រុមហ៊ុនមិនស្របច្បាប និងការទៅរកការងារធ្វើនៅ ក្រៅប្រទេសដោយខ្លួនឯង។ ទម្រង់នៃការរងគ្រោះទាំងនោះ រួមមាន ការបំពានពីនិយោជក, ការជួញដូរផ្លូវភេទ,ការ រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ, ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ។

ជាមួយគ្នានេះអគ្គស្នងការដ្ឋាននគរបាលជាតិ បានសម្ភាសពលករខ្មែរដែលត្រឡប់ពីបណ្ដាប្រទេស ផ្សេងៗចំនួន ៧០នាក់ បានរកឃើញថា ពលករ ៥៥នាក់ ចាញ់បោកមេខ្យល់ ៣នាក់ក្រុមហ៊ុន និង១២នាក់ រក ការងារធ្វើដោយខ្លួនឯង។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្តល់សេវាស្នាក់នៅ និងស្តារនីតិសម្បទា ដល់ជនរងគ្រោះចំនួន ៤៩៤ នាក់ (ស្ត្រី ៣៦៧) និងអង្គការដៃគូបានជួយដល់ជនរងគ្រោះចំនួន ៣២៣ នាក់ (២២៦ នាក់)។

គួរបញ្ជាក់ថា ក្នុងឆ្នាំ២០១៧ ពលករ-ពលការិនីខ្មែរចំនួន ៩៨៦នាក់ ត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជួយសង្គ្រោះ និងរៀបចំបញ្ជូនមកកម្ពុជាវិញ៕

## សង្គមស៊ីវិលៈ នៅមានពលករច្រើនជាង២ម៉ឺននាក់ ដែលរដ្ឋាភិបាលកម្ពុជាត្រូវជួយសង្គ្រោះបន្ត

http://km.rfi.fr/cambodia/ ដោយ អេង គីមហុង05/11/2018

យ៉ាងហោចណាស់ពលករខ្មែរប្រមាណជាជិត២ម៉ឺននាក់(១៩,៨៨៦៩នាក់) ត្រូវបានអាជ្ញាធរប្រទេសចំនួន ១៨បញ្ជូនត្រឡប់មកកម្ពុជាវិញ គិតត្រឹមរយៈពេល៦ខែក្នុងឆ្នាំ២០១៨នេះ។ ប៉ុន្តែសង្គមស៊ីវិលធ្វើការផ្ដែកសិទ្ធិមនុស្សឲ្យដឹងថា នៅមានពលករច្រើនជាងនេះទៀត ដែលរដ្ឋាភិបាលកម្ពុជាត្រូវជួយសង្គ្រោះបន្តទៀត។

ការបញ្ជូនពលករ ពលការិនីខ្មែរជិត២ម៉ឺននាក់មកកម្ពុជាវិញធ្វើឡើងក្រោយការរកឃើញរបស់អាជ្ញាធរនៃប្រទេសចំនួន១៨ បន្ទាប់ពីពួកគេបានចាញ់បោកមេខ្យល់ ក្រុមហ៊ុនមិនស្របច្បាប់ និងការចេញទៅរកការងារធ្វើនៅក្រៅប្រទេសដោយខ្លួនឯង។ ទម្រង់គ្រោះថ្នាក់ដែលអាជ្ញាធរបរទេសរកឃើញនោះរួមមានៈ ការបំពានពីនិយោជក, ការជួញដូរផ្លូវភេទ, ការរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ, ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ។ នេះបើយោងតាមរបាយការណ៍ ៦ខែរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីសិទ្ធិការងារនៃ អង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ឲ្យដឹងនៅថ្ងៃចន្ទនេះថា ពលករនិងពលការិនីខ្មែរច្រើនជាង២ម៉ឺននាក់ទៀតដែលកំពុងត្រូវការជួយសង្គ្រោះពីរដ្ឋាភិបាលកម្ពុជា។ ក្នុងនោះគឺសំដៅដល់ការជួយសង្គ្រោះស្ត្រីខ្មែរដែលបានចាញ់បោកមេខ្យល់រត់ពន្ធទៅរៀបការជាមួយបុរសជនជាតិចិន រួមនឹងពលករនិងពលការិនីដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ីជាដើម។ បើតាមមន្ត្រីសង្គមស៊ីវិលរូបនេះ មុនមានការជួយសង្គ្រោះភាគច្រើនពលករ ពលការិនីខ្មែរបានរត់ចេញពីកន្លែងគ្រោះថ្នាក់ដោយខ្លួនឯងរួចទៅហើយ។ នេះក៏ដោយសារតែការដាក់ឲ្យដំណើរការប្រព័ន្ធជួយសង្គ្រោះ ឬយន្តការនៃការជួយសង្គ្រោះមិនសូវមានប្រសិទ្ធភាពតាមរយៈការគ្រប់គ្រងទិន្នន័យមិនមានភាពច្បាស់លាស់។ មិនច្បាស់លាស់គឺការជួយដូរស្ត្រីខ្មែរទៅប្រទេសចិនឬប្រទេសដទៃគឺមិនបានដឹងថា ពួកគេទៅកន្លែងណាឡើយ។ ប៉ុន្តែកន្លងមក មន្ត្រីរដ្ឋាភិបាលបានថ្លែងថា ខ្លួនបានយកចិត្តទុកដាក់ខ្ពស់ចំពោះសុវត្ថិភាពពលករ បំរើការនៅក្រៅប្រទេសតាមរយៈអន្តរាគមន៍ពីមន្ត្រីទូតឬកុងស៊ុលនៅតាមប្រទេសដែលកម្ពុជាបញ្ជូនពលករទៅ។

សូមបញ្ជាក់ថា ក្នុងឆ្នាំ២០១៧ ពលករ-ពលការិនីខ្មែរចំនួន ៩៨៦នាក់ ត្រូវបានក្រសួងការបរទេស ជួយសង្គ្រោះ និងរៀបចំបញ្ជូនមកកម្ពុជាវិញ។ បើតាមរដ្ឋាភិបាល នៅមានពលករ និងពលការិនីខ្មែរប្រមាណ១លាន៨សែននាក់កំពុងបំរើការងារនៅក្រៅប្រទេស ខណៈរបាយការណ៍របស់អង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ថា មានជាង២លាននាក់៕

## ពលករខ្មែរ ១២នាក់ ត្រូវឃាត់ខ្លួន ក្នុងអំឡុងការចុះបង្ក្រាបរបស់សមត្ថកិច្ចថៃ នៅហាងមួយកន្លែង

http://kleykley.sabay.com.kh/ ០៤/១១/២០១៨ ម៉ោង 14:22

ប៉ូលិស និងគយថៃ ជាង ៥០នាក់ នៅព្រឹកថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៨ បានឃាត់ខ្លួនជនអន្តោប្រវេសន៍ខុសច្បាប់ចំនួន ២២នាក់ ក្នុងនោះ ខ្មែរ ១២នាក់ ចិន៧នាក់ មីយ៉ាន់ម៉ា ២នាក់ និងម្នាក់ទៀតជាជនជាតិថៃ ត្រូវជាម្ចាស់ហាង ។ នេះបើតាមការចុះផ្សាយរបស់ The Nation។ សមត្ថកិច្ចថៃ ក្នុងផ្សារ Sua Pa Plaza នៅក្រុងបាងកក នាព្រឹកថ្ងៃទី៤វិច្ឆិកា ២០១៨។

ការឃាត់ខ្លួននេះ ធ្វើឡើងនៅក្នុងអំឡុងការចុះបង្ក្រាបនៅហាងមួយកន្លែងដែលស្ថិតក្នុងផ្សារ Sua Pa Plaza ក្រុងបាងកក។ ការចុះបង្ក្រាបនេះ ធ្វើឡើងក្រោយពេលដែលសមត្ថកិច្ចថៃទទួលដំណឹងថា ហាងនេះ មានពលករខុសច្បាប់កំពុងតែធ្វើការ និងលក់ផលិតផលដែលបំពានច្បាប់កម្មសិទ្ធិបញ្ញា។ ជាលទ្ធផល សមត្ថកិច្ចថៃបានរកឃើញទូរសព្ទ និងគ្រឿងបន្ទាប់បន្សំ (accessory) ដែលរត់ពន្ធខុសច្បាប់ជាង ៦ម៉ឺនគ្រឿងក្នុងហាងនេះ

គិតជាទឹកប្រាក់ជាង ១២លានបាត (ជាង ៣៦ម៉ឺនដុល្លារ)។ នេះបើតាមការឱ្យដឹងពីលោក Surachate Hakparn ដែលជាអ្នកដឹកនាំកម្លាំងចុះបង្ក្រាប។

បើតាមសារព័ត៌មានថៃខាងលើ បន្ថែមថា ពលករខុសច្បាប់ដែលសមត្ថកិច្ចថៃរកឃើញក្នុងបណ្តាហាងនៃផ្សារនេះ នឹងត្រូវប្រឈមមុខនឹងការចោទប្រកាន់ពាក់ព័ន្ធនឹងការធ្វើការងារដោយគ្មានលិខិតអនុញ្ញាត ហើយថៅកែរបស់ពួកគេ ក៏នឹងត្រូវទទួលទោសទណ្ឌផងដែរ៕

## ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨

### អនិច្ចាជីវិតជាពលករ!!! បុរសម្នាក់ជាពលករថៃ ស្ទើរតែបាត់បង់ជីវិតដោយសារតែ

http://vdoamazing.com/ November 6, 2018

ជីវិតជាពលករ រស់នៅចំណាកស្រុក ចាកឆ្ងាយពីប្រទេសកំណើតខ្លួន បងប្អូន សាច់ញាតិ គ្រួសារ ដើម្បីតែលុយ ទើបសំរេចចិត្តធ្វើបែបនេះ ពិតជារឿងមួយដ៏ពិបាកខ្លាំងណាស់ រីឯខ្លួនឯងវិញត្រូវរស់នៅធ្វើការយ៉ាងហត់នឿយ មិនស្គាល់គេ និយាយមិនយល់គ្នា ចង់ទៅណាក៏មិនស្គាល់ផ្លូវ ហើយរកលុយបានហើយនៅតែយកផ្គត់ផ្គង់គ្រួសារមិនទៀត។

ដោយឡែកកាលពី ថ្ងៃ០២ ខែវិច្ឆិកា ឆ្នាំ២០១៨ បងប្រុសម្នាក់ដែលជាពលករនេសាត្រីនៅប្រទេសថៃ គាត់បានជួបឧបទ្វវហេតុលេចទូកនៅក្នុងសមុទ្រ តែសំណាងហើយបានគេជួយទាន់ បើមើលទៅរូបរាងគាត់គឺពិតជាគួរឲ្យអាណិតខ្លាំងណាស់ នេះហើយជីវិតជាពលករ។

យោងតាមគណនីហ្វេសប៊ុកឈ្មោះ Toem Chanthy បានសរសេររៀបរាប់ថា "នៅពេលបងប្អូនបានឃើញជនរួមជាតិយើងដែលធ្លាក់ក្នុងស្ថានភាពបែបនេះ តើបងប្អូនខ្មែរយើងមានអារម្មណ៍យ៉ាងណា? សំរាប់រូបខ្ញុំវិញ បេះដូងស្ទើរតែបែកចេញជាពីរទៅហើយ តើពេលណាទៅទើបពលរដ្ឋខ្មែរយើងមានជីវភាពដូចប្រទេសដទៃទៅ។ ពលករខ្មែរដែលទៅធ្វើការ នៅក្នុងទូកនេសាទថៃ ដោយយកជីវិតទៅប្តូរ ដើម្បីបានប្រាក់កម្រៃខ្លះយកទៅដោះបំណុលនៅក្នុងគ្រួសារ ប៉ុន្តែជាអកុសលទូករបស់គាត់ ត្រូវបានលិចស្ទើរតែស្លាប់ទៅហើយ តែសំណាងល្អគេជួយទាន់ពេលវេលា។ សូមបញ្ជាក់៖ ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃ០២ ខែ១១ ឆ្នាំ២០១៨នៅក្នុងសមុទ្រថៃ"។

## ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨

### កម្ពុជាគ្រោងបញ្ជូនពលករ៥ពាន់នាក់ ទៅធ្វើការប្រទេសប្រទេសគុយវ៉ែត

http://freshnewsasia.com/ 2018-11-06

**(ភ្នំពេញ)៖** កម្ពុជាគ្រោងបញ្ជូនពលករ៥ពាន់នាក់ ទៅធ្វើការនៅប្រទេសគុយវ៉ែត នៅឆ្នាំ២០១៩ ខាងមុខនេះ។ លោក Zaher M. Al-Khuraineg ភារធារីស្ថានទូតគុយវ៉ែតប្រចាំកម្ពុជា បានអះអាងថា ការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសគុយវ៉ែត មិនមានហានិភ័យនោះទេ ដោយសារតែប្រទេសទាំងពីរ បានយកចិត្តទុកដាក់ សិក្សាស្រាវជ្រាវ អំពីបញ្ហាកើតមានចំពោះពលករ ព្រមទាំងបានបង្កើតមជ្ឈមណ្ឌល ដើម្បីដោះស្រាយបញ្ហាពលករ និងមានមេធាវីសម្រាប់ការពារជូនពួកគាត់ផងដែរ។

ការលើកឡើងបែបនេះរបស់ លោក Zaher M. Al-Khuraineg បានធ្វើឡើងនៅរសៀលថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ ក្នុងឱកាសដែលលោកបានផ្តល់បទសម្ភាសជាមួយ លោក លឹម ជាវុត្ថា ស្ថាបនិក និងជានាយកប្រតិបត្តិអង្គភាពព័ត៌មាន Fresh News នៅឯស្ថានទូតរបស់គុយវ៉ែត រាជធានីភ្នំពេញ។ លោកបានបញ្ជាក់យ៉ាងដូច្នេះ៖ «គុយវ៉ែតមានទាំងមជ្ឈមណ្ឌលគាំពារពលករ មេធាវីសម្រាប់ការពារពលករ មានទាំងការទំនាក់ទំនងផ្ទាល់ខាងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងការងារ នឹងផ្តល់កន្លែងស្នាក់នៅដល់ពលករដែលមានបញ្ហាទាំងអស់ នឹងផ្ត

ល់មេធាវី សម្រាប់រកខុសត្រូវដែលត្រូវបានគេបំពានណាមួយនៅកន្លែងធ្វើការ»។ លោក Zaher M. Al-Khuraineg បានបន្តថា គុយវ៉ែត ជឿជាក់ថាទៀតថា ទាំងពលករខ្មែរ និងពលករបរទេសផ្សេងទៀត នឹងមិនមានហានិភ័យនោះទេ ដែលមកធ្វើការនៅប្រទេសរបស់ខ្លួន ដោយសារតែរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ អំពីបញ្ហានេះ ហើយមួយវិញទៀត ជាមួយគ្នានេះដែរភាគីទាំងពីរ ក៏មានស្ថានទូតប្រចាំប្រទេសរៀងៗខ្លួន ព្រមទាំងបង្កើតមជ្ឈមណ្ឌល ដើម្បីដោះស្រាយបញ្ហាពលករផងដែរ។

លោកក៏បានលើកឡើងពីអត្ថប្រយោជន៍ជាច្រើនដែលពលករបរទេសបំពេញការងារនៅក្នុងប្រទេសគុយវ៉ែត ដោយទទួលបាននៅប្រាក់ខែសមរម្យ គឺពលករខ្លះដែលមានជំនាញ និងបទពិសោធន៍ការងារច្រើនឆ្នាំ នឹងទទួលបានប្រាក់ខែ រហូតដល់៥ពាន់ដុល្លារអាមេរិក និងទាបបំផុតក៏ត្រឹម៣០០ដុល្លារអាមេរិក។ ភារជារីរូបនេះ បានបញ្ជាក់ថា ប្រទេសគុយវ៉ែត មានក្រុមហ៊ុនបរទេសច្រើន ដែលកំពុងមានវត្តមាននៅទីនោះ ហើយតម្រូវការពលកម្ម កម្លាំងជំនាញ ក៏មានការកើនឡើងដែរ។ ដូច្នេះគុយវ៉ែត ត្រូវការកម្លាំងពលករបរទេស ដើម្បីបំពេញតម្រូវការការងាររបស់ខ្លួន នាពេលបច្ចុប្បន្ននេះផងដែរ៕

## ស្ថានទូតគុយវ៉ែត ចេញសេចក្តីថ្លែងការណ៍ អំពីលទ្ធផលទស្សនកិច្ចរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចគុយវ៉ែត មកកាន់កម្ពុជា

http://freshnewsasia.com/ 2018-11-06

**(ភ្នំពេញ)៖** ស្ថានទូតគុយវ៉ែតប្រចាំនៅប្រទេសកម្ពុជានៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ បានចេញសេចក្តីថ្លែងការណ៍មួយ ដោយចាត់ទុកថា ដំណើរទស្សនកិច្ចរបស់ លោកស្រី ហ៊ីន ស៊ូពៃហ៍ (Hend Subaih B ALSUBAIH) រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារ និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចនៃរដ្ឋគុយវ៉ែត មកកាន់កម្ពុជា កាលពីសប្តាហ៍មុន គឺបានទទួលនូវលទ្ធផលជោគជ័យ និងផ្លែផ្កាដ៏មហិមា។

អគ្គរដ្ឋទូតគុយវ៉ែតប្រចាំនៅកម្ពុជា លោក ហ្សាហឺ អេម ប៊ី អេម អាល់ខូរ៉េនិច បានបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់ លោកស្រី ហ៊ីន ស៊ូពៃហ៍ គឺជាដំណើរទស្សនកិច្ចដំបូង ក្នុងគោលបំណងបញ្ជាក់ និងជំរុញអនុស្សារណៈនៃការយោគយល់គ្នា ក្នុងវិស័យផ្លាស់ប្តូរហត្ថពលកម្ម ដែលប្រទេសទាំងពីរ បានចុះហត្ថលេខា កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៨ នៅរដ្ឋគុយវ៉ែត ឱ្យកាន់តែដំណើរការទៅមុខ និងមានប្រសិទ្ធភាព។ លោកបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ថា៖ «**ដំណើរទស្សនកិច្ចរបស់ លោកជំទាវ មកកាន់ប្រទេសកម្ពុជា បានទទួលនូវលទ្ធផលជោគជ័យ និងផ្លែផ្កាដ៏មហិមា។ ទាំងនោះ គឺដោយសារតែមានការសហការ និងសហប្រតិបត្តិការល្អរបស់ក្រសួងការងារ និងមានការសម្រួលពីគ្រប់ស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាលកម្ពុជា**»។

កាលពីថ្ងៃទី២៤-២៥ ខែតុលា កន្លងទៅ លោកស្រី ហ៊ីន ស៊ូពៃហ៍ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារ បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ស្របពេលដែលរាជរដ្ឋាភិបាលអាណត្តិថ្មីរបស់កម្ពុជា ដែលកើតចេញពីការបោះឆ្នោត បានបង្កើតឡើងជាផ្លូវការ។ ក្នុងពេលបំពេញទស្សនកិច្ចនៅកម្ពុជា រដ្ឋមន្ត្រីក្រសួងការងាររបស់កម្ពុជា និងគុយវ៉ែត បានព្រមព្រៀងគ្នាថា នឹងជំរុញកិច្ចសហប្រតិបត្តិការ ឱ្យកាន់តែជិតស្និទ្ធថែមទៀត លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយវិនិយោគិនគុយវ៉ែត ក៏មានបំណងចង់ស្វែងរកឱកាសវិនិយោគនៅកម្ពុជា។ ជាមួយគ្នានេះ កម្ពុជានឹងបញ្ជូនពលកររបស់ខ្លួនចំនួន ៥ពាន់នាក់ ទៅបម្រើការងារលើកដំបូង នៅប្រទេសគុយវ៉ែត នៅឆ្នាំ២០១៩ ខាងមុខនេះ។

លោកអគ្គរដ្ឋទូតបានបញ្ជាក់ថា៖ «**ក្នុងអាណត្តិរបស់ខ្ញុំនៅព្រះរាជាណាចក្រកម្ពុជា ខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើការ ដោយយកចិត្តទុកដាក់ និងស្មោះត្រង់ ដើម្បីរួមចំណែកក្នុងការពង្រឹង ពង្រីកទំនាក់ទំនងទ្វេភាគីរវាងប្រទេសជា**

មិត្តទាំងពីរ ឱ្យកាន់តែរីកចម្រើនបន្ថែមទៀត លើគ្រប់វិស័យ ទាំងវិស័យនយោបាយ ពាណិជ្ជកម្ម សេដ្ឋកិច្ច វិនិយោគ វប្បធម៌ និងសង្គម»៕

## ស្ថានទូតកូរ៉េ អំពាវនាវឲ្យពលរដ្ឋកម្ពុជាទៅធ្វើការនៅប្រទេសរបស់ខ្លួន

https://www.postkhmer.com/ គង់ មេត្តា | Publication date 07 November 2018 | 09:01 ICT

**ភ្នំពេញ:** ស្ថានទូតកូរ៉េបានអំពាវនាវឲ្យប្រជាពលរដ្ឋកម្ពុជាទៅធ្វើការនៅប្រទេសរបស់ខ្លួន និងបានជំរុញជាមុនឲ្យអ្នកទៅធ្វើការនៅទីនោះ ត្រូវតែខិតខំប្រឹងប្រែងធ្វើការជាមួយនឹងការព្រមានថា ប្រសិនបើធ្វើឲ្យមានកំហុសម្ដងហើយម្ដងទៀតនោះនឹងត្រូវបញ្ជូនត្រឡប់មកវិញ បើទោះបីជានៅពេលនេះពុំទាន់មានពលរដ្ឋខ្មែរណាម្នាក់បានទៅធ្វើការនៅប្រទេសមួយនេះនៅឡើយក៏ដោយ។

ប្រទេសកម្ពុជា និងប្រទេសកូរ៉េតបានចុះអនុស្សរណៈយោគយល់គ្នាកាលពីថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០០៩ ក្នុងវិស័យផ្លាស់ប្ដូរហត្ថពលកម្ម ហើយក្នុងអំឡុងដំណើរទស្សនកិច្ចនៅកម្ពុជារបស់លោកស្រី ហ៊ីន ស៊ូពៃហ៍ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារនៃរដ្ឋកូរ៉េតកាលពីថ្ងៃទី ២៤-២៥ ខែតុលា ឆ្នាំ ២០១៨ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជាបានឯកភាពថានឹងបញ្ជូនពលករចំនួន ៥០០០ នាក់ជាលើកដំបូងឲ្យទៅធ្វើការនៅប្រទេសកូរ៉េត នៅក្នុងឆ្នាំ ២០១៩ ខាងមុខនេះ។

នៅក្នុងសន្និសីទកាសែតមួយនៅថ្ងៃទី ៦ ខែវិច្ឆិកា លោក ហ្សាហ៊ី អេមប៊ី អេមអាល់ ខូរ៉េនិច ភារធារីស្ថានទូតកូរ៉េតប្រចាំនៅកម្ពុជាបានជំរុញឲ្យពលរដ្ឋកម្ពុជាទៅធ្វើការនៅប្រទេសកូរ៉េត។ លោក ហ្សាហ៊ី អេមប៊ី អេមអាល់ ខូរ៉េនិច បានថ្លែងថា៖ «ខ្ញុំសូមឲ្យប្រជាជនកម្ពុជាមកធ្វើការនៅកូរ៉េតហើយខំប្រឹងធ្វើការ។ សូមឲ្យគាត់មានភាពស្មោះត្រង់នឹងការងាររបស់គាត់។ កុំលួចដេក ហើយនិយាយថាហេតុអ្វីអត់បើកប្រាក់ខែឲ្យយើង។ បើសិនជាអ្នកមកធ្វើការត្រូវតែមានភាពស្មោះត្រង់។ ត្រូវតែធ្វើការងារឲ្យបានត្រឹមត្រូវ ហើយគោរពក្រុមហ៊ុន អ៊ីចឹងក្រុមហ៊ុននឹងគោរពអ្នកវិញ»។

ជាមួយគ្នានេះលោកក៏បានព្រមានផងដែរថា៖ «បើសិនជាអ្នក (ពលករ) លួចខ្ជិល ដើរទៅមកអត់ធ្វើការ បើសិនជាបង្កើតកំហុសដែលគេបានបង្រៀន ម្ដងហើយម្ដងទៀត អ៊ីចឹងគេនឹងចាត់វិធានការបណ្ដេញចេញ»។ ទោះយ៉ាងណាលោក ហ្សាហ៊ីអេមប៊ី អេមអាល់ ខូរ៉េនិច បញ្ជាក់ថា ប្រសិនបើពលករទាំងនោះត្រូវបានគេកេងប្រវ័ញ្ច រំលោភបំពាន ឬបៀតបៀន ពួកគេអាចរាយការណ៍ទៅកាន់ស្ថានទូតកម្ពុជាប្រចាំនៅកូរ៉េត។ លោកបញ្ជាក់ថា៖ «ប្រទេសនីមួយៗតែងតែមានបញ្ហា ប៉ុន្តែយើងមិនមើលលើតែផ្នែកនៃបញ្ហានោះទេ គឺយើងត្រូវមើលពីថា តើត្រូវធ្វើដូចម្ដេចដើម្បីដោះស្រាយបញ្ហា? ក្រសួងការងាររបស់យើង ប្រទេសកូរ៉េត យើងមានទូតរបស់ប្រទេសកម្ពុជានៅកូរ៉េត។ អ្នកអាចប្រាប់ទូតរបស់អ្នក និងធ្វើការទាក់ទងទៅក្រសួងការងារ ពួកគេនឹងជួលមេធាវីដើម្បីការពារសិទ្ធិរបស់កម្មករ និងដោះស្រាយបញ្ហា»។ លោកអះអាងថា ច្បាប់ការងារ និងច្បាប់ផ្សេងទៀតរបស់ប្រទេសកូរ៉េតគឺសុទ្ធតែត្រូវបានតាក់តែងឡើងដោយផ្អែកទៅលើច្បាប់អន្តរជាតិ។ ប៉ុន្តែទោះយ៉ាងណាលោកបានបញ្ជាក់ថាជាទូទៅនិយោជកគឺជាអ្នកកាន់កាប់លិខិតឆ្លងដែនរបស់ពលករ។

ទាក់ទងទៅនឹងករណីនេះលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានថ្លែងកាលពីម្សិលមិញថា ប្រទេសកូរ៉េតមាននីតិវិធីរបស់គេ ហើយកម្ពុជាក៏មាននីតិវិធីរបស់ខ្លួនផងដែរ។ លោកបានបញ្ជាក់តាមសារអេឡិចត្រូនិកថា៖ «យើងបញ្ជូនពលករយើងទៅ តែនៅពេលតម្រូវការរបស់កម្ពុជាទាំងអស់ត្រូវបានសម្រេច ហើយយើងច្បាស់ថា សុវត្ថិភាព សិទ្ធិ និងអត្ថប្រយោជន៍ពលករយើង គឺត្រូវការពារយ៉ាងល្អ»។

លោក មឿន តុលា ប្រធានអង្គការសង់ត្រាល់ ជាអង្គការដែលធ្វើការជួយគាំពារសិទ្ធិពលករចំណាកស្រុក បានថ្លែងថា អ្វីដែលលោកចង់ក្រើនរំឭកដល់ប្រទេសទាំង ២ គឺត្រូវពិនិត្យលើផ្លូវច្បាប់ជាពិសេសត្រូវត្រួតពិនិត្យច្បាប់កម្មករចំណាកស្រុក ថា តើមានហើយឬនៅ នៅក្នុងប្រទេសកូរ៉េត? បន្ទាប់មកកម្ពុជាត្រូវពិនិត្យមើលយន្តការផ្សេងៗ ថាតើប្រសិនបើមានអំពើហិង្សា ឬវិវាទការងារកើតឡើង តើគេដោះស្រាយយ៉ាងដូចម្ដេច? លោក តុលា បញ្ជាក់ថា៖

«ប្រទេសកម្ពុជាត្រូវធានាថា យើងមានសមត្ថភាពដើម្បីតាមដាន និងជួយសង្គ្រោះពេលពលករយើងមានបញ្ហា។ ខ្ញុំសូមផ្តល់យោបល់ថា គួរមានការធ្វើគម្រោងសាកល្បងសិន ឧទាហរណ៍ដូចជាត្រូវបញ្ជូនពលករត្រឹម១០០នាក់សិន៕

## អគ្គនាយកអន្តោប្រវេសន៍ថៃ បានបើកប្រតិបត្តិការដឹកនាំកម្លាំងប៉ូលីស ទាហាន ចុះធ្វើការត្រួតពិនិត្យទីតាំងចំនួន៩កន្លែង

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ ថ្ងៃទី០៧ ខែវិច្ឆិការ ឆ្នាំ២០១៨

កាលពីថ្ងៃទី០៦ ខែវិច្ឆិការ ឆ្នាំ២០១៨ ឯកឧត្តម ស៊ុរ៉ាចេត ហាកកាផាន អគ្គនាយកអន្តោប្រវេសន៍ថៃ បានបើកប្រតិបត្តិការដឹកនាំកម្លាំងប៉ូលីស ទាហាន ចុះធ្វើការត្រួតពិនិត្យទីតាំងចំនួន៩កន្លែងដែលជាតំបន់មានពលករបរទេសស្នាក់នៅច្រើន ស្ថិតនៅជាប់ផ្សារស៊ីមុំមឿង ខេត្តផាធុមថានី។ ប្រតិបត្តិការនេះមានឈ្មោះថា "Operation X-Ray Out Law Foreigner at Simummuang Market" ក្នុងគោលបំណងបង្ក្រាបបទល្មើស ពាក់ពន្ធ័នឹងគ្រឿងញៀន អាវុធជាតិផ្ទុះ និងការស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសថៃ។ ក្នុងប្រតិបត្តិការនេះ បានធ្វើការត្រួតពិនិត្យពលករបរទេសចំនួនជាង១០០០នាក់ ដោយពិនិត្យឃើញមានពលករប្រព្រឹត្តបទល្មើសចំនួន ១៧០នាក់ មានដូចជា:

១.ចូលមកក្នុងប្រទេសថៃដោយមិនមានការអនុញ្ញាតចំនួន៤៥នាក់ ជនជាតិភូមា១៧នាក់ ជនជាតិកម្ពុជា២៨នាក់។ ២.ស្នាក់នៅក្នុងប្រទេសថៃលើសសុពលភាពកំណត់ ចំនួន០៧នាក់ ជនជាតិភូមា០៥នាក់ ជនជាតិកម្ពុជា០១នាក់ និងជនជាតិឡាវ០១នាក់។ ៣.មិនជូនដំណឹងអំពីកន្លែងស្នាក់នៅចំនួន១០៥ នាក់ ជនជាតិភូមា ៧៤នាក់ និងជនជាតិខ្មែរ៣១នាក់ ។ ៤.ម្ចាស់ផ្ទះជនជាតិថៃចំនួន០៣នាក់។ ៥.ជនជាតិថៃចំនួន០២នាក់ ដែលបានផ្តល់កន្លែងស្នាក់នៅអោយពលករបរទេសខុសច្បាប់ ។ ៦.មិនបានមកបង្ហាញខ្លួននៅការិយាល័យអន្តោប្រវេសន៍រៀងរាល់៩០ថ្ងៃម្តង ចំនួន០៥នាក់។ ៧.មិនមានលិខិតឆ្លងដែននៅជាប់ជាមួយចំនួន០៣នាក់។ ជាមួយគ្នានេះដែរក៏បានដកហូតវត្ថុតាងមួយចំនួនដូចជា ឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀនចំនួន០១ឈុត កំបិទចំនួន០៤ ស្នាបដៃចំនួន០១ ។

# ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨

## កម្ពុជាស្នើឱ្យថៃគាំទ្រនិងការពារពលករកម្ពុជាធ្វើការនៅប្រទេសថៃ

http://wmc.org.kh/ ថ្ងៃពុធ ទី៧ ខែកញ្ញា ឆ្នាំ២០១៨ ដុំ ដោគជាតា

ភ្នំពេញ៖ ឧបនាយករដ្ឋមន្ត្រីកម្ពុជាបានស្នើទៅភាគីថៃឱ្យជួយគាំទ្រ និងការពារពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ និងជួយពង្រឹងកិច្ចសហប្រតិ បត្តិការណ៍លើការងារត្រួតពិនិត្យគ្រឿងញៀនរវាងប្រទេសទាំងពីរ។ នេះបើតាមការចុះផ្សាយលើគេហទំព័ររបស់អគ្គស្នងការដ្ឋាននគរបាលជាតិកាលពីថ្ងៃទី៦ វិច្ឆិកា។

តាមការចុះផ្សាយនេះបញ្ជាក់ថា ការស្នើសុំនេះ ធ្វើឡើងក្នុងជំនួបរវាងលោក កែវ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀនជាមួយលោក ផាន់ យ៉ាក់វ៉ាក់កូលថាប់ អគ្គរាជទូតវិសាមញ្ញនៃព្រះរាជាណាចក្រថៃ ប្រចាំកម្ពុជា។ នាឱកាសជំនួបនោះ លោក កែវ គឹមយ៉ាន បានស្នើសុំទៅភាគីថៃ ឱ្យការជួយគាំទ្រនិងការពារដល់ពលករកម្ពុជាដែលបាននិងកំពុងបំពេញការងារនៅប្រទេសថៃ។ ក្រៅពីស្នើឱ្យភាគីថៃជួយការពារពលករកម្ពុជា ប្រធានអាជ្ញាធរប្រយុទ្ធប្រឆាំងនិងគ្រឿងញៀនរូបនេះ ក៏បានស្នើឱ្យមានការជួយពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន BLO និងការអនុវត្តផែនការភូមិសគ្មានគ្រឿងញៀនសំដៅទប់ស្កាត់ការចរាចរណ៍គ្រឿងញៀនឆ្លងកាត់ព្រំដែន។ ជាងនេះ ភាគីថៃត្រូវបន្តជួយលើការងារកសាងហេដ្ឋារចនាសម្ព័ន្ធ មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្មគ្រ័ចិត្ត និងផ្អែកលើសហគមន៍នៅខេត្តព្រះសីហនុ និង ផ្តល់ឧបករណ៍ដល់មន្ទីរពិសោធន៍គ្រឿងញៀនជាដើម។

ណា លោក ផាន់យ៉ាក់ ភូលថាប់ អគ្គរាជទូតថៃទទួលយកនូវរាល់សំណូមពរសំដៅពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនរវាងប្រទេសទាំងពីរ៕ អត្ថបទ៖ លោក សោម លាភ

## ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី អ៊ិត សំហេង ស្នើសមាគមបញ្ជូន-ទទួលពលករ ជួយរៀបចំផ្ទះស្នាក់បណ្ដោះអាសន្នសម្រាប់ពលករកម្ពុជានៅថៃ

http://www.mlvt.gov.kh/ Wednesday, 07 November 2018 18:58

(ភ្នំពេញ)៖ ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានស្នើឱ្យសមាគមពាក់ព័ន្ធនានាដែលធ្វើការងារលើការបញ្ជូន និងទទួលពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃ ជួយរៀបចំផ្ទះស្នាក់នៅបណ្ដោះអាសន្ន សម្រាប់ពលករកម្ពុជានៅតាមតំបន់សំខាន់ៗ ដែលអាចពួកគេអាចស្នាក់នៅបណ្ដោះអាសន្ន ក្នុងអំឡុងពេលប្ដូរការងារ ឬរង់ចាំការដោះស្រាយវិវាទជាមួយនិយោជក។

ការស្នើរបស់ ឯកឧត្តមរដ្ឋមន្ត្រីយ៉ាងដូច្នេះ ត្រូវបានធ្វើឡើងក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការការពារ និងគ្រប់គ្រងពលករកម្ពុជាធ្វើការនៅប្រទេសថៃ រវាងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា សមាគមជ្រើសរើសពលករកម្ពុជា និងសមាគមទំនាក់ទំនងកម្ពុជា-ថៃ នៅសណ្ឋាគារជីក្រេដខូក រាជធានីភ្នំពេញ នាថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨។ ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងយ៉ាងដូច្នេះថា «ដោយឆ្លងតាមបទពិសោធន៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងការគ្រប់គ្រងពលករខ្មែរនៅសាធារណរដ្ឋកូរ៉េ ខ្ញុំសូមស្នើសុំសមាគមពិចារណាក្នុងការរៀបចំផ្ទះស្នាក់នៅបណ្ដោះអាសន្ន សម្រាប់ពលករកម្ពុជានៅតាមតំបន់ក្នុងប្រទេសថៃ ដែលអាចឱ្យពលករកម្ពុជាស្នាក់នៅបណ្ដោះអាសន្ន ក្នុងអំឡុងពេលប្ដូរការងារ ឬរង់ចាំការដោះស្រាយវិវាទជាមួយនិយោជក»។

ពាក់ព័ន្ធនឹងការចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នាខាងលើ ឯកឧត្តម អ៊ិត សំហេង បានលើកឡើងថា មុនឈានដល់ការចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីកិច្ចសហប្រតិបត្តិការការពារ និងគ្រប់គ្រងពលករកម្ពុជាធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍ នាពេលនេះ គឺសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) សមាគមជ្រើសរើសពលករកម្ពុជា (ACRA) និងសមាគមទំនាក់ទំនងកម្ពុជាកម្ពុជា-ថៃ (TCRA) បានខិតខំសហការជាមួយគ្នា ប្រកបដោយការទទួលខុសត្រូវខ្ពស់។ ឯកឧត្តមបានបន្តថា អនុស្សរណៈនៃការយោគយល់គ្នានេះ គឺជាវឌ្ឍនភាព និងយន្តការបន្ថែមថ្មីមួយទៀត ក្នុងការការពារដល់ពលករកម្ពុជា ដែលទៅធ្វើការនៅប្រទេសថៃបន្ថែមលើកិច្ចការពារ ដែលមាននាពេលបច្ចុប្បន្ន ព្រមទាំងចូលរួមចំណែកប្រទេសថៃ ឱ្យមានភាពកាន់តែប្រសើរឡើងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

ឯកឧត្តមរដ្ឋមន្ត្រីបានស្នើសុំដល់សមាគមទាំងបី ត្រូវសហការគ្នាឱ្យបានស្អិតល្មួត ធ្វើយ៉ាងណាផ្ដល់នូវការការពារសុវត្ថិភាព សុខមាលភាពសង្គមដល់ពលករកម្ពុជា ដែលធ្វើការនៅប្រទេសថៃឱ្យបានជាអតិបរមា និងសូមគាំទ្រនូវគម្រោងរបស់សមាគមទាំងបី ដែលនឹងរៀបចំផ្ដល់ជូនសេវាកម្មធានារ៉ាប់រងដល់ពលករកម្ពុជា លើការជានាគ្រោះថ្នាក់ការងារ និងអាយុជីវិត ដែលស្របតាមអនុសាសន៍របស់ប្រមុខរដ្ឋាភិបាលកម្ពុជា គឺសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី៕

## លោកទូតសុំឲ្យអាជ្ញាធរកូរ៉េ ជួយមើលថែពលរដ្ឋខ្មែរ និងអ្នកមានប្ដីកូរ៉េនៅទីនេះឲ្យដូចពលរដ្ឋរបស់ខ្លួន

http://www.rasmeinews.com/ November 7, 2018, 11:02 PM ដោយៈរ៉ាម៉ន

ភ្នំពេញ៖ លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណៈរដ្ឋកូរ៉េហៅកូរ៉េខាងត្បូង កាលពីពេលថ្មីៗនេះ បានធ្វើការផ្ដាំផ្ញើ និងអំពាវនាវឲ្យអាជ្ញាធរកូរ៉េខាងត្បូង ជួយគាំពារដល់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលមកធ្វើការ និងមានគ្រួសារជាប្ដីជនជាតិកូរ៉េ ឱ្យមើលថែរក្សា និងយកចិត្តទុកដាក់ដូចពលរដ្ឋរបស់ខ្លួន។

ចំពោះការផ្ដែផ្ដាំ និងអំពាវនាវរបស់លោក ឡុង ឌីម៉ង់ បែបនេះ គឺខណៈដែលលោកបានដឹកនាំមន្ត្រីស្ថានទូតខ្មែរ ចុះសាកសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ ដែលមករស់នៅ និងមានគ្រួសារកូរ៉េ នៅស្រុក Changyeong ដែលជាកូនស្រុកមួយ នៅតំបន់ភាគខាងត្បូងរបស់ប្រទេសកូរ៉េ ដែលមាននារីជាជនជាតិខ្មែរ យកស្វាមីជាជនជាតិកូរ៉េ ចំនួន១៧គ្រួសារ កំពុងរស់នៅទីនោះ។

បើយោងតាមរយៈទំព័រ Facebook ផ្លូវការរបស់លោក ឡុង ឌីម៉ង់ បានថ្លែងយ៉ាងដូច្នេះថា «ខ្ញុំបានផ្ដែផ្ដាំអាជ្ញាធរមានសមត្ថកិច្ចកូរ៉េ ជួយបន្តគាំពារបងប្អូនពលរដ្ឋខ្មែរយើងចាត់ទុកជាកូនជាចៅទៀត។ លើសពីនេះទៅទៀត បងប្អូនបានបេះផ្លែប៉េងប៉ោះដែលគាត់ដាំផ្ទាល់ដៃ និងអ្នកខ្លះចាក់ជាវត្ថុអនុស្សាវរីយ៍ជូនខ្ញុំទៀតផង»។ ក្នុងនោះលោក ឡុង ឌីម៉ង់ បានបន្តថា នៅក្នុងដំណើររបស់លោក និងក្រុមការងារ ត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់អភិបាលស្រុក ជាមួយនឹងសមាគម Happy Dreamer ដែលមានសណ្ដានចិត្តដ៏ល្អ ជួយយកអាសារមើលថែពលរដ្ឋខ្មែរ យើងទាំងនៅកូរ៉េផងដែរ។ ជាមួយគ្នានេះដែរ លោក ឌីម៉ង់ បានបង្ហាញថា បងប្អូនប្រជាពលរដ្ឋខ្មែរដែលរស់នៅទីនេះ តែងតែធ្វើសកម្មភាពសប្បុរសធម៌ជាច្រើន ទៅប្រទេសកម្ពុជា ហើយមិនតែប៉ុណ្ណោះស្នាមញញឹម ដ៏ស្មោះពីបងប្អូននារីខ្មែរ អានិកជនដែលមានគ្រួសារកូរ៉េ ចំនួន១៧នាក់ បានធ្វើឱ្យលោកសប្បាយរីករាយចងចាំមិនភ្លេចនោះទេ។

គួរបញ្ជាក់ថា៖កន្លងមកលោក ឯកអគ្គរាជទូតខ្មែរប្រចាំកូរ៉េខាងត្បូង លោកតែងតែ ដឹកនាំមន្ត្រីស្ថានទូត ចុះសាកសួរសុខទុក្ខបងប្អូនកម្មករ និងពលរដ្ឋខ្មែរ ដែលមករស់នៅ និងធ្វើការនៅលើទឹកដីកូរ៉េ ជាហូរហែរ ដើម្បីស្វែងយល់ពីការរស់នៅ និងស្ថានភាពនានារបស់ពលរដ្ឋខ្មែរយើងនៅទីនោះ៕

## សង្គមស៊ីវិលស្នើឲ្យរបបក្រុងភ្នំពេញជួបជជែកជាមួយភាគីថៃករណីថៃចាប់បញ្ជូនពលរដ្ឋខ្មែរ

https://www.rfa.org/khmer/ 2018-11-07

សង្គមស៊ីវិលធ្វើការងារទាក់ទងនឹងពលរដ្ឋចំណាកស្រុក ស្នើទៅរបបក្រុងភ្នំពេញឲ្យជួបជជែកជាមួយភាគីថៃរកដំណោះស្រាយលើបញ្ហាសមត្ថកិច្ចថៃ ចុះចាប់ពលរដ្ឋខ្មែរដែលធ្វើការខុសច្បាប់។ សង្គមស៊ីវិលលើកឡើងបែបនេះ ដោយសារតែសមត្ថកិច្ចប្រទេសថៃកំពុងសម្រុកចុះចាប់ពលរដ្ឋខ្មែររាប់រយនាក់ជារៀងរាល់ថ្ងៃបញ្ជូនមកកម្ពុជាវិញ។ ក្រុមសង្គមស៊ីវិលយល់ថា បើជំនួបទ្វេភាគីកម្ពុជា-ថៃបន្តអូសបន្លាយទៀតនឹងធ្វើឲ្យពលរដ្ឋខ្មែរដែលធ្វើការងារនៅប្រទេសនេះរងគ្រោះ ព្រោះការចាប់បញ្ជូនពលរដ្ឋខ្មែរពីសំណាក់សមត្ថកិច្ច ថៃនឹងធ្វើឲ្យពលករទាំងនោះជួបប្រទះបញ្ហាជីវភាពគ្រួសារធ្ងន់ធ្ងរ។

មន្ត្រីកម្មវិធីសិទ្ធិការងារនៃអង្គការសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ លោក ឌី ថេហូយ៉ា និយាយថា ភាគីកម្ពុជា-ថៃគួរតែពិចារណាពីដំណោះស្រាយការចាប់បញ្ជូនពលករខ្មែរពីសំណាកអាជ្ញាធរថៃ។ លោកបន្តថា បើគ្មានការអន្តរាគមន៍ទាន់ពេលវេលាទេ ក្រុមពលករទាំងនោះនឹងរងគ្រោះកាន់តែខ្លាំងថែមទៀត៖ «រ

ដ្ឋាភិបាលគួរយកចិត្តនិងតាមដានឲ្យមែនទែនទៅលើករណីចាប់បញ្ជូនដោយអាចថា មានការរំលោភសិទ្ធិមនុស្សអីចឹង យើងដឹងហើយថាថៃគាត់ពិន័យជាប្រាក់ឬចាប់ដាក់គុកជាដើម»។

មន្ត្រីសង្គមស៊ីវិលដែលធ្វើការងារទាក់ទងនឹងពលករចំណាកស្រុករូបនេះប្រាប់ថា បញ្ហាចំណាកស្រុករបស់ពលករខ្មែរមិនអាចទប់ស្កាត់បាននោះទេ ដូច្នេះភាគីកម្ពុជាគួរធ្វើផែនការទទួលពលករទាំងនោះ ដោយរៀបចំឯកសារស្របច្បាប់ដល់ពួកគេខណៈសំណើបំពេញឯកសារនេះមានលក្ខណៈស្មុគស្មាញ៖ «គួរមានគម្រោងច្បាស់លាស់ទាក់ទងទៅរឿងការធ្វើឯកសារ ហើយរយៈពេលនៃការផ្តល់ភាពស្របច្បាប់កុំអោយរង់ចាំរយៈពេលវែងពេក និងកុំឲ្យមានភាពស្មុគស្មាញនៃដំណើរដាក់ពាក្យស្នើសុំ»។

សមត្ថកិច្ចអន្តោប្រវេសន៍ថៃរាប់ពាន់នាក់បានចុះឆែកឆេរ និងចាប់ខ្លួនពលករខ្មែរដែលកំពុងធ្វើការ និងរស់នៅខុសច្បាប់លើទឹកដីថៃដល់កន្លែងពួកគេស្នាក់នៅតែម្តង។ ពលករខ្មែរនិយាយថា សូម្បីតែអ្នកមានឯកសារក៏ត្រូវសមត្ថកិច្ចថៃចាប់បញ្ជូនខ្លួនទៅស្នួរនាំដែរ។ ការចាប់បញ្ជូននេះត្រូវបានអាជ្ញាធរថៃហៅថាជាយុទ្ធនាការណ៍បោសសំអាតឧក្រិដ្ឋកម្មឆ្លងដែនដើម្បីសេចក្តីសុខពលរដ្ឋថៃ។

អាស៊ីសេរីមិនទាន់អាចសុំការប្រតិកម្មពីអ្នកនាំពាក្យរបបក្រុងភ្នំពេញ លោក ផៃ ស៊ីផាន និង អ្នកនាំពាក្យក្រសួងការបរទេសលោក កេត សោផាន់ បានទេ ដោយទូរស័ព្ទរោទ៍ជាច្រើនដង គ្មានអ្នកទទួល។

ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ លោក វន់ ពៅ មានប្រសាសន៍ថា លោកចង់ឃើញភាគីកម្ពុជា និងថៃ រកដំណោះស្រាយមួយដែលក្នុងនាមជាប្រទេសជិតខាងក្នុងក្របខ័ណ្ឌមនុស្សធម៌។ លោកបន្តថា បើសិនគ្មានដំណោះស្រាយបន្ទាន់ទេ ពលករនឹងត្រូវបាត់បង់ការងារ និងមិនទទួលបានប្រាក់ឈ្នួលពីថៅកែហើយ ថែមទាំងត្រូវសមត្ថកិច្ចថៃជំរិតទារលុយពួកគេថែមទៀតផង៖ «រដ្ឋាភិបាលទាំងពីរគួរជជែកគ្នារកដំណោះស្រាយដើម្បីធ្វើឲ្យពលករខ្មែរទាំងនៅប្រទេសថៃទទួលបានភាពស្របច្បាប់ កាលពីបញ្ជូនមកស្រុកខ្មែរវិញគឺពិបាក»។

របាយការណ៍ ៦ខែ នៃឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបង្ហាញថា យ៉ាងហោចណាស់ពលករខ្មែរជិត ២ម៉ឺននាក់ត្រូវបានអាជ្ញាធរប្រទេសចំនួន ១៨ចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ។

រីឯរបាយការណ៍ក្រសួងមហាផ្ទៃបានបញ្ជាក់ឲ្យដឹងដែរថា គិតត្រឹមពាក់កណ្តាលឆ្នាំ២០១៨នេះ ពលករខ្មែរ ១លាន ៥ម៉ឺននាក់ កំពុងបម្រើការងារនៅក្នុងប្រទេសថៃ ក្នុងនោះមានពលករស្របច្បាប់ជិត៥៥ម៉ឺននាក់(៥៤៨ ៤៧០នាក់)៕

## កម្ពុជា-ថៃនឹងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធជ្រើសរើសពលករតាមប្រព័ន្ធអនឡាញ

http://bayontv.com.kh/ 08/11/2018

ភ្នំពេញ ៖ ក្នុងគោលបំណងដើម្បីសម្រួលភាពងាយស្រួល ក្នុងការបញ្ជូនពលករកម្ពុជា ទៅធ្វើការ និងរស់នៅប្រទេសថៃមានភាពរហ័ស និងអាចកាត់បន្ថយការចំណាកស្រុកប្រទេសកម្ពុជា-ថៃ គ្រោងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិ សម្រាប់ជ្រើសរើសពលករតាម អនឡាញ (Online) នៅចុងឆ្នាំនេះ។

ក្រោយបញ្ចប់ពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការការពារ និងគ្រប់គ្រងពលករកម្ពុជាធ្វើការនៅថៃរវាងសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា សមាគមជ្រើសរើសពលករកម្ពុជា និងសមាគមទំនាក់ទំនងកម្ពុជា-ថៃ កាលពីរសៀលថ្ងៃទី៧ វិច្ឆិកា ឆ្នាំ២០១៨កន្លងទៅ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ថា ការដាក់ឲ្យដំណើរការប្រើប្រាស់ប្រព័ន្ធអនឡាញនេះ ដើម្បីសម្រួលដល់ដំណើរការបញ្ជូន និងទទួលពលករបានស្រួលកាត់បន្ថយពេលវេលាយ៉ាងច្រើន ជាពិសេសភាគីថៃនឹងកាត់បន្ថយរយៈពេលពីប្រមាណ៣ខែ មកត្រឹម២សប្តាហ៍ ចាប់ពីការស្នើសុំការប្រើប្រាស់ពលករបរទេស (កូតា)

ដល់ការបញ្ជូនពលករ មកធ្វើការព្រមទាំងកាត់បន្ថយបែបបទឯកសារ ដោយប្រើប្រាស់តាមប្រព័ន្ធអេឡិច-ត្រូនិកជំនួសវិញ។

ឯកឧត្តម បន្តថា ក្រៅពីការបញ្ជូនពលករកម្ពុជា ទៅធ្វើការនៅប្រទេសថៃ តាមប្រព័ន្ធអនឡាញ ក៏បានបញ្ចៀសបានពីការធ្វើទេសន្តរប្រវេសក៍ ដោយប្រថុយប្រថាន គ្មានឯកសារ និងជាការចូលរួមប្រយុទ្ធប្រឆាំង នឹងការជួញដូរមនុស្សឆ្លងដែនផងដែរ។ ទន្ទឹមនោះ ឯកឧត្តម បានស្នើសមាគមពិចារណា ក្នុងការរៀបចំផ្ទះស្នាក់នៅបណ្ដោះអាសន្នសម្រាប់ពលករកម្ពុជា នៅតាមតំបន់ក្នុងប្រទេសថៃ ដែលអាចឲ្យពលករកម្ពុជាស្នាក់នៅបណ្ដោះអាសន្នក្នុងអំឡុងពេលប្ដូរការងារ ឬរង់ចាំការដោះស្រាយវិវាទជាមួយនិយោជក។ ឯកឧត្តម អ៊ិត សំហេង បានបន្តថា នេះជាវឌ្ឍនភាព និងយន្តការបន្ថែមថ្មីមួយទៀតក្នុងការការពារដល់ពលករកម្ពុជា ដែលទៅធ្វើការនៅប្រទេសថៃបន្ថែមលើកិច្ចការពារ ដែលមាននាពេលបច្ចុប្បន្ន ព្រមទាំងចូលរួមចំណែកប្រទេសថៃឲ្យមានភាពកាន់តែប្រសើរឡើងប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផលខ្ពស់៕

# ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨

## ឃាត់ខ្លួនស្ត្រី១៣នាក់ស៊ីឈ្នួលពពោះ លក់បន្តអោយជនបរទេស

http://cambodiapolice.com/policekh/ 7:54 am 10 វិច្ឆិកា 2018 91

ភ្នំពេញ ៖ កម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដោយមានការចូលរួមពីអភិបាលខណ្ឌសែនសុខ និងអធិការនគរបាលខណ្ឌ បានបើកការស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ បានចុះបង្ក្រាបទីតាំងមួយកន្លែង ដែលពាក់ព័ន្ធករណីស៊ីឈ្នួលពពោះជំនួស ដោយឃាត់ខ្លួនបានមនុស្ស១៥នាក់ ក្នុងនោះមានស្ត្រីដែលពពោះកំពុងមានទម្ងន់១១នាក់ និងប្រុស២នាក់ ហើយ២នាក់ផ្សេងទៀតជាចុងភៅ ដែលទីតាំងខាងលើនេះ ស្ថិតក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

លោក ទូច សារ៉េន នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មិនទាន់បានបញ្ជាក់នៅឡើយទេ ព្រោះលោកថា មនុស្សទាំងអស់កំពុងតែស្ថិតក្រោមការសួរនាំរបស់សមត្ថកិច្ចជំនាញ ដើម្បីកសាងសំណុំរឿងចាត់វិធានការតាមផ្លូវច្បាប់ ។

គួរជម្រាបថា ចំពោះករណីពពោះជំនួសនេះនៅកម្ពុជា ត្រូវបានចាត់ទុកថាជាអំពើខុសច្បាប់ ខណៈដែលក្រសួងមហាផ្ទៃ កំពុងតែធ្វើការចងក្រងច្បាប់ ដើម្បីធ្វើការផ្ដន្ទាទោសផងដែរ ៕

## លោកស្រី ជូ ប៊ុនអេង៖ ការពពោះជំនួសដោយលាក់លៀមត្រូវបានចាត់ចូលជាបទល្មើសក្រោយថ្ងៃ៨មករាឆ្នាំ២០១៧

http://km.rfi.fr/cambodia ដោយ អ៊ឹង ប៊ុនថន11/11/2018

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានគូសបញ្ជាក់ថា ការពពោះជំនួសដោយលាក់លៀមត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌចាប់តាំងពីក្រោយថ្ងៃទី៨ខែមករាឆ្នាំ២០១៧។ ការបញ្ជាក់របស់លោកស្រី គឺដោយសារតែនៅពេលថ្មីៗនេះ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីខ្មែរចំនួន១៣នាក់ទៀត ដែលរងការចោទថា ស៊ីឈ្នួលពពោះជំនួស។ លោកស្រី ជូ ប៊ុនអេង បានប្រាប់វិទ្យុបារាំងអន្តរជាតិRFIនៅថ្ងៃអាទិត្យនេះថា កាលពីមុនថ្ងៃទី៨ខែមករាឆ្នាំ២០១៧ រដ្ឋាភិបាលកម្ពុជាមានការយោគយល់ដោយផ្ដល់ឱកាសដល់ស្ត្រីដែលពពោះជំនួស មកធ្វើកិច្ចសន្យា និងសហការជាមួយតុលាការ។ ប៉ុន្តែលោកស្រីកត់

សំគាល់ថា មិនមានស្ត្រីពពោះជំនួសមកបង្ហាញខ្លួនដូចដែលអាជ្ញាធរចង់បានទេតែករណីពពោះជំនួសនេះនៅតែកើតមានទើបសមត្ថកិច្ចចុះឃាត់ខ្លួនបញ្ជូនទៅតុលាការជាបន្តបន្ទាប់នៅពេលថ្មីៗនេះ។

កាលពីថ្ងៃទី ៨ ខែវិច្ឆិកានេះ កម្លាំងនគរបាលបានឆ្មក់ចូលផ្ទះមួយកន្លែងក្នុងខណ្ឌសែនសុខ ហើយឃាត់ខ្លួនស្ត្រីស៊ីឈ្នួល ពពោះជំនួសចំនួន១៣នាក់។ លើសពីនេះទៀត សាលាដំបូងរាជធានីភ្នំពេញកាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨ បានសម្រេចចោទប្រកាន់ស្ត្រីស៊ីឈ្នួលពពោះជំនួស៣២នាក់ ដោយចោទពី «ការជួញដូរមនុស្សដោយឆ្លងដែន» តាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម។

លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជា បានឲ្យដឹងថា អ្នកដែលជួលឲ្យស្ត្រីខ្មែរពពោះជំនួសនោះ គឺសុទ្ធតែជាជនបរទេសដែលត្រូវយកទារកឆ្លងដែន ហើយក្នុងនោះក៏មានជនជាតិចិនផងដែរ។ លោកស្រី ចាត់ទុកករណីនេះថា មានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ថា នាំមនុស្សឆ្លងមនុស្សឆ្លងដែនខុសច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម បន្ទាប់មានការពពោះដោយលាក់លៀម ខណៈច្បាប់ស្តីពីការពពោះជំនួសកំពុងតែព្រាងនៅឡើយ។

នៅពេលសួរថាតើទារកនៅក្នុងផ្ទៃរបស់ស្ត្រីខ្មែរដែលពពោះជំនួសនោះ ជាកូនរបស់ភាគីដែលជួលឬយ៉ាងណា លោកស្រី ជូ ប៊ុនអេង ក៏មិនដឹងច្បាស់ដែរ ដោយគ្រាន់តែដឹងថា ទារកដែលគេចាត់ទុកថាជាជនរងគ្រោះ គឺបង្កកំណើតតាមបែបវិទ្យាសាស្ត្រ៕

## ប៉ូលិសបញ្ជូនអ្នកពាក់ព័ន្ធ ស៊ីឈ្នួលពពោះ ១៥ នាក់ទៅកាន់តុលាការ

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 12 November 2018 | 08:46 ICT

**ភ្នំពេញៈ** អាជ្ញាធរជំនាញខាងបង្ក្រាប និងប្រឆាំងការជួញដូរមនុស្សគ្រោងបញ្ជូនស្ត្រីចំនួន ១៣ នាក់ និងបុរស ២ នាក់ដែលពាក់ព័ន្ធនឹងការស៊ីឈ្នួលពពោះជំនួសទៅកាន់សាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃចន្ទនេះ ក្រោយពីចាប់ខ្លួនពួកគេបាននៅក្នុងខណ្ឌសែនសុខកាលពីថ្ងៃទី ៨ ខែវិច្ឆិកា។ យោងតាមលោក ទូច សារ៉េន នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានថ្លែងប្រាប់កាសែតភ្នំពេញ-ប៉ុស្តិ៍កាលពីម្សិលមិញ។

លោក សារ៉េន ថ្លែងថា៖ «យើងឃាត់ខ្លួនបាន ១៥ នាក់ក្នុងនោះមានស្ត្រីកំពុងពពោះ ១១ នាក់។ យើងកំពុងកសាងសំណុំរឿងតាមនីតិវិធីទៅតុលាការ។ យើងកំពុងធ្វើនីតិវិធីនៅមិនទាន់ចប់ទេ។ យើងបញ្ជូនគាត់ទៅឆាប់ៗហ្នឹង ពេលដែលយើងរៀបចំឯកសារហើយយើងបញ្ជូនទៅហើយ។ យើងធ្វើមិនទាន់ទេដូច្នេះហើយយើងសុំតុលាការពន្យារពេលដើម្បីធ្វើការស្រាវជ្រាវតាមនីតិវិធីឲ្យបានគ្រប់ជ្រុងជ្រោយថ្ងៃចន្ទយើងបញ្ជូនទៅហើយ»។ លោក សារ៉េន ឲ្យដឹងផងដែរថាក្នុងប្រតិបត្តិការកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានឃាត់ខ្លួនមនុស្ស ១៥ នាក់ក្នុងនោះមានប្រុស ២ នាក់ និងស្រី ១៣ នាក់ដែលក្នុងនោះមានស្ត្រី ១១ នាក់បាននិងកំពុងមានផ្ទៃពោះ។ មនុស្សទាំងអស់កំពុងតែស្ថិតក្រោមការសួរនាំរបស់សមត្ថកិច្ចជំនាញដើម្បីកសាងសំណុំរឿងចាត់វិធានការតាមផ្លូវច្បាប់។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានឲ្យដឹងថា កម្លាំងអាជ្ញាធរបានកំពុងស្វែងរកមេខ្លោងដែលពាក់ព័ន្ធករណីស៊ីឈ្នួលពពោះ។ លោកស្រីបញ្ជាក់ថា ទោះបីជាមានការផ្សព្វផ្សាយទូលំទូលាយ និងការអប់រំតាមសហគមន៍ និងតាមខេត្តផ្សេងៗ តែនៅតែមានអ្នកប្រព្រឹត្តផ្ទើននឹងច្បាប់ ដូច្នេះអ្នកដែលជាប់ពាក់ព័ន្ធករណីស៊ីឈ្នួលពពោះជំនួសនឹងប្រឈមមុខនឹងច្បាប់ពីការបង្ក្រាបការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងច្បាប់ក្រមព្រហ្មទណ្ឌ។ លោកស្រី ប៊ុន អេង ថ្លែងថា៖ «យើងកំពុងតែធ្វើការស្រាវជ្រាវដោយសារពេលដែលយើងបង្ក្រាបនោះគឺយើងអត់បានឃើញមេខ្លោងនៅទីតាំងនោះទេ។ យើងកំពុងតែតាមដាន និងស៊ើបអង្កេតរកប្រភព ហើយខ្ញុំគិតថាករណីនេះមិនខុសគ្នាពី

ករណីមុនៗទេ រឿងនេះគឺទើបតែកើតពេលថ្មីៗនេះហាក់ដូចជាវាផ្ទើនជាមួយនឹងការអនុវត្តច្បាប់។ មកដល់ពេលនេះហើយគាត់ (អង្គការសង្គមស៊ីវិល) នៅតែគិតថា គាត់(អ្នកត្រូវឃាត់ខ្លួន) ជាជនរងគ្រោះទៀតនោះគឺវាមិនស័ក្តិសមនោះទេ ដោយសារគាត់មានចេតនា បើសិនជាយើងសួរគាត់មួយណាក៏គាត់ដឹងយ៉ាងច្បាស់ថា កូនហ្នឹងត្រូវបានដោះដូរជាមួយនឹងលុយតម្លៃប៉ុន្មាន ដូច្នេះគាត់មានចេតនាក្នុងការឃុបឃិតជាមួយជនដៃដល់»។

កាលពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៨ កន្លងទៅសមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីពពោះជំនួសចំនួន ៣២ នាក់ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ហើយត្រូវបានសមត្ថកិច្ចចាប់បញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាលក្នុងនាមជាជនរងគ្រោះ ប៉ុន្តែនៅទីបំផុតពួកគេត្រូវបានចោទប្រកាន់ និងឃុំខ្លួនមុនការជំនុំជម្រះដោយចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញកាលពីខែកក្កដាក្រោមការចោទប្រកាន់ពីបទប៉ុនប៉ងលក់ ទិញ ឬដោះដូរមនុស្សសម្រាប់ការផ្ទេរឆ្លងព្រំដែន និងប្រព្រឹត្តជាអន្តរការីរវាងឪពុក ម្តាយសុំកូន និងស្ត្រីដែលមានផ្ទៃពោះតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ និងមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។

កាលពីចុងខែតុលាឆ្នាំ ២០១៨ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបានឲ្យដឹងថា មេធាវីការពារឲ្យស្ត្រីពពោះទាំង ៣២ នាក់បានរៀបចំឯកសារដាក់ទៅតុលាការដើម្បីស្នើសុំឲ្យតុលាការធ្វើការពិចារណាដោះលែងពួកគេឲ្យនៅក្រៅឃុំបណ្តោះអាសន្នដើម្បីឲ្យពួកគេបានចិញ្ចឹមកូនៗដែលពួកគេស៊ីឈ្នួលបង្កើតឲ្យអ្នកផ្សេងនោះ ដោយពួកគេមិនបញ្ជូនកូនទាំងនោះទៅឲ្យអ្នកដែលជួលពួកគេឡើយ។

មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្សធ្លាប់ឲ្យដឹងថា ស្ត្រីខ្មែរត្រូវបានជួលឲ្យពពោះជំនួសក្នុងតម្លៃ ១ ម៉ឺនដុល្លារក្នុងម្នាក់ដោយពួកគេទទួលបានប្រាក់កក់ដំបូងពេលមានផ្ទៃពោះ ៥០០ ដុល្លារ ហើយពេលកូនកើតមកពួកគេទទួលបាន ៣០០ ដុល្លារក្នុង ១ ខែរហូតគ្រប់ចំនួន៕

## **អង្គការ CENTRAL ៖ ការរៀបចំផ្ទះស្នាក់នៅបណ្តោះអាសន្ន សម្រាប់ពលករខ្មែរនៅថៃគឺល្អ តែចង់ឲ្យមានគាំទ្រទាំងស្រុង**

http://wmc.org.kh/ ថ្ងៃព្រហស្បតិ៍ ទី៨ ខែកញ្ញា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ នាយកប្រតិបត្តិអង្គការ Central យល់ថា ជាចំណុចល្អដែលរដ្ឋមន្ត្រីស្នើឲ្យរៀបចំផ្ទះស្នាក់នៅបណ្តោះអាសន្នសម្រាប់ពលករកម្ពុជានៅថៃ អំឡុងពេលដែលប្តូរការងារ និងរង់ចាំដំណោះស្រាយវិវាទការងារជាមួយថៅកែនិយោជក។ តែលោកចង់ឲ្យគាំទ្រទាំងទាំងការស្នាក់នៅ និងម្ហូបអាហារ។

ជំនួបរវាងរដ្ឋមន្ត្រីក្រសួងការងារ ជាមួយសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) និងសមាគមទំនាក់ទំនងកម្ពុជា-ថៃ (TCRA) គឺដើម្បីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពី "ការសហការការពារពលករកម្ពុជាធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍"។ ជំនួបនេះធ្វើឡើងកាលពីរសៀលថ្ងៃទី០៧ ខែវិច្ឆិកា នៅរាជធានីភ្នំពេញ។ ក្នុងជំនួបនេះ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើទៅសមាគមបញ្ជូន និងទទួលពលករ ធ្វើការនៅថៃ រៀបចំផ្ទះស្នាក់បណ្តោះអាសន្ន សម្រាប់ពលករកម្ពុជានៅថៃ បន្ទាប់ពីបានធ្វើដោយជោគជ័យនៅប្រទេសកូរ៉េខាងត្បូង។ លោករដ្ឋមន្ត្រីក្រសួងការងារ បានផ្តួចផ្តើមរៀបចំឲ្យមានកន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ពលករកម្ពុជា ធ្វើការនៅប្រទេសកូរ៉េ ក្នុងអំឡុងពេលដែលពួកគេ ផ្លាស់ប្តូរការងារ ឬក៏រង់ចាំដំណោះស្រាយវិវាទការងារជាមួយថៅកែនិយោជក។ កន្លែងស្នាក់នៅបណ្តោះអាសន្ននេះ មិនមែនត្រឹមតែជាកន្លែងស្នាក់នៅប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកន្លែងប្រឹក្សាយោបល់សម្រាប់ពលករផងដែរ។ ចាប់តាំងពីកន្លែងស្នាក់នៅបណ្តោះអាសន្ននេះបានបង្កើតឡើង គឺបានសម្រួលយ៉ាងច្រើនដល់ពលករកម្ពុជានៅប្រទេសកូរ៉េ។ ក្រោយពីការមើលឃើញ ផលវិជ្ជមានដូចនេះទើបលោករដ្ឋមន្ត្រី មានបំណងចង់ឲ្យកន្លែងស្នាក់នៅបណ្តោះអាសន្នបែបនេះ នៅប្រទេសថៃដែរ ៖«កន្លែងស្នាក់នៅបណ្តោះអាសន្ន

នេះ គេអាចមកស្នាក់នៅ គេអាចមកទទួលប្រឹក្សាយោបល់ ហើយក៏អាចទទួលឱកាសដើម្បីស្វែងរកការងារថ្មីដែលខ្លួនពេញចិត្ត។ ជាជាងការដែលឲ្យបងប្អូនយើងចេញមកហើយ ទៅនៅត្រង់នេះ ត្រង់នោះ ដែលមិនច្បាស់លាស់។ បាទនេះគឺជាបទពិសោធន៍មួយដែលយើងធ្វើបានជោគជ័យនៅសាធារណរដ្ឋកូរ៉េ»។

ចំពោះករណីនេះ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធមនុស្សហៅកាត់ថា (Central) យល់ថា ជារឿងដែលល្អក្នុងការជួយដល់ពលករកម្ពុជានៅថៃ។ តែលោកគិតថា កន្លែងនោះគួរតែរៀបចំឲ្យបានសមស្របតាមស្តង់ដារ ដោយដាក់ឲ្យបានដាច់ដោយឡែកពីគ្នារវាងស្ត្រី និងបុស ឬក៏គូស្វាមី លើសពីនេះបន្ទប់ទឹកគួរតែមានដាច់ឡោយឡែក។ ជាងនេះលោកគិតថា ក៏គួរតែមានការគាំទ្រផ្នែកម្ហូបអាហារផង៖«មួយទៀតហ្នឹងគឺរឿងស្បៀងអាហារសំខាន់ណាស់។បើសិនអត់មានស្បៀងអាហារឬក៏ការគាំពារផ្នែកសង្គមអីមួយចំនួនដល់គាត់ទៀតក៏មិនទាន់គ្រប់គ្រាន់ដែរនិយាយឲ្យខ្លីទៅមិនគួរមានតែទីតាំងមួយមុខទេគឺត្រូវតែមានហេដ្ឋារចនាសម្ព័ន្ធអីថែមទៀត»។ បន្ថែមលើនេះលោកថា បើក្នុងករណីដែលតម្រូវឲ្យមានការបង់ថវិកាអំឡុងស្នាក់នៅផ្ទះស្នាក់បណ្តោះអាសន្ន លោកយល់ថា គួរតែមានការបង់តិចតួចប៉ុណ្ណោះ ដើម្បីជាការសម្រួលកាន់តែច្រើនទៀតដល់ការចំណាយរបស់ពលករខ្មែរធ្វើការនៅថៃ។

តាមប្រសាសន៍របស់លោករដ្ឋមន្ត្រី បញ្ជាក់ថា ផ្ទះស្នាក់នៅបណ្តោះអាសន្នេះអាចនឹងបង្កើតនៅតំបន់មួយមាន ២ ឬក៏ ៣កន្លែង តាមស្ថានភាពជាក់ស្តែង។ លោកថា អាជ្ញាធរនឹងជូនដំណឹងទៅពលករខ្មែរធ្វើការនៅថៃឲ្យបានដឹង ប្រសិនកន្លែងស្នាក់បណ្តោះអាសន្ននេះ មាននៅតំបន់ណា។ លោក អ៊ិត សំហេង បន្តថា គិតមកដល់ពេលនេះពលករកម្ពុជាមានចំនួនប្រមាណជា ១លាន ៨ម៉ឺននាក់ គឺសុទ្ធតែបានទទួលភាពស្របច្បាប់ជាពលករបរទេស។ តែយ៉ាងណាលោកគិតថា ក៏អាចមានចំនួនតិចតួចទៀត ដែលមិនទាន់បានទទួលភាពស្របច្បាប់។ ករណីនេះលោករដ្ឋមន្ត្រី សំណូមពរថា ពលករកម្ពុជាដែលដឹងថា ខ្លួនកំពុងធ្វើការដោយខុសច្បាប់ ឬក៏ផុតសុពលភាពការងារ ឬលិខិតឆ្លងដែន ត្រូវរួសរាន់ផ្តល់ដំណឹងមកស្ថានទូតខ្មែរប្រចាំនៅទីនោះ ដើម្បីគេចផុតពីការចាត់វិធានការផ្លូវច្បាប់ពីអាជ្ញាធរថៃ ៖«នៅក្នុងករណីដែលរកឃើញ ឬក៏បងប្អូនដឹងថា ខ្លួនឯងហ្នឹងវាហួសពេលវេលានៃលិខិតឆ្លងដែន ហួសពេលវេលានៃការស្នាក់នៅនៃការធ្វើការងារហ្នឹង ហើយមិនទាន់បានធ្វើឯកសារឡើងវិញ គឺសុំឲ្យជូនដំណឹងទៅស្ថានទូតភ្លាម ហើយស្ថានទូតនឹងចាត់មន្ត្រីឲ្យចុះទៅដើម្បីនឹងចេញលិខិតធ្វើដំណើរបណ្តោះអាសន្ន។ ភាគីថៃបានព្រមព្រៀងចំណុចនេះសម្រួលសម្រាប់បងប្អូនពលករយើង មិនឲ្យមានការចាត់វិធានការផ្លូវច្បាប់អីចំពោះករណីនេះទេ»។

រដ្ឋមន្ត្រីក្រសួងការងារ អះអាងថា រដ្ឋាភិបាលកំពុងរៀបចំយន្តការជាច្រើនដើម្បីធ្វើយ៉ាងណាការពារពលរដ្ឋខ្មែរ ដែលកំពុងធ្វើការនៅក្រៅប្រទេស ឲ្យបានទទួលផលប្រយោជន៍ និងគេផុតពិការកេញប្រវ័ញ្ច។ លោកសង្កត់ធ្ងន់ថា ការចុះអនុស្សរណៈ ស្តីពី "ការសហការការពារពលករកម្ពុជាធ្វើការនៅព្រះរាជាណាចក្រថៃឡង់ដ៍"នេះ គឺជាយន្តការថ្មីមួយទៀត ក្នុងការការពារដល់ពលករកម្ពុជា ដែលទៅធ្វើការនៅប្រទេសថៃបន្ថែមលើកិច្ចការពារ ដែលមាននាពេលបច្ចុប្បន្ន ព្រមទាំងរួមចំណែកជួយដល់ករខ្មែរនៅប្រទេសថៃ ឲ្យមានភាពកាន់តែប្រសើរឡើង ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ជាងនេះលោកក៏បានបង្ហាញការគាំទ្រចំពោះសមាគមទាំងបី ដែលនឹងរៀបចំផ្តល់ជូនសេវាកម្មជានារ៉ាប់រងដល់ពលករកម្ពុជា លើការជានាគ្រោះថ្នាក់ការងារ និងអាយុជីវិត ដែលស្របតាមអនុសាសន៍របស់ប្រមុខដឹកនាំរដ្ឋាភិបាលកម្ពុជា៕

## ពលករកាប់ឈើគ្រញូងក្នុងទឹកដីថៃ ក្នុងចំណោម៣នាក់ ត្រូវសមត្ថកិច្ចថៃចាប់បានម្នាក់ ពីរនាក់ទៀត រត់ចូលប៉ុស្តិ៍នគរបាលវរៈការពារព្រំដែនគោកលេខ៧០២

http://nokorwatnews.com/ 11-11-2018

ខេត្តឧត្តរមានជ័យ៖ មូលហេតុ សមត្ថកិច្ចថៃ ចាប់ខ្លួនពលករខ្មែរជាបន្តបន្ទាប់ជាច្រើនឆ្នាំមកនេះ ល្បីថា លោក គង់ សុខាន់ មេបញ្ជាការនគរបាលវរៈការពារព្រំដែនគោក៧០២ បើកភ្លើងខៀវ ឲ្យមេឧក្រិដ្ឋកម្មឈើឆ្លងដែន ឈ្មោះ ឈឿង សក្តិ ធ្វើសកម្មភាពនៅដែនសមត្ថកិច្ចរបស់ខ្លួន ។ ជាក់ស្តែង ពលករខ្មែរកាប់ឈើគ្រញូងក្នុងទឹកដីថៃ ក្នុងចំណោម ៣នាក់ ម្នាក់ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន និងពីរនាក់ផ្សេងទៀតបានរត់រំដោះខ្លួនរួចដោយ ចូលមកប៉ុស្តិ៍នគរបាលវរៈការពារព្រំដែនគោកលេខ៧០២ ។ កាលពីវេលាម៉ោង២ និង២០នាទីរសៀល ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ២០១៨ នៅទល់មុខប៉ុស្តិ៍នគរបាលវរៈការពារព្រំដែន៧០២ ក្នុងភូមិអូស្មាច់ សង្កាត់អូស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។

បើតាមប្រភពបានបង្ហើបឲ្យដឹងថា មូលហេតុនៃការចាប់ខ្លួនពលករខ្មែរពីសំណាក់សមត្ថកិច្ចថៃ ជារៀងរាល់ខែ គ្មានស្រាកស្រាននៅក្នុងតំបន់នគរបាលវរៈការពារព្រំដែនគោកលេខ៧០២ ក៏ដោយសារតែ លោកវរៈសេនីយ៍ឯក គង់ សុខាន់ មេបញ្ជាការរូបនេះ បានបើកភ្លើងខៀវ ឲ្យមេឧក្រិដ្ឋកម្មឈើប្រណីតឆ្លងដែន និងគៀងគរពលករឆ្លងដែន ឈ្មោះឈឿង សក្តិ ដែលជានាយទាហាននៅអង្គភាពកងពលតូចលេខ៤២ ដេញថ្លៃផ្តាច់មុខប្រមូលទិញបទល្មើសឈើនៅដែនសមត្ថកិច្ចរបស់ខ្លួន ។ ប្រភពបានបន្តថា ទោះជាពលករខ្មែរត្រូវបានរងគ្រោះ ដោយសមត្ថកិច្ចចាប់ខ្លួនយកទៅអនុវត្តទោសប្រទេសថៃជារៀងរាល់ខែយ៉ាងណាក៏ដោយ ក៏លោកវរៈសេនីយ៍ឯក គង សុខាន់ មេបញ្ជាការនគរបាលមិនខ្វាយខ្វល់ដែរ ប្រហែលខ្វាយខ្វល់តែប្រាក់ លោកជឿង សក្តិ បង់ឲ្យផ្តាច់មុខហើយមើលទៅ ? ទើបឈឿង សក្តិ ធ្វើសកម្មភាព រកស៊ីបទល្មើស និងគៀងគរពលករកាប់ឈើ យ៉ាងអនាធិបតេយ្យ បែបនេះ ។ ប៉ែន នួន

## គណៈកម្មការនីតិកម្មផ្តើមសិក្សាសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងកម្ពុជា និងសហព័ន្ធរុស្ស៊ី

http://bayontv.com.kh/ 12/11/2018

ភ្នំពេញ៖ ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា បានដឹកនាំសមាជិកសមាជិកាគណៈកម្មការប្រជុំពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។ នេះជាកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ មុននឹងមានកិច្ចប្រជុំដើម្បីពិនិត្យសិក្សាលើអត្ថបទសេចក្តីព្រាងច្បាប់នេះ ជាមួយតំណាងរាជរដ្ឋាភិបាលក្នុងពេលឆាប់ៗនេះ មុននឹងសុំការអនុម័តយល់ព្រមពីរដ្ឋសភាជាតិនាពេលខាងមុខ។

សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ីបានចុះហត្ថលេខាកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ នៅរដ្ឋធានីមូស្គូ សហព័ន្ធរុស្ស៊ី។ ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា បានមានប្រសាសន៍ថា សន្ធិសញ្ញានេះមានគោលបំណងជួយសម្រួល ដល់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងបទល្មើស ឲ្យមានប្រសិទ្ធភាពរវាងគូភាគី ជាពិសេសអត្ថប្រយោជន៍ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ ដ៏មានប្រសិទ្ធភាពរវាងប្រទេសទាំងពីរ ក្នុងការលុបបំបាត់ឧក្រិដ្ឋកម្ម ដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យគ្នាទៅវិញទៅមក សមភាព និងផលប្រយោជន៍ទាំងសងខាង។ ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា បានលើកឡើងបន្តថា សន្ធិសញ្ញាបត្យាប័ននេះបានកំណត់ឲ្យភាគីនីមួយៗ មានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀត នូវជនទាំងឡាយណាដែលត្រូវបានរកឃើញនៅលើទឹកដីនៃភាគីណាមួយ ហើយកំពុងត្រូវគេតាមចាប់ខ្លួនដើម្បីធ្វើការចោទប្រកាន់ ធ្វើការជំនុំជម្រះក្តី ឬអនុវត្តទណ្ឌកម្មតាមទោស

កំណត់ នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសណាមួយ។ ដូចនេះសម្រាប់ក្របខ័ណ្ឌច្បាប់ដើម្បីស្វែងរកនូវឧក្រិដ្ឋជន ទាមទារឲ្យមានកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ ក្នុងវិស័យព្រហ្មទណ្ឌតាមរយៈជួយគ្នាទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ការធ្វើបត្យាប័ន និងការផ្ទេរទណ្ឌិត។

ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សន្និសញ្ញា ស្តីពីបត្យាប័នបែបនេះមានចំនួន ៧ ប្រទេសរួចមកហើយ មានជាមួយប្រទេសថៃនៅឆ្នាំ១៩៩៩, ជាមួយប្រទេសចិននៅឆ្នាំ២០០០, ជាមួយប្រទេសឡាវឆ្នាំ២០០៥, ជាមួយប្រទេសឥណ្ឌាឆ្នាំ២០០៩, ជាមួយសាធារណរដ្ឋកូរ៉េឆ្នាំ២០១០, ជាមួយប្រទេសវៀតណាមឆ្នាំ២០១៤ ហើយនៅពេលនេះជាមួយប្រទេសរុស្ស៊ីនេះ។ ឯកឧត្តមបណ្ឌិត ប៉ែន បញ្ញា បានស្នើដល់សមាជិកគណៈកម្មការទាំងអស់ពិនិត្យ និងសិក្សាសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រម លើសន្និសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ីនេះឲ្យបានល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយ ដើម្បីជួបប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលក្នុងពេលឆាប់ៗនេះ៕

## ស៊ីឈ្នួលពពោះ៖ ម្តាយបានប្រាក់ចាប់ពី៨ពាន់ដល់១ម៉ឺនដុល្លារ ឯកូនកើតមកភ្លាមត្រូវប្រគល់ម្ចាស់ប្រាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៨

រាជធានីភ្នំពេញ ៖ កាលពីថ្ងៃទី៨ ខែវិច្ឆិកា កន្លងទៅ នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ សហការជាមួយនគរបាលខណ្ឌសែនសុខ និងមានការសម្របសម្រួលពីសំណាក់លោក គុជ គឹមឡុង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការបង្រ្កាបជាក់ស្តែង ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សសម្រាប់នាំឆ្លងដែន និងអន្តរការីរវាងអ្នកសុំកូននិងស្រ្តីពពោះ ។

ការបង្រ្កាបនេះ សមត្ថកិច្ចបានធ្វើឡើងចំនួន៣កន្លែងក្នុងខណ្ឌសែនសុខ ហើយជាលទ្ធផលឃាត់ខ្លួនជនសង្ស័យចំនួន១៥នាក់ ក្នុងនោះ មានស្រ្តីអ្នកមើលការខុសត្រូវ(មេការ)២នាក់ អ្នករត់ម៉ូតូឌុប២នាក់ និងស្រ្តីមានផ្ទៃពោះ(ស្រ្តីពពោះ)ចំនួន១១នាក់ ។ ចំពោះវត្ថុតាងដកហូតមានលិខិតឆ្លងដែន១ក្បាល ឧបករណ៍ពេទ្យមួយចំនួន (សឺរ៉ាំងថ្នាំពេទ្យប្រើរួចនិងមិនទាន់ប្រើ) និងរ៉ឺម៉កចំនួន២គ្រឿង ។

ទាក់ទិននឹងករណីបង្រ្កាបនេះ សមត្ថកិច្ចបានបង្ហើបឱ្យដឹងថា ស្រ្តីមានផ្ទៃពោះទាំង១១នាក់ សុទ្ធសឹងជាស្រ្តីបម្រើការងារនៅតាមរោងចក្រ ដែលមេខ្យល់បានដើរអូសទាញឱ្យមកប្រកបមុខរបរនេះ ។ ស្រ្តីស៊ីឈ្នួលពពោះត្រូវបានគេយកទៅចាក់មេជីវិត ដោយផ្តល់ប្រាក់ឱ្យម្នាក់២០០ដុល្លារអាមេរិក ដើម្បីយកទៅប្រើប្រាស់ និងទិញម្ហូបអាហារបំប៉នសុខភាព ។ បន្ទាប់មក មេខ្យល់ឱ្យពួកគេស្នាក់នៅជួបជុំគ្នា ងាយស្រួលថែទាំគ្រប់គ្រង និងបានផ្តល់ប្រាក់លើការហូបចុកក្នុងម្នាក់១ថ្ងៃ១០ដុល្លារអាមេរិក ។ លុះដល់ពេលសម្រាលបានទារក ម្តាយត្រូវទទួលបានប្រាក់ឈ្នួលម្នាក់ ចាប់ពី៨ពាន់ ដល់១ម៉ឺនដុល្លារអាមេរិក ហើយកូនដែលកើតមកភ្លាមនោះ ត្រូវបានប្រគល់ឱ្យទៅម្ចាស់ប្រាក់ ។ ពេលនេះជនសង្ស័យជាមេខ្លោង ដែលបានរៀបចំប្រមែប្រមូលស្រ្តីធ្វើការតាមរោងចក្រឱ្យពពោះជំនួសនោះ មិនទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ ចាប់បានតែមេការនិងអ្នកចាត់ចែងទូទៅប៉ុណ្ណោះ ។

បើតាមចម្លើយមេការនិងស្រ្តីពពោះបានប្រាប់សមត្ថកិច្ចថា ទារកដែលគេបង្កើតបាន ឬក៏ម្តាយដែលមានទារកនៅក្នុងផ្ទៃ ភាគច្រើនត្រូវមេខ្លោងនាំចេញទៅប្រទេសចិន ។ សមត្ថកិច្ចគ្រោងនឹងបញ្ជូនជនសង្ស័យ៤នាក់ គឺមេការ២នាក់និងអ្នករត់ម៉ូតូឌុប(ឡំប្រឺតាឥណ្ឌា)២នាក់ ទៅសាលាដំបូងរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១២ ខែវិច្ឆិកា ដើម្បីធ្វើការសាកសួរតាមនីតិវិធី ។ បន្ទាប់ពីសាកសួរនិងចោទប្រកាន់ជនសង្ស័យទាំង៤នាក់នេះហើយ សមត្ថកិច្ចនឹងបន្តបញ្ជូនស្រ្តីពពោះចំនួន១១នាក់ទៅសាលាដំបូងដែរ ដើម្បីសុំការសម្រេច ។ លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានបញ្ជាក់ថា ការពពោះជំនួសដោយ

លាក់លៀម ត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ ចាប់តាំងពីក្រោយថ្ងៃទី៨ ខែមករា ឆ្នាំ២០១៧មក ។ ការបញ្ជាក់របស់លោកជំទាវនេះ គឺបន្ទាប់ពីសមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីខ្មែរដែលរងការចោទថាស៊ីឈ្នួលពពោះជំនួស ។

លោកជំទាវ ជូ ប៊ុនអេង បានប្រាប់វិទ្យុបារាំងអន្តរជាតិ(RFI) កាលពីថ្ងៃអាទិត្យទី១១ខែវិច្ឆិកាថា កាលពីមុនថ្ងៃទី៨ ខែមករា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលកម្ពុជាមានការយោគយល់ ដោយផ្តល់ឱកាសដល់ស្ត្រីដែលពពោះជំនួសមកធ្វើកិច្ចសន្យានិងសហការជាមួយតុលាការ។ ប៉ុន្តែលោកជំទាវកត់សម្គាល់ថា មិនមានស្ត្រីពពោះជំនួសមកបង្ហាញខ្លួនដូចដែលអាជ្ញាធរចង់បានទេ ហើយករណីពពោះជំនួសនេះនៅតែកើតមាន ទើបសមត្ថកិច្ចចុះឃាត់ខ្លួនបញ្ជូនទៅតុលាការ ។ លោកជំទាវបានឲ្យដឹងថា អ្នកដែលជួលស្ត្រីខ្មែរឲ្យពពោះជំនួសនោះ គឺសុទ្ធតែជាជនបរទេសដែលត្រូវយកទារកឆ្លងដែន ហើយក្នុងនោះក៏មានជនជាតិចិនផងដែរ ។ លោកជំទាវចាត់ទុកករណីនេះថា មានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទនាំមនុស្សឆ្លងដែនខុសច្បាប់ ហើយការចាប់ឃាត់ខ្លួននេះគឺជាការបង្ក្រាបការជួញដូរមនុស្ស ៕

## ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨

### មន្ត្រីយោធាស្រុកអន្លង់វែង រងការចោទថា បានឃុបឃិតបញ្ជូនពលករឲ្យចូលកាប់ឈើប្រណីតក្នុងដីថៃ

http://nokorwatnews.com/ 12-11-2018

ខេត្តឧត្តរមានជ័យ៖ មន្ត្រីយោធា នៃមូលដ្ឋានសឹកអន្លង់វែងកាលពីពេលថ្មីៗនេះ រងការចោទថា បានបើកភ្លើងខៀវឲ្យពលករចូលទៅកាប់ឈើប្រណីតក្នុងដីទឹកដីថៃ យកមកលក់ឲ្យខ្លួន ។ តាមសេចក្តីរាយការណ៍ថា ក្នុងភូមិសាមគ្គី ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង តាមផ្លូវយុទ្ធសាស្ត្រព្រំដែនខ្មែរ-ថៃ ដោយមានការត្រូវរ៉ូវគ្នាជាមួយលោកវរៈសេនីយ៍ត្រី ភោគ ភន មេបញ្ជាការយោធាសឹករងស្រុកអន្លង់វែង បានបើកឲ្យមានការចូលទៅកាប់ឈើប្រណីតក្នុងដីថៃ ។ ថៅកែដែលតែងតែដាក់ទុនឲ្យពលករឆ្លងដែនទាំងនោះ ត្រូវគេស្គាល់ឈ្មោះ អ៊ុំ សុខា (ហៅង៉ែត) និងឈ្មោះ វិត ។ អ្នកទាំងពីរជាមេបញ្ជាការរងយោធាសឹករងស្រុកអន្លង់វែង ។

ប្រភពថា ជាក់ស្តែងកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨ មានរថយន្តមួយគ្រឿងម៉ាកនីសាន់ពណ៌ត្រីអ៊ី បានចូលទៅភូមិសាស្ត្រខាងលើ ដើម្បីប្រមូល និងដឹកជញ្ជូនឈើប្រភេទ បេង និងធ្នង់ យកមកស្តុកទុកនៅទីរួមស្រុកអន្លង់វែង ដែលជាទីសំចតចុងក្រោយ មុននឹងបញ្ជូនចេញទៅកាន់ទីផ្សារ ។

ជុំវិញករណីនេះ ក្រុមការងារមិនអាចសុំការបំភ្លឺពីលោកអនុសេនីយ៍ឯក អ៊ុំ សុខា (ហៅង៉ែត) មេបញ្ជាការរងយោធាសឹករងស្រុកអន្លង់វែងបានទេ។ ចំណែកលោក វិត បានឲ្យដឹងតាមទូរស័ព្ទ ថា ពិតមានការដឹកជញ្ជូនឈើពីចំណុចខាងលើមែន ដោយលោកខ្ចីរថយន្តលោក អ៊ុំ សុខា (ហៅង៉ែត) ដើម្បីដឹក ។ តែជាប្រភេទឈើត្រសេកទេ ។ ដោយឡែក លោកវរៈសេនីយ៍ត្រី ភោគ ភន មេបញ្ជាការយោធាសឹករងស្រុកអន្លង់វែង ក៏មិនអាចសុំការបកស្រាយបានដែរ ។ តែយ៉ាងណាក៏ដោយ លោកឧត្តសេនីយទោ តុន ញាណ មេបញ្ជាការសឹករងខេត្តមានជ័យ បានឲ្យដឹងថា រឿងហ្នឹងលោកអត់បានដឹងទេ តែលោក នឹងស្រាវជ្រាវ៕ ប៉ែន នួន

### សំណុំរឿងស្ត្រីស៊ីឈ្នួលពរពោះជំនួស: ប៉ូលិសបញ្ជូនមនុស្សចំនួន០៤នាក់ទៅតុលាការ

http://www.rasmeinews.com/ November 12, 2018, 9:48 PM

ដោយ: មុនីរ័ត្ន / ភ្នំពេញ: ជនសង្ស័យចំនួន០៤នាក់ ពាក់ព័ន្ធក្នុងករណីពរពោះជំនួស ត្រូវបានប៉ូលិសការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលរាជធានីភ្នំពេញ បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការសាកសួរ។ នេះបើតាមការបញ្ជាក់របស់លោក ទូច សារ៉េន នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនថ្លែងប្រាប់

ខ្លីៗ នៅរសៀលថ្ងៃទី១២ ខែវិច្ឆិកា នេះ។ លោក ទូច សារ៉េន បានឲ្យដឹងទៀតថា ចំពោះស្ត្រីចំនួន១១ ដែលស៊ីឈ្នួលពរពោះជំនួស គឺកំពុងតែសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយសារតែពួកគាត់មានបញ្ហាសុខភាព។

ចំណែកលោក លី សុផាណា អ្នកនាំពាក្យសាលាដំបូងរាជធានីភ្នំពេញបានឲ្យដឹងថា ចំពោះមនុស្សទាំង០៤នាក់នេះ អយ្យការកំពុងពិនិត្យនិងចាត់ការ ។

ប៉ូលិសប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបង្ក្រាបករណីស្ត្រីស៊ីឈ្នួលពរពោះជំនួស ដោយបានឃាត់ខ្លួនស្ត្រីពរពោះជំនួសចំនួន ១១នាក់ និងមនុស្សប្រុសស្រីចំនួន៤នាក់ផ្សេងទៀត សង្ស័យជាមេខ្យល់។ ដោយការ បង្ក្រាបនេះ បានធ្វើឡើងកាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ គឺបានធ្វើឡើងនៅទីតាំងពីរផ្សេងគ្នា គឺនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ការបង្ក្រាបនេះ បានធ្វើឡើងដោយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

លោក ទូច សារ៉េន នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលរាជធានីភ្នំពេញ បានឲ្យដឹងថា ចំពោះករណីស្ត្រីពរពោះជំនួសទាំង១១នេះ សមត្ថកិច្ចមិនទាន់បញ្ជូនទៅតុលាការនៅឡើយទេ ដោយសារតែការធ្វើនីតិវិធីមិនទាន់បញ្ចប់។ ហើយករណីនេះសមត្ថកិច្ចកំពុងស្រាវជ្រាវរកអ្នកពាក់ព័ន្ធដើម្បីយកមកផ្តន្ទាទោសតាមច្បាប់។

សេចក្តីរាយការណ៍បានឲ្យដឹងថា ការឃាត់ខ្លួនស្ត្រីពរពោះជំនួសនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺខណៈពេលដែលពួកគេបម្រុងនឹងចេញដំណើរទៅក្រៅប្រទេស។ ហើយស្ត្រីពរពោះជំនួសទាំង១១នាក់ សមត្ថកិច្ចបាននាំខ្លួនមកសាកសួរព័ត៌មានដើម្បីបំពេញបែបបទតាមនីតិវិធី ដើម្បីបញ្ជូនទៅតុលាការ។

សូមរម្លឹកថា កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ កន្លងទៅ នៅចំណុចផ្ទះវីឡាលេខ២A ផ្លូវ៣៤៨ និងផ្ទះវីឡាលេខ៩A ផ្លូវ៣៤៨ ស្ថិតនៅក្នុងបុរី វិមានភ្នំពេញ តាមបណ្តោយផ្លូវលេខ៥ ក្នុងសង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ សមត្ថកិច្ចបានឃាត់ខ្លួនស្ត្រីពរពោះជំនួសចំនួន៣២នាក់ និងមេខ្យល់ចំនួន៥នាក់។ ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ក៏បានសម្រេចឃុំខ្លួនមនុស្សចំនួន០៥នាក់ ដែលជាមេការជាប់សង្ស័យក្នុងការប្រព្រឹត្តបទល្មើសលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន ក្នុងនោះមានបុរសជនជាតិចិនម្នាក់ និងនារីខ្មែរចំនួន ០៤នាក់ផងដែរ ដើម្បីរង់ចាំការស៊ើបអង្កេតជាបន្តទៀត។

ជនសង្ស័យទាំង៥នាក់មានដូចជា៖ ១.ឈ្មោះ Tiu Qiang ភេទប្រុស ជនជាតិចិន អាយុ ៤៩ឆ្នាំ ជាមេការ។ ២. ឈ្មោះ ស្វាយ ស៊ីណុច ភេទស្រី អាយុ ៣៤ឆ្នាំ ជាមេការ។ ៣. ឈ្មោះ នឿន ស្រីឡាង ភេទស្រី អាយុ ២៧ឆ្នាំ ជាមេការ។ ៤. ឈ្មោះ លឹម សុភាព ភេទស្រី អាយុ ១៩ឆ្នាំ ជាអ្នកបកប្រែ និង៥. ឈ្មោះ ថៃ ភាព ភេទស្រី អាយុ ៤៣ឆ្នាំ ជាមេការ។ មនុស្សទាំង០៥នាក់នេះ ជាប់សង្ស័យក្នុងការប្រព្រឹត្តបទល្មើសលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន។

បើតាមចម្លើយរបស់នារីពរពោះជំនួសទាំង៣២នាក់ នាពេលកន្លងមក បានឱ្យដឹងថា ក្នុងកូនមួយដែលពួកគេពរពោះជំនួសនេះ ទទួលបានប្រាក់កំរៃចំនួន ១ម៉ឺនដុល្លារ គិតចាប់ពីខែដំបូង ឱ្យចំនួន៥០០ដុល្លារ ខែបន្ទាប់ ៣០០ដុល្លារ រហូតដល់កើត ទើបទទួលបានចំនួន ៦៣ាន់ដុល្លារបន្ថែមទៀត។ ចំពោះការថែទាំគភ៌ ការប្រសូត្រ គឺជាបន្ទុករបស់ក្រុមហ៊ុន។ លក្ខណៈពិសេស នៃការពរពោះជំនួសក្នុងករណីនេះ គឺពេលជិតដល់ត្រូវឆ្លងទន្លេ ប្រសូត្រ គឺក្រុមហ៊ុនបញ្ជូនស្ត្រីពរពោះទៅប្រទេសចិន សម្រាលកូនរួចទើបបញ្ជូនមកស្រុកខ្មែរវិញ ហើយប្រគល់លុយបង្គ្រប់ ១ម៉ឺនដុល្លារ៕ ល

# ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨

## ថៃចាប់បញ្ជូនពលករខ្មែរខុសច្បាប់ដល់ទៅចំនួន២៦,៩៨១នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ម៉ោង ១៥:២៤ ប៊ុន ធឿន

បន្ទាយមានជ័យ ៖ អាជ្ញាធរមានសមត្ថកិច្ចថៃចាប់បញ្ជូនពលករខ្មែរខុសច្បាប់ រយៈពេល១០ខែ ឆ្នាំ២០១៨ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន២៦,៩៨១នាក់ ដោយតាមរបាយការណ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងកិច្ចប្រជុំ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ ។

លោកឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាអិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបានមានប្រសាសន៍ថា ពលករចំណាកចេញទៅប្រទេសក្រៅប្រចាំខែតុលា ឆ្នាំ២០១៨ មានសរុបចំនួន ១,៤៦៩នាក់ ស្រី៦៨៦នាក់ កុមារ៥នាក់ កុមារី២នាក់ បើប្រៀបធៀបខែកញ្ញា ឆ្នាំ២០១៨ មានចំនួន ១,៥៦២នាក់ មានការថយចុះចំនួន៩៣នាក់ ។ ចេញដោយស្របច្បាប់ ៤៤៥នាក់ ស្រី២៥៣នាក់ ចេញមិនស្របច្បាប់១,០២៤នាក់ ស្រី៤៣៣នាក់ កុមារ៥នាក់ កមារី២នាក់ពលរដ្ឋត្រឡប់មកវិញចំនួន១,៤៤៧នាក់ (ស្រី៧១៧នាក់ កុមារ១៨នាក់ កុមារី៤នាក់ ។ លោកបានបញ្ជាក់ថា អាជ្ញាធរមានសមត្ថកិច្ចថៃបានបញ្ជូនពលករខ្មែរខុសច្បាប់តាមច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រយៈពេល១០ខែ ក្នុងឆ្នាំ២០១៨ មានសរុបចំនួន ២៦,៩៨១នាក់ (ស្រី៩,២២៤នាក់) ក្នុងនោះមានកុមារ២,៩៣២នាក់ (កុមារី១,០៣៩នាក់) ។ បើប្រៀបធៀមនិងរយៈពេល១០ខែឆ្នាំ២០១៧ មានចំនួន៦២,៧២៨នាក់ គឺមានការថយចុះចំនួន៣៥,៧៤៧នាក់ ។

លោកស្រី ប៉ុក ណាឌី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្តបានមានប្រសាសន៍ថា ដោយយោងតាមរបាយការណ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ខេត្ត ក្នុងកិច្ចប្រជុំលទ្ធផលប្រចាំខែតុលា ឆ្នាំ២០១៨ និងរយៈពេល១០ខែ ឆ្នាំ២០១៨ ឃើញថា ពលករខ្មែរចេញទៅរកការងារធ្វើខុសច្បាប់ នៅប្រទេសថៃមានការថយចុះ ។ លោកស្រីបានមានប្រសាសន៍ណែនាំ និងដាក់វិធានការដល់មន្ត្រី និងសមត្ថកិច្ចជំនាញ និងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែនមានកម្លាំងនគបាលការពារព្រំដែនគោក និងកម្លាំងយោធាតាមបន្ទាត់ព្រំដែនត្រូវទប់ស្កាត់ពលករចំណាក់ស្រុកខុសច្បាប់ និងអំពើជួញដូរ និងរត់ពន្ធមនុស្សខុសច្បាប់ត្រូវទប់ស្កាត់ឲ្យបាននូវសុវត្ថិភាពបងប្អូនប្រជាពលរដ្ឋ ៕

## សំណុំរឿងស្ត្រីស៊ីឈ្នួលពរពោះជំនួស: ចោទប្រកាន់មនុស្ស១៨នាក់ ពីបទលក់ដូរមនុស្សសម្រាប់ឆ្លងដែន-សមគំនិត

http://www.rasmeinews.com/ November 13, 2018, 4:43 PM

ដោយ: មុនីរ័ត្ន / ភ្នំពេញ: លោកលី សុផាណា អ្នកនាំពាក្យក្សសាលាដំបូងរាជធានីភ្នំពេញ បានប្រាប់រស្មីកម្ពុជានៅរសៀលថ្ងៃទី១៣ ខែវិច្ឆិកា នេះថា ក្រោយពីពិនិត្យនិងចាត់ការសំណុំរឿងចប់សព្វគ្រប់ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានសម្រេចបើកការស៊ើបសួរដោយចោទប្រកាន់ទៅលើជនសង្ស័យចំនួន១៤នាក់ ពីបទលក់ដូរមនុស្សសម្រាប់ឆ្លងដែន និងបទធ្វើអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ តាមមាត្រា១៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងមាត្រា៣៣២ នៃក្រមព្រហ្មទណ្ឌ។ លោកបន្តថា ចំពោះជនសង្ស័យចំនួន ៤ នាក់ ផ្សេងទៀត ចោទប្រកាន់ពីបទសមគំនិតក្នុងអំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន និងធ្វើអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ តាមមាត្រា ១៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស មាត្រា ២៩ និងមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ និងបញ្ជូនជនត្រូវចោទចំនួន១៥ នាក់និងសំណុំរឿងទៅចៅក្រមស៊ើបសួរដើម្បីចាត់ការបន្តតាមនីតិវិធី ។ ជនសង្ស័យទាំង០៤នាក់ មានដូចជា ១.ឈ្មោះ សុខ ឃឿន ២.ឈ្មោះ ខៀវ វណ្ណា ៣.ឈ្មោះ ចេង សំអុល និង៤.

ឈ្មោះ អៀង ម៉ាន់។ អ្នកនាំពាក្យសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថា រឿងនេះមានជនសង្ស័យសរុប១៨នាក់ ដែលចាប់ខ្លួនបាន ១៥នាក់ ហើយគេចខ្លួន ៣នាក់ ។ ជនសង្ស័យចំនួន០៤នាក់ ពាក់ព័ន្ធក្នុងករណីពរពោះជំនួស ត្រូវបានប៉ូលិសការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលរាជធានីភ្នំពេញ បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីឲ្យព្រះរាជអាជ្ញាធរធ្វើការសាកសួរ។

ប៉ូលិសប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបង្ក្រាបករណីស្រ្តីស៊ីឈ្នួលពរពោះជំនួស ដោយបានឃាត់ខ្លួនស្រ្តីពរពោះជំនួសចំនួន ១១នាក់ និងមនុស្សប្រុសស្រីចំនួន៤នាក់ផ្សេងទៀត សង្ស័យជាមេខ្យល់។ ដោយការ បង្ក្រាបនេះ បានធ្វើឡើងកាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ គឺបានធ្វើឡើងនៅទីតាំងពីរផ្សេងគ្នា គឺនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ការបង្ក្រាបនេះ បានធ្វើឡើងដោយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ សេចក្ដីរាយការណ៍បានឲ្យដឹងថា ការឃាត់ខ្លួនស្រ្តីពរពោះជំនួសនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺខណៈពេលដែលពួកគេបម្រុងនឹងចេញដំណើរទៅក្រៅប្រទេស៕ ល

## ពលករនៅប្រទេសថៃ និងសង្គមស៊ីវិលគាំទ្រការរៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្ន សម្រាប់ពលករខ្មែរនៅថៃ

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2018-11-13

សង្គមស៊ីវិលធ្វើការងារទាក់ទងនឹងពលករចំណាកស្រុក និងពលករខ្មែរ ដែលកំពុងធ្វើការងារនៅប្រទេសថៃ គាំទ្រការរៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្នសម្រាប់ពលករខ្មែរនៅថៃ។ ប៉ុន្តែទាមទារឲ្យការរៀបចំការងារនេះប្រកបដោយប្រសិទ្ធិភាព ដើម្បីឆ្លើយតបទៅនឹងចំនួនដ៏ច្រើនលើសលប់នៃពលករខ្មែរដែលមានក្នុងនៅប្រទេសថៃ។ ការរៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្នសម្រាប់ពលករខ្មែរនៅប្រទេសថៃត្រូវបានភាគីពាក់ព័ន្ធ រួមមាន ក្រសួងការងារ សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា (MAC) សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) និងសមាគមទំនាក់ទំនងកម្ពុជា-ថៃ (TCRA) រួមគ្នាផ្ដួចផ្ដើមការរៀបចំនេះ ដើម្បីការពារពលករកម្ពុជា ដែលជួបបញ្ហាការងារនៅព្រះរាជាណាចក្រថៃ។

មន្ត្រីកម្មវិធីសិទ្ធិការងារនៃអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា សង់ត្រាល់ លោក ឌី ថេហូយ៉ា ដែលធ្វើការងារទាក់ទងពលករចំណាកស្រុកយល់ថា នេះជាគំនិតផ្ដួចផ្ដើមមួយដែលរួមចំណែកជួយដល់ពលរខ្មែរដែលធ្វើការនៅប្រទេសថៃ។ ប៉ុន្តែសង្គមស៊ីវិលរូបនេះ ទាមទារឲ្យអ្នកពាក់ព័ន្ធធ្វើការងារនេះឲ្យបានពេញលេញ ដើម្បីឆ្លើយតបទៅនឹងចំនួនពលករខ្មែររាប់សិបម៉ឺននាក់ ដែលកំពុងធ្វើការងារនៅប្រទេសថៃ៖ «» មន្ត្រីសង្គមស៊ីវិលរូបនេះបន្តថា កន្លងមកពលករខ្មែរដែលមានបញ្ហាការងារ ឬខ្វះខាតឯកសារ ធ្លាប់សុំអន្តរាគមន៍ពីស្ថានទូតខ្មែរនៅប្រទេសថៃដែរ ប៉ុន្តែមិនទទួលបានការឆ្លើយតបនោះទេ។

សារព័ត៌មានក្នុងស្រុកបានដកស្រង់សម្ដីរដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង កាលពីថ្ងៃទី៧ ខែវិច្ឆិកា ដោយលោករដ្ឋមន្ត្រីមានបំណងរៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្ននេះ មិនមែនត្រឹមតែជាកន្លែងស្នាក់នៅប៉ុណ្ណោះទេប៉ុន្តែក៏ជាកន្លែងប្រឹក្សាយោបល់សម្រាប់ពលករក្នុងអំឡុងពេល ដែលពួកគេផ្លាស់ប្ដូរការងារ ឬរង់ចាំដំណោះស្រាយវិវាទការងារជាមួយថៅកែ។ លោកបន្តទៀតថា គម្រោងនៃការបង្កើតកន្លែងនេះគឺអាស្រ័យទៅនឹងភូមិសាស្ត្រ និងស្ថាន ភាពជាក់ស្ដែង។

អាស៊ីសេរីអាចសុំការពន្យល់បន្ថែមពីអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ បានទេ នៅថ្ងៃទី១២ ខែវិច្ឆិកា។

ចំណែកពលករខ្មែរម្នាក់ដែលកំពុងធ្វើការងារនៅប្រទេសថៃឲ្យអាស៊ីសេរីដឹងថា សព្វថ្ងៃនេះលោកកំពុងជួបបញ្ហាខ្វះខាតឯកសារការងារ។ ដូច្នេះលោកថា បើកន្លែងប្រឹក្សាការងារហ្នឹងជួយសម្រួលបញ្ហារបស់កម្មករ ជារឿងល្អចំពោះពលករនៅប្រទេសថៃ។ ពលកររូបនេះ ស្នើសុំទៅក្រសួងការងាររៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្ននេះដោយកុំតម្រូវឲ្យពលករបង់លុយ និងមិនត្រូវរើសអើងនិន្នាការនយោបាយ៖ _ការរៀបចំកន្លែងស្នាក់បណ្ដោះអាសន្នសម្រាប់ពលករកម្ពុជានៅថៃរបស់ភាគីពាក់ព័ន្ធនៅពេលនេះបន្ទាប់ពីបានធ្វើការងារនេះជោគជ័យនៅប្រទេសកូរ៉េខាងត្បូង។ មន្ត្រីកម្មវិធីសិទ្ធិការងារនៃអង្គការសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស លោក ឌី ថេហូយ៉ា ចង់ ឃើញអ្នកពាក់ព័ន្ធ ជាពិសេសក្រសួងការងារបង្កើតកន្លែងស្នាក់បណ្ដោះអាសន្នបន្ថែមទៀត ដល់ពលករខ្មែរដែលធ្វើការងារនៅប្រទេសចិន និងម៉ាឡេស៊ី។ លោកបានលើកឡើងថា ពលករធ្វើការងារនៅប្រទេសទាំងពីរនេះមានបញ្ហាស្មុគស្មាញក្នុងការជួយសង្គ្រោះជនដែលរងគ្រោះដោយសារការទៅធ្វើការងារនៅទីនោះ៕

## ស្នងការខេត្តកំពង់ធំដឹកនាំ កិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលការងារអធិការកិច្ចហត្ថពលកម្មបរទេស

http://cambodiapolice.com/policekh/ 8:38 pm 13 វិច្ឆិកា 2018

**កំពង់ធំ៖**នៅថ្ងៃអង្គារ៍ ៦កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័កព.ស២៥៦២ ត្រូវនិងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ លោកឧត្តមសេនីយ៍ទោ អ៊ុក កុសល ស្នងការនគរបាលខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលការងារអធិការកិច្ចហត្ថពលកម្មបរទេស នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ។ សមាសភាពអញ្ជើញចូលរួម លោកស្នងការរង លោកនាយលោកស្រីនាយរងការិយាល័យ លោកអធិការរង នាយ នាយរងផ្នែកមន្ត្រីនគរបាលចំណុះអោយផែនការងារអន្តោប្រវេសន៍ ចូលរួមប្រមាណ ២៩ នាក់ ស្រី ០១នាក់។

លោកវរសេនីយ៍ឯក គឹម យន នាយការិយាល័យគ្រប់គ្រងជនបរទេស បានផ្សព្វផ្សាយសេចក្ដីណែនាំលេខ ០០៩ សណន របស់ក្រសួងមហាផ្ទៃ ស្ដីពី ការគ្រប់គ្រងវត្តមានជនបរទេស ក្នុងព្រះរាជាណាចក្រកម្ពុជា និងបានអានរបាយការណ៍ លទ្ធផលបញ្ចប់ការងារអធិការកិច្ចហត្ថពលកម្មជនបរទេស នៃក្រុមចម្រុះអធិការកិច្ចហត្ថពលកម្មជនបរទេស ដោយចាប់ផ្ដើមដំណើរការងាររបស់ខ្លួនចាប់ពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨ ក្នុងខេត្តកំពង់ធំ ដោយក្រុមការងារចម្រុះចុះត្រួតពិនិត្យ ចំនួន ៥០ គោលដៅ -ប្រើប្រាស់ពលករខ្មែរសរុបចំនួន ៥៧២៤ នាក់ស្រី ២០៤៣នាក់។

ប្រើប្រាស់ពលករបរទេសសរុបចំនួន ៥៥៩ នាក់ស្រី ៩០ នាក់មាន១៥សញ្ជាតិ ក្នុងនោះមានប័ណ្ណការងារ និងសៀវភៅចំនួន ៥៣៤ នាក់,ប្រើប្រាស់ទិដ្ឋាការB.Cចំនួន ២២ នាក់,មានបង្កាន់ដៃចំនួន ០១ នាក់,គ្មានប័ណ្ណសៀវភៅចំនួន ០២ នាក់,ធ្វើការផាកពិន័យជាទឹកប្រាក់សរុបចំនួន ១.០០០.០០០រៀល។_លោកវរសេនីយ៍ឯក គឹម យន ជំរុញអនុវត្ត បន្តអនុក្រឹត្យលេខ១២៩ អនុក្រ.បក រហូតដល់បំណាច់ឆ្នាំ២០១៨។

លោកឧត្តមសេនីយ៍ទោ អ៊ុក កុសល ស្នងការនគរបាលខេត្តកំពង់ធំ មានប្រសាសន៍ បូកសរុបផ្ដាំផ្ញើ លើកសរសើរដល់កងកម្លាំងចំណុះអោយផែនការងារ អន្តោប្រវេសន៍ ដែលមានការសាមគ្គីភាព ឯកភាពផ្ទៃក្នុង បានល្អផ្ដើមចេញពី គោរពវិន័យ តួនាទី ភារកិច្ច ក្រមសីលធម៌ វិជ្ជាជីវៈនគរបាលជាតិ ព្រមទាំងចូលរួមចំណាយថវិកាកសាង ជួសជុលការិយាល័យ និសម្ភារបច្ចេកទេស សម្រាប់បំរើជំនាញ ក្នុងអង្គភាពរបស់ខ្លួន។ ទន្ទឹមនោះដែរ ត្រូវបន្តពង្រឹងការសាមគ្គីភាពឯកភាពផ្ទៃក្នុង ខាងលើនេះអោយបានរឹងមាំជានិរន្តរ៍ ដើម្បីបន្តចូលរួមបំពេញ កិច្ចការជំនាញបានជោគជ័យ ក៏ដូចជាការកសាងអង្គភាព មានការរីចម្រើនអភិវឌ្ឍបន្ថែមទៀត ។_លោកឧត្តមសេនីយ៍ទោ អ៊ុក កុសល ស្នងការនគរបាលខេត្ត មានប្រសាសន៍ ណែនាំពង្រឹងសមត្ថភាពជំនាញ វិធានជំនាញ របៀបរបបការងារជំនាញ ជាពិសេសការអនុវត្តបែបបទការងារផ្នែករដ្ឋបាលពង្រឹងគ្រប់គ្រងកងកម្លាំងក្រោមឱវាទ របស់ខ្លួន

ត្រួតពិនិត្យបញ្ជីវត្តមាន (វត្តមាន-អវត្តមាន)ជាប្រចាំថ្ងៃអោយបានច្បាស់លាស់ដើម្បីរកអោយឃើញមន្ត្រី ដែលសកម្មនិងអសកម្មព្រមទាំងមូលហេតុដែលធ្វើអោយមន្ត្រីនោះអសកម្ម ហេតុដែលធ្វើអោយមន្ត្រីនោះអសកម្ម ត្រូវមានវិធានការដាក់វិន័យទៅតាមលក្ខន្តិកៈរបស់មន្ត្រីនគរបាលជាតិ ព្រមទាំងផ្តល់ជានិតិវិធី បទពិសោធន៍ មួយចំនួនដល់អស់លោក លោកស្រី ដែលទទួលការងារជំនាញចំណុះផ្នែកការងារជំនាញនីមួយៗយកទៅអនុវត្តក្នុងកិច្ចការងាររបស់ខ្លួនសម្រេចបានជោគជ័យគ្រប់ភារកិច្ច៕

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សខេត្តព្រះសីហនុ បើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារ១០ខែ ដើមឆ្នាំ២០១៨

http://akp.gov.kh/kh/ AKP ព្រះសីហនុ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុ បើកកិច្ចប្រជុំ បូកសរុបលទ្ធផលការងាររយៈពេល១០ខែ ដើមឆ្នាំ២០១៨ នៅព្រឹកថ្ងៃព្រហស្បតិ៍ ១កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីតាមដាន ត្រួតពិនិត្យរាល់សកម្មភាពជួញដូរមនុស្ស និងការរំលោភបំពាន ការបៀតបៀនកេរ្តិ៍ខ្មាស សេវាកម្មបម្រើផ្លូវភេទនៅខេត្តព្រះសីហនុ ក្រោមអធិបតីភាពលោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ។

លោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ បានមានប្រសាសន៍ថា គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុ បានខិតខំបំពេញការងារ បង្ការទប់ស្កាត់ និងផ្សព្វផ្សាយការបង្ក្រាបការជួញដូរមនុស្ស និងផ្តល់ការអប់រំដល់ប្រជាពល រដ្ឋនៅតាមសហគមន៍ និងចុះបង្ក្រាបមុខ សញ្ញានៅតាមគោលដៅដោយសហការជា មួយកម្លាំងសមត្ថកិច្ច តាមដានផ្ទះម៉ា ហ្សា កោសជប់ ខារ៉ាអូខេ ក្នុងក្រុងព្រះ សីហនុ និងសហការជាមួយអង្គការដៃគូ តាមដានសកម្មភាពជនបរទេសដែលរស់ នៅ និងប្រកបអាជីវកម្មក្នុងខេត្តព្រះសីហនុ។ ក្រុមការងារក៏បានផ្សព្វផ្សាយ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាពបានចំនួន៥៥លើក មានប្រជាពលរដ្ឋចូលរួម ៥៩១នាក់ ជួយសង្គ្រោះជនរងគ្រោះបានចំនួន ២១លើក ក្នុងនោះជន រងគ្រោះ ៤២នាក់ ជនជាតិចិន ២៤នាក់ ៣នាក់ ជាអនីតិជន។ បញ្ជូនសំណុំរឿងទៅសាលាដំបូងខេត្តព្រះសីហនុ ២១ករណី ស្មើ ៣១មុខសញ្ញា ជនជាតិ ចិន ១៣មុខសញ្ញា។ លោកស្រីបានបន្តថា ទោះបីការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស យ៉ាងណាក៏ដោយ នៅមានចំណុចប្រឈម មួយចុះនួននៅតាមមូលដ្ឋាន ដូចជាប្រជាពលរដ្ឋមិនបានអប់រំកូនចៅការពារករណីចាញ់ បោកការជួញដូរផ្លូវភេទ និងការធ្វើចំណាកស្រុកជាដើម។ ទិសដៅខាងមុខក្រុមការងារបន្តអនុវត្តន៍ស្រាវជ្រាវមុខសញ្ញាជនសង្ស័យតាមសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ក្លឹបកម្សាន្តរាត្រី កាស៊ីណូរៀបចំបណ្តាញស៊ើបការណ៍នៅតាមច្រក បន្តគ្រប់គ្រងមុខសញ្ញាប្រកបអាជីវកម្មផ្លូវភេទ និងការជួញដូរមនុស្សទាំងក្នុងស្រុក និងឆ្លងដែនទៅក្រៅប្រទេសបង្កើនការងារបង្ក្រាបបទល្មើស ជួញដូរមនុស្ស និងការពារអនីតិជនឱ្យកាន់តែល្អប្រសើរបន្ថែមទៀត ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងពីអាជ្ញាធរមូលដ្ឋាន៕ ដោយ ងូ សុមុនី

## ក្រសួងសង្គមកិច្ច ចុះ MoU ជាមួយអង្គការធំៗចំនួន៣ ក្នុងទំហំទឹកប្រាក់ជាង២លានដុល្លារ សម្រាប់គម្រោង៣ឆ្នាំ ជួយដល់កុមារ ស្ត្រីរងគ្រោះ និងងាយរងគ្រោះនៅកម្ពុជា

http://www.freshnewsasia.com/ ថ្ងៃទី ១៣ វិច្ឆិកា ២០១៨

(ភ្នំពេញ)៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ បានចុះកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការធំៗចំនួន៣ ក្នុងទំហំទឹកប្រាក់ជាង២លានដុល្លារ សម្រាប់គម្រោង៣ឆ្នាំ ជួយដល់កុមារនិងស្ត្រីរងគ្រោះ និងងាយរងគ្រោះនៅកម្ពុជាទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត។ អង្គការចំនួន៣ ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច នាព្រឹកមិញនេះ រួមមាន៖ អង្គការហ្វូលច័ដើម្បីសុខុមាលភាព ដោយមានគម្រោងថវិកាចំនួន៣៦ម៉ឺនដុល្លារ សម្រាប់រយៈពេល៣ឆ្នាំ, អង្គការពន្លឺកម្ពុជា ដោយមានគម្រោងថវិកាចំនួន៧៩១,១៦៨ដុល្លារ សម្រាប់រយៈពេល៣ឆ្នាំ និងអង្គការជំហានដំបូងកម្ពុជា មានគម្រោងថវិកាចំនួន៨៥៨, ៨៣១ដុល្លារ សម្រាប់រយៈពេល៣ឆ្នាំ។ ពិធីចុះហត្ថលេខានេះមានការចូលរួមពី លោក ហាច ហ៊ាន អនុរដ្ឋលេខាធិការតំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, មន្ត្រីពាក់ព័ន្ធរបស់ក្រសួង រួមនឹងតំណាងរបស់អង្គការទាំង៣ និងមន្ត្រី-ក្រុមការងារនៅតាមបណ្តាខេត្តជាច្រើនរូបទៀត។

លោក ហាច ហ៊ាន បានស្នើឲ្យក្រុមការងារក្រសួង និងអង្គការ ដែលសហការនាពេលនេះរួមគ្នា ដើម្បីធ្វើការងារជួយដល់ការអប់រំ ការសិក្សា និងអភិវឌ្ឍន៍កុមារងាយរងគ្រោះនៅកម្ពុជា ដាច់ស្រយាល និងជួយដល់ កុមារកំព្រា កុមារក្រីក្រ និងកុមារដែលរងគ្រោះ ដោយសារអំពើហិង្សា។ សម្រាប់ក្រសួងសង្គមកិច្ចវិញ នៅតែស្វាគមន៍ជានិច្ច ជាមួយ ដៃគូពាក់ព័ន្ធ និងអង្គការនានា ដើម្បីជួយដល់ជនរងគ្រោះនៅកម្ពុជា ឲ្យមានជីវភាព និងជីវិតរស់នៅ ល្អប្រសើរថែមមួយកម្រិត ទៀត។ អនុរដ្ឋលេខាធិការរូបនេះ បានលើកឡើងថា ការចុះហត្ថលេខា ជាមួយអង្គការចំនួន៣នេះ គោលដៅសំខាន់ គឺផ្តោតលើការងារជួយឧបត្ថម្ភផ្នែកអប់រំសុខុមាលភាព និងជីវភាពរស់នៅរបស់កុមារ ជនរងគ្រោះ និងជនងាយរងគ្រោះ។ លោកបានស្នើឲ្យក្រុមការងារទាំងអស់ធ្វើការងារនេះ ដោយភាពស្មោះត្រង់ ដើម្បីជួយដល់សង្គមកម្ពុជា ឲ្យកាន់តែល្អប្រសើរឡើង។ ជាមួយគ្នានោះ លោកបានស្នើដល់អង្គការទាំង៣នេះ ត្រូវប្រើប្រាស់ថវិកាទាំងនេះឲ្យចំទិសដៅដល់ជនរងគ្រោះ និងងាយរងគ្រោះផ្ទាល់ ឲ្យបានច្រើនជាងការចំណាយផ្នែករដ្ឋបាល។ លោកបានស្នើដល់អង្គការទាំង៣នេះ អនុវត្តគោរពទៅតាមការចុះកិច្ចព្រមព្រៀង មានភាពស្មោះត្រង់ក្នុងការជួយសង្គមកម្ពុជាយ៉ាងពិតប្រាកដ។

ជាការឆ្លើយតបតំណាងអង្គការទាំង៣ ដែលបានចុះ MoU ជាមួយក្រសួងសង្គមកិច្ច នាពេលនេះ បានសម្តែងការត្រេកអរ និងរីករាយដែលបានសហការជួយដល់កុមារ និងស្ត្រីរងគ្រោះ និងាយរងគ្រោះនៅកម្ពុជា តាមរយៈការចុះកិច្ចព្រមព្រៀងនាពេលនេះ។ អង្គការទាំង៣ រំពឹងថា នឹងបន្តការសហការ ជាមួយក្រសួងឲ្យបានល្អបំផុតតាមដែលអាចធ្វើបាន ហើយនឹងយកថវិកាទាំងនោះ ទៅប្រើប្រាស់ឲ្យមានប្រសិទ្ធភាពបំផុត៕

## ស្ថានទូតខ្មែរនៅកូរ៉េ និងចុះផ្តល់សេវាពន្យាសុពលភាព លិខិតឆ្លងដែនដោយឥតគិតថ្លៃ នៅថ្ងៃទី២៥ វិច្ឆិកា នៅទីក្រុងអ៊ុយចងប៊ូ

https://www.dap-news.com/ ByID:114 Posted on 14 November 2018 | 10:18

ភ្នំពេញ៖ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េមានកិត្តិយសសូមជម្រាបជូនដំណឹង ដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលកំពុងរស់នៅ សិក្សា និងធ្វើការ នៅសាធារណរដ្ឋកូរ៉េឱ្យបានជ្រាបថា ក្នុងគោលបំណងចូលរួមកាត់បន្ថយចំណាយ និងពេលវេលារបស់បងប្អូន ព្រមទាំងដើម្បីអនុវត្តយន្តការបង្វិតសេវា ឱ្យគៀកជិតប្រជាពលរដ្ឋខ្មែរ កាន់តែទូលំទូលាយ និងដោយមានការស្នើសុំ ពីថ្នាក់ដឹកនាំរបស់ធនាគារ Shinhan Bank ស្ថានឯកអគ្គ

រាជទូតកម្ពុជា នឹងចុះផ្តល់សេវាពន្យាសុពលភាព លិខិតឆ្លងដែនដោយឥតគិតថ្លៃ ប្រឹក្សាយោបល់ផ្នែកច្បាប់ការងារ និងផ្សព្វផ្សាយកម្មវិធីវិលត្រឡប់វិញ ក្រោយចប់អាណត្តិការងារ នៅថ្ងៃអាទិត្យទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៨ នៅទីក្រុងអ៊ីយចងប៊ូ អគារធនាគារ Shinhan Bank ជាន់ទី៤ ដែលមានអាសយដ្ឋាន경기도 의정부시 행복로8길 의정부동 176-4 (ស្ថានីយរថភ្លើង 의정부 ច្រកចេញលេខ ៥-៣) ចាប់ពីម៉ោង ១៣:០០ ដល់ម៉ោង ១៧:០០ រសៀល។_អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ អញ្ជើញមកទទួលសេវា នេះឱ្យបានច្រើនកុះករ និងសូមចូលរួមផ្សព្វផ្សាយព័ត៌មាន ឱ្យបានទូលំទូលាយ៕

## ថ្ងៃទី១៤ខែវិច្ឆិកា ឆ្នាំ២០១៨

### ឯកអគ្គរដ្ឋទូតបានអរគុណលោកឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង

https://www.facebook.com/us.embassy.phnom.penh/ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៨

នៅក្នុងពេលចូលជំរាបលាថ្ងៃនេះ លោកឯកអគ្គរដ្ឋទូតបានអរគុណលោកឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង ចំពោះកិច្ចសហប្រតិបត្តិការ និងភាពជាអ្នកដឹកនាំលើបញ្ហានានាជាច្រើនទាក់ទងនឹងសន្តិសុខ និងការអនុវត្តច្បាប់ ដោយរួមទាំងការស្វែងរក និងការបញ្ជូនត្រឡប់វិញ នូវជនជាតិអាមេរិកគេចខ្លួន ការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ការជួញដូរមនុស្ស និងការបង្កើនការខិតខំក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរសត្វព្រៃ និងគ្រឿងញៀន។ លោកឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណចំពោះការខិតខំរបស់លោករដ្ឋមន្ត្រីក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការលើការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋកម្ពុជាពីសហរដ្ឋអាមេរិក។ លោកថែមទាំងបានស្វាគមន៍ជំហានក្នុងពេលថ្មីៗនេះ របស់រដ្ឋាភិបាល ដោយរួមមានដំណើរការឡើងវិញនូវការធ្វើសហប្រតិបត្តិការទាក់ទងនឹងឈ្លើយសឹក និងទាហានបាត់ខ្លួន ហើយបានកត់សំគាល់ថា រយៈពេលប៉ុន្មានខែខាងមុខ នឹងមានសារៈសំខាន់សម្រាប់តម្រង់ទិសនៃទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា។ នៅក្នុងបរិបទនេះ លោកឯកអគ្គរដ្ឋទូតបានសុំអោយរដ្ឋាភិបាលអនុវត្តនូវវិធានការបន្ថែមទៀត នៅក្នុងការជំរុញការផ្សះផ្សាជាតិ និងបើកឡើងវិញនូវលំហនយោបាយ។

In a farewell call today, the Ambassador thanked Deputy Prime Minister and Minister of the Interior Sar Kheng for his cooperation and leadership on a broad range of security and law enforcement matters, including locating and returning U.S. fugitives, combatting child sex tourism and human trafficking and intensifying efforts against wildlife and drug trafficking. The Ambassador expressed appreciation for the Minister's efforts to improve cooperation on the repatriation of Cambodian citizens from the United States. He also welcomed recent steps taken by the government, including the resumption of POW-MIA cooperation, and noted that the next few months will be important for the direction of the U.S. – Cambodia relationship. In that context, he urged the government to take additional steps to promote national reconciliation and re-open the political space.

# ទូតអាមេរិក ចប់អាណត្តិ ស្នើឲ្យរដ្ឋាភិបាល អាមេរិក ពិចារណាដកការ ដាក់ទណ្ឌកម្ម ទិដ្ឋាការពីមន្ត្រីរដ្ឋាភិបាល កម្ពុជា

https://www.dap-news.com/ ByID:030 Posted on 14 November 2018 | 20:55

ភ្នំពេញ ៖ លោក William A. Heidt ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចប់អាណត្តិប្រចាំកម្ពុជា បានស្នើឲ្យរដ្ឋាភិបាល សហរដ្ឋ អាមេរិក ពិចារណាដកការ ដាក់ទណ្ឌកម្មទិដ្ឋាការ (Visa) ពីមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មួយចំនួន ដើម្បីបន្តពង្រឹងនូវកិច្ចសហប្រតិបត្តិការនៃប្រទេស ទាំងពីរ ។នេះបើ យោងតាមការចេញផ្សាយរបស់ អគ្គស្នងការដ្ឋាននគរបាលជាតិ។ នេះជាការថ្លែងរបស់ លោក ផាត សុផានិត អ្នកនាំពាក្យរងក្រសួង មហាផ្ទៃ ប្រាប់ក្រុមអ្នកសារព័ត៌មាន ក្រោយបញ្ចប់ជំនួប សម្តែងការគួរសម របស់លោក William A. Heidt ជាមួយសម្តេចក្រឡាហោម ស ខេង នាយករដ្ឋមន្ត្រីស្តីទី នារសៀលថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ នៅទីស្តីការ ក្រសួងមហាផ្ទៃ ។ លោក ផាត សុផានិត អ្នកនាំពាក្យរងក្រសួងមហាផ្ទៃ បានប្រាប់ក្រុមអ្នកសារព័ត៌មាន ក្រោយបញ្ចប់ជំនួបនេះយ៉ាងដូច្នេះថា "ក្នុងនាមឯកឧត្តមផ្ទាល់ខ្លួន បានស្នើយោបល់គួរឲ្យសហរដ្ឋអាមេរិក អាចពិនិត្យលទ្ធភាពសម្រួល ឬដកចេញនូវទណ្ឌកម្ម Visa ដែលបានដាក់មកលើមន្ត្រីរបស់ កម្ពុជាមួយចំនួន ។ ទោះបីជាមកដល់ពេលនេះ ឯកឧត្តម មិនទាន់ទទួលបានការឆ្លើយ តបយ៉ាងណាពីខាងអន្តោប្រវេសន៍សហរដ្ឋអាមេរិក ប៉ុន្តែឯកឧត្តម នឹងបន្តយកបញ្ហានេះទៅជជែកជាមួយសហរដ្ឋអាមេរិកទៀត នៅពេលឯកឧត្តមទៅកាន់សហរដ្ឋអាមេរិកវិញ"។

ជាការឆ្លើយតប សម្តេចក្រឡាហោម ស ខេង ក៏បានសម្តែងនូវការអរគុណចំពោះឯកអគ្គរាជទូត ដែលបានស្នើឲ្យមានពិចារណាដើម្បីដកការដាក់ទណ្ឌកម្មនេះ ហើយប្រសិនបើអាមេរិកលុបចោលនូវបំរាមនោះបាន សម្តេចចាត់ទុកថា នេះជាការផ្តល់កាដូមួយសម្រាប់កម្ពុជា ដើម្បីលើកកម្ពស់នូវទំនាក់ទំនង កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។

បន្ថែមពីនេះ លោក William A. Heidt ក៏បានថ្លែងអំណរគុណដល់សម្តេចក្រឡាហោម ស ខេង ដែលបានពូនជ្រុំនូវកិច្ចសហប្រតិបត្តិការរវាងកងកម្លាំងអនុវត្តច្បាប់ នៃប្រទេសទាំងពីរ ពិសេសក្រសួងមហាផ្ទៃ ជាមួយកងកម្លាំងអនុវត្តច្បាប់នៅសហរដ្ឋអាមេរិក លើការងារប្រឆាំងការជួញដូរមនុស្ស, ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការងារថែរក្សាសន្តិសុខយ៉ាងល្អប្រសើរជូនបុគ្គលិកស្ថានទូតអាមេរិកនៅកម្ពុជា ។

សូមរំលឹកថា សហរដ្ឋអាមេរិក បានផ្អាកការផ្តល់ទិដ្ឋាការ (Visa) ប្រភេទ B1 និង B2 (ប្រភេទទេសចរណ៍ និងជំនួញ) ដល់មន្ត្រីក្រសួងការបរទេសកម្ពុជា ចាប់តាំងពីថ្នាក់អគ្គនាយករហូតដល់ថ្នាក់កំពូល ហើយសម្តេចតេជោ ហ៊ុន សែន ក៏សម្រេចផ្អាកជាបណ្តោះអាសន្ន នូវកិច្ចសហប្រតិបត្តិការរុករកអដ្ឋិធាតុទាហានអាមេរិកនៅកម្ពុជាវិញផងដែរ ។

ថ្មីៗនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានប្រកាសតាមលិខិតឆ្លើយតបថា រាជរដ្ឋាភិបាលកម្ពុជា បានយល់ព្រមបើកឡើងវិញនូវប្រតិបត្តិការរុករក អដ្ឋិធាតុទាហានអាមេរិក នៅក្នុងប្រទេសកម្ពុជា ។ នេះបើយោងតាមលិខិតរបស់សម្តេចតេជោ ហ៊ុន សែន ផ្ញើជូន និងឆ្លើយតបជាមួយសំណើរបស់សមាជិកព្រឹទ្ធសភា រដ្ឋវ៉ាស៊ីនតោន សហរដ្ឋអាមេរិកលោក ដុក អេរិកសុន (Doug Ericksen) និងតំណាងរាស្ត្រ ឯកឧត្តម វីនសុន បាយ្ស (Vicent Buys) ៕

ដោយ ៖ អេង ប៊ូឆេង

## ស្ត្រីជនជាតិអូស្ត្រាលីមានទោសករណីពពោះជំនួសត្រូវបានដោះលែងខណៈអាជីវកម្មនេះកក្រើកជាថ្មី

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី_2018-11-14

មន្ត្រីពន្ធនាគារ បានអោយដឹងនៅថ្ងៃទី១៣ វិច្ឆិកា ថា ស្ត្រីគ្រូពេទ្យជនជាតិអូស្ត្រាលីឈ្មោះ ថាំមី ដាវីស ឆាលេស (Tammy Davis- Charles) ដែលត្រូវបានអាជ្ញាធរចាប់ខ្លួនកាលពីខែវិច្ឆិកា ឆ្នាំ២០១៦_ពីបទធ្វើអាជីវកម្មពពោះជំនួស សម្រាប់អតិថិជនជនជាតិអូស្ត្រាលី ត្រូវបានដោះលែង_កាលពីថ្ងៃទី២២ ខែឧសភាកន្លងទៅ។

ការដោះលែងនេះ ស្របពេលដែល អាជីវកម្មពពោះជំនួសនៅក្នុងប្រទេសកម្ពុជាបានកក្រើកជាថ្មីម្តងទៀត ខណៈអាជ្ញាធរកម្ពុជានាពេលថ្មីៗ នេះបានចាប់ស្ត្រីកម្ពុជាដែលមានផ្ទៃពោះចំនួន ៤៣នាក់ ដែលកំពុងពពោះជំនួសអោយអតិថិជនមកពីប្រទេសចិន។_តាមសារព័ត៌មាន The Guardian ផ្សាយនៅថ្ងៃទី១៤ វិច្ឆិកានេះថា ការដោះលែងស្ត្រីគ្រូពេទ្យជនជាតិអូស្ត្រាលីរូបនេះ មិនត្រូវគេប្រកាសជាសាធារណៈនោះឡើយ ហើយស្ត្រីរូបនេះក៏មិនដែលបាននិយាយអ្វីជាមួយអ្នកកាសែតទេ ចំពោះការជាប់ពន្ធនាគារព្រៃសរបស់អ្នកស្រី។ ស្ត្រីរូបនេះ ត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារចំនួន ១ឆ្នាំកន្លះ កាលពីខែសីហា_ឆ្នាំ២០១៦កន្លងទៅ ពីបទចោទថាបានក្លែងក្លាយឯកសារផ្សេងៗដូចជាសំបុត្រកំណើតទារកដែលកើតចេញពីពីការពពោះនោះ៕

## ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាន ក្រសួងសង្គមកិច្ច ក៏នៅមានបញ្ហាប្រឈមជាច្រើន ដែលទាមទារ ឲ្យរួមគ្នាបន្តខិតខំរិះរកដំណោះស្រាយ

http://www.cen.com.kh/archives/ November 15, 2018

ភ្នំពេញ ៖ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ជម្រាបជូនរដ្ឋសភា អំពីសមិទ្ធិផលនានារបស់ក្រសួងសម្រេចបានក្នុងអាណត្តិទី៥។ លោក វង សូត បានលើកឡើងផងដែរថា ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបាន ក្រសួងក៏នៅមានបញ្ហាប្រឈមជាច្រើនទៀត ដែលទាមទារឲ្យយើងរួមគ្នាបន្តខិតខំរិះរកដំណោះស្រាយ ដូចជាបញ្ហាការប្រែប្រួលអាកាសធាតុ ការផ្ទុះចេញនូវជំងឺប្លែកៗ បញ្ហាចំណាកស្រុក បញ្ហាជនអនាថា ការជួញដូរមនុស្ស ជួញដូរពលកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ ការប្រើប្រាស់គ្រឿងញៀន និងបម្រែបម្រួលផ្នែកប្រជាសាស្ត្រជាដើម។

គណៈប្រតិភូរដ្ឋសភាដឹកនាំដោយ លោកស្រី ឡោក ខេង ប្រធានគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងវិស័យទទួលបន្ទុករបស់គណៈកម្មការ នាព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅទីស្តីការក្រសួង។

លោក វង សូត បានជម្រាបជូនគណៈប្រតិភូរដ្ឋសភាថា ក្នុងអាណត្តិទី៥កន្លងមកនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសម្រេចបានលទ្ធផលការងារជាច្រើន ស្របទៅនឹងផែនការយុទ្ធសាស្ត្រ៣យ៉ាង និងកម្មវិធីអាទិភាព៨ចំនុចរបស់ក្រសួង។ យុទ្ធសាស្ត្រទាំង៣ រួមមាន ១-បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២-ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម ៣-ពង្រឹងសមត្ថភាពស្ថាប័ន និងកៀងគរប្រភពធនធាន ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ ចំណែកឯកម្មវិធីអាទិភាពទាំង៨ចំណុចរបស់ក្រសួងវិញមាន ១-អភិវឌ្ឍន៍សុខុមាលភាពសម្រាប់ជនរងគ្រោះ ជនងាយរងគ្រោះ និងកិច្ចការគ្រួសារ ២-អភិវឌ្ឍន៍សុខុមាលភាពកុមារ និងយុវនីតិសម្បទា ៣-អភិវឌ្ឍន៍សុខុមាលភាពជនពិការ ៤-អភិវឌ្ឍន៍ សុខុមាលភាពចាស់ជរា ៥-អភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៦-អភិវឌ្ឍន៍សុខុមាលភាពអតីតយុទ្ធជន ៧-សិក្សាស្រាវជ្រាវ បង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា ៨-អភិឌ្ឍន៍សមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ។

លោក រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ផងដែរថា ថ្មីៗនេះក្រសួងបានសហការជាមួយអង្គការ UNICEF រៀបចំសន្និសីទថ្នាក់តំបន់ ឆ្ពោះទៅរកការអនុវត្តយុទ្ធសាស្ត្រអ៊ិនស្ពៃ (INSPIRE) ចំនួន៧ ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ដែលមានការចូលរួមពី ប្រទេសចំនួន២១ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ សន្និសីទបានចាត់ទុកប្រទេសកម្ពុជាជាប្រទេសឈានមុខគេ ដែលបានសិក្សាស្រាវជ្រាវថ្នាក់ជាតិ ស្តីពីអំពើហិង្សាលើកុមារ និងមានផែនការសកម្មភាពដើម្បីទប់ស្កាត់ ក៏ដូចជាឆ្លើយតបចំពោះអំពើហិង្សាលើកុមាររយៈពេល៥ឆ្នាំ (២០១៧-២០២១) មុនគេ ។ លោក រដ្ឋមន្ត្រី បន្តថា កន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលបានប្រកាសដាក់អោយអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយ សង្គមសេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ។

លោកស្រី ឡោក ខេង ប្រធានគណៈកម្មការទី៨នៃរដ្ឋសភា បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងនៅគ្រប់កាលៈទេសៈ ដើម្បី អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ទៅតាមផែនការ និងគោលនយបាយរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ លោកស្រី ប្រធានគណៈកម្មការបានសម្តែងក្តីសង្ឃឹមថា ក្រសួងនឹងបន្តនូវកិច្ចសហប្រតិបត្តិការដ៏ល្អនេះ ដើម្បីរួមគ្នាធ្វើយ៉ាងណា អោយការអនុវត្តយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ ទទួលបានជោគជ័យ៕ ដោយ ៖ បញ្ញាស័ក្តិ

## ប៉ូលិសបញ្ជូនស្ត្រីស៊ីឈ្នួលពរពោះជំនួស ទៅតុលាការ ព្រឹកនេះ

http://kleykley.sabay.com.kh/ ថ្ងៃទី 15 វិច្ឆិកា 2018 ម៉ោង 10:42

ប៉ូលិសបានបញ្ជូនស្ត្រីស៊ីឈ្នួលពរពោះជំនួសចំនួន ១១នាក់ ទៅសាលាដំបូងរាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការសាកសួរ។ នេះបើតាមការបញ្ជាក់របស់លោក កែវ ធា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលរាជធានីភ្នំពេញ។

សូមរំលឹកថា កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ត្រីពរពោះជំនួសទាំង១១នាក់ និងមនុស្សប្រុសស្រីចំនួន ៤នាក់ផ្សេងទៀត ដែលជាមេខ្យល់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ការឃាត់ខ្លួននេះ ធ្វើឡើងនៅទីតាំងពីរផ្សេងគ្នា គឺនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅក្នុងខណ្ឌសែនសុខ។ ការឃាត់ខ្លួនស្ត្រីពរពោះជំនួសនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺខណៈដែលពួកគេបម្រុងនឹងចេញដំណើរទៅក្រៅប្រទេស ដើម្បីសម្រាលកូន។ ចំណែកជនសង្ស័យចំនួន ០៤នាក់ ដែលជាមេខ្យល់ត្រូវបានប៉ូលិសការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨៕ អត្ថបទ៖ សោភា

## នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ជួបពិភាក្សាការងារជាមួយមន្ត្រីFBI

http://cambodiapolice.com/ 1:49 pm 15 វិច្ឆិកា 2018

**ភ្នំពេញ ៖** ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិតនេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតទទួលជួបពិភាក្សាការងារជាមួយ លោកចន ឌី. វៀលសុន (Jonh D. Wilson) ដែលជាអនុព័ន្ធផ្នែកច្បាប់តំណាងការិយាល័យស៊ើបអង្កេតសហព័ន្ធ អេហ្វប៊ីអាយអាមេរិក (FBI) ។ ជំនួបនេះ បានធ្វើនៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានការអញ្ជើញចូលរួមពីមន្ត្រីនគរបាលកម្ពុជានិង មន្ត្រីអាមេរិកមួយចំនួនទៀតដែលជាប់ពាក់ព័ន្ធ ។

ជំនួយការអគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានសេនាធិការ ឯកឧត្តម ឧត្តមសេនីយ៍ឯក ពៅ សាលីដេត បានប្រាប់សារព័ត៌មាននគរបាលជាតិ ថាជំនួបគ្នានេះ បានផ្តោតលើកគម្រោងចុះហត្ថលេខាលើអនុស្សារណៈ

រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ ជាមួយនឹងការិយាល័យ FBI ។ ជំនួយការអគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានសេនាធិការ បានបញ្ជាក់ថា អនុស្សារណៈដែលគ្រោងចុះហត្ថលេខានោះ គឺជាគម្រោង « **ស៊ើបអង្កេតរួមគ្នាមួយដែលនឹងធ្វើរវាងអគ្គស្នងការដ្ឋាននគរបាលជាតិ ជាមួយនឹង FBI និងក៏មានការចូលរួមជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ផងដែរ** » ។ លោកបន្តថា ស្ថាប័នទាំង ៣នេះ នឹងសហការគ្នា តាមរយៈអនុស្សារណៈនេះ ដើម្បីទប់ស្កាត់ទៅលើឧក្រិដ្ឋកម្មផ្សេងៗ ដូចជាទប់ស្កាត់បញ្ហា ជួញដូរគ្រឿងញៀន ការជួញដូរមនុស្សខុសច្បាប់ ឧក្រិដ្ឋកម្មឆ្លងដែន និងបទឧក្រិដ្ឋនានាដើម្បីពង្រឹងសន្តិសុខដល់ប្រទេសទាំង២ ។

ក្នុងជំនួបនោះផងដែរ ភាគីអាមេរិកមានគម្រោងអញ្ជើញ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិកម្ពុជា ដើម្បីទៅបំពេញទស្សនកិច្ចនៅទីបញ្ជាការធំរបស់ FBI ដែលស្ថិតក្នុងរដ្ឋធានីវ៉ាស៊ីនតោនឌីស៊ី ដើម្បីចុះហត្ថលេខា លើអនុស្សារណៈនោះ ជាមួយប្រធានការិយាល័យស៊ើបអង្កេតសហព័ន្ធអេហ្វប៊ីអាយ (FBI) ។ ក្នុងប្រសាសន៍ឆ្លើយតប ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានមានប្រសាសន៍ ជម្រុញអោយមានការត្រួតពិនិត្យខ្លឹមសារអឹមអូយូ (MOU) នេះបន្ថែមទៀត ហើយឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នឹងពិនិត្យរកមើលឱកាស និងពេលវេលាសមស្របណាមួយដើម្បីឆ្លើយតបការបំពេញទស្សនកិច្ចរបស់ FBI ៕

## នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ជួបពិភាក្សាការងារជាមួយ សេនានុព័ន្ធស៊ើបអង្កេតសន្តិសុខមាតុភូមិអាមេរិក

http://cambodiapolice.com/ 1:37 pm 15 វិច្ឆិកា 2018

**ភ្នំពេញ ៖** ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតអោយមន្ត្រីសេនានុព័ន្ធស៊ើបអង្កេតសន្តិសុខមាតុភូមិ របស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា លោក រ៉ះស៊ើល ជេ. បែស្ស (Russell J. Bash) អញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ក្នុងឱកាសទើបចូលកាន់តំណែងថ្មីក្នុងប្រទេសកម្ពុជា ។ ជំនួបនេះ បានធ្វើនៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានការអញ្ជើញចូលរួមពីមន្ត្រីនគរបាលកម្ពុជា និងមន្ត្រីអាមេរិកមួយចំនួនទៀតដែលជាប់ពាក់ព័ន្ធ ។

ជំនួយការអគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានសេនាធិការ ឯកឧត្តម ឧត្តមសេនីយ៍ឯក ពៅ សាលីដេត បានប្រាប់សារព័ត៌មាននគរបាលជាតិ ថា ជំនួបគ្នានេះ បានផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា ជាមួយនឹងស្ថាប័នស៊ើបអង្កេតសន្តិសុខមាតុភូមិអាមេរិកប្រឆាំងអំពើឧក្រិដ្ឋកម្ម ។ ភាគីកម្ពុជា និងអាមេរិក បានបង្ហាញភាពរីករាយក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នា «**លើវិស័យប្រឆាំងការ ជួញដូរមនុស្ស វិស័យប្រឆាំងភេរវកម្ម វិស័យប្រឆាំងអំពើអនាចារលើកុមារ និងវិស័យប្រឆាំងគ្រឿងញៀនជាដើម**» ។ ក្នុងជំនួបនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានសុំស្នើដល់ភាគីអាមេរិក ដើម្បី «**អោយបន្តជួយកម្ពុជា លើការងារបណ្តុះបណ្តាល ដែលកន្លងមកសេនានុព័ន្ធស៊ើបអង្កេតសន្តិសុខមាតុភូមិ អាមេរិកនេះ បានជួយកម្ពុជាលើការបណ្តុះបណ្តាលផ្សេងៗដូចជាការបណ្តុះបណ្តាលលើការជួញដូរ ការបណ្តុះ បណ្តាលទៅលើការប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែនជាដើម**» ។

ជាមួយគ្នានោះដែរ មន្ត្រីសេនានុព័ន្ធស៊ើបអង្កេតសន្តិសុខមាតុភូមិរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជា បានថ្លែងអំណរគុណដល់អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលកន្លងមកបានជួយសហការ «**ចាប់ខ្លួនឧក្រិដ្ឋជនទេសចរណ៍ផ្លូវភេទលើកុមារដែលបានប្រព្រឹត្តបទល្មើសនៅអាមេរិក ហើយបានរត់មកលាក់ខ្លួនក្នុងប្រទេសកម្ពុជា និងបានជួយស្វែងរកភស្តុតាងនានាជូនបន្ថែមដើម្បីការកាត់ទោសជនសង្ស័យនៅសហរដ្ឋអាមេរិក**» ៕

# ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

## សង្គមស៊ីវិលថា ថៃនៅតែបន្តបញ្ជូនពលករខ្មែរត្រឡប់មកស្រុកកំណើតតាមច្រកព្រំដែនប៉ោយប៉ែត

https://www.rfa.org/khmer/news/ ដោយ ជាតិ ចំណាន 2018-11-15

មន្ត្រីអង្គការសង្គមស៊ីវិលនៅខេត្តបន្ទាយមានជ័យលើកឡើងថា សមត្ថកិច្ចថៃបានចាប់បញ្ជូនពលករខ្មែរត្រឡប់មកស្រុកកំណើតតាមច្រកព្រំដែនប៉ោយប៉ែតនៅតែមានចំនួនច្រើន។ មន្ត្រីទាំងនោះអះអាងថា ពលករខ្មែរត្រូវបានចាប់ដឹកតាមឡានទ្រុងយ៉ាងណែនចង្អៀតដូចសត្វធាតុ ដែលទង្វើនេះជាការរំលោភសិទ្ធិមនុស្ស។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក (Adhoc) ខេត្តបន្ទាយមានជ័យលោក ស៊ុំ ច័ន្ទគា មានប្រសាសន៍ថា ពលករខ្មែរនៅតែបន្តឆ្លងដែនទៅធ្វើការប្រទេសថៃខុសច្បាប់ជារៀងរាល់ថ្ងៃ ស្របពេលដែលថៃនៅតែចាប់បញ្ជូនត្រឡប់មកស្រុកកំណើតវិញនៅតែមានចំនួនច្រើនដដែល។ អាជ្ញាធរខេត្តបន្ទាយមានជ័យបានចេញរបាយការណ៍ឲ្យដឹងថារយៈពេល១០ខែក្នុងឆ្នាំ២០១៨សមត្ថកិច្ចថៃចាប់បញ្ជូនពលករខុសច្បាប់ត្រឡប់មកកម្ពុជាតាមច្រកប៉ោយប៉ែតដល់ទៅជិត៣ម៉ឺននាក់។ លោក ស៊ុំ ច័ន្ទគារ បន្ថែមទៀតថា ថៃចាប់បញ្ជូនពលករជាង២ម៉ឺននាក់តាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតនេះ ជាតួលេខដ៏ច្រើនគួរឲ្យព្រួយបារម្ភ ដោយសារពួកគេគ្មានការងារធ្វើនៅក្នុងស្រុក ទើបបានជានាំគ្នាទៅធ្វើការទាំងប្រថុយប្រថាននៅក្រៅប្រទេសនោះ៖ «ដូច្នេះអាជ្ញាធររបបលោកហ៊ុន សែនគិតយ៉ាងណាដែរ ហើយមួយវិញទៀតបញ្ហាខ្វះកម្លាំងពលកម្មនៅក្នុងស្រុកច្រើន ប៉ុន្តែពលរដ្ឋមិនចូលចិត្តធ្វើដោយសារតម្លៃប្រាក់ឈ្នួលថោក និងមិនយកចិត្តដាក់លើការធានារ៉ាប់រងអាយុជីវិតអំឡុងពេលធ្វើការ ដូច្នេះរឿងនេះវាជាដំបៅនៅក្នុងសង្គម»។

ពលករធ្វើការនៅប្រទេសថៃលោក ជា សុខណា ឲ្យដឹងនៅថ្ងៃទី១៤វិច្ឆិកាថា លោកទៅធ្វើការប្រទេសថៃជាង ៤ឆ្នាំហើយ ដោយសារនៅផ្ទះគ្មានការងារធ្វើ ហើយគ្មានមុខរបរដើម្បីរកប្រាក់ចំណូលដោះស្រាយជីវភាពគ្រួសារ។ ពលកររូបនេះបន្ថែមទៀតថា បើសិនជានៅក្នុងស្រុកមានការងារធ្វើបានប្រាក់ខែសមរម្យលោកនឹងនាំប្រពន្ធកូនត្រឡប់ទៅផ្ទះវិញ ដោយមិននៅធ្វើការស្រុកគេនោះទេ ព្រោះធ្វើការស្រុកគេគ្មានសិទ្ធិសេរីភាពពេញលេញហើយឃ្លាតឆ្ងាយពីឪពុកម្ដាយ៖ «ហើយយើងពិបាកនៅពេលយើងប្ដូរថៅកែពិបាកធ្វើលិខិតស្នាមណាស់ កាលណាយើងចេញពីការងារមួយទៅការងារមួយទៀតគេមិនសូវប្ដូរឲ្យយើងទេ ដូចជាការងារចាស់អស់ការងារទៅហើយប្ដូរទៅថៅកែថ្មីហើយថៅកែថ្មីគេតម្រូវឲ្យយើងយកឯកសារពីថៅកែចាស់មកបង្ហាញគេទើបគេទទួលឲ្យចូលធ្វើការដូច្នេះពលករនៅថៃជួបការលំបាកលើរឿងនេះគ្រប់គ្នា»។

លោក ស៊ុំ ច័ន្ទគា អះអាងទៀតថា អាជ្ញាធរថៃនៅតែចាប់បញ្ជូនពលករខ្មែរត្រឡប់មកកម្ពុជា ដឹកតាមរថយន្តទ្រុងហើយពួកគេឈរតម្រៀបគ្នាយ៉ាងណែនពិបាកដកដង្ហើម ដោយមិនទាន់មានការកែសម្រួលឲ្យបានល្អនៅឡើយទេ។ សព្វថ្ងៃពលករខ្មែរធ្វើការនៅថៃមានជាង ១លាននាក់៕

## ឃុំខ្លួនស្ត្រីពពោះ១១នាក់ បន្ទាប់ពីឃុំមេការ និងអ្នកចាត់ការ៤នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ម៉ោង ២១:១០ ឃឹម ប៊ុនណាក់

រាជធានីភ្នំពេញ ៖ លោក ម៉ុង មុនីសោភា ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី ១៥ វិច្ឆិកា នេះបានសម្រេចចេញដីកាឃុំខ្លួនស្ត្រីមានផ្ទៃពោះចំនួន១១នាក់ ដាក់ពន្ធនាគារជាបណ្ដោះអាសន្ន ក្រោមការចោទប្រកាន់លើសំណុំរឿងអំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន និងអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ ។ បានជាមានការឃុំខ្លួនស្ត្រីមានផ្ទៃពោះចំនួន១១នាក់នេះ ព្រោះកាលពីរសៀលថ្ងៃទី១៤ វិច្ឆិកា ២០១៨ ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនមនុស្ស៤នាក់ដាក់ពន្ធនាគាររួចហើយដែរ ដែលក្នុងនោះមានស្ត្រី២នាក់ ជាមេការ និង

បុរស២នាក់ជាអ្នកចាត់ការ។ មនុស្ស៤នាក់មានម្នាក់ឈ្មោះ ខៀវ ផល្លា អាយុ៣២ឆ្នាំ និងម្នាក់ឈ្មោះ សុខ អឿន អាយុ៤០ឆ្នាំ ជាមេការ ត្រូវឃុំខ្លួនដាក់ពន្ធនាគារ(មណ្ឌលកែប្រែម២)។

ចំណែកបុរស២នាក់ ជាអ្នកចាត់ការទូទៅម្នាក់ឈ្មោះ ចេង សំអុល អាយុ៥០ឆ្នាំ និងម្នាក់ឈ្មោះ អ៊ា ម៉ាន់ អាយុ៤២ឆ្នាំ មុខរបរត់ឡាំប្រឺតាកង់បីឥណ្ឌា សម្រេចដាក់ពន្ធនាគារ(មណ្ឌលកែប្រែម១)ព្រៃស។ ក្រោយពីឃុំខ្លួនមនុស្ស៤ នាក់នោះហើយ នៅព្រឹកថ្ងៃទី១៥ វិច្ឆិកា កម្លាំងសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទៅដឹកជញ្ជូនស្ត្រីពពោះចំនួន១១នាក់ តាមរថយន្តទូរីស១២កៅអី ១គ្រឿង មក កាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការសាកសួរ លើសំណុំរឿង.អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន និង អន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ។

ស្ត្រីទាំង១១នាក់ ត្រូវបាននាំទៅឃាត់ទុកអស់រយៈពេល១សប្តាហ៍ហើយ នៅមន្ទីរពេទ្យ១៦ ឧសភា ដែលជាមន្ទីរពេទ្យនគរបាលជាតិ ស្ថិតនៅភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក្រោមការគ្រប់គ្រងដែនសមត្ថកិច្ចជាអ្នកបង្ក្រាប ដែលមិនទាន់បានដល់ដៃតុលាការនៅឡើយនោះ ។ ស្ត្រីជាប់សង្ស័យលើករណីពពោះ ១១នាក់ ពេលនេះបានស្ថិតដល់ដៃលោក ម៉ុង មុនីសោភា ចៅក្រមស៊ើបសួរ ដោយមិនចំបាច់ឆ្លងកាត់ស្ថាប័នអយ្យការនោះទៀតទេ ព្រោះសំណុំរឿងតែមួយ ដែលតំណាងអយ្យការបានចោទ ប្រកាន់រួចហើយ ដូចជនសង្ស័យ ៤នាក់ខាងលើនេះដែរ។ គួរបញ្ជាក់ថា កាលពីព្រឹកថ្ងៃទី១២ វិច្ឆិកា កម្លាំងសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ បានធ្វើការបញ្ជូនជនសង្ស័យ៤នាក់ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការសាកសួរ និងចោទប្រកាន់ជាផ្លូវការ។

ស្ត្រីជាមេការម្នាក់ឈ្មោះ ខៀវ ផល្លា អាយុ៣២ឆ្នាំ និងម្នាក់ឈ្មោះ សុខ អឿន អាយុ៤០ ឆ្នាំ ចំណែកអ្នកចាត់ការទូទៅម្នាក់ឈ្មោះ ចេង សំអុល ភេទប្រុស អាយុ៥០ឆ្នាំ និងម្នាក់ឈ្មោះ អ៊ា ម៉ាន់ ភេទប្រុស អាយុ៤២ឆ្នាំ ទាំងពីរនាក់មុខរបរត់ឡាំប្រឺតាកង់បីឥណ្ឌា។ រីឯស្ត្រីពពោះ១១នាក់ និងត្រូវបញ្ជូនទៅសាលាដំបូង រាជធានីភ្នំពេញដែរ ក្រោយពេលសាកសួរ មេការ និងអ្នកចាត់ការ៤នាក់រួចរាល់។ គួរំលឹកថា កាលពីថ្ងៃទី៨ វិច្ឆិកា កម្លាំងសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ បានចុះសហការជាមួយនគរមូលដ្ឋានខណ្ឌសែនសុខ ដោយមានការសម្របសម្រួលពីសំណាក់លោក គុជ គឹមឡុង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ធ្វើការបង្ក្រាបដាក់ស្លែងពាក់ព័ន្ធករណីអំពើលក់ដូរ មនុស្សសម្រាប់នាំឆ្លងដែន និងអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ។

កិច្ចសហការបង្ក្រាបនោះសមត្ថកិច្ចបាន ធ្វើឡើង នៅចំណុចចំនួន៣កន្លែង ក្នុងទឹកដីខណ្ឌសែនសុខ រាជធានីភ្នំពេញ។ លទ្ធផលឃាត់ខ្លួនជនសង្ស័យ ចំនួន១៥នាក់ ក្នុងនោះមានអ្នកមើលការខុសត្រូវ(មេការស្ត្រី)២នាក់ អ្នករត់ម៉ូតូកង់បី ២នាក់ និងស្ត្រីមានផ្ទៃពោះ (ស្ត្រីពពោះ)ចំនួន១១នាក់។ វត្ថុតាងដកហូតមានលិខិតឆ្លងដែន១ក្បាល ឯកសារពេទ្យមួយចំនួន.(ស៊ីរ៉ាំង និងថ្នាំពេទ្យ.ប្រើរួច និងមិនទាន់ប្រើ) និងម៉ូតូកង់បី ចំនួន២គ្រឿង។ ជនសង្ស័យ និងវត្ថុតាងត្រូវបានសមត្ថកិច្ច នាំទៅកាន់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីកសាងសំណុំរឿងបញ្ជូនទៅកាន់ សាលាដំបូងរាជធានីភ្នំពេញតាមនីតិវិធី៕

## តុលាការឃុំខ្លួនមនុស្ស៤នាក់ពាក់ព័ន្ធជួលស្ត្រីខ្មែរឱ្យពពោះជំនួស

http://www.rasmeinews.com/ November 15, 2018, 6:29 PM

ដោយៈសរិទ្ធ/ភ្នំពេញៈ មនុស្ស៤នាក់ក្នុងចំណោមមនុស្ស១៤នាក់ ដែលជាប់ពាក់ព័ន្ធករណីជួលស្ត្រីខ្មែរពពោះជំនួសភ្នំពេញបានត្រូវលោកម៉ុងមុនីសោភាចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញនៅរសៀលថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨បានចេញដីកាសម្រេចឃុំខ្លួនដាក់ពន្ធនាគារ។មនុស្សចំនួន៤នាក់នេះ ឈ្មោះ សុខ ឃឿន ឈ្មោះ ខៀវ វណ្ណា ឈ្មោះ ចេង សំអុល និងឈ្មោះ អៀង ម៉ាន់ ។ ការសម្រេចឃុំខ្លួននេះ គឺធ្វើឡើងបន្ទាន់ពីលោក ស៊ិន វីៈព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ បានចោទចោទប្រកាន់ពីបទ «សមគំនិតក្នុងអំពើលក់ដូរមនុស្ស សម្រាប់ឆ្លងដែន និងធ្វើអន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ» តាមមាត្រា១៦ នៃច្បាប់ស្តីពីការទប់ស្កាត់

អំពើជួញដូរមនុស្ស មាត្រា២៩និងមាត្រា៣៣២នៃក្រមព្រហ្មទណ្ឌ។ដោយឡែកមនុស្ស១១នាក់ផ្សេងទៀតក៏ត្រូវបានតុលាការធ្វើការចោទប្រកាន់រួចហើយដែរតែកំពុងស្ថិតនៅមន្ទីរពេទ្យ។ដូច្នេះតុលាការនឹងបន្តនីតិវិធីសាកសួរនៅពេលក្រោយ។

គួររំលឹកថាកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដោយមានការចូលរួមពីអភិបាលខណ្ឌសែនសុខ និងអធិការនគរបាលខណ្ឌ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ បានចុះបង្ក្រាបទីតាំងមួយកន្លែង ស្ថិតក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលពាក់ព័ន្ធករណីស៊ីឈ្នួលពពោះជំនួស ដោយឃាត់ខ្លួនបានមនុស្ស១៥នាក់។ ក្នុងចំណោមមនុស្ស១៥នាក់នេះមានស្រី១៣នាក់ ប្រុស២នាក់ជាអ្នករត់ម៉ឺម៉កម៉ូតូកង់៣។ក្នុងចំណោមស្ត្រី១៣នាក់មានស្ត្រី១១នាក់ កំពុងតែមានផ្ទៃពោះ និង២នាក់ផ្សេងទៀតជាចុងភៅ៕S/

## ឆ្នាំ២០១៨នេះ ពលករខ្មែរនៅកូរ៉េខាងត្បូងបញ្ជូនថវិកាចូលក្នុងប្រទេសច្រើនជាង៦០០លានដុល្លារ

http://bayontv.com.kh/ 16/11/2018

ភ្នំពេញ ៖ គិតត្រឹមឆ្នាំ២០១៨នេះ ពលករខ្មែរដែលកំពុងបម្រើការងារនៅប្រទេសកូរ៉េខាងត្បូងមានចំនួន៥ម៉ឺន៦ពាន់នាក់។ ទន្ទឹមនឹងនេះ អគ្គរាជទូតកម្ពុជាប្រចាំកូរ៉េខាងត្បូងឯកឧត្តម ឡុង ឌីម៉ង់ បានប្រាប់ទូរទស្សន៍BTV តាមរយៈទូរស័ព្ទនៅថ្ងៃទី១៦នេះ ថាពលករខ្មែរធ្វើការនៅកូរ៉េ បានបញ្ជូនថវិកាចូលក្នុងស្រុកប្រមាណ៦០០លានដុល្លារក្នុង១ឆ្នាំៗ។ ឯកឧត្តម ឡុង ឌីម៉ង់ បានថ្លែងថា ពលករខ្មែរម្នាក់ដែលធ្វើការនៅកូរ៉េខាងត្បូងបានបញ្ជូនថវិកាមកកាន់គ្រួសារក្នុងស្រុកវិញយ៉ាងហោចណាស់១ពាន់ដុល្លារក្នុងមួយខែ ដើម្បីជួយបង្កើនសកម្មភាពសេដ្ឋកិច្ចគ្រួសារ។ ឯកឧត្តម បានបន្តលើកឡើងថា ចំនួនថវិកា ប្រមាណ៦០០លានដុល្លារនេះ គឺជាចំណែកមួយដ៏សំខាន់សម្រាប់ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចប្រទេសជាតិដែលពលករទាំងអស់បានរួមចំណែក។ ទន្ទឹមនឹងនេះ ឯកឧត្តមអគ្គរាជទូត បានលើកឡើងពីការយកចិត្តទុកដាក់ របស់ស្ថានទូតដល់ពលករដែលកំពុងធ្វើការនៅគ្រប់តំបន់ក្នុងប្រទេសកូរ៉េខាងត្បូងដូចជាការផ្តល់សេវាកម្មពិសុខភាពដោយឥតគិតថ្លៃដល់កន្លែងធ្វើការ និងការផ្តល់សេវាកម្មផ្លូវច្បាប់ដោយឥតគិតថ្លៃដល់ទីកន្លែងធ្វើការផងដែរ។ គិតត្រឹមឆ្នាំ២០១៨នេះ ពលករខ្មែរចំនួន៥ម៉ឺន៦ពាន់នាក់ កំពុងបម្រើការងារលើវិស័យចំនួន៣ធំៗគឺ កសិកម្ម វិស័យសំណង់ និងឧស្សាហកម្មដែលទទួលប្រាក់បៀវត្សរ៍ ពីជាង១ពាន់ដុល្លារដល់ជាង៤ពាន់ដុល្លារ។ ជាមធ្យមកូរ៉េខាងត្បូងទទួលយកពលករខ្មែរប្រមាណ៨ទៅ៩ពាន់នាក់ ក្នុងមួយឆ្នាំៗ តាមរយៈកូតាអនុគ្រោះដែលបានចុះហត្ថលេខាដោយរដ្ឋាភិបាលកម្ពុជានិងកូរ៉េខាងត្បូង៕

# ថ្ងៃទី១៩ខែវិច្ឆិកា ឆ្នាំ២០១៨

## របបក្រុងភ្នំពេញកំពុងសម្របសម្រួលជាមួយភាគីថៃ អំពីការចាប់បញ្ជូនពលករខ្មែរ

https://www.rfa.org/khmer/news/ ដោយ យន់ សាមៀន 2018-11-17

អ្នកនាំពាក្យរបបក្រុងភ្នំពេញអះអាងថា ក្រសួងការងារក្រសួងការបរទេស និងស្ថានទូតខ្មែរប្រចាំប្រទេសថៃ កំពុងជួបជជែកជាមួយភាគីថៃ ដើម្បីសម្របសម្រួលករណីការចាប់បញ្ជូនពលករខ្មែរដែលកំពុងធ្វើការងារខុសច្បាប់នៅប្រទេសថៃ ដើម្បីដោះស្រាយបញ្ហានេះ។ កន្លងមកសង្គមស៊ីវិល លើកឡើងថា អាជ្ញាធរបានរំលោភសិទ្ធិពលករខ្មែរ ដោយការចាប់បញ្ជូនពួកគេមកកម្ពុជាវិញធ្វើ ឲ្យគ្មានស្តង់ដារ ដោយសារចាប់ពួកគេដាក់ក្នុងទ្រុងដូចសត្វធាតុ។ លោក ផៃ ស៊ីផាន ឲ្យអាស៊ីសេរីដឹងថ្ងៃទី១៧ ខែវិច្ឆិកាថា ទន្ទឹមនឹងការស្វែងរកដំណោះស្រាយបញ្ហាពលករនេះ សមត្ថកិច្ចកម្ពុជា ក៏កំពុងស្វែងរកចាប់មេខ្យល់ដែលនាំពលករទៅធ្វើការងារខុសច្បាប់នៅថៃផងដែរ ព្រោះក្រុមមេ

ខ្យល់នេះ គឺជាប្រភពនាំពលករទៅធ្វើការងារខុសច្បាប់។ អ្នកនាំពាក្យរូបនេះបញ្ជាក់ថា របបលោកកំពុងព្យាយាមប្រែក្លាយពលករធ្វើការងារនៅថៃខុសច្បាប់ឲ្យស្របច្បាប់វិញ៖ «កំពុងរៀបចំធ្វើឲ្យពួកគាត់ក្លាយជាអ្នកធ្វើការស្របច្បាប់តែម្តង។ បាទកំពុងតែបន្តការសម្របសម្រួលដល់ពលករ ដែលចូលធ្វើការរួចហើយ ដែលខុសច្បាប់នេះឯង»។

មន្ត្រីកម្មវិធីសិទ្ធិការងារនៃអង្គការសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស ហៅកាត់ថា សង់ ត្រាល់ លោក ឌី ថេហូយ៉ា ស្នើសុំថា លទ្ធផលនៃកិច្ចប្រជុំកម្ពុជា និងថៃត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដើម្បីឲ្យពលករអាចស្នើសុំឯកសារស្របច្បាប់។ លោកទាមទារឲ្យអាជ្ញាធររៀបចំកន្លែងធ្វើឯកសារឲ្យមានសេវាកម្មល្អ គ្មានអំពើពុករលួយ ឬគ្មានអ្នករត់ការខុសច្បាប់៖ «បើតម្លៃប៉ុណ្ណាប៉ុណ្ណឹង ទៅកុំឲ្យមានអ្នករត់ការក្រៅស្មុគស្មាញ និយាយឲ្យស្រួល គឺបង្កលក្ខណៈងាយស្រួលដល់ពលករក្នុងការធ្វើឯកសារ»។

សមត្ថកិច្ចអន្តោប្រវេសន៍ថៃរាប់ពាន់នាក់កំពុងសម្រុកចុះចាប់ខ្លួនពលករខ្មែរ ដែលកំពុងធ្វើការ និងរស់នៅខុសច្បាប់លើទឹកដីថៃដល់កន្លែងពួកគេស្នាក់នៅ កន្លែងពួកគេធ្វើការ និងទីកន្លែងដែលមានពលករខ្មែរក្នុងយុទ្ធនាការបោសសម្អាតឧក្រិដ្ឋកម្មឆ្លងដែន ដើម្បីសេចក្តីសុខពលរដ្ឋថៃ។

អាស៊ីសេរីនៅមិនទាន់មានតួលេខពលករខ្មែរត្រូវចាប់ខ្លួនសរុបនៅឡើយទេ ប៉ុន្តែ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្ហាញរបាយការណ៍រយៈពេល ១០ខែ ឆ្នាំ២០១៨ នេះថា សមត្ថកិច្ចថៃបានបញ្ជូនពលករខ្មែរ ដែលធ្វើការងារខុសច្បាប់នៅប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតជិត ៣ម៉ឺននាក់។

របាយការណ៍ក្រសួងមហាផ្ទៃគិតត្រឹមពាក់កណ្តាលឆ្នាំ២០១៨នេះបង្ហាញថា ពលករខ្មែរ ១លាន ៥ម៉ឺននាក់កំពុងបម្រើការងារនៅក្នុងប្រទេសថៃ ក្នុងនោះមានពលករស្របច្បាប់តែជាង ៥សែននាក់ប៉ុណ្ណោះ៕

## សម្តេចក្រឡាហោម ស ខេង ណែនាំដល់អាជ្ញាធរខេត្ត និងកងកម្លាំងសមត្ថកិច្ចព្រំដែន ត្រូវទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់របស់ពលរដ្ឋខ្មែរចូលប្រទេសថៃ

http://akpnews.info/kh/ AKP ឧត្តរមានជ័យ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំដល់កងកម្លាំងនគរបាល និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ដែលនៅប្រចាំការការពារតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ត្រូវធ្វើការទប់ស្កាត់ឱ្យខាងតែបានចំពោះការលួចចូលឆ្លងដែនខុសច្បាប់ ពីសំណាក់ប្រជាពលរដ្ឋខ្មែរទៅកាន់ប្រទេសថៃ ដើម្បីកាប់ឈើគ្រញូង តាមច្រករបៀងខុសច្បាប់ ។ ការលើកឡើងរបស់សម្តេចក្រឡាហោមនេះបានធ្វើឡើង ក្នុងពិធីប្រកាសផ្ទេរភារកិច្ច និងតែងតាំងអភិបាលខេត្តឧត្តរមានជ័យថ្មី កាលពីថ្ងៃសៅរ៍ ១០កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ។ សម្តេចក្រឡាហោមបានជំរុញដល់អាជ្ញាធរនិងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវសហការជាមួយថៃ ស្នើឱ្យភាគីថៃ កុំបាញ់ប្រជាពលរដ្ឋខ្មែរដែលឆ្លងដែនខុសច្បាប់ ត្រូវសហការចាប់បញ្ជូនមកវិញតាមនីតិវិធីច្បាប់ និងតាមនីតិវិធីដែលអាចធ្វើទៅបាន ។

សម្តេចក្រឡាហោមបានលើកឡើងទៀតថា ច្រករបៀងមិនមែនជាច្រកស្របច្បាប់ទេ ព្រំដែនកម្ពុជា-ថៃមានប្រវែង២២១គីឡូម៉ែត្រ សព្វថ្ងៃនេះក្នុងមួយថ្ងៃៗថៃចាប់បញ្ជូនប្រជាពលរដ្ឋខ្មែរដែលឆ្លងដែនខុសច្បាប់មកវិញពី៨០ទៅ១០០នាក់។ ទន្ទឹមនេះ មន្ត្រីសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ដែលការពារព្រំដែន ធ្វើយ៉ាងណាត្រូវទប់ស្កាត់ឱ្យបានពីការលួចចូលឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ ហេតុនេះ កងកម្លាំងសមត្ថកិច្ចពាក់ព័ន្ធ គ្រប់គ្រងច្រកព្រំដែនឱ្យបានត្រឹមត្រូវ គឺធ្វើយ៉ាងរក្សាសន្តិសុខសណ្តាប់ធ្នាប់ឱ្យបាន ហើយមានប្រយោជន៍ដល់ប្រជាជននៃប្រទេសទាំងពីរ ។ សម្តេចក្រឡាហោមបានគូសបញ្ជាក់ថា បើតាមលទ្ធផលនៃការផ្តល់សេវារដ្ឋបាល របស់ការិយាល័យច្រកចេញចូលតែមួយ ដែលបង្កើតឡើងនៅតាមបណ្តាក្រុង ស្រុក ខណ្ឌ នាពេលកន្លងមកបានបង្ហាញឱ្យឃើញនូវលទ្ធផល

វិជ្ជមាន គួរជាទីមោទនគី មានការសម្របសម្រួល ដោះស្រាយបញ្ហាបន្ទឹងនានារបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា។ លើសពីនេះទៀត ការិយាល័យទាំងពីរនេះ បាននិងកំពុងប្រតិបត្តិការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋយ៉ាងសកម្ម ស្របតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលបានកំណត់ បង្កដល់ភាពងាយស្រួល ជូនប្រជាពលរដ្ឋដែលមកទទួលសេវា និងបានផ្តល់សេវាជូនពួកគាត់បានទាន់ពេលវេលា ព្រមទាំងបានប្រមូលចំណូលចូលថវិកាជាតិ ពីការផ្តល់សេវានេះ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងចូលរួមចំណែកក្នុងការទប់ស្កាត់អំពើពុករលួយផងដែរ ។

សូមបញ្ជាក់ថា ការប្រកាសចូលកាន់មុខតំណែង ឯកឧត្តម ប៉ែន កុសល្យ អតីតអភិបាលរងខេត្តត្បូងឃ្មុំ ទៅជាអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ជំនួស ឯកឧត្តម ស ថាវី ត្រូវបានផ្ទេរភារកិច្ច និងទទួលតំណែងថ្មីជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ៕ ដោយ ទិត ស្រ៊

## លោក ស ខេង៖ ករណីពលរដ្ឋ លួចឆ្លងដែន ចូលទៅកាប់ឈើ នៅទឹកដីថៃ គឺដោយសារមានមន្ត្រីព្រំដែន លួចបើកដៃ

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 18 November 2018 | 19:46 ICT

ឧត្តរមានជ័យៈ លោកឧបនាយករដ្ឋមន្ត្រី ស ខេង បានថ្លែងថា ករណីពលរដ្ឋកាប់ឈើគ្រញូងនៅតាមបន្ទាត់ព្រំដែន និងការលួចឆ្លងដែនចូលទៅកាប់ដល់ក្នុងទឹកដីថៃដោយខុសច្បាប់ នាពេលកន្លងមក គឺដោយសារមានការលួចបើកដៃពីមន្ត្រីនៅព្រំដែន ប៉ុន្តែបច្ចុប្បន្ន ករណីនេះ មានភាពស្ងប់ស្ងាត់បន្តិច ដែលទំនងជាមកពីអស់ឈើកាប់។ លោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង បានលើកឡើងនូវបញ្ហានេះ នៅក្នុងឱកាសលោកអញ្ជើញចូលរួមពិធីប្រកាសតែងតាំង លោក ប៉ែន កុសល្យ ជាអភិបាលខេត្តឧត្តរមានជ័យ កាលពីថ្ងៃសៅរ៍ ទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៨។ លោកបានថ្លែងដោយរំលឹកដល់មន្ត្រីពាក់ព័ន្ធនានា នៅតាមព្រំដែនម្តងហើយម្តងទៀតថា ច្រករបៀងមិនមែនជាច្រកស្របច្បាប់ទេ ដូច្នេះករណីពលរដ្ឋចំណាកស្រុក ដែលមកពីក្នុងផ្ទៃប្រទេស ចេញទៅថៃ តាមច្រករបៀង គឺខុសច្បាប់ ដែលមួយថ្ងៃៗភាគីថៃបានចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ពី ៨០នាក់ទៅ ១០០នាក់។ លោកបញ្ជាក់ថា៖«ឥឡូវ[ខ្ញុំ]សុំអង្វរបិទច្រករបៀងទាំងអស់ទៅ។ មិនមែនខ្ញុំមិនយល់អ្វីនោះទេ អ្នកដែលឲ្យពលរដ្ឋចេញ ទៅតាមច្រករបៀង គ្មានអ្នកណាក្រៅពី សមត្ថកិច្ចយើងនៅជាប់ព្រំដែននោះទេ»។ លោករដ្ឋមន្ត្រីបានបន្តថា ពីមុនមានករណីកាប់ឈើគ្រញូង នៅតាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ អ្នកដែលត្រូវបានបង្ក្រាបចាប់បានភាគច្រើន ជាពលរដ្ឋដែលចំណាកស្រុកពីខេត្ត ស្វាយរៀង កំពង់ចាម និង ខេត្តផ្សេងទៀត ដែលពួកគាត់មួយចំនួនមិនទាំងស្គាល់ដើមគ្រញូងយ៉ាងដូចម្តេចផង ហើយរឹតតែមិនដឹងថា ឈើគ្រញូងហ្នឹង វាដុះនៅត្រង់កន្លែងណាទៀត ប៉ុន្តែ ហេតុអ្វី បានជាពួកគាត់ពូកែម្លេះ មកចំកន្លែងដុះឈើគ្រញូង ហើយនាំគ្នាកាប់យ៉ាងអាណាធិបតេយ្យទាំងនៅក្នុងទឹកដីខ្មែរនិងក្នុងទឹកដីថៃ។

លោកបញ្ជាក់ថា៖«ចឹងករណីហ្នឹង វាមានតែឈ្មួញឈើ ខ្មែរ និង ថៃ ដែលនៅជាប់ព្រំដែនឃុបឃិតគ្នា រួចប្រើឲ្យពួកគាត់ហ្នឹង ទៅកាប់។ ការពិតពួកគាត់ មិនដឹងខ្យល់អីទេ ហើយអ្នកដែលរងគ្រោះ គឺពួកគាត់ដែលគេប្រើឲ្យទៅកាប់ហ្នឹងឯង»។ លោកបានបន្ថែមថា៖«ឥឡូវ[ករណីហ្នឹង] វាធូរបន្តិច ព្រោះវាអស់[ឈើ]កាប់ហើយ...តែថា ខាងថៃគេនៅមានឈើ ចឹងយើងស្នើឲ្យភាគីថៃ ធ្វើម៉េចកុំបាញ់សម្លាប់ [បើឃើញមានករណីបែបនេះកើតឡើង] សូមចាប់យកទៅដាក់គុកតាមច្បាប់ហ្នុងទៅ ឬ ក៏ត្រូវបញ្ជូនមកកម្ពុជាវិញ»។ ជាមួយគ្នានេះ លោករដ្ឋមន្ត្រី ក៏បានអំពាវនាវនឹងជំរុញឲ្យលោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ ដែលទើបត្រូវបានតែងតាំងថ្មីនេះ បន្តកិច្ចសហប្រតិបត្តិការ ជាមួយមន្ត្រីពាក់ព័ន្ធគ្រប់ផ្នែកទាំងអស់ ទប់ស្កាត់ឲ្យបាននូវបញ្ហាអវិជ្ជមានដែលបានលើកឡើងខាងលើនេះ ដើម្បីធានាដល់សុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងដើម្បីការពារនូវកិត្យានុភាពរបស់ជាតិ ដោយធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋឲ្យបញ្ឈប់ការកាប់ឈើ និង ការឆ្លងដែនខុសច្បាប់ទៅកាន់ប្រទេសជិតខាង។

ជុំវិញករណីនេះ លោក ស៊ុន បូរ៉ាន់ មេបញ្ជាការផ្នែកសិករង ស្រុកត្រពាំងប្រាសាទ បានទទួលស្គាល់ថា កន្លងមកពិតជាមានបទល្មើសព្រៃឈើកើតឡើង នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដែលបង្កឡើង ដោយក្រុមឈ្មួញឈើក្នុងស្រុកឃុបឃិតជាមួយឈ្មួញឈើថៃ ជួលពលករចំណាកស្រុក ពីខេត្តផ្សេងៗឲ្យមកកាប់ ប៉ុន្តែករណីនេះ ត្រូវបានក្រុមសមត្ថកិច្ចយោធា និង នគរបាលព្រំដែន រួមគ្នាជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើការបង្រ្កាបចាប់ និង ទប់ស្កាត់បានជាបន្តបន្ទាប់ផងដែរ។ លោកបូរ៉ាន់ បានថ្លែងថា៖«បច្ចុប្បន្ន ករណីនេះ មានភាពស្ងប់ស្ងាត់ ប៉ុន្តែ មិនមានន័យថា វាគ្មានបទល្មើសហ្នឹងកើតមាននោះទេ គឺ វាអាចមានដោយកន្លែង ព្រោះពួកឈ្មួញទុច្ចរឹត វាតែងតែឆ្លៀតឱកាសនៅពេលដែលយើងមានភាពធូរលែង»។ លោកបូរ៉ាន់ ក៏បានបដិសេធផងដែរ នៅពេលដែលសួរថា តើកន្លងមកមានមន្ត្រីយោធាព្រំដែនខ្លះ មានការលួចឃុបឃិតជាមួយឈ្មួញឈើខ្មែរ និងឈ្មួញឈើថៃ នាំពលករខ្មែរចំណាកស្រុកពីខេត្តផ្សេងៗ ចូលទៅកាប់ឈើនៅក្នុងទឹកដីថៃដែរឬទេ?

ដូចគ្នានេះដែរ លោក ប៉ុក សុផល មេបញ្ជាការយោធាវរៈព្រំដែនលេខ ៤០២ បានថ្លែងថា មន្ត្រីយោធាណាមួយ ដែលមានការជាប់ពាក់ព័ន្ធក្នុងការជួយសម្រួលឲ្យមានបទល្មើសនឹងត្រូវទណ្ឌកម្មតាមវិន័យកងទ័ព។ លោក សុផល បានបញ្ជាក់ថា៖«កន្លងមក យើងបានអនុវត្តដោយដាក់ពិន័យ ទៅលើមន្ត្រីយោម្នាក់ ដែលបានអនុវត្តផ្ទុយពីបទបញ្ជារបស់កងកម្លាំង បន្ទាប់ពីមានសេចក្តីរាយការណ៍ ពីជនរងគ្រោះ ជាពលករចំណាកស្រុកថា បានយកលុយពីពួកគេជាថ្នូរក្នុងការអនុញ្ញាតឲ្យពួកគេ ឆ្លងដែនចូលទៅកាប់ឈើនៅក្នុងទឹកដីថៃ ហើយត្រូវភាគីថៃចាប់បញ្ជូនខ្លួនមកវិញ»។

ជុំវិញករណីនេះផងដែរ លោក ស្រី ណារ៉េន អ្នកសម្របសម្រួលសមាគមសិទ្ធិមនុស្សអាដហុក ខេត្តឧត្តរមានជ័យ បានគាំទ្រចំពោះសេចក្តីថ្លែងរបស់លោក ស ខេង ដែលជំរុញឲ្យសមត្ថកិច្ចពាក់ព័ន្ធគ្រប់ផ្នែកទាំងអស់ ទប់ស្កាត់ឲ្យបាននូវរាល់បទល្មើស ពិសេសបទល្មើសឆ្លងដែនខុសច្បាប់ ទៅក្នុងទឹកដីថៃ ។ លោក ណារ៉េន បានថ្លែងថា៖«ដើម្បីសុវត្ថិភាពពលរដ្ឋ និងកិត្យានុភាពរបស់ជាតិ យើងទាំងអស់គ្នា គាប់បីរួមគ្នា បញ្ឈប់ និង ទប់ស្កាត់ឲ្យបាននូវរាល់សកម្មភាពល្មើសច្បាប់ទាំងឡាយ ពិសេសបទល្មើសគ្រឿងញៀន កាប់បំផ្លាញព្រៃឈើ នេសាទ អាជីវកម្មរ៉ែខុសច្បាប់ និង ការឆ្លងដែនខុសច្បាប់ ជាដើម»៕

## រដ្ឋមន្ត្រីមហាផ្ទៃ អំពាវនាវឲ្យទប់ស្កាត់ ពលរដ្ឋខ្មែរដែលចូលកាប់ឈើ ខុសច្បាប់និងស្នើ ថៃ កុំបាញ់សម្លាប់

https://www.dap-news.com/ ByID:115 Posted on 18 November 2018 | 08:59

ភ្នំពេញ៖ ក្រោយសង្កេតឃើញមាន ប្រជាពលរដ្ឋខ្មែ រចូលទៅកាប់ឈើខុសច្បាប់ក្នុងទឹកដីថៃ តាមច្រករបៀងជាបន្តបន្ទាប់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអំពាវនាវដល់សមត្ថកិច្ចពាក់ព័ន្ធ ធ្វើយ៉ាងណាទប់ស្កាត់បញ្ហានេះឲ្យបាន ក្នុងនោះសម្តេចក៏បានស្នើភាគីថៃ កុំឲ្យមានការបាញ់សម្លាប់ដោយគ្រាន់តែ ចាប់ដាក់គុកឬចាប់បញ្ជូនមកខ្មែរវិញ។ ក្នុងពិធីប្រកាសតែងតាំងលោក ប៉ែន កោសល្យ ជាអភិបាលខេត្តឧត្តរមានជ័យជំនួស លោក ស ថារី កាលពីថ្ងៃទី១៧ ខែ វិច្ឆិកា សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា គ្មានអ្នកណាក្រៅពីសមត្ថកិច្ចខ្មែរនៅតាមច្រកព្រំដែនជាអ្នកបើកឲ្យប្រជាពលរដ្ឋចូលកាប់ឈើខុសច្បាប់ក្នុងទឹកដីប្រទេសថៃហើយដោយសារមានការឃុបឃិតពីឈ្មួញរកស៊ីឈើខុសច្បាប់ខ្មែរនិងថៃជាអ្នកនាំផ្លូវប្រជាពលរដ្ឋខ្មែរចូលទៅកាប់ឈើព្រោះប្រជាពលរដ្ឋខ្មែរភាគច្រើនមិនស្គាល់ឈើគ្រញូងនោះទេ។

សម្តេចក្រឡាហោមថ្លែងបញ្ជាក់ថា "ខ្ញុំរំលឹកដដែលជាដដែលទេថាដែលហៅថារបៀងវា មិនមែនជាច្រកស្របច្បាប់ ទេរឿងនេះមិនមែនជាបន្ទុក របស់ខេត្តណាមួយទេ។ ឧទាហរណ៍ ថាឧត្តរមានជ័យជាប់ព្រំដែនជាបន្ទុកដោយឡែករបស់ឧត្តរមានជ័យទេ ព្រោះប្រជាជនមកពីខាងក្នុងផ្ទៃប្រទេស។ មកចេញទៅព្រំដែនចូលទៅថៃ ដោយ

អត់ច្បាប់ហើយមួយថ្ងៃៗ ថៃចាប់បញ្ជូនមក៨០-១០០(នាក់)រាល់ថ្ងៃហើយសុទ្ធតែចូលទៅអត់ច្បាប់។ មានអ្នកមួយចំនួនដែលទៅយូរហើយ ទៅយូរហើយក៏ខុសច្បាប់ដែរដូចគ្នាអីចឹង"។ សម្ដេចក្រឡាហោមបន្ថែមថា "ខ្ញុំយល់បញ្ហាហ្នឹងមិនមែនខ្ញុំមិនយល់ទេអ្នក ឲ្យចេញទៅគ្មានពីណាក្រៅពី សមត្ថកិច្ចយើងជាប់ព្រំដែនទេ ដូចពីមុនកាប់ឈើគ្រញូងអីចឹង អ្នកព្រៃវែង ស្វាយរៀង កំពង់ចាមអ្នកខ្លះមិនស្គាល់ឈើគ្រញូង ផងមិនមែនអ្នកខ្លះទេភាគច្រើនតែម្ដងអត់ស្គាល់ឈើគ្រញូង ហើយវាមិនដឹងថាឈើគ្រញូងដុះនៅទីណាទៀត ម៉េចក៏គាត់ពូកែម្ល៉េះ ពូកែដឹងថាគ្រញូងដុះនៅដីថៃ ដុះនៅត្រង់ណាទៅដល់ កាប់យកតែម្ដង។ អីចឹងឈ្មួញពីខ្មែរផងឈ្មួញពីថៃ ផងខ្ញុំប្រាប់ថៃថាខ្មែរខ្ញុំអត់ទាន់ស្គាល់គ្រញូង ផងនោះអីហើយវាមានតែឈ្មួញថៃនិងឈ្មួញខ្មែរ ទាក់ទងគ្នាប្រើអ្នកទៅកាប់គ្នាគ្មានដឹងខ្យល់អីទេ ហើយរងគ្រោះអ្នកកាប់បន្តិច ឥឡូវធូរបន្តិចវាអស់ហើយ! តែគ្រាន់តែថៃនៅឈើ ចូលទៅកាប់ឈើនានាឃើញថាយើងស្នើគាត់ថាសុំធ្វើម៉េច កុំឲ្យបាញ់សម្លាប់ចាប់មក ចាប់ហើយដាក់គុកទៅនៅហ្នឹងឬមួយ ក៏ចាប់បញ្ជូនមកវិញមក ប៉ុន្តែយើងក៏ត្រូវពន្យល់ ពលរដ្ឋយើងហើយទប់ស្កាត់ការចេញចូល"។

ជាងនេះទៅទៀតសម្ដេចក៏បានស្នើឲ្យអាជ្ញាធរ គ្រប់ជាន់ថ្នាក់ត្រូវបម្រើសេវាជូនប្រជាពលរដ្ឋ ឲ្យបានល្អមិនត្រូវមានការបែងចែកពលរដ្ឋ និងរើសអើងនិន្នាការនយោបាយនោះទេ៕

## ពលករខ្មែរម្នាក់ ជួបគ្រោះថ្នាក់ចរាចរណ៍នៅថៃស្លាប់

http://www.arey-news.com/ (ថ្ងៃទី 19 November 2018 ម៉ោង 10:20 am)

ថៃ៖ កាលពីថ្ងៃអាទិត្យ ទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង៧យប់ ពលករខ្មែរម្នាក់ ដែលធ្វើការនៅប្រទេសថៃ បានជួបគ្រោះថ្នាក់ចរាចរណ៍ នៅខេត្តរ៉ាក់យ៉ង នៅប្រទេសថៃ បណ្ដាលឲ្យស្លាប់ភ្លាមនៅនឹងកន្លែងកើតហេតុ។ សពជនរងគ្រោះឈ្មោះ កិម សៀនធៀន ភេទប្រុស អាយុ២២ឆ្នាំ ធ្វើការនៅប្រទេសថៃ គ្មានសាច់ញាតិនោះទេ។ គ្រួសារនៃសពចង់បានសពកូនយកទៅធ្វើបុណ្យនៅឯស្រុកកំណើត នៅស្រុកសំឡូត ខេត្តបាត់ដំបង តែពុំមានលទ្ធភាពដោយគ្រួសារនៃសពមានភាពខ្វះខាត ដូច្នោះក្រុមគ្រួសារសពសូមឲ្យស្ថានទូតខ្មែរប្រចាំប្រទេសថៃ សូមជួយដល់គ្រួសារគាត់ផង៕

## មីងអើយមីង...ឃើញទេលទ្ធផលទង្វើខ្លួន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ម៉ោង ១៤:០២ ប៊ុន លីនណា

ខេត្តក្រចេះ ៖ ស្ត្រីជាមេខ្យល់មុខសញ្ញាជួញដូរមនុស្សឱ្យទៅយកប្តីនៅប្រទេសចិនខុសច្បាប់ម្នាក់ ត្រូវបានតុលាការសម្រេចឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគារខេត្ត ក្រោមបទចោទពីបទលក់ដូរ សម្រាប់នាំឆ្លងដែនត្រូវបានកម្លាំងនគរបាលខេត្តក្រចេះស្រាវជ្រាវ ពន្លាតដែនដីចាប់ខ្លួនបាននៅខេត្តត្បូងឃ្មុំ ។

ស្ត្រីមុខសញ្ញាជាមេខ្យល់ខាងលើ ឈ្មោះ កង ជឹម អាយុ៥០ឆ្នាំ រស់នៅស្រុកត្បូងឃ្មុំ ខេត្ត ត្បូងឃ្មុំ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តក្រចេះ លោក ញឹល ប៊ុនលី សម្រេច ចេញដីការឃុំខ្លួនបណ្ដោះអាសន្ន នៅថ្ងៃទី១៩ វិច្ឆិកា ។

ស្នងការរងប្រឆាំងការជួញដូរមនុស្ស និងការពារអនីតជនលោកស្រីវរសេនីយ៍ឯក នៅ រតនា បានឲ្យដឹងថានារីរងគ្រោះអាយុ២២ឆ្នាំ រស់នៅក្នុងស្រុកចិត្របុរី ខេត្តក្រចេះ ត្រូវបានស្ត្រីសង្ស័យនិងបក្សពួកបានបោកបញ្ឆោតលក់នៅប្រទេសចិនដើម្បីឲ្យយកប្ដី តែដោយខុសច្បាប់ កាលពីឆ្នាំ២០១៦ ក្នុងតម្លៃខ្លួនជិត២ពាន់ដុល្លារក្រោមលេសថា នាំទៅរកការងារធ្វើ ដើម្បីរកចំណូលមកដោះស្រាយជីវភាព ។ លោកស្រីស្នងការរងបានសម្រងបណ្ដឹងរបស់ស្ត្រីជាម្ដាយនារីរងគ្រោះឲ្យដឹងទៀតថា ក្រោយពេលកូនស្រីគាត់បានទៅដល់ប្រទេសចិនក៏បាត់ការទំនាក់ទំនង ។ ព្រោះនាងត្រូវបានបង្ខំឲ្យយកប្ដីដោយខុសច្បាប់និងត្រូវបានបង្ខាំងទុក មិនឱ្យមានការទំនាក់ទំនងមកស្រុកខ្មែរបាននោះទេ ។ តែក្រោយមក នាងបានលួចទំនាក់ទនងមកស្ត្រីជាម្ដាយ ទើបដឹងថា នាងបានចាញ់បោកគេ ដោយត្រូវមេ

ខ្យល់បង្ខំឲ្យមកយកប្ដីនៅប្រទេសចិន ។ លោកស្រីស្នងការរងបានឲ្យដឹងទៀតថា ស្ត្រីជាម្ដាយនារីរងគ្រោះបានមកដាក់ពាក្យបណ្ដឹងឲ្យជួយអន្តរាគមន៍កូនស្រីគាត់ តាមរយៈអង្គការពាក់ព័ន្ធនានា ក៏ដូចជាមកការិយាល័យនគរបាលជំនាញ ។ ក្រោយការទទួលបានពាក្យបណ្ដឹង កម្លាំងនគរបាលជំនាញបានចុះស្រាវជ្រាវ និងឈានឲ្យមានការចាប់ខ្លួនស្ត្រីជាមុខសញ្ញាមេខ្យល់រូបនេះបាន។ ដោយលោកស្រីអះអាងថា ចំពោះនារីរងគ្រោះ ដែលត្រូវបានក្រុមមេខ្យល់បោកនាងយកទៅលក់នេះក៏ត្រូវបានអាជ្ញាធរប្រទេសទាំងពីរកំពុងតែទំនាក់ទំនងគ្នា ដើម្បីនាំនាងត្រឡប់មកស្រុកកំណើតវិញ ។

# ថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០១៨

## សម្ដេចតេជោ ហ៊ុន សែន ស្នើដល់ក្រសួងអប់រំ និងក្រសួងសង្គមកិច្ច ត្រៀមទទួលយកមជ្ឈមណ្ឌលនានាក្រោយពេលជំនួយបរទេសដកថយ

http://akpnews.info/kh/ AKP ភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានមានប្រសាសន៍ស្នើឱ្យក្រសួងអប់រំយុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតត្រៀមទទួលយកដូចជា មជ្ឈមណ្ឌលកុមារកំព្រា។ល។ ដើម្បីមកទទួលរ៉ាប់រងដោយខ្លួនឯង ក្រោយពេលដែលជំនួយរបស់បរទេសបានដកថយ ទៅកាន់កន្លែងផ្សេងនោះ។

ការលើកឡើងរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រីបានធ្វើឡើង ក្នុងខណៈដែលសម្ដេច និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អញ្ជើញសួរសុខទុក្ខ ព្រមទាំងរៀបចំអាហារជូនកុមារពិការគ-ថ្លង់ និងកុមារកំព្រា មកពីសាលាគ្រួសារថ្មី និងមណ្ឌលកុមារកំព្រានានាក្នុងរាជធានីភ្នំពេញ ចំនួន៨៧៨នាក់ នាព្រឹកថ្ងៃអាទិត្យ១១ កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានថ្លែងទាក់ទងជាមួយនឹងជំនួយរបស់បរទេសដែលកំពុងជួយលើវិស័យមួយចំនួននៅកម្ពុជាថា ពេលដែលក្ខខណ្ឌសេដ្ឋកិច្ចនៅកម្ពុជាកើនឡើងអ្នកផ្ដល់ជំនួយគេនឹងដកថយជំនួយនោះ ទៅឱ្យប្រទេសដទៃដែលមិនមានលក្ខខណ្ឌអនុគ្រោះដូចកម្ពុជា។ សម្ដេចតេជោបានបញ្ជាក់ថា "ប្រទេសយើងគ្រាន់តែបញ្ជាខ្ចីលុយគេ បើយើងនៅក្រ ខ្ចីលុយគេត្រឹមអាត្រាការប្រាក់សម្បទាន ប៉ុន្តែបើយើងឡើងឋានៈក្លាយទៅជាប្រទេសដែលមានចំណូលសមល្មមហើយ គឺយើងខ្ចីលុយគេត្រូវទទួលអាត្រាការប្រាក់ពាណិជ្ជកម្មតែម្ដង ព្រោះភាពអនុគ្រោះទាំងឡាយ ត្រូវបានផ្ដល់តែប្រទេសអភិវឌ្ឍន៍តិចតួចតែប៉ុណ្ណោះ"។ សម្ដេចតេជោបានបន្តថា ពេលដែលមានការកើនឡើងសេដ្ឋកិច្ច គឺគេនឹងដកថយ ដើម្បីផ្ទេរជំនួយនោះទៅកាន់ទីកន្លែងផ្សេងដែលមានការលំបាក។ ដូច្នេះទាំងផ្នែកសង្គមកិច្ច ទាំងផ្នែកអប់រំ ត្រូវត្រៀមទទួលយកនៅបណ្ដាមជ្ឈមណ្ឌលទាំងឡាយ ដើម្បីយើងទទួលរ៉ាប់រងខ្លួនឯង។ សម្ដេចតេជោបានអះអាងថា ហេតុនេះហើយបានជាទំហំថវិកាទៅលើវិស័យអប់រំ វិស័យសុខាភិបាល វិស័យសង្គមកិច្ច កាន់តែធំទៅៗ ហើយដែលនេះគឺជាការទទួលរបស់យើងចំពោះប្រទេសមួយនេះ។

នៅក្នុងពិធីនោះដែរ សម្ដេចតេជោនាយករដ្ឋមន្ត្រីបានលើកឡើងថា រាជរដ្ឋាភិបាល កំពុងយកចិត្តទុកដាក់លើបញ្ហាស្ត្រីមានផ្ទៃពោះ និងស្ត្រីឆ្លងទន្លេ ទៅក្នុងគោលនយោបាយគាំពារសង្គម ដែលក្នុងនោះ កត្តាអាហារូបត្ថម្ភវាក៏អាចជួយ ដើម្បីជំនះនូវការលំបាកទាក់ទងជាមួយ និងស្ថានភាពទារកដែលកើតឡើងក្លាយទៅជាជនពិការតាំងពីកំណើត។ ទន្ទឹមនេះ យើងចង់ឱ្យប្រជាពលរដ្ឋរបស់យើង កើតមកមានកាយសម្បទាល្អ មានបញ្ញាឈ្លាសវៃ ដែលអាចឈានទៅរកប្រទេសមួយដែលមានការរីកលូតលាស់។ សម្ដេចតេជោ ហ៊ុន សែន ក៏បានបន្តការដាស់តឿនដល់កុមារគ ថ្លង់ទាំងអស់ត្រូវខិតខំរៀនសូត្រ បើទោះបីជាកាយសម្បទា មិនគ្រប់គ្រាន់ក្ដី ក៏ប៉ុន្តែការមិនគ្រប់គ្រាន់ខាងកាយសម្បទានាសម័យនេះ បើសិនជាយើងចេះជម្នះវា ការមិនគ្រប់គ្រាន់ខាងកាយសម្បទានោះ វាមិនមែនជា

ឧបសគ្គនៃការអភិវឌ្ឍខ្លួននោះទេ។ សម្តេចតេជោបានបន្ថែមថា ព្រោះឥឡូវនេះ វាមានអក្សរស្ទាប និងកាបកប្រែភាសាជាកាយវិការ ដែលធ្វើឱ្យកុមារ គ ថ្លង់ និងពិការភ្នែកមួយ ចំនួន បានទទួលការបណ្តុះបណ្តាលរហូតទៅដល់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ដែល បច្ចុប្បន្ននេះមានកុមារ គ ថ្លង់ មួយចំនួនកំពុងធ្វើការនៅស្ថាប័នរដ្ឋ និងវិស័យឯកជនផងដែរ។ សម្តេចតេជោក៏បានអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធ និងលោកគ្រូ អ្នកគ្រូ ឱ្យបន្តការយកចិត្តទុកដាក់ ក្នុការថែទាំ កុមារ គ ថ្លង់ទាំងអស់ឱ្យបានល្អ ដើម្បីឱ្យពួកគេទទួលបានការអប់រំមួយខ្ពស់ និងអាចម្ចាស់ការលើខ្លួនឯងបាននាពេលអនាគត៕ ដោយ ជឹម ណារី

## ទីតាំងម៉ាស្សាបង្កប់សេវាផ្លូវភេទ១កន្លែង នគរបាលបង្ក្រាបនិងឃាត់ខ្លួនមនុស្ស៦នាក់ នៅភ្នំពេញ

http://www.arey-news.com/ ( ថ្ងៃទី 19 November 2018 ម៉ោង 9:07 pm )

(ភ្នំពេញ)៖ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅផ្ទះលេខ៣២B ផ្លូវ២១៧ ម្តុំប្រមុះជ្រូកស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ «វណ្ណនី រីករាយ» មានបង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន ឃាត់ខ្លួនមនុស្សចំនួន៦នាក់ ក្នុងនោះម្ចាស់ទីតាំងម្នាក់ និងនារីរងគ្រោះចំនួន៥នាក់។ ក្នុងប្រតិបត្តិការនេះ ដោយមានចង្អុលបង្ហាញពីឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការសម្របសម្រួលពីលោក គុជ គីមឡុង ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមានការបញ្ជាផ្ទាល់ដោយសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ម្ចាស់ទីតាំងមានឈ្មោះ ហួត សុវណ្ណនី ភេទស្រី អាយុ៣៦ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ៣២B ផ្លូវ២១៧ ម្តុំប្រមុះជ្រូកស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យរាជធានីភ្នំពេញ។ ទីតាំងម៉ាស្សាកោសជប់ឃីហោ «វណ្ណនី រីករាយ» ចាប់ផ្តើមបើកបម្រើសេវាចាប់ពីម៉ោង១០៖០០ព្រឹក រហូតដល់ម៉ោង២៖០០ រំលងអាធ្រាត ដោយមាននារីក្មេងចាស់ចំនួន៥នាក់ រង់ចាំភ្ញៀវមកម៉ាស្សា និងរួមភេទ ដោយតម្លៃរួមភេទ១លើក ចាប់ពី២០ដុល្លារអាមេរិក ទៅ២៥ដុល្លារអាមេរិក។ ប្រតិបត្តិការនេះ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនមនុស្សចំនួន៦នាក់ ក្នុងនោះនារីរងគ្រោះចំនួន ៥នាក់ ដែលមានអនីតិជន២នាក់ អាយុ១៤ឆ្នាំ និងអាយុ១៦ឆ្នាំ និងម្ចាស់ទីតាំងស្រីម្នាក់។ ម្ចាស់ទីតាំងត្រូវបាននាំខ្លួនយកមកការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីបន្តការសាកសួរតាមនីតិវិធី។ ចំណែកឯនារីរងគ្រោះទាំង៥នាក់នោះ ត្រូវបាន សមត្ថកិច្ចប្រគល់ជូនអង្គការសង្គមកិច្ច ដើម្បីធ្វើការអប់រំ៕

## ឯកឧត្តម អ៊ិត សំហេង ៖ ក្រុមហ៊ុនត្រូវធានានូវសុវត្ថិភាព ផាសុខភាព ភាពត្រឹមត្រូវ សេចក្តីថ្លៃថ្នូ លក្ខខណ្ឌការងារ ជូនដល់បងប្អូនពលករិនីកម្ពុជា

http://www.mlvt.gov.kh/ Monday, 19 November 2018 17:14 Written by MLVT

(ភ្នំពេញ)៖ ថ្លែងក្នុងពិធីដាក់ឱ្យដំណើរការក្រុមហ៊ុន INTERNATIONAL EASY REACH CO., LTD ជាក្រុមហ៊ុនដែលធ្វើការជ្រើសរើស បណ្តុះបណ្តាល គ្រប់គ្រង និងបញ្ជូនពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង នារសៀលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើដល់ក្រុមហ៊ុនមួយនេះ ត្រូវបន្តការយកចិត្តទុកដាក់ ខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាសម្របសម្រួលនាំចេញពលករទៅកាន់ទីក្រុងហុងកុង ប្រកបដោយជោគជ័យ ដោយគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីធានាបាននូវសុវត្ថិភាព ផាសុខភាព ភាពត្រឹមត្រូវ សេចក្តីថ្លៃថ្នូ ពិសេសការធានាបាននូវលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរឡើង ជូនដល់បងប្អូនពលការិនីកម្ពុជា ដែលនឹងចេញទៅបម្រើការងារជាជំនួយការផ្ទះនៅទីក្រុងហុងកុង នាពេលខាងមុខឆាប់ៗនេះ។

ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានប្រសាសន៍លើកឡើងថា រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពិសេសការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់ នៅក្រៅប្រទេស, ទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារដោយខុសច្បាប់, លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ, កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេរបេបសន្តិសុខសង្គមមកក្នុងប្រទេស,ការផ្តល់ប្រឹក្សាការងារធ្វើ និង ការបង្កើតមុខរបរដោយខ្លួនឯង។ ជាក់ស្តែង ដើម្បីឱ្យការបញ្ជូនពលការិនីជំនួយការផ្ទះទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុងទទួលបានជោគជ័យ សម្រាប់ដំណាក់កាលសាកល្បងដំបូង នៅឆ្នាំ២០១៧កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយសមាគមអភិវឌ្ឍធនធានមនុស្សកម្ពុជានៅហុងកុងដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើការផ្តល់សេវាគាំពារ និងសេវាគាំទ្រនានាសម្រាប់ពលការិនីជំនួយការផ្ទះ និងផ្សព្វផ្សាយណែនាំអំពីពលការិនីជំនួយការផ្ទះកម្ពុជាទៅដល់និយោជកហុងកុង។

សព្វថ្ងៃនៅទីក្រុងហុងកុងមានពលករបរទេសបម្រើការងារផ្ទះ មានចំនួនប្រហែល ៣៥៧ ០០០នាក់ ភាគច្រើនជាជនជាតិហ្វីលីពីន និងឥណ្ឌូនេស៊ី ដោយពួកគេទទួលបានសិទ្ធិ និងលក្ខខណ្ឌការងារដូចពលករហុងកុងដែរ ដោយរួមមាន៖

- ការឈប់សម្រាកប្រចាំសប្តាហ៍
- ការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួល ចំនួន៧ ថ្ងៃ ទៅ១៤ថ្ងៃ ក្នុង១ឆ្នាំ
- ការឈប់សម្រាកលំហែមាតុភាព ចំនួន១០សប្តាហ៍
- ការធានារ៉ាប់រងពេលមានជំងឺ
- ផ្តល់បន្ថែមប្រាក់លើកទឹកចិត្តសម្រាប់ពលករដែលបម្រើការងារយូរឆ្នាំ។

រដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង បានដាក់អោយមាននូវកិច្ចសន្យាការងារស្តង់ដាសម្រាប់គាំពារបន្ថែមជូនដល់ពលករបរទេសបម្រើ ការងារតាមផ្ទះ រួមមានប្រាក់បៀវត្សទាបបំផុតត្រឹម ប្រមាណ៥៧០ដុល្លារអាមេរិក ដែលនឹងត្រូវត្រួតពិនិត្យឡើងវិញជាទៀងទាត់ ការផ្តល់អាហារ ឬប្រាក់ហូបចុកចំនួន ១៣៣ដុល្លារអាមេរិក ក្នុង១ខែ ការស្នាក់នៅសមរម្យដោយមិនគិតថ្លៃ ការចេញថ្លៃសំបុត្រយន្តហោះត្រឡប់មកវិញ និងការព្យាបាលជំងឺដោយមិនគិតថ្លៃ។ល។ គួរបញ្ជាក់ថា បច្ចុប្បន្នប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសបាន ចំនួន៦ប្រទេសគឺ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន និងសឹង្ហបូរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់។ ហើយកន្លងមកពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ។ នៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញ ពួកគាត់នឹងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពីព្រោះតាមរយៈការធ្វើការងារនៅបរទេស ពួកគាត់មិនត្រឹមតែអាចរកប្រាក់ចំណូលបានបន្ថែមទេ ថែមទាំងទាំងទទួលបាននូវជំនាញ បទពិសោធន៍ ចំណេះដឹងភាសា និងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង៕

# ក្រសួងការបរទេស៖ អនុស្សារណៈស្តីពីការ ធ្វើមាតុភូមិនិវត្តន៍ របស់ពលរដ្ឋខ្មែរពីអាមេរិកនៅ តែបន្ត

https://www.dap-news.com/ ByID:030 Posted on 19 November 2018 | 19:49

ភ្នំពេញ៖ លោក កេត សោផាន់ អ្នកនាំពាក្យក្រសួងការ បរទេសខ្មែរបាន បញ្ជាក់ថាការទទួលយកពលរដ្ឋខ្មែរ ដែលបានប្រព្រឹត្តខុស ច្បាប់ហើយផុតទោស នៅអាមេរិកនៅតែបន្តជានិច្ចពោល គឺគ្មានការលុបចោល អនុស្សារណៈ (MOU) ស្តីពីការធ្វើមាតុភូមិនិវត្តន៍ របស់ពលរដ្ឋខ្មែរ ពីអាមេរិកនោះទេ។

សូមរំលឹកថា រាជរដ្ឋាភិបាលកម្ពុជា និងអាមេរិកបានចុះអនុស្សារណៈ (MOU) ស្តីពីការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរពីអាមេរិកកាលពីឆ្នាំ២០០២។ ហើយក្នុងចំណោមពលរដ្ឋខ្មែរ-អាមេរិកកាំងដែលត្រូវបានរដ្ឋាភិបាលអាមេរិក បញ្ជូនមកកម្ពុជា ចំនួន៤៣នាក់ កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ ត្រូវបានសាច់ញាតិ ទទួលយកអស់មួយចំនួនខណៈអ្នកនៅសេសសល់ កំពុងស្រាវជ្រាវ រកសាច់ញាតិ និងអ្នកផ្សេងទៀត មិនមានសាច់ញាតិនោះទេ។

លោក កេត សោផាន់បានថ្លែងប្រាប់ ក្រុមអ្នកសារព័ត៌មានក្រោយ ជំនួបរវាង លោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសខ្មែរ និងលោក William A. Heidt ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចប់អាណត្តិប្រចាំកម្ពុជានៅថ្ងៃទី១៩ ខែ វិច្ឆិកានេះថា"គម្រោងនៃការធ្វើមាតុភូមិនិវត្តន៍ របស់ប្រជាជនកម្ពុជាដែលភាគច្រើនគាត់បានទៅសហរដ្ឋអាមេរិកក្រោយ ឆ្នាំ១៩៩៤ ហើយជាក់ស្តែងនៅឆ្នាំ២០១៧ពេញមួយឆ្នាំគឺយើងទទួលពួកគាត់ ១០០នាក់។យើងនឹងបន្តកម្មវិធីនេះតទៅទៀត ដោយតាមការពិភាក្សានោះយើងអាចរក វិធីសាស្ត្រយ៉ាងណាដូចជាការធ្វើបទ សម្ភាសន៍ចំពោះពួកគាត់ព្រោះពួកគាត់ទៅ ដល់អាមេរិកយូរហើយនិងគ្មាន ឯកសាររដ្ឋបាលដើម្បីបញ្ជាក់អ្វីទេអីចឹងយើង រកវិធីសម្រួល"។

យោងតាមរបាយការណ៍ ស្តីពីសកម្មភាពការងារ របស់អគ្គនាយកដ្ឋាន អន្តោប្រវេសន៍ប្រចាំឆ្នាំ២០១៦ បានឲ្យដឹងថា គិតត្រឹម ឆ្នាំ២០១៧ ពលរដ្ឋខ្មែរនៅអាមេរិក ដែលបានធ្វើមាតុភូមិនិវត្តន៍ មាន ចំនួន២២៦លើក ក្នុងនោះមានពលរដ្ឋ៥៤៤នាក់ ស្រី១៤នាក់។

លោក កេត សោផាន់ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បានលើកឡើងបន្ថែមថា ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរីករាយស្វាគមន៍ និងត្រៀមសហការធ្វើការយ៉ាងជិតស្និទ ជាមួយ លោក Patrick Murphy ដែលនឹងត្រូវបន្តតួនាទីបំពេញបេសកកម្ម ជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជាក្រោយមានការឯកភាព ពីព្រឹទ្ធសភាសហរដ្ឋអាមេរិក។

លោក William A. Heidt ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចប់អាណត្តិប្រចាំកម្ពុជា ក៏បានថ្លែងអំណរគុណចំពោះឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ដែលតែងតែបើកចំហរការជួបពិភាក្សាការងារជាមួយលោកក្នុងពេលកន្លងមក។ លោក William A. Heidt បានសម្តែងក្តីរំពឹងថា ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុននឹងដឹកនាំក្រសួងការបរទេសកម្ពុជាប្រកបដោយលក្ខណៈបើកចំហរហើយទូតថ្មីរបស់អាមេរិកអាចនឹងអញ្ជើញធ្វើបទឧទ្ទេសនាមនៅវិទ្យាស្ថានការទូត និងទំនាក់ទំនងអន្តរជាតិនៃក្រសួងការបរទេសកម្ពុជា។

ទន្ទឹមនេះឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ក៏បានសម្តែងការរីករាយដែលចំណងទំនាក់ទំនងនៃប្រទេសកម្ពុជា និងអាមេរិកនៅតែបន្តរីកចម្រើន ហើយប្រទេសទាំងពីរតែងតែបើកចំហរការប្រាស្រ័យទាក់ទ្នា។ ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានថ្លែងអំណរគុណដល់សហរដ្ឋអាមេរិក ដែលនៅបន្តគាំទ្រ និងផ្តល់ជំនួយសម្រាប់សកម្មភាពកំចាត់មីនកម្ពុជា ដើម្បីកំណត់គោលដៅឲ្យកម្ពុជាក្លាយជាប្រទេសគ្មានមីននៅឆ្នាំ២០២៥។ ជាពិសេសកម្ពុជា និងអាមេរិកនៅតែបន្តកិច្ចសហការគ្នាលើការប្រឆាំងភេរវកម្ម ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនជាដើម៕

# រដ្ឋមន្ត្រីក្រសួងការងារៈទីក្រុងហុងកុងគឺជាទីផ្សារគោលដៅ និងមានតំរូវការកម្លាំងពលកម្មខ្ពស់

http://www.rasmeinews.com/ November 19, 2018, 9:42 PM

ដោយៈដេប៉ូ / ភ្នំពេញៈលោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងថា នាពេលបច្ចុប្បន្ននេះគេឃើញថាទីក្រុងហុងកុងគឺជាទីផ្សារគោលដៅមួយដ៏សំខាន់របស់កម្ពុជា ហើយក៏គេត្រូវយកចិត្តទុកដាក់ផងដែរ។ លោក អ៊ិតសំហេង រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងពិធីសម្ពោធ ដាក់ឱ្យដំណើរការក្រុមហ៊ុន INTERNATIONAL EASY REACH CO., LTD កាលពីល្ងាចថ្ងៃទី១៩ខែវិច្ឆិកាឆ្នាំ២០១៨។

ការបញ្ជាក់ឱ្យដឹងរបស់លោករដ្ឋមន្ត្រីក្រសួងការងារបែបនេះធ្វើឡើងក្នុងពិធី សម្ពោធ ដាក់ឱ្យដំណើរការក្រុមហ៊ុន INTERNATIONAL EASY REACH CO., LTD កាលពីល្ងាចថ្ងៃទី១៩ខែវិច្ឆិកាឆ្នាំ២០១៨កន្លងមក។ ទាក់ទិនទៅនឹងការជ្រើសរើសពលករកម្ពុជាទៅបម្រើការងារនៅទីក្រុងហុងកុងនេះដែរលោករដ្ឋមន្ត្រីបានលើកឡើងថា ក្រុមហ៊ុន Easy ReachInternational Col., Ltd បានអភិវឌ្ឍន៍ខ្លួន និងរៀបចំទីតាំងក្រុមហ៊ុនដោយមានបំពាក់នូវឧបករណ៍ សម្ភារៈបរិក្ខារ ឆ្លើយតបទៅនឹងកម្មវិធីបណ្តុះបណ្តាលជំនាញមេផ្ទះ ដើម្បីអាចឱ្យសិក្ខាកាមពលការិនីមានសមត្ថភាព និងជំនាញគ្រប់គ្រាន់ ចេញទៅបម្រើការងារជាជំនួយការផ្ទះនៅតំបន់រដ្ឋបាលពិសេសហុងកុង។ លោកបានមានប្រសាសន៍ថា បច្ចុប្បន្ន ប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសបានចំនួន៦ ប្រទេស គឺ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន និងសឹង្ហ បូរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់។កន្លងមកពួកគាត់បានផ្ញើរថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ។

លោកបានបញ្ជាក់ថា "ជាក់ស្តែង ដើម្បីឱ្យការបញ្ជូនពលការិនីជំនួយការផ្ទះទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុងទទួលបានជោគជ័យ សម្រាប់ដំណាក់កាលសាកល្បងដំបូង នៅឆ្នាំ២០១៧កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយសមាគមអភិវឌ្ឍធនធានមនុស្សកម្ពុជានៅហុងកុង ដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើការផ្តល់សេវាគាំពារ និងសេវាគាំទ្រនានាសម្រាប់ពលការិនីជំនួយការផ្ទះ និងផ្សព្វផ្សាយណែនាំអំពីពលការិនីជំនួយការផ្ទះកម្ពុជាទៅដល់និយោជកហុងកុង"។លោកថារដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង បានដាក់ឱ្យមាននូវកិច្ចសន្យាការងារស្តង់ដាសម្រាប់គាំពារបន្ថែមជូនដល់ពលករបរទេសបម្រើ ការងារតាមផ្ទះ រួមមានប្រាក់បៀវត្សទាបបំផុតត្រឹម ប្រមាណ៥៧០ដុល្លារអាមេរិក ដែលនឹងត្រូវត្រួតពិនិត្យឡើងវិញជាទៀងទាត់ ការផ្តល់អាហារ ឬប្រាក់ហូបចុកចំនួន ១៣៣ដុល្លារអាមេរិក ក្នុង១ខែ ការស្នាក់នៅសមរម្យដោយមិនគិតថ្លៃ ការចេញថ្លៃសំបុត្រយន្តហោះត្រឡប់មកវិញ និងការព្យាបាលជំងឺដោយមិនគិតថ្លៃ។ល។

ដោយឡែក លោកស្រីយូឆេង តំណាងឱ្យក្រុមហ៊ុន INTERNATIONAL EASY REACH CO., LTD បានឱ្យដឹងថា ពលករកម្ពុជាដែលត្រូវបានជ្រើសរើសនេះ នឹងត្រូវបានបណ្តុះបណ្តាលមុននឹងបញ្ជូន។ ចំពោះកិច្ចការងារដែលត្រូវបំពេញនោះរួមមាន អ្នកចុងភៅ អ្នកថែទាំមនុស្សចាស់និងកុមារជាដើម។ សម្រាប់ប្រាក់ឈ្នួលគឺ ៥៧០ដុល្លារក្នុងមួយខែ។

គួរបញ្ជាក់ថាទីក្រុងហុងកុងមានពលករបរទេសបម្រើការងារផ្ទះ មានចំនួនប្រហែល ៣៥៧ ០០០នាក់ ភាគច្រើនជាជនជាតិហ្វីលីពីន និងឥណ្ឌូនេស៊ី ដោយពួកគេទទួលបានសិទ្ធិ និងលក្ខខណ្ឌការងារដូចពលករហុងកុងដែរ ដោយរួមមានៈ ការឈប់សម្រាកប្រចាំសប្តាហ៍ ,ការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួល ចំនួន៧ ថ្ងៃទៅ១៤ថ្ងៃ ក្នុង១ឆ្នាំ ការឈប់សម្រាកលំហែមាតុភាព ចំនួន១០សប្តាហ៍ ការធានារ៉ាប់រងពេលមានជំងឺ ផ្តល់បន្ថែមប្រាក់លើកទឹកចិត្តសម្រាប់ពលករដែលបម្រើការងារយូរឆ្នាំ៕ ល

## តុលាការកំពូលបង្វិលសំណុំរឿងនាំស្រីរៀបការប្តីចិន

https://www.postkhmer.com/ គឹម សារុំ | Publication date 20 November 2018 | 08:30 ICT

**ភ្នំពេញៈ** តុលាការកំពូលកាលពីម្សិលមិញបានសម្រេចបង្គាប់ឲ្យសាលាឧទ្ធរណ៍ជម្រះឡើងវិញនូវសំណុំរឿងស្ត្រីជាប់ចោទម្នាក់រឿងនាំនារីខ្មែរទៅរៀបការប្តីនៅចិន ជាការសម្រេចបន្ទាប់ពីជំនុំជម្រះកាលពីថ្ងៃទី ១២ ខែវិច្ឆិកា ខណៈដែលរឿងនេះត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់គុក ៨ ឆ្នាំ។

នៅក្នុងបន្ទប់សវនាការកាលពីម្សិលមិញលោកចៅក្រម ស៊ឹង បញ្ញាវុឌ្ឍ បានអានសាលដីកានៅចំពោះស្ត្រីជាប់ចោទថា ក្រោយពីបានសួរដេញដោល និងស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ និងមេធាវីជនជាប់ចោទមកក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា៖ «សំណុំរឿងដែលមានជនជាប់ចោទឈ្មោះ វ៉ន ស្រីម៉ុម អាយុ ៣២ ឆ្នាំ ដែលតុលាការកំពូលបើកការជំនុំជម្រះកាលពីថ្ងៃទី១២ ខែវិច្ឆិកាគឺពេលនេះតុលាការកំពូលសម្រេចបង្វិលសំណុំរឿងនេះឲ្យសាលាឧទ្ធរណ៍ជម្រះឡើងវិញដោយសារមានចំណុចខ្លះគឺសាលាឧទ្ធរណ៍សម្រេចមិនត្រឹមត្រូវតាមច្បាប់ទេ»។

លោកស្រី អ៊ុង ស៊ីឡេត មេធាវីការពារសិទ្ធិឲ្យស្ត្រីជាប់ចោទបានប្រាប់តាមទូរស័ព្ទពីម្សិលមិញថា ការបង្វិលសំណុំរឿងកូនក្តីលោកស្រីឱ្យជម្រះឡើងវិញនេះជាការល្អ ព្រោះសាលាឧទ្ធរណ៍មិនទាន់បានពិចារណាឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់លើការសម្រេចរបស់សាលាដំបូងខេត្តកណ្តាល។ លោកស្រីថ្លែងថា៖ «តុលាការកំពូលបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍នេះជាការត្រឹមត្រូវហើយ ព្រោះតុលាការកំពូលយល់ថា កាលពីជំនុំជម្រះលើកមុន មិនបានត្រឹមត្រូវតាមផ្លូវច្បាប់»។

គួររំឭកថាកាលពីថ្ងៃបើកសវនាការ ស្ត្រីជាប់ចោទ វ៉ន ស្រីម៉ុម បានឆ្លើយប្រាប់ចៅក្រមថា ការចោទប្រកាន់របស់សមត្ថកិច្ចថាគាត់នាំនារីរងគ្រោះឲ្យទៅរៀបការនៅចិននោះគឺមិនពិតទេ តែគាត់គ្រាន់តែបានឲ្យលេខទូរស័ព្ទរបស់នារីនេះទៅបុរសម្នាក់ឈ្មោះ ភូ តុងណាំ ប៉ុណ្ណោះ ដោយដឹងថាបុរសនោះជាអ្នករកស៊ីរត់ការរឿងនេះស្រាប់។ ស្រី ម៉ុម បញ្ជាក់ថា៖ «ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាបានផ្តល់លេខទូរស័ព្ទនារីរងគ្រោះឲ្យទៅបុរសនោះពិតមែន។ ខ្ញុំសុំឲ្យតុលាការរកយុត្តិធម៌ដល់ខ្ញុំផង ព្រោះខ្ញុំមានកូនតូចដល់ទៅ ៦ នាក់រស់នៅវេទនាណាស់ជាមួយជីដូនចាស់»។

តាមកំណត់ហេតុរបស់តុលាការបង្ហាញថា កាលពីអំឡុងឆ្នាំ ២០១៥ នារីរងគ្រោះ ឈ្មោះ ស.រ.ថ អាយុ ២៥ ឆ្នាំមានបំណងទៅប្រទេសចិនរួចក៏បានទាក់ទងជាមួយស្ត្រីជាប់ចោទ ហើយដោយស្ត្រីជាប់ចោទស្គាល់បុរសឈ្មោះ ភូ តុងណាំ ដែលជាអ្នកធ្លាប់រត់ការរឿងនេះក៏ឲ្យលេខទូរស័ព្ទនារីរងគ្រោះទៅបុរសនោះ ហើយក៏ឈានដល់ការរត់ការរហូតបានរៀបការប្តីចិន។ ប៉ុន្តែដោយនារីរងគ្រោះជួបបញ្ហាប្តីចិនធ្វើបាបក៏ទូរស័ព្ទមកប្រាប់ក្រុមគ្រួសារ ហើយដោយចង់បានកូនស្រីត្រឡប់មកកម្ពុជាវិញ ម្តាយឪពុកនារីរងគ្រោះបានប្តឹងទៅនគរបាលខេត្តកណ្តាល ហើយត្រូវសមត្ថកិច្ចកសាងសំណុំរឿងទៅសាលាដំបូងខេត្តកណ្តាល តែមិនទាន់ឃាត់ទេ៕

## ពលករនិកម្ពុជានៅបរទេស អាចរកប្រាក់ចំណូលបន្ថែម ថែមទាំងទាំងទទួលបាន នូវជំនាញ បទពិសោធន៍ ចំណេះដឹងភាសា

http://www.cen.com.kh/archives/ November 20, 2018

ភ្នំពេញ ៖ បច្ចុប្បន្នប្រទេសកម្ពុជា បានបញ្ជូនពលករ ទៅបម្រើការងារ នៅបរទេសបានចំនួន៦ ប្រទេសគឺ ប្រទេសថៃ សាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន និងសឹង្ហបូរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ ១លាន២សែននាក់។ ហើយកន្លងមក ពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាព ក្រុមគ្រួសាររបស់ពួកគាត់ ប្រមាណជាង២ពាន់លានដុល្លារ ក្នុង១ឆ្នាំៗ។ នៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញ ពួកគាត់នឹងក្លាយជាធនធានមនុស្ស ដ៏សំខាន់ ក្នុងការចូលរួម អភិវឌ្ឍសេដ្ឋកិច្ចជាតិ ពីព្រោះតាមរយៈ ការធ្វើការងារ

នៅបរទេស ពួកគាត់មិនត្រឹមតែអាចរកប្រាក់ចំណូល បានបន្ថែមទេ ថែមទាំងទាំងទទួលបាន នូវជំនាញ បទពិសោធន៍ ចំណេះដឹងភាសា និងរបៀបរបបរស់នៅ ក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង។

ថ្លែងក្នុងពិធីដាក់ឱ្យដំណើរការក្រុមហ៊ុន INTERNATIONAL EASY REACH CO., LTD ជាក្រុមហ៊ុនដែលធ្វើការជ្រើសរើសបណ្តុះ បណ្តាល គ្រប់គ្រង និងបញ្ជូនពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង នារសៀលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើដល់ក្រុមហ៊ុនមួយនេះ ត្រូវបន្តការយកចិត្តទុកដាក់ ខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាសម្របសម្រួលនាំចេញពលករទៅកាន់ទីក្រុងហុងកុង ប្រកបដោយជោគជ័យ ដោយគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីធានាបាននូវសុវត្ថិភាព ផាសុកភាព ភាពត្រឹមត្រូវ សេចក្តីថ្លៃថ្នូ ពិសេសការធានាបាននូវលក្ខ ខណ្ឌការងារ ឱ្យកាន់តែល្អប្រសើរឡើង ជូនដល់បងប្អូនពលការិនីកម្ពុជា ដែលនឹងចេញទៅបម្រើការងារជាជំនួយការផ្ទះនៅទីក្រុងហុងកុង នាពេលខាងមុខឆាប់ៗនេះ។

លោក អ៊ិត សំហេង បានប្រសាសន៍លើកឡើងថា រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពិសេសការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេរភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់ នៅក្រៅប្រទេស, ទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារដោយខុសច្បាប់, លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ, កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស,ការផ្តល់ប្រឹក្សាការងារធ្វើ និង ការបង្កើតមុខរបរ ដោយខ្លួនឯង។

ជាក់ស្តែង ដើម្បីឱ្យការបញ្ជូនពលការិនីជំនួយការផ្ទះទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុងទទួលបានជោគជ័យ សម្រាប់ដំណាក់កាលសាកល្បងដំបូង នៅឆ្នាំ២០១៧កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយសមាគមអភិវឌ្ឍធនធានមនុស្សកម្ពុជានៅហុងកុង ដើម្បីធ្វើកិច្ចសហប្រតិបត្តិការលើការផ្តល់សេវាគាំពារ និងសេវាគាំទ្រនានាសម្រាប់ពលការិនីជំនួយការផ្ទះ និងផ្សព្វផ្សាយណែនាំអំពីពលការិនីជំនួយការផ្ទះកម្ពុជាទៅដល់និយោជកហុងកុង។ សព្វថ្ងៃនៅទីក្រុងហុងកុងមានពលករបរទេសបម្រើការងារផ្ទះ មានចំនួនប្រហែល ៣៥៧.០០០នាក់ ភាគច្រើនជាជនជាតិហ្វីលីពីន និងឥណ្ឌូណេស៊ី ដោយពួកគេទទួលបានសិទ្ធិ និងលក្ខខណ្ឌការងារដូចពលករហុងកុងដែរ ដោយរួមមាន៖

ការឈប់សម្រាកប្រចាំសប្តាហ៍ ការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួល ចំនួន៧ ថ្ងៃ ទៅ១៤ថ្ងៃ ក្នុង១ឆ្នាំ ការឈប់សម្រាក លំហែមាតុភាព ចំនួន១០សប្តាហ៍ ការធានារ៉ាប់រងពេលមានជំងឺ ផ្តល់បន្ថែមប្រាក់លើកទឹកចិត្តសម្រាប់ពលករដែលបម្រើការងារយូរឆ្នាំ។

រដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង បានដាក់ឲ្យមាននូវកិច្ចសន្យាការងារស្តង់ដារ សម្រាប់គាំពារបន្ថែមជូនដល់ ពលករបរទេសបម្រើ ការងារតាមផ្ទះ រួមមានប្រាក់បៀវត្សរ៍ទាបបំផុតត្រឹម ប្រមាណ៥៧០ដុល្លារអាមេរិក ដែលនឹងត្រូវត្រួតពិនិត្យឡើងវិញជាទៀងទាត់ ការផ្តល់អាហារ ឬប្រាក់ហូបចុកចំនួន ១៣៣ដុល្លារអាមេរិកក្នុង១ខែ ការស្នាក់នៅសមរម្យដោយមិនគិតថ្លៃ ការចេញថ្លៃសំបុត្រយន្តហោះត្រឡប់មកវិញ និងការព្យាបាលជំងឺដោយមិនគិតថ្លៃ។ល៕ ដោយ ៖ បញ្ញាស័ក្តិ

# កម្ពុជាបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសចំនួនប្រមាណ១លាន២សែននាក់

ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ម៉ោង ១០:៤៧ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ បច្ចុប្បន្នប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសមានពលករសរុបចំនួនប្រមាណ១លាន២សែននាក់ ហើយកន្លងមកពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ។ នេះបើតាមលោករដ្ឋមន្ត្រីក្រសួងការងារ ។

ថ្លែងក្នុងពិធីដាក់ឱ្យដំណើរការក្រុមហ៊ុន INTERNATIONAL EASY REACH CO., LTD ជាក្រុមហ៊ុនដែលធ្វើការជ្រើសរើសបណ្តុះបណ្តាលគ្រប់គ្រង និងបញ្ជូនពលករខ្មែរទៅធ្វើការនៅតំបន់រដ្ឋបាល ពិសេសហុងកុងនារសៀលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានស្នើដល់ក្រុមហ៊ុនមួយនេះត្រូវបន្តការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាសម្របសម្រួលនាំចេញពលករទៅកាន់ទីក្រុងហុងកុង ប្រកបដោយជោគជ័យ ដោយគោរពតាមបទបញ្ញត្តច្បាប់ជាធរមាន ដើម្បីធានាបាននូវសុវត្ថិភាពផាសុខភាព ភាពត្រឹមត្រូវ សេចក្តីថ្លៃថ្នូ ពិសេសការធានាបាននូវលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរឡើងជូនដល់បងប្អូនពលការិនីកម្ពុជាដែលនឹងចេញទៅបម្រើការងារជាជំនួយការផ្ទះនៅទីក្រុងហុងកុង នាពេលខាងមុខឆាប់ៗនេះ ។ លោកបន្តថា រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភាបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពិសេសការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារ ដោយខុសច្បាប់ លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយគ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តតាមរយៈការទទួលស្គាល់ជំនាញការផ្ទេរបេបសន្សិសុខសង្គមមកក្នុងប្រទេស ការផ្តល់ប្រឹក្សាការងារធ្វើ និងការបង្កើតមុខរបរដោយខ្លួនឯង ។

លោករដ្ឋមន្ត្រីបន្ថែមថាជាក់ស្តែង ដើម្បីឱ្យការបញ្ជូនពលការិនីជំនួយការផ្ទះទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុងទទួលបានជោគជ័យសម្រាប់ដំណាក់កាលសាកល្បងដំបូង នៅឆ្នាំ២០១៧ កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះអនុស្សរណៈ នៃកិច្ចព្រមព្រៀងជាមួយសមាគមអភិវឌ្ឍធនធានមនុស្សកម្ពុជានៅហុងកុង ដើម្បីធ្វើកិច្ចសហ ប្រតិបត្តិការលើការផ្តល់សេវាគាំពារ និងសេវាគាំទ្រនានាសម្រាប់ពលការិនីជំនួយការផ្ទះ និង ផ្សព្វផ្សាយណែនាំអំពីពលការិនីជំនួយការផ្ទះកម្ពុជាទៅដល់និយោជកហុងកុង ។ ជាមួយគ្នានោះដែរ លោករដ្ឋមន្ត្រីក៏បានឲ្យដឹងថា សព្វថ្ងៃនៅទីក្រុងហុងកុងមានពលករបរទេសបម្រើការងារផ្ទះមានចំនួនប្រហែល៣៥៧០០០នាក់ ភាគច្រើនជាជនជាតិហ្វីលីពីន និងឥណ្ឌូនេស៊ី ដោយពួកគេទទួលបានសិទ្ធិ និងលក្ខខណ្ឌការងារដូចពលករហុងកុងដែរដោយរួមមាន – ការឈប់សម្រាកប្រចាំសប្តាហ៍ – ការឈប់សម្រាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលចំនួន៧ថ្ងៃទៅ១៤ថ្ងៃ ក្នុង១ឆ្នាំ – ការឈប់សម្រាកលំហែមាតុភាពចំនួន១០សប្តាហ៍ – ការធានារ៉ាប់រងពេលមានជំងឺ – ផ្តល់បន្ថែមប្រាក់លើកទឹកចិត្តសម្រាប់ពលករដែលបម្រើការងារយូរឆ្នាំ ។ លោករដ្ឋមន្ត្រីបានលើកឡើងទៀតថា រដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង បានដាក់ឲ្យមាននូវកិច្ចសន្យាការងារស្តង់ដាសម្រាប់គាំពារបន្ថែមជូនដល់ពលករបរទេសបម្រើការងារតាមផ្ទះ រួមមានប្រាក់បៀវត្សទាបបំផុតត្រឹមប្រមាណ៥៧០ដុល្លារអាមេរិកដែលនឹងត្រូវត្រួតពិនិត្យឡើងវិញជាទៀងទាត់ការផ្តល់អាហារ ឬប្រាក់ហូបចុកចំនួន១៣៣ដុល្លារអាមេរិកក្នុង១ខែ ការស្នាក់នៅសមរម្យដោយមិនគិតថ្លៃ ការចេញថ្លៃសំបុត្រយន្តហោះត្រឡប់មកវិញ និងការព្យាបាលជំងឺដោយមិនគិតថ្លៃ ។

ជាមួយគ្នានោះដែរ លោករដ្ឋមន្ត្រីក៏បានលើកឡើងថា បច្ចុប្បន្នប្រទេសកម្ពុជាបានបញ្ជូនពលករទៅបម្រើការងារនៅបរទេសបានចំនួន៦ ប្រទេស គឺប្រទេសថៃសាធារណរដ្ឋកូរ៉េ ម៉ាឡេស៊ី ជប៉ុន និងសឹង្ហបូរី និងហុងកុង ដែលមានពលករសរុបចំនួនប្រមាណ១លាន២សែននាក់ ។ ហើយកន្លងមកពួកគាត់បានផ្ញើថវិកាមកកម្ពុជា ដើម្បីជួយទ្រទ្រង់ជីវភាពក្រុមគ្រួសាររបស់ពួកគាត់ប្រមាណជាង២ពាន់លានដុល្លារក្នុង១ឆ្នាំៗ ។ នៅពេលបញ្ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកកម្ពុជាវិញ ពួកគាត់នឹងក្លាយជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ ពីព្រោះតាមរយៈការធ្វើការងារនៅបរទេសពួកគាត់មិនត្រឹមតែអាចរកប្រាក់ចំណូលបានបន្ថែមទេ ថែមទាំងទទួលបាននូវជំនាញបទពិសោធន៍ចំណេះដឹងភាសា និងរបៀបរបបរស់នៅក្នុងប្រទេសអភិវឌ្ឍន៍ទៀតផង ៕

## ក្រុមហ៊ុន INTERNATIONAL EASY RECH ត្រៀមបញ្ជូនពលការិនី ៣រូបបន្ថែមទៀតទៅទីក្រុងហុងកុង

http://wmc.org.kh/ ថ្ងៃអង្គារ ទី២០ ខែកញ្ញា ឆ្នាំ២០១៨_លៀ ស៊ីណា

ភ្នំពេញ ៖ ថ្លែងក្នុងពិធីសម្ពោធជាផ្លូវការនូវក្រុមហ៊ុន INTERNATIONAL EASY REACH CO.,LTD នៅថ្ងៃទី១៩ ខែវិច្ឆិកា តំណាងក្រុមហ៊ុននេះបញ្ជាក់ថា កំពុងត្រៀមបញ្ជូនពលការិនីចំនួន ៣រូបបន្ថែមទៀត ទៅបម្រើការងារជាជំនួយការមេផ្ទះនៅទីក្រុងហុងកុង។ លោករដ្ឋមន្ត្រីក្រសួងការងារ ប្រាប់ឲ្យក្រុមហ៊ុននេះ ត្រូវយកចិត្តទុកដាក់ឲ្យបានខ្ពស់ក្នុងការធានាសុវត្ថិភាពពលពលការិនី និងលក្ខខណ្ឌការងារ។

តំណាងក្រុហ៊ុន INTERNATIONAL EASY REACH CO.,LTD លោកស្រី យី ឆេង បានថ្លែងក្នុងពិធីនេះថា ក្រុមហ៊ុននឹងខិតខំបណ្តុះពលការិនីឲ្យមានសមត្ថភាព ដែលអាចទៅធ្វើការងារនៅទីក្រុងហុងបាន ស្របតាមទិសដៅក្រសួងការងារ ដែលធ្វើយ៉ាងណាបញ្ជូនពលការិនីទៅកាន់ទីក្រុងហុងកុង ឲ្យបានយ៉ាងហោចណាស់ ១០០០ នាក់ក្នុងមួយឆ្នាំ។_លោកស្រី យី ឆេង បន្តថា សព្វថ្ងៃនេះក្រុមហ៊ុនលោកស្រីបាននឹងកំពុងតែបន្តផ្សព្វផ្សាយក្នុងការជ្រើសរើសកម្មការិនី ដើម្បីយកមកបណ្តុះបណ្តាល ត្រៀមបញ្ជូនទៅទីក្រុងហុង។ លោកស្រីបន្តថា បច្ចុប្បន្នេះក្រុមហ៊ុន កំពុងតែបណ្តុះបណ្តាលពលការិនីចំនួន ១៣រូប ដែលនឹងបញ្ចប់វគ្គក្នុងពេលដ៏ខ្លីខាងមុខនេះ ស្របពេលដែលមានកម្មការិនីចំនួន ៣រូប បានជាប់កិច្ចសន្យាធ្វើការងារនៅទីក្រុងហុងកុង ៖«*មានដៃគូនៅហុងកុង បានចុះហត្ថលេខាជាមួយក្រុមហ៊ុនរួចរាល់ ដោយរង់ចាំការអនុញ្ញាតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសម្របសម្រួលនាំពលករទៅហុងកុង*»។

ទាក់ទិនករណីនេះលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ មានប្រសាសន៍ក្នុងពិធីនេះ ដោយស្នើដល់ក្រុមហ៊ុនមួយនេះ ត្រូវបន្តការយកចិត្តទុកដាក់ ខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាសម្របសម្រួលនាំចេញពលករទៅកាន់ទីក្រុងហុង ប្រកបដោយជោគជ័យ ដោយគោរពតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីធានានូវសុវត្ថិភាព ផាសុខភាព ភាពត្រឹមត្រូវ និង សេចក្តីថ្លៃថ្នូ។ ជាងនេះ ក្រុមហ៊ុនត្រូវ តែធានានូវលក្ខខណ្ឌការងារឲ្យកាន់តែល្អឡើង ជូនដល់កម្មការិនីកម្ពុជា ដែលនឹងចេញទៅបម្រើការងារជាជំនួយការមេផ្ទះនៅទីក្រុងហុងកុង នាងពេលខាងធាប់ៗខាងមុខ។_លោករដ្ឋមន្ត្រីអះអាង រដ្ឋាភិបាលអាណត្តិទី៦នេះ បាននឹងកំពុងខិតខំបន្ថែមទៀតក្នុង**ការ**រឹតចំណងទាក់ទងទ្វេភាគីជាអន្តរជាតិ ដើម្បីធ្វើយ៉ាងណាបើកឲ្យកាន់តែទូលាយនូវទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស និងទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារក្រៅប្រទេសដោយខុសច្បាប់។

កម្ពុជា បានបញ្ជូនពលការិនីចំនួន ១៤នាក់ ទៅធ្វើជាជំនួយការតាមផ្ទះនៅកាន់ទីក្រុងហុងកុង ជាលើកដំបូងកាលពីចុងឆ្នាំ២០១៧។ បើសិនដូចការគ្រោងទុករបស់ក្រុមហ៊ុន INTERNATIONAL EASY REACH CO.,LTD ដែលត្រៀមបញ្ជូនពលការិនីទៅបន្ថែមទៀត នេះគឺជាលើកទី២ហើយ សម្រាប់ការបញ្ជូនកម្មការិនីទៅទីក្រុងហុងកុង។

# ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៨

## ជើងកាងផ្ទះបន ខឹងនារីបំរើសេវាផ្លូវភេទ មិនព្រមទទួលភ្ញៀវ វាយធ្វើទារុណកម្មរហូតដល់ស្លាប់, ជនដៃដល់២នាក់ត្រូវនគរបាលតាមចាប់ខ្លួន និងបញ្ជូនទៅតុលាការ

http://freshnewsasia.com/ 2018-11-20

**(ភ្នំពេញ)៖** នៅរសៀលថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ លោកវរសេនីយ៍ឯក ហួរ ម៉េងរ៉ាង អធិការនគរបាលខណ្ឌសែនសុខ បានធ្វើការបង្ហាញមុខជនសង្ស័យជាឃាតកប្រុសស្រី២នាក់ ដែលធ្វើទារុណកម្មនារីរកស៊ីផ្លូវភេទម្នាក់ រហូតដល់ស្លាប់ រួចពួកគេទាំង២នាក់នេះ ក៏បានដឹកសពជនរងគ្រោះ យកទៅបោះចោលនៅឈាបនដ្ឋានវត្តទឹកថ្លា កាលពីយប់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ កន្លងមកនេះ។ លោក ហួរ ម៉េងរ៉ាង បានប្រាប់អ្នកយកព័ត៌មានថា ជនសង្ស័យជាឃាតកដៃដៅទាំង២នាក់ ទី១-ឈ្មោះ ង្វៀង យ៉ាំងចូវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិវៀតណាម មុខរបរ អ្នកមើលការខុសត្រូវស្រីបម្រើផ្លូវភេទ ស្នាក់នៅផ្ទះលេខ១៥៨ ផ្លូវ៥៩៨ ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក និងទី២-ឈ្មោះ ង្វៀង ធីយុង ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិវៀតណាម មុខរបរលក់ឥវ៉ាន់ ស្នាក់នៅផ្ទះលេខ១៥៩ ផ្លូវ៥៩៨ ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ចំណែកឯនារីរងគ្រោះឈ្មោះ ង្វៀង ធីយុង អាយុ២៥ឆ្នាំ ជនជាតិវៀតណាម មុខរបរស្រីបម្រើផ្លូវភេទ ស្នាក់នៅផ្ទះលេខ១៥៨ ផ្លូវ៥៩៨ (តំបន់ត្រឡោកបែក)ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក។ សម្រាប់មូលហេតុនោះ ត្រូវបានលោកអធិការប្រាប់ថា បណ្តាលមកពីចាប់បង្ខំនារីរងគ្រោះឲ្យទទួលភ្ញៀវរួមភេទខ្លាំងពេក តែនារីរងគ្រោះមិនព្រម ក៏វាយសម្លាប់តែម្តង។

លោក ហួរ ម៉េងរ៉ាង បានបន្តទៀតថា កាលពីយប់រំលងអាធ្រាត្រថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ មានជនមិនស្គាល់មុខ បានដឹកនារីរងគ្រោះអាយុប្រហែលជាង២០ឆ្នាំ ជាជនជាតិវៀតណាម ដាក់តាមរ៉ឺម៉ក់ យកទៅទុកចោលនៅឈាបនដ្ឋានវត្តទឹកថ្លា ហើយបានប្រាប់លោកតាអាចារ្យ ឲ្យទៅហៅបងប្អូនជនរងគ្រោះ។ ក្រោយមកជនសង្ស័យទាំងនោះ ក៏នាំគ្នាគេចខ្លួនបាត់តែម្តង។ លុះដល់រសៀលថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយមិនឃើញមានសាច់ញាតិបងប្អូនណាមកដល់ ទើបលោកតាអាចារ្យ រាយការណ៍ប្រាប់ទៅសមត្ថកិច្ចជំនាញ ដើម្បីចុះមកកន្លែងតម្កល់សាកសព។ ភ្លាមៗនោះ ក្រោយពីទទួលបានដំណឹងនេះ សមត្ថកិច្ចជំនាញខណ្ឌ បានចុះទៅពិនិត្យ និងទាក់ទងទៅសមត្ថកិច្ចជំនាញផ្នែកកោសល្យវិច័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ ក្រោយពេល សមត្ថកិច្ចជំនាញផ្នែកកោសល្យវិចិយ ចុះមកដល់បានពិនិត្យឃើញថា សាកសពនារីរងគ្រោះខាងលើនេះ ត្រូវគេវាយ និងធ្វើទារុណកម្មបណ្តាលឲ្យរងរបួសជាំពេញខ្លួន រហូតដល់ស្លាប់តែម្តង។ ក្រោយមក កម្លាំងនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានសហការជាមួយនឹងកម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់រាជធានីភ្នំពេញ និងអធិការដ្ឋាននគរបាលខណ្ឌទួលគោក ដើម្បីស្វែងរកតាមចាប់ជនសង្ស័យដែលជាឃាតករដៃដៅខាងលើ។ រហូតដល់យប់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កម្លាំងនគរបាលខណ្ឌសែនសុខ បានឃាត់ខ្លួនជនសង្ស័យប្រុសស្រី២នាក់ យកមកធ្វើការសាកសួរ នៅអធិការខណ្ឌសែនសុខ ដោយសង្ស័យពាក់ព័ន្ធ ក្នុងការវាយធ្វើទារុណកម្មលើនារីរកស៊ីផ្លូវភេទម្នាក់រហូតដល់ស្លាប់។

ក្រោយពីសាកសួរជនសង្ស័យទាំង ២នាក់ខាងលើរួចមក នៅព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ កម្លាំងនគរបាលខណ្ឌសែនសុខ បានសហការជាមួយកម្លាំងនគរបាលខណ្ឌទួលគោក ដើម្បីឆែកឆេរទីតាំងផ្ទះបនស្រី មួយកន្លែង ដែលជ្រកក្រោមសញ្ញាយីហោ ម៉ាស្សាកោសជប់ តាមបណ្តោយផ្លូវ៥៩៨ ក្នុងសង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលជាទីតាំងវាយធ្វើទារុណកម្មលើនារីរូបនោះ។ ចំណែកឯមេបន ដែលជាមេក្លោងប្រចាំនៅផ្ទះនេះ បានរត់គេចខ្លួនបាត់ស្រមោល។ ក្រោយធ្វើការបង្ហាញមុខជនសង្ស័យជាឃាតករដៃដៅរួចមក សមត្ថកិច្ចបញ្ជូនពួកគេទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីដាក់ទោសតាមនីតិវិធីច្បាប់៕

## ពលករខ្មែរម្នាក់ កំពុងធ្លាក់ខ្លួនឈឺ នៅថៃ គ្មានសាច់ញ្ញាតិមើលថែ

ByID:030 Posted on 20 November 2018 | 18:39

ភ្នំពេញ៖ ពលករខ្មែរឈ្មោះ វ៉ាន់ ខ្លង ភេទប្រុស អាយុ២៩ ឆ្នាំ បានធ្លាក់ខ្លួនឈឺ និងទុរគតគ្មានសាច់ញ្ញាតិ ថែទាំ កំពុងសំរាកនៅមន្ទីរពេទ្យ បង្អែកស្រុកអារញ្ញប្រាថេត ខេត្តសាកែវ ប្រទេសថៃ។ ដោយសារក្តីអាណិតអាសូរជាពន់ពេក មន្ត្រីស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំខេត្តសាកែវ នៃព្រះរាជាណាចក្រថៃឡង់ដ៏ ក៏បានចុះសួរសុខទុក្ខ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ផងដែរ៕

## តំណាង UNODC ជួបពិភាក្សាការងារជាមួយតំណាងនគរបាលជាតិ

http://cambodiapolice.com/ 2:43 pm 20 វិច្ឆិកា 2018

ភ្នំពេញ ៖ តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ួ សាគុណ និងលោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា បានទទួលជួប មន្ត្រីការិយាល័យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកគ្រឿងញៀន និងឧក្រិដ្ឋកម្ម UNODC ដឹកនាំដោយលោក Julien Garsany កាលពីថ្ងៃទី១៩ វិច្ឆិកា នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។ ក្នុងជំនួបនោះ លោក Julien Garsany បានធ្វើការណែនាំខ្លួនរបស់លោកក្នុងតួនាទីថ្មី ដែលលោកគឺជាអនុប្រធានការិយាល័យ UNODC ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និងកិច្ចពិភាក្សាបានផ្តោតលើយុទ្ធសាស្ត្រ ទូទៅនិងកិច្ចការជាអាទិភាពរបស់នគរបាលជាតិកម្ពុជា ពាក់ព័ន្ធនឹងការងារគ្រប់គ្រងព្រំដែន និងបញ្ហាការជួញដូរខុសច្បាប់ ។

កិច្ចពិភាក្សាបានផ្តោតលើវិធានការណ៍ និងយន្តការសំដៅទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ដែលកើតមានតាមតំបន់ព្រំដែន, ក្តីបារម្ភចំពោះការកើនឡើងនូវប្រភេទបទល្មើសគ្រឿងញៀនខុសច្បាប់, ការជួញដូរនិងរត់ពន្ធមនុស្សនៅតាមខ្សែបន្ទាត់ព្រំដែន, បញ្ហាប្រឈមជារួម ពាក់ព័ន្ធនឹងឧបាយកលនិងវិធីសាស្ត្រថ្មីៗរបស់ពួកឧក្រិដ្ឋជន, កិច្ចខិតខំប្រឹងប្រែងតស៊ូករណី និងការអនុវត្តតួនាទីភារកិច្ចជំនាញ។ កិច្ចពិភាក្សាបានផ្តោតផងដែរ លើការងារប្រឆាំងការជួញដូរមនុស្ស ដែលសង្កត់ធ្ងន់លើប្រភេទបទល្មើសថ្មីបំផុត គឺការស៊ីឈ្នួលពរពោះជំនួស និងការជួញដូរសរីរាង្គ ។

ក្នុងការពិភាក្សានោះថែមទៀត មន្ត្រីនគរបាលជាតិកម្ពុជា បានស្នើតំណាង UNODC បើកវគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលជំនាញ និងការស្នើលើការជួយផ្តល់សម្ភារៈបច្ចេកទេស ពាក់ព័ន្ធនឹងបច្ចេកវិទ្យាទំនើបសម្រាប់បំរើការងារជំនាញ ។

តំណាង UNODC បានថ្លែងកោតសរសើរនគរបាលជាតិកម្ពុជា ចំពោះការប្តេជ្ញាទប់ស្កាត់និងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសឆ្លងដែន ដែលចាត់ទុកថា សកម្មភាពនេះគឺជាការចូលរួមចំណែកដែលមិនអាចខ្វះបានសម្រាប់ធានាសន្តិសុខនិងសុវត្ថិភាពនៅក្នុងតំបន់ ក៏ដូចជាសកលលោក ៕

# ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨

## ឃាតកប្រុសស្រីជនជាតិវៀតណាម២នាក់ ដែលវាយធ្វើទារុណកម្មលើនារីបំរើសេវាផ្លូវភេទរហូតដល់ស្លាប់ ត្រូវតុលាការចេញដីការបង្គាប់ឲ្យឃុំខ្លួន

http://freshnewsasia.com/ 2018-11-23

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លោក ឡុង វណ្ណា បានចេញដីការបង្គាប់ឱ្យឃុំខ្លួន ក្រុមឃាតកប្រុសស្រី២នាក់ នៅពន្ធនាគារព្រៃស រង់ចាំកាត់

ទោសនៅពេលក្រោយ តាមកំណត់ច្បាប់ ករណីពួកគេបានធ្វើទារុណកម្មនារីកេស៊ីផ្លូវភេទម្នាក់ ហូតដល់ស្លាប់ រួចដឹកសពជនរងគ្រោះ យកទៅបោះចោលនៅឈាបនដ្ឋានវត្តទឹកថ្លា។ ការសម្រេចរបស់លោកចៅក្រម បានធ្វើឡើងបន្ទាប់ពីតំណាងអយ្យការលោក ងិន ពេជ្រ បានបញ្ចប់ការស៊ើបសួរលើក្រុមជនដៃដល់ ទី១៖ឈ្មោះ ង្វៀង យ៉ាំងចូវ និងទី២៖ ង្វៀង ធីយុង ហៅ ចិន ស៊ីណេត ពីបទ «ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដោយសារមរណភាពជនរងគ្រោះ» ដែលបទល្មើសនេះ ត្រូវផ្តន្ទាទោសតាមមាត្រា២២២ នៃក្រមព្រហ្មទណ្ឌ។

គួររំលឹកថា កាលពីរសៀលថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ លោកវរសេនីយ៍ឯក ហួរ ម៉េងវ៉ាង អធិការនគរបាលខណ្ឌសែនសុខ បានបង្ហាញមុខជនសង្ស័យជា ឃាតកប្រុសស្រី២នាក់ ដែលធ្វើទារុណកម្មនារីកេស៊ីផ្លូវភេទម្នាក់ ហូតដល់ស្លាប់ រួចពួកគេទាំង២នាក់នេះ ក៏បានដឹកសពជនរងគ្រោះយកទៅបោះចោលនៅឈាបនដ្ឋានវត្តទឹកថ្លា កាលពីយប់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨។ លោក ហួរ ម៉េងវ៉ាង បានបញ្ជាក់ថា ជនសង្ស័យជាឃាតកដៃដៅទាំង២នាក់ ទី១៖ឈ្មោះ ង្វៀង យ៉ាំងចូវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិវៀតណាម មុខរបរ អ្នកមើលការខុសត្រូវស្រីបម្រើផ្លូវភេទ ស្នាក់នៅផ្ទះលេខ១៥៨ ផ្លូវ៥៩៨ ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក និងទី២៖ឈ្មោះ ង្វៀង ធីយុង ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិវៀតណាម មុខរបរលក់ឥវ៉ាន់ ស្នាក់នៅផ្ទះលេខ១៥៩ ផ្លូវ៥៩៨ ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ចំណែកឯនារីរងគ្រោះឈ្មោះ ង្វៀង ធីយុង អាយុ២៥ឆ្នាំ ជនជាតិវៀតណាម មុខរបរស្រីបម្រើផ្លូវភេទ ស្នាក់នៅផ្ទះលេខ១៥៨ ផ្លូវ៥៩៨ (តំបន់ត្រឡោកបែក) ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក។ សម្រាប់មូលហេតុនោះ ត្រូវបានលោកអធិការប្រាប់ថា បណ្តាលមកពីចាប់បង្ខំនារីរងគ្រោះឲ្យទទួលភ្ញៀវរួមភេទខ្លាំងពេក តែនារីរងគ្រោះមិនព្រមក៏វាយសម្លាប់តែម្តង។ លោក ហួរ ម៉េងវ៉ាង បានបន្តទៀតថា កាលពីយប់រំលងអាធ្រាត្រថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ មានជនមិនស្គាល់មុខ បានដឹកនារីរងគ្រោះ អាយុប្រហែលជាង២០ឆ្នាំ ជាជនជាតិវៀតណាម ដាក់តាមរ៉ឺម៉ក់ យកទៅទុកចោកនៅឈាបនដ្ឋានវត្តទឹកថ្លា ហើយបានប្រាប់លោកតាអាចារ្យ ឲ្យទៅហៅបងប្អូនជនរងគ្រោះ។ ក្រោយមកជនសង្ស័យទាំងនោះ ក៏នាំគ្នាគេចខ្លួនបាត់តែម្តង។

លុះដល់រសៀលថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយមិនឃើញមានសាច់ញាតិបងប្អូនណាមកដល់ ទើបលោកតាអាចារ្យរាយការណ៍ ប្រាប់ទៅសមត្ថកិច្ចជំនាញ ដើម្បីចុះមកកន្លែងតម្កល់សាកសព។ ភ្លាមៗនោះ ក្រោយពីទទួលបានដំណឹងនេះ សមត្ថកិច្ចជំនាញខណ្ឌ បានចុះទៅពិនិត្យ និងទាក់ទងទៅសមត្ថកិច្ចជំនាញផ្នែកកោសល្យវិច័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។ ក្រោយពេលសមត្ថកិច្ចជំនាញផ្នែកកោសល្យវិច័យ ចុះមកដល់បានពិនិត្យឃើញថា សាកសពនារីរងគ្រោះខាងលើនេះ ត្រូវគេវាយ និងធ្វើទារុណកម្មបណ្តាលឲ្យរងរបួសជាំពេញខ្លួន ហូតដល់ស្លាប់តែម្តង។ ក្រោយមកកម្លាំងនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានសហការជាមួយនឹងកម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់រាជធានីភ្នំពេញ និងអធិការដ្ឋាននគរបាលខណ្ឌទួលគោក ដើម្បីស្វែងរកតាមចាប់ជនសង្ស័យ ដែលជាឃាតកដៃដៅខាងលើ។ ហូតដល់យប់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កម្លាំងនគរបាលខណ្ឌសែនសុខ បានឃាត់ខ្លួនជនសង្ស័យប្រុសស្រី២នាក់ យកមកធ្វើការសាកសួរ នៅអធិការខណ្ឌសែនសុខ ដោយសង្ស័យពាក់ព័ន្ធ ក្នុងការវាយធ្វើទារុណកម្មលើនារីកេស៊ីផ្លូវភេទម្នាក់ ហូតដល់ស្លាប់។ ក្រោយពីសាកសួរជនសង្ស័យទាំង២នាក់ខាងលើរួចមក នៅព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ កម្លាំងនគរបាលខណ្ឌសែនសុខ បានសហការជាមួយកម្លាំងនគរបាលខណ្ឌទួលគោក ដើម្បីឆែកឆេរទីតាំងផ្ទះបនស្រីមួយកន្លែង ដែលជ្រកក្រោមសញ្ញាយីហោ ម៉ាស្សាកោសជប់ តាមបណ្តោយផ្លូវ៥៩៨ ក្នុងសង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលជាទីតាំងវាយធ្វើទារុណកម្មលើនារីរូបនោះ។ ចំណែកឯមេបន ដែលជាមេក្លោងប្រចាំនៅផ្ទះនេះ បានរត់គេចខ្លួនបាត់ស្រមោល។ ក្រោយធ្វើការបង្ហាញមុខជនសង្ស័យ ជាឃាតកដៃដៅរួចមក សមត្ថកិច្ចបញ្ជូនពួកគេទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីដាក់ទោសតាមនីតិវិធីច្បាប់៕

# ពលរដ្ឋខ្មែរមួយគ្រួសារចាញ់បោកមេខ្យល់រឿងរត់ការឯកសារធ្វើការនៅប្រទេសថៃ

https://www.rfa.org/khmer/news/human-rights/Cambodian-workers ដោយ យន់ សាមៀន 2018-11-24

ពលរដ្ឋខ្មែរមួយគ្រួសារពីរនាក់ប្ដីប្រពន្ធឲ្យដឹងថា ពួកគេត្រូវមេខ្យល់ហៅឲ្យមកធ្វើការងារនៅប្រទេសថៃ និងជួយរត់ការរកការងារឲ្យធ្វើ ប៉ុន្តែក្រោយពេលពួកគេមកដល់ប្រទេសថៃ និងបានប្រគល់លិខិតឆ្លងដែនព្រមទាំងលុយថ្លៃរត់ការងារអស់ជាងពីររយដុល្លាររួចមក មេខ្យល់រូបនោះមិនបានធ្វើតាមការសន្យានោះទេ។ សង្គមស៊ីវិលដែលធ្វើការងារទាក់ទងពលករចំណាកស្រុកលើកឡើងថា បញ្ហានេះកើតឡើងច្រើនករណីណាស់នៅប្រទេសថៃ និងពិបាកក្នុងការជួយដាក់ពាក្យបណ្ដឹង ព្រោះភាគច្រើនជនរងគ្រោះមិនបានស្គាល់អត្តសញ្ញាណជនខិលខូចច្បាស់លាស់។ ជាងពីរខែមកហើយដែលពលរដ្ឋខ្មែរមួយគ្រួសារ ត្រូវបង្ខំចិត្តលួចធ្វើការងារនៅប្រទេសថៃទាំងខុសច្បាប់ក្រោយចាញ់បោលមេខ្យល់។ ពលរដ្ឋទាំងពីរនាក់ប្ដីប្រពន្ធព្រួយបារម្ភថា ពួកគេនឹងប្រឈមត្រូវសមត្ថកិច្ចថៃចាប់បញ្ជូនខ្លួនដាក់ពន្ធនាគារនៅប្រទេសថៃ ឬត្រូវបញ្ជូនទៅខ្មែរវិញ ខណៈសមត្ថកិច្ចថៃកំពុងបើកយុទ្ធនាការចាប់បញ្ជូនខ្លួនពលករខ្មែរខុសច្បាប់។

លោក នាគ ហូ ឲ្យអាស៊ីសេរីដឹងថ្ងៃទី២៥ ខែវិច្ឆិកា ថា លោកមកថៃ ដោយសារពិបាករកការងារធ្វើនៅក្នុងប្រទេសកម្ពុជា៖ «គាត់ហៅមកថា យ៉ាងយូរតែម្ដៃទេ បើមិនបានការងារឲ្យកាត់កគាត់ ខ្ញុំក៏ដេកចាំៗអត់បានមួយថ្ងៃហើយមួយថ្ងៃទៀត»។ លោកបន្តថា អស់រយៈពេលបីខែហើយ ក្រោយពីលោកបានបាញ់បោកមេខ្យល់ ហើយមិនទាន់អាចយកលិខិតស្នាមមកបានដើម្បីធ្វើការងារស្របច្បាប់នៅឡើយ៖ «រកស៊ីអត់ទៀងទាត់ជាពលករអ៊ីចឹងអត់កើតទេ ខ្ញុំចេះទៅធ្វើការជាមួយគេអត់មានលិខិតឆ្លងដែន (Passport) អីក្នុងខ្លួនចេះតែទៅឲ្យរួចថ្លៃម្ហូបថ្លៃបន្ទប់»។

អាស៊ីសេរីមិនទាន់មានមធ្យោបាយសុំការបំភ្លឺករណីនេះពីមន្ត្រីស្ថានខ្មែរប្រចាំប្រទេសថៃបាន នៅឡើយទេ ចំណែកអ្នកនាំពាក្យក្រសួងការងារ ក៏មិនអាចសុំការពន្យល់បានដែរ នៅថ្ងៃទី២៥ វិច្ឆិកា។ មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្សសង់ត្រាល់ (CENTRAL) លោក ឌីថេ ហូយ៉ា មានប្រសាសន៍ថា ការផ្សព្វផ្សាយរបស់ស្ថាប័នមានសមត្ថកិច្ចទាក់ទងសុវត្ថិភាពការងារនៅក្រៅប្រទេសនៅមានកម្រិតនោះ ទើបបណ្ដាលឲ្យមានករណីពលករចាញ់បោកមេខ្យល់ក៏នៅតែមានច្រើន។ លោកបន្តថា សង្គមស៊ីវិលពិបាក ជួយអន្តរាគមន៍ ឬការជួយដាក់ពាក្យបណ្ដឹងណាស់ព្រោះពលរដ្ឋដែលចាញ់បោកមេខ្យល់មិនបានស្គាល់អត្តសញ្ញាណរបស់មេខ្យល់ច្បាស់លាស់៖ «មុននឹងលោក (ពលករ) ចំណាយលុយទៅលើបុគ្គលណាម្នាក់សុំសិក្សាមើលថាតើគេធ្វើការងារនៅក្រុមហ៊ុនណា ប៉ុន្តែគ្រាន់តែប្រមូលលុយហើយសន្យាថាធ្វើបានសូមមេត្តាកុំចំណាយលុយលើបុគ្គលនោះ»។

កន្លងមក លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ ធ្លាប់បានលើកឡើងថា ក្រសួងការងារ និងអ្នកពាក់ព័ន្ធគ្រោងរៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្នដល់ពលករខ្មែរធ្វើការងារនៅប្រទេសថៃ។ លោកអះអាងថា កន្លែងដែលគ្រោងនឹងបង្កើតនេះវាមិនមែនត្រឹមតែជាកន្លែងស្នាក់នៅប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាកន្លែងប្រឹក្សាយោបល់សម្រាប់ពលករក្នុងអំឡុងពេលដែលពួកគេផ្លាស់ប្ដូរការងារ ឬរង់ចាំដំណោះស្រាយវិវាទការងារជាមួយថៅកែ។ លោក ឌីថេ ហូយ៉ា ស្នើទៅរបបក្រុងភ្នំពេញផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយទៅដល់ពលរដ្ឋខ្មែរដែលមានបំណងចង់មកធ្វើការងារនៅក្រៅប្រទេស ដើម្បីជៀសវាងការទទួលបាននូវព័ត៌មានមិនបានច្បាស់លាស់ ជាហេតុនាំឲ្យពួកគេបន្តការចាញ់បោកមេខ្យល់បន្តទៀត៕

# ក្រុមអ្នកជួញដូរមនុស្ស ផ្ដោតទៅលើអ្នកដែលភៀសខ្លួន ពីអំពើហិង្សា នៅមីយ៉ាន់ម៉ា

https://www.postkhmer.com/ AFP | Publication date 26 November 2018 | 12:28 ICT

**ក្រុងបាហ្វារ:** មន្ត្រីបង់ក្លាដែស ព្រមានថា ខណៈតម្រូវការកាន់តែកើនឡើងខ្លាំងនៅក្នុងជំរំដ៏កខ្វក់ ដែលជាកន្លែងសម្រាប់ជនភៀសខ្លួនរ៉ូហ៊ីងយ៉ាមួយលាននាក់ ដែលមិនមានការរីកចម្រើន ហើយជារឿយៗមានមនុស្សស្លាប់

ចំណែកឯបណ្ដាញជួញដូរមនុស្ស បានចាប់ផ្ដើមរើបឡើងវិញ។ ក្រុមអ្នករត់ពន្ធមនុស្ស កំពុងប្រើប្រាស់ទូកនេសាទរបស់ពួកគេ ដើម្បីដឹកមនុស្សដែលភៀសខ្លួនចេញពីអំពើហិង្សានៅមីយ៉ាន់ម៉ា ដោយយកថ្លៃតិចតួចពីពួកគេសម្រាប់ការធ្វើដំណើរប្រកបដោយគ្រោះថ្នាក់ទៅកាន់តំបន់អាស៊ីអាគ្នេយ៍ ដោយបានសន្យាជូនទៅដល់កន្លែងតាំងលំនៅថ្មី។ ទូកដំបូង ដែលចាកចេញពីបង់ក្លាដែសទៅកាន់ម៉ាឡេស៊ីចាប់តាំងពីនៅចុងរដូវវស្សា ត្រូវចាប់បានដោយការអនុវត្តច្បាប់ ដែលព្រមានអ្នកដទៃទៀតថា នឹងប្រឈមមុខតាមច្បាប់ដូចគ្នា។

មេដឹកនាំសហគមន៍ជាច្រើននិងក្រុមការងារជួយសង្គ្រោះបាននិយាយថាមានជនជាតិភាគតិចរ៉ូហ៊ីងយ៉ាជាច្រើននៅក្នុងជំរំនៃក្រុងបាស្សារ មានអារម្មណ៍ថា ពួកគេមិនមានជម្រើសអ្វីផ្សេងក្រៅពីព្យាយាមរត់គេចខ្លួនចេញពីជំរំដើម្បីទៅរកការងារធ្វើនោះទេ។

កិច្ចព្រមព្រៀងមួយ ដើម្បីបញ្ជូនជនភៀសខ្លួនមូស្លីមរ៉ូហ៊ីងយ៉ាដែលរងទុក្ខបុកម្នេញទៅមីយ៉ាន់ម៉ាដោយសុវត្ថិភាពបានបរាជ័យ ដោយធ្វើឲ្យពួកគេស្ថិតនៅក្នុងស្ថានភាពមិនប្រាកដប្រជា និងជួបប្រទះការខ្វះស្បៀងអាហារនៅតាមជំរំដែលពួកគេត្រូវបានរារាំងមិនឲ្យចេញ ឬ ស្វែងរកការងារធ្វើ ដើម្បីជីវភាពរបស់ពួកគេប្រសើរឡើងនោះ៕

# ថ្ងៃទី២៧ខែវិច្ឆិកា ឆ្នាំ២០១៨

## លោកជំទាវ អ៊ឹង កន្ថាផាវី ជួបប្រជុំជាមួយមន្ត្រីជំនាញដោះស្រាយករណីប្រើប្រាស់អំពើហិង្សានិងការរំលោភបំពានលើស្ត្រីនៅខេត្តក្រចេះ

http://information.gov.kh/ ចេញផ្សាយ ថ្ងៃទី 27 ខែ វិច្ឆិកា ឆ្នាំ 2018

AKP ក្រចេះ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ –លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានជួបប្រជុំជាមួយមន្ត្រីជំនាញដោះស្រាយករណីប្រើប្រាស់អំពើហិង្សា និងការរំលោភបំពានគ្រប់រូបភាពលើស្ត្រីនៅខេត្តក្រចេះ កាលពីរសៀលថ្ងៃចន្ទ ៤រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

តាមការបញ្ជាក់ពីមន្ទីរកិច្ចកានារីខេត្តក្រចេះបានឱ្យដឹងថា ការជួបប្រជុំជាមួយមន្ត្រីជំនាញនាពេលនោះគឺក្នុងគោលបំណងដើម្បីប្រមូលព័ត៌មាន និងលទ្ធផលនៃការអនុវត្តច្បាប់ជាតិ គោលនយោបាយ អនុសាសន៍ដ៏ខ្ពស់ខ្ពស់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី និងអនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ( CEDAW ) ដើម្បីរៀបចំរបាយការណ៍កិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនិងរបាយការណ៍ជាតិតាមការកំណត់ ដើម្បីបញ្ជូនទៅអង្គភាពសហប្រជាជាតិ និងដើម្បីឈ្វេងយល់ពីបញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធ និងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខុមាលភាពស្ត្រី ។

លោកជំទាវ អ៊ឹង កន្ថាផាវី ក៏បានជួបប្រជុំជាមួយស្នងការ នៃស្នងការដ្ឋាននគរបាលខេត្ត និង ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តក្រចេះដាច់ដោយឡែកពីគ្នាផងដែរ កាលពីរសៀលថ្ងៃចន្ទនេះដើម្បីត្រួតពិនិត្យនិងស្ដាប់របាយការណ៍អំពីករណីបទល្មើស និងការដោះស្រាយ ការប្រើប្រាស់អំពើហិង្សានិងការរំលោភបំពានលើស្ត្រីនៅខេត្តក្រចេះផងដែរ ។ លោកជំទាវរដ្ឋមន្ត្រី បានមានប្រសាសន៍ថា ស្ត្រីគឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តជំរុញ និងលើកកម្ពស់សមត្ថភាពស្ត្រីក្នុងការចូលរួមទាំងវិស័យរដ្ឋ និងឯកជន។ លោកជំទាវបានបញ្ជាក់ថា ការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករ ពលការិនី ទាំងក្នុងប្រទេស និងក្រៅប្រទេស ក៏ត្រូវបានបន្តយកចិត្តទុកដាក់ផងដែរ ។ ដោយឡែកសម្រាប់ស្ត្រីកម្ពុជាដែលបានចូលបម្រើការងារ ជាមន្ត្រីរាជការស៊ីវិល បានកើនឡើងនៃចំនួនមន្ត្រីរាជការដែលត្រូវបានចូលបម្រើការងារ និងត្រូវបានតែងតាំងក្នុងតំណែង ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ លោកជំទាវបានកោតសរសើរដល់មន្ត្រីជំនាញពាក់ព័ន្ធទាំងអស់ ដែលបានខិតខំដោះ ស្រាយនិងទប់ស្កាត់ នូវរាល់ករណីរំលោភបំពាន និងប្រើ

អំពើហិង្សាពីគ្រប់រូបភាពមកលើស្ត្រី ក្នុងសហគមន៍របស់ខ្លួន និងសូមបន្តការចូលរួមពង្រឹងដោះស្រាយ និងទប់ស្កាត់ឈានទៅលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ( CEDAW ) ដែលជាគោលនយោបាយជាតិ ៕ ដោយជួន សុជាតិ

## ថៃដោះលែងជនជាតិកម្ពុជាម្នាក់ពីពន្ធនាគារឱ្យត្រឡប់មកកម្ពុជាវិញ

http://www.rasmeinews.com/ November 27, 2018, 11:28 AM

*ដោយបាយ័ន/ ឧត្តរមានជ័យ*:អាជ្ញាធរប្រទេសថៃបានបញ្ជូនពលរដ្ឋកម្ពុជាម្នាក់ឱ្យត្រឡប់មកកាន់ស្រុកកំណើតវិញបន្ទាប់ពីភាគីថៃ បានធ្វើការដោះលែងឱ្យមានសេរីភាពពីពន្ធនាគារដោយជននោះបានឆ្លងដែនទៅកាប់ឈើគ្រញូងដោយខុសច្បាប់នៅក្នុងទឹកដីថៃកន្លងមក។ ពិធីប្រគល់និងទទួលនេះបានធ្វើឡើងតាមច្រកអន្តរជាតិជាំស្រងាំក្នុងទឹកដីស្រុកអន្លង់វែងខេត្តឧត្តរមានជ័យកាលពីវេលាម៉ោង១៦និង២០នាទី ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨។ សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថាពលរដ្ឋកម្ពុជាដែលត្រូវបានភាគីថៃបញ្ជូនមកស្រុកកំនើតវិញនោះគឺមានឈ្មោះ រ៉ន ពេជ្រ ភេទប្រុស អាយុ១៦ឆ្នាំ រស់នៅភូមិត្រពាំងបី ឃុំ ព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ សមត្ថកិច្ចបានបន្តថា ជនខាងលើត្រូវបានអាជ្ញារថៃចាប់ខ្លួនកាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៨កន្លងទៅ។ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ដោយចូលតាមច្រកភូមិសាស្ត្រអូរ៥០ ភ្នំដងរែក ស្រុកអន្លង់វែង ជាប់នឹងខេត្តអ៊ុប៊ុន ប្រទេសថៃ។បន្ទាប់ពីចាប់ខ្លួនជនឈ្មោះ រ៉ន ពេជ្រ ត្រូវបានភាគីថៃយកទៅដាក់ពន្ធនាគារចាប់តាំងពីថ្ងៃនោះមករហូតដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ ទើបត្រូវបានដោះលែងឱ្យមានសេរីភាព ហើយបញ្ជូនមកកកាន់ស្រុកកំណើតវិញ។ បន្ទាប់ពីទទួលពីភាគីថៃរួចមកភាគីកម្ពុជាបានធ្វើការអប់រំណែនាំមិនឱ្យឆ្លងដែនដោយខុសច្បាប់បែបនេះទៀតទេ រួចឱ្យវិលត្រឡប់ទៅកាន់លំនៅស្ថានដើម្បីជួបជុំក្រុមគ្រួសារវិញ៕S/

## វៀតណាម និងចក្រភពអង់គ្លេសចុះហត្ថលេខាលើអនុស្សារណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://information.gov.kh/ ចេញផ្សាយ ថ្ងៃទី 26 ខែ វិច្ឆិកា ឆ្នាំ 2018

AKP ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ -- រដ្ឋាភិបាលវៀតណាម និងរដ្ឋាភិបាលចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាមួយ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ អនុស្សារណៈយោគយល់គ្នានេះត្រូវបានចុះហត្ថលេខាដោយ រដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈរបស់វៀតណាម លោកឧត្តមសេនីយ៍ទោ To Lam និងលេខាធិការរបស់ចក្រភពអង់គ្លេស លោក Sajid Javid ក្នុងអំឡុងពេលនៃកិច្ចចរចាដែលជាផ្នែកមួយនៃដំណើរទស្សនកិច្ចការងាររបស់លោក Lam ទៅកាន់ចក្រភពអង់គ្លេស។ នៅក្នុងពិធីទទួលស្វាគមន៍គណៈប្រតិភូនៃក្រសួងសន្តិសុខសាធារណៈរបស់វៀតណាម លោក Javid បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការរបស់ក្រសួងទាំងពីរក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ជាពិសេសក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មចាត់តាំង និងឆ្លងដែន ឧក្រិដ្ឋកម្មជួញដូរមនុស្ស និងឧក្រិដ្ឋជនដែលប្រើប្រាស់បច្ចេកវិទ្យាខ្ពស់។

លោក Lam បានអះអាងថា រដ្ឋាភិបាលវៀតណាមយកចិត្តទុកដាក់ដល់កិច្ចអភិវឌ្ឍន៍ទំនាក់ទំនងរបស់ខ្លួនជាមួយចក្រភពអង់គ្លេស និងចាត់ទុកជាកត្តាអាទិភាពមួយនៅក្នុងគោលនយោបាយការបរទេសរបស់ខ្លួនសម្រាប់សន្តិភាព កិច្ចសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍន៍។

កាលពីខែកញ្ញា ឆ្នាំ ២០១០ ប្រទេសទាំងពីរបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមមួយ ស្តីពីការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រ ដែលក្នុងនោះវិស័យការទូត សន្តិសុខ និងការពារជាតិ គឺជាសសរស្តម្ភ សំខាន់ៗទាំង ៣ ។ លោកបាននិយាយបន្ថែមថា វៀតណាមពេញចិត្តចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការយ៉ាងទូលំទូលាយ ជាពិសេសផ្នែកការទូត សន្តិសុខ ការពារជាតិ សេដ្ឋកិច្ច ពាណិជ្ជកម្ម សុខភាព វប្បធម៌ អប់រំ បរិស្ថាន និងការឆ្លើយតបចំពោះបម្រែបម្រួលអាកាសធាតុ៕

# ថ្ងៃទី២៨ខែវិច្ឆិកា ឆ្នាំ២០១៨

## សម្តេច ស ខេង ប្រាប់ទូតកាណាដាថា កម្ពុជាកំពុងតាក់តែង សេចក្តីព្រាងច្បាប់ ដើម្បីគ្រប់គ្រង និងដោះស្រាយ បញ្ហាពពោះជំនួស

https://www.dap-news.com/ ByID:119 Posted on 27 November 2018 | 21:15

**ភ្នំពេញ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ប្រាប់លោកស្រី Donica Pottie ឯកអគ្គរដ្ឋទូតកាណាដាថា បច្ចុប្បន្នកម្ពុជាកំពុងតាក់តែងសេចក្តីព្រាងច្បាប់ ដើម្បីគ្រប់គ្រង និងដោះស្រាយបញ្ហាពពោះជំនួស បើទោះបីជាច្បាប់នោះមិនទាន់ចេញជារូបរាង ក៏ប៉ុន្តែរាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់។

ក្នុងឱកាសជួបពិភាក្សាការងារ ជាមួយ លោកស្រី Donica Pottie ឯកអគ្គរដ្ឋទូតកាណាដា នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ សម្តេច ស ខេង បានមានប្រសាសន៍ថា "បច្ចុប្បន្នកម្ពុជាកំពុងតាក់តែង សេចក្តីព្រាងច្បាប់ ដើម្បីគ្រប់គ្រង និងដោះស្រាយបញ្ហានេះ និងថាបើទោះបីជាច្បាប់នោះ មិនទាន់ចេញជារូបរាង រាជរដ្ឋាភិបាល បាននិងកំពុងយកចិត្តទុកដាក់ខ្ពស់ ចំពោះករណីដ៏ស្មុគស្មាញនេះ"។ ឆ្លៀតឱកាសនោះដែរ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានលើកឡើងថា លទ្ធិប្រជាធិបតេយ្យកម្ពុជា គ្មានការប្រែប្រួលនោះទេ ដោយសារកម្ពុជា កំពុងអនុវត្តតាមរដ្ឋធម្មនុញ្ញ និងមានការរៀបចំ ការបោះឆ្នោតជាទៀងទាត់។ ជាងនេះទៅទៀត រដ្ឋមន្ត្រីបន្ថែមថា ប្រជាពលរដ្ឋខ្មែរ បានចូលរួមបោះឆ្នោតដ៏ច្រើន នាពេលកន្លងទៅនេះ គឺជាការបង្ហាញយ៉ាងច្បាស់ថា ពលរដ្ឋ បានប្រើប្រាស់ សិទ្ធិរបស់ពួកគាត់តាមច្បាប់កំណត់។

ចំណែកលោកស្រី Donica Pottie បានថ្លែងអំណរគុណ សម្តេចក្រឡាហោម ចំពោះការផ្តល់ព័ត៌មានអស់ទាំងនេះ និងបានជំរាបជូនសម្តេច ក្រឡាហោម ស ខេង ពីការសម្រេចបន្តផ្តល់មូលនិធិ ជូនក្រសួងមហាផ្ទៃឡើងវិញ សម្រាប់ការបណ្តុះបណ្តាល មន្ត្រីការពារព្រំដែន បន្ទាប់ពីបានសម្រេច ផ្អាកអស់មួយរយៈមកនោះ។

បន្ថែមពីនេះ សម្តេចក្រឡាហោម ក៏បានផ្តល់ព័ត៌មានមួយចំនួនទៅកាន់ លោកស្រី Donica Pottie ពាក់ព័ន្ធនឹងការលើកកម្ពស់ កិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាល ជាមួយសមាគម និងអង្គការក្រៅរដ្ឋាភិបាល ពិសេសការបង្កើតក្រុមការងារ ពិគ្រោះយោបល់ និងការមិនតម្រូវឲ្យជូនដំណឹង មកអាជ្ញាធរមុនពេលធ្វើ សកម្មភាពជាដើម។ ដោយ ៖ អេង ប៊ូឆេង

## វីង ប្រកាសពីភាពជាដៃគូ ជាមួយធនាគារ ស៊ីនហាន ដើម្បីផ្តល់ភាពងាយស្រួល ដល់ពលករខ្មែរ ក្នុងការផ្ទេរប្រាក់ពីក្រៅប្រទេស

http://www.cen.com.kh/archives/ November 27, 2018

ភ្នំពេញ ៖ សេចក្តីប្រកាសព័ត៌មាន កាលពី ថ្ងៃទី 25 ខែវិច្ឆិកា ឆ្នាំ 2018 បានឲ្យដឹងថា ធនាគារឯកទេស វីង (ខេមបូឌា) លីមីតធីត បានប្រកាសពីភាពជាដៃគូ ជាមួយធនាគារស៊ីនហាន របស់កូរ៉េខាងត្បូង ដើម្បីផ្តល់ភាពងាយស្រួលដល់ពលករខ្មែរ ដែលរស់នៅក្នុងប្រទេសកូរ៉េខាងត្បូង ក្នុងការផ្ទេរប្រាក់ពីក្រៅប្រទេសមកកាន់កម្ពុជា។

ធនាគារ ស៊ីនហាន គឺជាធនាគារទី ៧ នៅក្នុងប្រទេសកូរ៉េខាងត្បូង ដែលបានសហការជាមួយធនាគារឯកទេស វីង ដើម្បីបង្កើនភាពងាយស្រួលបន្ថែមមួយកម្រិតទៀត សម្រាប់ប្រជាជនកម្ពុជា ដែលកំពុងរស់នៅទីនោះ និងមានតម្រូវការក្នុងការផ្ទេរប្រាក់ មកកាន់មនុស្សជាទីស្រលាញ់របស់ខ្លួន នៅស្រុកកំណើត។ ភាពជាដៃគូថ្មីនេះ អនុញ្ញាតឱ្យប្រជាជនកម្ពុជា ដែលរស់នៅ និងធ្វើការនៅក្នុងប្រទេសកូរ៉េខាងត្បូង អាចផ្ទេរប្រាក់តាមរយៈកម្មវិធីស្មាតហ្វូនរបស់ធនាគារ ស៊ីនហាន (Shinhan Global S Bank) និងអនុញ្ញាតឱ្យអ្នកទទួលប្រាក់ នៅក្នុងប្រទេសកម្ពុជា អាចទទួលបានប្រាក់បញ្ញើភ្លាមៗ តាមរយៈកម្មវិធីស្មាតហ្វូន វីង ឬក៏នៅតាមភ្នាក់ងារ វីង ជាង ៦០០០កន្លែង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ ស៊ីនហាន ក៏មានផ្តល់សេវាបើកប្រាក់បៀវត្សរ៍ សម្រាប់បុគ្គលិកនៅក្នុងប្រទេសកូរ៉េខាងត្បូងផងដែរ។ នេះមានន័យថា ពលករខ្មែរដែលទទួលប្រាក់បៀវត្សរ៍ប្រចាំខែ តាមរយៈធនាគារ ស៊ីនហាន អាចផ្ញើប្រាក់ មកប្រកាន់ទេសកម្ពុជាភ្លាមៗ ដោយប្រើប្រាស់កម្មវិធីស្មាតហ្វូន របស់ធនាគារ ស៊ីនហាន។

យោងតាមរបាយការណ៍ប្រចាំឆ្នាំ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានចេញផ្សាយកាលពីខែមីនាឆ្នាំ២០១៨ បានអះអាងថា បច្ចុប្បន្នមានប្រជាជនកម្ពុជាជាង ៤៥.០០០នាក់ កំពុងធ្វើការនៅក្នុងប្រទេសកូរ៉េខាងត្បូង ហើយប្រជាពលករប្រមាណជា ៥០.០០០នាក់ បន្ថែមទៀត ត្រូវបានរំពឹងថា នឹងស្វែងរកការងារធ្វើនៅក្នុងប្រទេសនេះ នៅក្នុងឆ្នាំ ២០១៩ ខាងមុខនេះ។

លោក ចូចូ ម៉ាឡូឡូស អគ្គនាយកធនាគារឯកទេស វីង បានមានប្រសាសន៍ថា ភាពជាដៃគូថ្មីនេះ នឹងធ្វើឲ្យការធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារនៅប្រទេសកូរ៉េខាងត្បូង រឹតតែមានភាពទាក់ទាញដល់ប្រជាជនកម្ពុជា ដែលតែងតែមានការព្រួយបារម្ភ អំពីសុវត្ថិភាពនៃប្រាក់ចំណូល ដែលពួកគេខិតខំប្រឹងប្រែងរកបានយ៉ាងលំបាក។ លោក ចូចូ ម៉ាឡូឡូស បានបន្តថា "យោងតាមរបាយការណ៍ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រទេសកូរ៉េខាងត្បូង គឺជាប្រទេសធំបំផុតទី ២ ដែលបានផ្តល់ការងារ ដល់ពលករចំណាកស្រុករបស់កម្ពុជា បន្ទាប់ពីប្រទេសថៃ។ សម្រាប់ពលករខ្មែរ វាគឺជាការពិចារណាដ៏សំខាន់មួយ ក្នុងការដែលអាចផ្ញើប្រាក់មកផ្ទះបានភ្លាមៗ និងប្រកបដោយសុវត្ថិភាព ពីប្រទេសកូរ៉េខាងត្បូង។ ធនាគារឯកទេស វីង នៅតែមានការប្តេជ្ញាចិត្ត ក្នុងការសម្រួលដល់ការផ្ទេរប្រាក់ទាំងនេះ តាមរយៈតម្លៃសេវាមួយដែលសាកសម ដោយមានជំនួយពីដៃគូអន្តរជាតិរបស់យើង គឺធនាគារ ស៊ីនហាន ដែលមានសាខាប្រមាណ ៩០០ នៅទូទាំងប្រទេសកូរ៉េខាងត្បូង។"

ធនាគារ ស៊ីនហាន គឺជាផ្នែកមួយនៃ Shinhan Financial Group ហើយក៏ជាធនាគារមួយ ក្នុងចំណោមធនាគារធំបំផុត របស់ប្រទេសកូរ៉េខាងត្បូង។ នាយកប្រតិបត្តិរបស់ធនាគារ ស៊ីនហាន លោក Wi Sung-ho បាននិយាយថា ភាពជាដៃគូជាមួយ ធនាគារឯកទេស វីង គឺជាឱកាសមួយសម្រាប់ក្រុមហ៊ុនទាំងពីរ ក្នុងការសម្រេចបាននូវគោលដៅរួមគ្នាមួយ។ លោក Wi Sung-ho បន្តថា "ធនាគារ ស៊ីនហាន តែងតែបង្កើតនូវតម្លៃបន្ថែម សម្រាប់អតិថិជនរបស់ខ្លួន តាមរយៈវិធីសាស្ត្រថ្មីៗ ដែលជួយឲ្យអតិថិជនរបស់យើង គ្រប់គ្រងប្រាក់របស់ពួកគេ និងតាមទាន់របថនៃការផ្លាស់ប្តូរនានា នៅក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ដូចគ្នានឹងធនាគារឯកទេស វីង ដែរ យើងប្តេជ្ញាដើម្បីឧត្តមភាព និងធ្វើអ្វីៗលើសពីដែនកំណត់ នៃឧស្សាហកម្មធនាគារ តាមរយៈការផ្លាស់ប្តូរ និងការច្នៃប្រឌិត។ វាស្របទៅតាមបេសកកម្មនេះដែរ យើងមានមោទនភាព ក្នុងការពង្រីកសេវាកម្មផ្ទេរប្រាក់អន្តរជាតិរបស់យើងដល់ប្រជាជនកម្ពុជាដែលកំពុងធ្វើការ នៅក្នុងប្រទេសកូរ៉េខាងត្បូង។"

ភាពជាដៃគូអន្តរជាតិចុងក្រោយបំផុត របស់ធនាគារឯកទេស វីង មួយនេះ មានគោលបំណងគាំទ្រ ដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការប្រើប្រាស់កម្លាំងពលកម្មចំណាកស្រុក សម្រាប់ការអភិវឌ្ឍន៍ជាតិ។ ចំណុចចម្បងមួយនៃបញ្ហានេះ គឺការលើកកម្ពស់ការប្រើប្រាស់ ប្រាក់បញ្ញើអន្តរជាតិ ដែលមានប្រសិទ្ធិភាព និងចំណាយថ្លៃសេវាកម្មតិច ដែលជាប្រភពរីកលូតលាស់ នៃលំហូរចូលមូលធនសម្រាប់ប្រទេសជាតិ។ អតិថិជនរបស់ វីង នៅកម្ពុជា អាចទទួលបានប្រាក់បញ្ញើពីជាង ២០០ ប្រទេសនៅទូទាំងពិភពលោក រួមទាំងបណ្តាប្រទេស ដែលជនអន្តោ

ប្រវេសន៍កម្ពុជារស់នៅច្រើនបំផុត មានដូចជា ប្រទេសថៃ, កូរ៉េខាងត្បូង, ជប៉ុន, ម៉ាឡេស៊ី និងប្រទេសជាច្រើនទៀត ។ ដោយ ៖ កូឡាប

## អង្គការសង់ត្រាល់ សហការជាមួយអង្គការកាវីកាស បានរៀបចំវេទិកាស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព

https://www.facebook.com/CentralCambodiaOrg/ សង់ត្រាល់ - CENTRAL ២៨/១១/២០១៨

ចាប់ពីថ្ងៃទី២៦ដល់២៨ខែវិច្ឆិកានេះ អង្គការសង់ត្រាល់ សហការជាមួយអង្គការកាវីកាស បានរៀបចំវេទិកាស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងស្រុកចំនួន៤រួមមានស្រុករុក្ខគីរី ស្រុកគាស់ក្រឡ ស្រុកសំឡូត និងស្រុកសំពៅលូន ស្ថិតក្នុងខេត្តបាត់ដំបង។ក្នុងនោះមានពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានប្រមាណ២០០នាក់ចូលរួម។

# ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨

## អគ្គកុងស៊ុលខ្មែរ ប្រចាំខេត្តសាកែវ ប្រាប់បញ្ហាមួយចំនួន ដល់ពលករខ្មែរស្នាក់នៅ ក្នុងសហគមន៍

https://www.dap-news.com/ ByID:112 Posted on 28 November 2018 | 15:03

ភ្នំពេញ៖ លោក ហ៊ុន សារឿន អគ្គកុងស៊ុលខ្មែរ ប្រចាំខេត្តសាកែវ ប្រទេសថៃ នៅព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ បានដឹកនាំមន្ត្រីកុងស៊ុល ចុះជួបសំណេះ សំណាល ជាមួយពលរដ្ឋខ្មែរ ស្នាក់នៅក្នុងសហគមន៍២០០បន្ទប់ ដោយលោកបានប្រាប់ ពលរដ្ឋខ្មែរនៅទីនេះ នូវចំណុចមួយចំនួនផងដែរ ។ នេះបើយោងតាមការផ្សព្វផ្សាយរបស់ស្ថានកុងស៊ុលខ្មែរ ប្រចាំខេត្តសាកែវ ។

ចំណុចទាំងនោះរួមមាន ៖ ការឆ្លងដែនស្របច្បាប់ តាមរយៈការប្រើប្រាស់លិខិត ឆ្លងដែនពលរដ្ឋខ្មែរ ឬប័ណ្ណព្រំដែន , ការស្នាក់នៅស្របច្បាប់ និងរយៈពេលស្នាក់នៅ ស្របច្បាប់សម្រាប់អ្នកប្រើលិខិតឆ្លងដែន ឬប័ណ្ណព្រំដែន , ប្រភេទការងារស្របច្បាប់ និងនីតិវិធីក្នុងការធ្វើការងារស្របច្បាប់នៅថៃ , សិទ្ធិនិងកាតព្វកិច្ច របស់ស្ថានអគ្គកុងស៊ុល ក្នុងការផ្តល់កិច្ចគាំពារ និងការពារផលប្រយោជន៍ស្របច្បាប់ របស់ពលរដ្ឋខ្មែរក្រោមដែនកុងស៊ុល , សិទ្ធិនិងកាតព្វកិច្ចរបស់ពលរដ្ឋខ្មែរ ដែលរស់នៅក្រោមដែនកុងស៊ុល ក្នុងករណីមានការចាប់ខ្លួនពីសំណាក់អាជ្ញាធរម្ចាស់ផ្ទះ និងការចូលរួមថែរក្សាអនាម័យ ក្នុងសហគមន៍២០០បន្ទប់ ជាពិសេសគឺការទុកដាក់សំរាមឲ្យបានត្រឹមត្រូវ ៕

## បញ្ជូនខ្លួនជនសង្ស័យជនជាតិអង់គ្លេសម្នាក់ ទៅសាលាដំបូងរាជធានីភ្នំពេញ ពាក់ព័ន្ធប្រព្រឹត្តអំពើទិញពេស្យាចារកុមារ

http://cambodiapolice.com/policekh/ 4:22 pm 28 វិច្ឆិកា 2018

ភ្នំពេញ ៖ នគរបាល នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅរសៀលថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ បានបញ្ជូនខ្លួនជនសង្ស័យជនជាតិអង់គ្លេសម្នាក់ ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ពាក់ព័ន្ធករណីប្រព្រឹត្តអំពើទិញពេស្យាចារកុមារអាយុក្រោម ១៥ឆ្នាំ ។

លោកវរសេនីយ៍ឯក លៅ លីន នាយការិយាល័យការពារអនីតិជនបានឲ្យដឹងថា ជនសង្ស័យឈ្មោះ LORYMAN STEPHEN JOHN ភេទប្រុស អាយុ ៥៧ឆ្នាំ ជនជាតិអង់គ្លេស មុខរបរគ្រូបង្រៀន ស្នាក់នៅផ្ទះជួល ដីឡូតិ៍លេខ១៩ ភូមិតាង៉ូវក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ ។ លោកវរសេនីយ៍ឯក លៅ លីន បញ្ជាក់ថា នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង១២ និង៣០នាទី ជនសង្ស័យបាននាំក្មេងប្រុសចំនួន ៤នាក់ ចូលទៅផ្ទះជួលរបស់ខ្លួន ។ ដោយមានការសង្ស័យសមត្ថកិច្ចបានរាយការណ៍ទៅព្រះរាជអាជ្ញារង គុជ គឹមឡុង ដើម្បីស្នើសុំត្រួតពិនិ

ក្បផ្ទះជួលខាងលើ ។ ក្នុងការត្រួតពិនិត្យ និងដោយមានការសហការពីអាជ្ញាធរពាក់ព័ន្ធ សមត្ថកិច្ចបានរកឃើញថា នៅក្នុងផ្ទះជនសង្ស័យ មានជនសង្ស័យ និងកុមារចំនួន ៤នាក់ ហើយសមត្ថកិច្ចក៏បានអនុវត្តន៍តាមនីតិវិធី និងបាននាំជនសង្ស័យ និងគ្រឿងអេឡិចត្រូនិចមួយចំនួន ព្រមទាំងកុមារ ៤នាក់ មកនាយកដ្ឋាន ដើម្បីធ្វើការសាកសួរ ។

លោកវរសេនីយ៍ឯកនាយការិយាល័យការពារអនីតិជន បានបញ្ជាក់ទៀតថា តាមការឆ្លើយបំភ្លឺរបស់កុមាររងគ្រោះ និងតាមការបំភ្លឺដើមបណ្តឹង (ម្តាយកុមាររងគ្រោះ) ព្រមទាំងការបំភ្លឺរបស់សាក្សី ជនសង្ស័យបានប្រើប្រាស់មធ្យោបាយជាច្រើនដើម្បីទាក់ទាញកុមាររងគ្រោះដូចជា៖ អោយប្រាក់កាស, ទិញទូរស័ព្ទអោយ, ទិញចំណីអាហារឲ្យញ៉ាំ, នាំដើរលេង, ទិញសម្លៀកបំពាក់អោយ, ទិញសម្ភារៈសិក្សាអោយ, ទិញកង់អោយ ជាដើម ។ លោកវរសេនីយ៍ឯកនាយការិយាល័យការពារអនីតិជន បន្តថា ដោយយោងតាមការឆ្លើយបំភ្លឺរបស់កុមាររងគ្រោះ និងតាមការបំភ្លឺដើមបណ្តឹង (ម្តាយកុមាររងគ្រោះ) ព្រមទាំងការបំភ្លឺរបស់សាក្សី សមត្ថកិច្ចសន្និដ្ឋានថា ជនសង្ស័យពិតជាបានប្រព្រឹត្តអំពើរួមភេទ និងរំលោភបំពានផ្លូវភេទលើកុមារ ដោយប្រើប្រាស់សម្ភារៈ ប្រាក់កាស ជាការអូសទាញ និងសម្រេចកសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាងទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ៕

## តុលាការកំពូលតម្កល់ទោស ៩ ឆ្នាំជនជាតិទួរគីរឿងទិញពេស្យាចារកុមារ

https://www.postkhmer.com/ គឹម សារុំ | Publication date 29 November 2018 | 10:10 ICT

ពេញៈ បុរសជនជាតិតួកគីម្នាក់ ត្រូវបានតុលាការកំពូលប្រកាសសាលដីកាតម្កល់ទោសជាប់គុក ៩ ឆ្នាំដដែល បន្ទាប់ពីជំនុំជម្រះកាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំនេះក្នុងសំណុំរឿងទិញពេស្យាចារកុមារអាយុក្រោម ១៨ ឆ្នាំ ប្រព្រឹត្តកាលពីឆ្នាំ ២០១៤ នៅរាជធានីភ្នំពេញ។

លោកស្រី ចៅក្រម គិម សត្ថាវី បានអានសាលដីកានៅចំពោះមុខជនជាប់ចោទថា៖ «សំណុំរឿងដែលមានជនជាប់ចោទឈ្មោះ Aydin Goktepe អាយុ ៥១ ឆ្នាំពាក់ព័ន្ធនឹងរឿងទិញពេស្យាចារកុមារនេះ ក្រោយពីជំនុំជម្រះ និងតាមរយៈអង្គហេតុតុលាការកំពូលយល់ឃើញថា ជនជាប់ចោទប្រាកដជាបានប្រព្រឹត្តពិតមែន។ ដូច្នេះតុលាការសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល»។

គួរបញ្ជាក់ថាកាលពីថ្ងៃជំនុំជម្រះបុរសជាប់ចោទរូបនេះបានបដិសេធនៅមុខចៅក្រមថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទទេ ប៉ុន្តែថាខ្លួនបានចាញ់បោកនារីរកស៊ីផ្លូវភេទនៅវត្តភ្នំ ខណៈខ្លួនពឹងឲ្យរកនារីម្នាក់ដើម្បីរៀបការអំឡុងឆ្នាំ ២០១៤។ ជនជាប់ចោទដែលធ្លាប់ជាកាពីតែននាវាផងនោះបានរៀបរាប់ប្រាប់ចៅក្រមតុលាការកំពូលថា គាត់បានចូលមកប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៤ ហើយវីហ្សាស្នាក់កម្ពុជាកំណត់រយៈពេលតែ ១ ខែទេ។ ក្នុងអំឡុងពេលនោះគាត់មានបំណងរកស្ត្រីខ្មែរម្នាក់ធ្វើជាប្រពន្ធ ហើយពេលគាត់ទៅរមណីយដ្ឋានវត្តភ្នំក៏បានជួបស្ត្រីរកស៊ីផ្លូវភេទម្នាក់ឈ្មោះ ឌឿន ស្រីណែត ហើយនារីនោះណែនាំឲ្យស្គាល់ស្ត្រីម្នាក់ឈ្មោះ ឈឿន ស្រីណែត ដែលរកស៊ីផ្លូវភេទដូចគ្នា។ លោក Aydin Goktepe បន្តថាពេលស្គាល់ស្ត្រីឈ្មោះ ឈឿន ស្រីណែត ក៏ត្រូវស្ត្រីរូបនោះប្រាប់ថា នាងមានប្អូនស្រីម្នាក់អាយុ ១៨ ឆ្នាំ ហើយបានណែនាំឲ្យស្គាល់គ្នា និងណាត់គ្នាទៅជួបក្នុងហាងមួយនៅម្តុំផ្សារសូរិយា។ លោកបន្តថាក្រោយមកទៀតស្ត្រី ឈ្មោះ ឌឿន ស្រីណែត និង ឈឿន ស្រីណែត រួមទាំងប្អូនស្រីរបស់ ឈឿន ស្រីណែត បានជិះរ៉ឺម៉កកង់ ៣ ទៅចាំជួបគាត់នៅមុខផ្ទះសំណាក់ឈ្មោះ ស្រី ពេជ្រ ក្នុងសង្កាត់ផ្សារថ្មីទី ៣ ខណ្ឌដូនពេញ។ ប៉ុន្តែពេលនោះគាត់បានឃើញប្អូនស្រីរបស់ ឈឿន ស្រីណែត ក្មេងពេកគាត់ក៏ប្រកែកថា មិនយកធ្វើជាប្រពន្ធ ព្រោះនាងមានអាយុទើប ១៤ ឆ្នាំហើយគាត់បានឲ្យលុយទៅអ្នករត់ម៉ូតូកង់ ៣ ដឹកត្រឡប់ទៅវិញ។

កាលពីជំនុំជម្រះនៅតុលាការកំពូលនោះជនជាប់ចោទថា លោកមានកំហុស និងចាញ់បោកស្ត្រីរកស៊ីផ្លូវភេទ ដោយសារពួកគេប្រាប់ថារកនារីម្នាក់ដើម្បីរៀបការតែបែរជាយកនារីនៅក្មេងទៅវិញ ប៉ុន្តែលោកថាមិនបានរួមភេទជាមួយក្មេងស្រីនោះទេ។ លោកសូមឲ្យតុលាការដោះលែងលោក ព្រោះជាប់គុកបានជិត ៥ ឆ្នាំហើយ។

ប៉ុន្តែតាមកំណត់ហេតុនគរបាល និងចម្លើយរបស់ស្ត្រីឈ្មោះ ឈឿន ស្រីណែត បញ្ជាក់ថាក្នុងអំឡុងខែមេសា ឆ្នាំ ២០១៤ ខ្លួននិងឈ្មោះ ឡឿន ស្រីណែត រួមទាំងប្អូនស្រីបានទៅជួបជនជាប់ចោទនៅផ្ទះសំណាក់មួយឈ្មោះ ស្រី ពេជ្រ ហើយបានជួលបន្ទប់ ២ ដែលបន្ទប់ ១ សម្រាប់ពួកនាងរង់ចាំ និងបន្ទប់ ១ ទៀតទុកសម្រាប់ឲ្យលោក Goktepe និង ក្មេងស្រីរងគ្រោះឈ្មោះ យ. ស.ធ. ដេកដើម្បីរួមភេទ។ ឈឿន ស្រីណែត បន្តថាជនជាប់ចោទបានរួមភេទជាមួយប្អូនស្រីរបស់ខ្លួនម្តងឲ្យលុយ ៣០០ ដុល្លារ ហើយលុយនោះប្អូនស្រីនាងបានយកទៅឲ្យម្តាយនាងឈ្មោះ សាន់ នឿន ទៀតផង។ ប៉ុន្តែក្រោយមកក្រុមគ្រួសារក្មេងរងគ្រោះបានប្តឹងទៅអង្គការធ្វើការផ្នែកគាំពារកុមារ ហើយប្រាប់សមត្ថកិច្ចឲ្យចាប់ខ្លួនជនជាប់ចោទតែម្តង។

សំណុំរឿងនេះត្រូវសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសកាលពីថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៥ ឱ្យជនជាប់ចោទជាប់គុក ៩ ឆ្នាំដោយចោទពីបទទិញពេស្យាចារកុមារតាមមាត្រា ៣៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ និងបង្គាប់ឲ្យសងជំងឺចិត្ត ៦ លានរៀលទៅក្មេងស្រីរងគ្រោះ៕

## កម្លាំងអាជ្ញាធរថៃក្នុងខេត្តឈុនបុរធ្វើយុទ្ធនាការចុះត្រួតពិនិត្យឯកសារស្នាក់របស់ពលករបរទេសខុសច្បាប់

https://www.facebook.com/cambodiaworkers/ ថ្ងៃទី ២៨ វិច្ឆិកា ២០១៨

កាលពីព្រឹកថ្ងៃពុធ ទី28 ខែវិច្ឆិកា ឆ្នាំ2018 នេះ កម្លាំងអាជ្ញាធរថៃក្នុងខេត្តឈុនបុរធ្វើយុទ្ធនាការចុះត្រួតពិនិត្យឯកសារស្នាក់របស់ពលករបរទេសខុសច្បាប់ តាមពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋថៃនៅក្នុងសង្កាត់បរីន ស្រុកស៊ីរាឆា ខេត្តឈុនបុរី និងសង្កាត់តាខៀនទា ស្រុកបាងឡាម៉ុង ខេត្តឈុនបុរីប្រទេសថៃ។ ក្នុងការត្រួតពិនិត្យមានបុរសម្នាក់ឈ្មោះ ប្រសឹត ប៊ុនផាត់ អាយុ67ឆ្នាំ សញ្ជាតិខ្មែរ ជាអ្នកគ្រប់គ្រងពលករ ក្នុងការត្រួតពិនិត្យតំបន់នេះអាជ្ញាធរថៃរកឃើញពលករបរទេសចំនួន16នាក់ (ប្រុស13នាក់ស្រី03នាក់) មានប័ណ្ណស៊ីជម្ពូ ចំនួន03នាក់ (ស្រី02នាក់ប្រុស01នាក់)(សញ្ជាតិខ្មែរ) គ្មានឯកសារសម្គាល់ខ្លួនចំនួន11នាក់(ប្រុស10នាក់ស្រី01នាក់) ក្នុងការត្រួតពិនិត្យទឹកនោមរកសារជាតុញៀននៅក្នុងខ្លួនពលករ10នាក់ មានចំនួន07នាក់ មានសាជាតុញៀន រឹបអូសបានឧបករណ៍សេពគ្រឿង អាវុធជាវសាម៉ូរ៉ៃ និងកាំបិតមួយចំនួនធំ។

ក្រោយកើតហេតុអាជ្ញាធរសម្ថកិច្ចនៃមន្ទីការងារខេត្តឈុនបុរីធ្វើសំណុំរឿងប្តឹងនិយោជក់ពីបទទទួលពលករខុសច្បាប់គ្មានប័ណ្ណអនុញ្ញាតអោយធ្វើការដោយផាក់ពិន័យនិងចាត់វិធានការណ៍តាមផ្លូវច្បាប់។

# ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨

## ម៉ាឡេស៊ីចាប់ផ្តើមកែលំអលក្ខខណ្ឌជ្រើសរើសពលករបរទេសទធ្វើការនៅប្រទេសម៉ាឡេស៊ី

http://www.mlvt.gov.kh/ Thursday, 29 November 2018 14:44

ទីស្តីការក្រសួង៖ ថ្លែងក្រោយជំនួបពិភាក្សាការងាររវាង ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយទីភ្នាក់ងារជ្រើសរើសពលករម៉ាឡេស៊ីចំនួនបី នៅព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា នៅទីស្តីការក្រសួងការងារ ឯកឧត្តម ហ៊ូ វុទ្ធី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ថា លក្ខខណ្ឌការងារដែលភាគីម៉ាឡេស៊ីផ្លាស់ប្តូរថ្មី រួមមា នីតិវិធីក្នុងការជ្រើសរើសពលករ និងការតំឡើងប្រាក់ឈ្នួលខ្ពស់ជាងមុន ដើម្បីទាក់ទាញពលករបរទេស ពិសេសពលករកម្ពុជា ឲ្យទៅធ្វើការនៅប្រទេសរបស់ខ្លួនឲ្យកាន់តែច្រើនថែមទៀត ។

ឯកឧត្តម ហ៊ូ វុទ្ធី បានបន្តថា នីតិវិធីក្នុងការជ្រើសរើសពលករថ្មីនេះ គឺពលករមិនចាំបាច់ចំណាយពេលវេលាយូរដូចមុនទេ ពោលគឺឲ្យតែភាគីម៉ាឡេស៊ីត្រូវការពលករ គឺអាចបញ្ជូនទៅធ្វើការបាន ខណៈកាលពីមុនពលករត្រូវ

មានកិច្ចសន្យាការងារ និងបំពេញបែបបទផ្សេងៗទៀត ទើបអាចបញ្ជូនទៅបានត្រូវប្រើពេលយូរ។ ទន្ទឹមនឹងនេះម៉ាឡេស៊ីបានតំឡើងប្រាក់ឈ្នួលដល់ពលករបរទេសដែលទៅធ្វើការនៅម៉ាឡេស៊ីប្រមាណជាង៣០០ដុល្លារក្នុង១ខែ ដើម្បីឲ្យពលករទទួលបាននូវប្រាក់ចំណូលខ្ពស់ជាងមុនក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃ និងផ្ញើត្រឡប់មកស្រុកកំណើតផងដែរ។ ព្រមជាមួយគ្នានេះដែរ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី អ៊ិត សំហេង បានស្នើឲ្យទីភ្នាក់ងារជ្រើសរើសពលករម៉ាឡេស៊ីទាំងបីសហការជាមួយទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ត្រូវធ្វើការរួមគ្នាជាឯកច្ឆ័នក្នុងសំលេងតែមួយជាមុនសិនពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងារថ្មីៗ ហើយបន្ទាប់ពីបានលទ្ធផលហើយក្រុមការងារបច្ចេកទេស នៃប្រទេសទាំងពីរត្រូវពិភាក្សាគ្នាឡើងវិញលើកិច្ចការងារទាំងនេះ មុននឹងដាក់ជូនរដ្ឋមន្ត្រីប្រទេសទាំងពីរសម្រេចជាចុងក្រោយ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម អ៊ិត សំហេង នៅតែរក្សាចំហរទៅតាមកិច្ចព្រមព្រៀងលើអនុស្សរណៈនៃការយោគយល់គ្នា ដែលបានព្រមព្រៀងជាមួយគ្នាកន្លងមកលើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរ ដែលទៅធ្វើការនៅម៉ាឡេស៊ី ដែលរដ្ឋាភិបាល ទាំងពីរបានព្រមព្រៀងជាមួយគ្នារួចហើយ វាជាឯកសាផ្លូវការស្របច្បាប់ ដែលក្លាយជាក្របខណ្ឌកិច្ចសហប្រតិបត្តិការលើវិស័យការងារកាន់តែប្រសើរថែមទៀត។ ឯកឧត្តមរដ្ឋមន្ត្រី លើកឡើងបន្តថា ប្រាក់ឈ្នួលនៅកម្ពុជាក៏មានការកើនឡើងខ្ពស់ ដូច្នេះខាងម៉ាឡេស៊ីត្រូវផ្តល់ផលប្រយោជន៍ដល់ពលករកម្ពុជា តាមរយៈប្រាក់ឈ្នួលខ្ពស់ និងលក្ខខណ្ឌការងារល្អ ទើបអាចទាក់ទាញពលករកម្ពុជាចេញទៅធ្វើការនៅទីនោះបាន។ រីឯប្រទេសដែលជាគោលដៅប្រកួតប្រជែងក៏មានច្រើនផងដែរ ដូចជាកូរ៉េ ជប៉ុន សិង្ហបុរី ថៃជាដើម។

សូមបញ្ជាក់ថា បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានផ្អាកការជ្រើសរើស និងបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយន្តការ និងបទដ្ឋានគតិយុត្តិជាច្រើនសម្រាប់ការពារ គ្រប់គ្រង និងលើកកម្ពស់សិទ្ធិដល់ពលករខ្មែរទាំងអស់ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសម៉ាឡេស៊ី។ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋាភិបាលនៃប្រទេសទាំងពីរ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន ០២ ៖ (១) អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការជ្រើសរើស និងប្រើប្រាស់ពលករ (២)អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការជ្រើសរើស និងប្រើប្រាស់ពលករការងារផ្ទះ បច្ចុប្បន្នទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាដែលទទួលបានកាអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១០៣ ឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស។ ក្នុងនោះប្រទេសម៉ាឡេស៊ី មានចំនួន ៦៩ ក្រុមហ៊ុន (គិតត្រឹម ខែតុលា ឆ្នាំ២០១៨)។

## សមាគមបញ្ជូន និង រើសកម្មករមកពីប្រទេស ម៉ាឡេស៊ី ជំរុញឲ្យជ្រើសរើសកម្មករខ្មែរទៅធ្វើការនៅម៉ាឡេស៊ី

https://www.postkhmer.com/ គង់ មេត្តា | Publication date 30 November 2018 | 08:59 ICT

ភ្នំពេញៈ លោកអ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីម្សិលមិញ បានជួបពិភាក្សាជាមួយសមាគមបញ្ជូន និង រើសកម្មករចំនួនបីមកពីប្រទេស ម៉ាឡេស៊ី បំណងដើម្បីជំរុញឲ្យពលករខ្មែរទៅធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី។

ទោះជាយ៉ាងណាក៏ដោយ លោក ហ៊ូ វុទ្ធី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីម្សិលមិញ បានបដិសេធមិនផ្តល់ឈ្មោះសមាគមនទាំងបីនោះទេ រួមទាំងសមាគមនក្នុងស្រុកនៅកម្ពុជា។ លោកបានថ្លែងថា សមាគមនបញ្ជូននិងរើសកម្មករចំនួនបីដែលបានជួបជាមួយរដ្ឋមន្ត្រីនិងកំពុងធ្វើការជាមួយសមាគម បញ្ជូននិងរើសកម្មករចំនួនពីរនៅកម្ពុជាដើម្បីជំរុញការជ្រើសរើសពលករនិងបញ្ជូនឲ្យបានលឿន។ លោក វុទ្ធី ថ្លែងថា៖«គេមកផ្សព្វផ្សាយអញ្ចឹងគេមកក្នុងវិស័យឯកជនទេសមាគមអ្នករើសពលករហ្នឹងវាមាន៣សមាគមគេមកធ្វើការជាមួយសមាគមខ្មែរមានពីរសមាគម។គេមកដើម្បីជម្រុញការជ្រើសរើសពលករទៅកាន់ម៉ាឡេស៊ី»។ លោក វុទ្ធី អះអាងថាភាគីម៉ាឡេគេមកផ្សព្វផ្សាយ ថែមជំរុញឲ្យធ្វើការជ្រើសរើសទៅឲ្យបានលឿនដោយម៉ាឡេស៊ី បានបន្ថែមប្រាក់ឈ្នួលថែមទៀត ពីមុនមកប្រាក់ឈ្នួលអបបរិមារបស់គេត្រឹមតែ៩០០រីងគីតទេ ឥឡូវគេឡើងដល់១១០០រីងគីត។

លោក ថ្លែងថា៖«គេត្រូវការកម្មករគ្រប់ប្រភេទពីយើងទៅ អ្នកធ្វើការនៅតាមរោងចក្រ តាមហាង តាមផ្ទះ ហើយតាមជាក់ស្តែងត្រូវការអ្វីគេរើសទៅ»។ លោក ហ៊ូ វុទ្ធីបានបញ្ជាក់ថាបុច្ចុប្បន្នមានកម្មករកម្ពុជាកំពុងធ្វើការនៅម៉ាឡេស៊ីប្រមាណជាង៣០០០នាក់នេះមិនរាប់បញ្ចូលទាំងកម្មករមិនមានភាពស្របច្បាប់ហើយក្រសួងកំពុងសិក្សាកម្មករខ្មែរដែលគ្មានភាពស្របច្បាប់នៅម៉ាឡេស៊ី។ លោកបន្ត៖«នេះមិនមែនជាចំនួនសរុបទេ។មានកម្មករយើងគាត់ទៅដោយមិនមានច្បាប់ម៉ាឡេស៊ី។អ្នកខ្លះទៅហើយមិនត្រូវតាមច្បាប់ទម្លាប់អ្នកខ្លះទៅនៅយឺតពេល ឥឡូវយើងកំពុងសហការជាមួយម៉ាឡេស៊ីដើម្បីសិក្សាឡើងវិញត្រូវរៀបចំដើម្បីឲ្យគាត់បាន ភាពស្របច្បាប់។

បើយោងតាមហ្វេសប៊ុករបស់ក្រសួងការងារ បច្ចុប្បន្នមានទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាដែលទទួលបានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១០៣ភ្នាក់ងារ ឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស ក្នុងនោះប្រទេសម៉ាឡេស៊ី មានចំនួន ៦៩ ក្រុមហ៊ុន គិតត្រឹម ខែតុលា ឆ្នាំ២០១៨៕

## តុលាការសម្រេចឃុំខ្លួនបុរសម្នាក់ ពាក់ពន្ធ័ប្រព្រឹត្តអំពើអាណាចារលើកុមារកម្ពុជា នៅភ្នំពេញ

http://www.arey-news.com/archives/ ( ថ្ងៃទី 30 November 2018 ម៉ោង 1:19 pm )

(ភ្នំពេញ)៖ ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លោក ថាន់ ឡេង បានចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនសង្ស័យឈ្មោះ LORYMAN STEPHEN JOHN ភេទប្រុស អាយុ៥៧ឆ្នាំ ជនជាតិអង់គ្លេស មុខរបរគ្រូបង្រៀន ដាក់ពន្ធនាគារព្រៃស ដើម្បីរង់ចាំជំនុំជម្រះតាមនីតិវិធី នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨នេះ ។

ការសម្រេចរបស់លោកចៅក្រមនេះ ធ្វើឡើងបន្ទាប់ពីតំណាងអយ្យការលោក កុល បុន បានបញ្ចប់ការស៊ើបសួរ និងបានសម្រេចចោទប្រកាន់លើជនសង្ស័យពីបទប្រព្រឹត្តអំពើអាសលើអនីតិជន អាយុក្រោម១៥ឆ្នាំ តាមមាត្រា៤៣ ច្បាប់ស្តីពី ការបង្រ្កាបអំពើជួយដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។ សមត្ថកិច្ចនគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កាលពីរសៀលថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨កន្លងទៅ បានបញ្ជូនខ្លួនជនជាតិអង់គ្លេសម្នាក់ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ពាក់ព័ន្ធករណីប្រព្រឹត្តអំពើទិញពេស្យាចាកុមារអាយុក្រោម១៥ឆ្នាំ ។

ជនសង្ស័យឈ្មោះ LORYMAN STEPHEN JOHN ភេទប្រុស អាយុ៥៧ឆ្នាំ ជនជាតិអង់គ្លេស មុខរបរគ្រូបង្រៀន ស្នាក់នៅផ្ទះជួល ដីឡូត៍លេខ១៩ ភូមិតាង៉ូវក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ ។

រឿងរ៉ាវនេះ គឺកើតឡើងកាលពី ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង១២៖៣០នាទី។ ដោយជនសង្ស័យបាននាំក្មេងប្រុសចំនួន៤នាក់ ចូលទៅផ្ទះជួលរបស់ខ្លួន ហើយដោយមានការសង្ស័យសមត្ថកិច្ចបានរាយការណ៍ទៅព្រះរាជអាជ្ញារង គុជ គឹមឡុង ដើម្បីស្នើសុំត្រួតពិនិត្យផ្ទះជួលខាងលើ។ ត្រួតពិនិត្យ និងដោយមានការសហការពីអាជ្ញាធរពាក់ព័ន្ធ សមត្ថកិច្ចបានរកឃើញថា នៅក្នុងផ្ទះជនសង្ស័យមានជនសង្ស័យ និងកុមារចំនួន៤នាក់ ហើយសមត្ថកិច្ចក៏បានអនុវត្តន៍តាមនីតិវិធី និងបាននាំជនសង្ស័យ និងគ្រឿងអេឡិចត្រូនិចមួយចំនួន ព្រមទាំងកុមារ៤នាក់ មកនាយកដ្ឋាន ដើម្បីធ្វើការសាកសួរ ។

បំភ្លឺរបស់កុមាររងគ្រោះ និងតាមការបំភ្លឺដើមបណ្តឹងជាម្តាយកុមាររងគ្រោះ ព្រមទាំងការបំភ្លឺរបស់សាក្សី ជនសង្ស័យបានប្រើប្រាស់មធ្យោបាយជាច្រើន ដើម្បីទាក់ទាញកុមាររងគ្រោះដូចជា ៖ ឲ្យប្រាក់កាស, ទិញទូរស័ព្ទឲ្យ, ទិញចំណីអាហារឲ្យញុាំ, នាំដើរលេង, ទិញសម្លៀកបំពាក់ឲ្យ, ទិញសម្ភារសិក្សាឲ្យ, ទិញកង់ឲ្យជាដើម និងរបស់របរប្រើប្រាស់ផ្សេងៗទៀតផងដែរ ។ ជនសង្ស័យពិតជាបានប្រព្រឹត្តអំពើរួមភេទ និងរំលោភបំពានផ្លូវភេទលើកុមារដោយប្រើប្រាស់សម្ភារ ប្រាក់កាស ជាការអូសទាញ និងសម្រេចកសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាងបញ្ជូនទៅកសន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ទើបត្រូវតុលាការចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ៕